**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ភាគបម្រុង

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ញឹម សុគន្ធីតា**
**ក. អៀង រដ្ឋា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **យឹម ម៉ាណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ញឹម សុគន្ធីតា** និង **អៀង រដ្ឋា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២០ (សិក្សាបង់ថ្លៃ) ឆ្នាំសិក្សា២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

**-លោកឪពុកអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងបានលះបង់ទាំងកម្លាំងកាយចិត្ត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាងទាំងស្មារតី និងសម្ភារៈ ព្រមទាំងបានខិតខំប្រឹងប្រែងដើម្បីឲ្យកូនបានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

**-ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យ និងដេប៉ាតឺម៉ង់ចំណុះ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងកិច្ចដឹកនាំ គ្រប់គ្រង ជាពិសេសបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន ក៏ដូចជាបទពិសោធន៍ល្អៗជាច្រើនដែលជាទ្រព្យដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់រូប ដើម្បីជាស្ពានចម្លងទៅថ្ងៃអនាគតដ៏ភ្លឺស្វាង។

**-លោកស្រីសាស្ត្រាចារ្យ ឃឹម ម៉ាណែត** ដែលជាសាស្ត្រាចារ្យណែនាំក្នុងសារណាបញ្ចប់ការសិក្សា។ ក្នុងអំឡុងពេលនេះ លោកស្រីសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ណែនាំ ផ្តល់ដំបូន្មានល្អៗ ជួយជ្រោមជ្រែង កែសម្រួល និងលើកទឹកចិត្តយើងខ្ញុំក្នុងការស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

យើងខ្ញុំសូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចអវិជ្ជមាន រួមមានពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយកំហុសអចេតនា។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួង ដល់វត្ថុស័ក្តិសិទ្ធក្នុងលោក ព្រមទាំងទេវតាឆ្នាំថ្មី សូមតាមជួយថែរក្សាដល់លោកអ្នកមានគុណទាំងពីរ លោក លោកស្រីសាស្ត្រាចារ្យ និងសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការប្រកបដោយសេចក្តីសុខ ចម្រើន និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងអស់។

# អារម្ភកថា

យើងខ្ញុំទាំងពីររូប សូមគោរពចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ មិត្តអ្នកអាន និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និងសេចក្តីស្រឡាញ់។

យើងខ្ញុំទាំងពីររូប ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៩-២០២០ ដែលត្រូវបានសាកលអនុញ្ញាតឱ្យយើងខ្ញុំស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា លើប្រធានបទដែលយើងខ្ញុំបានស្នើសុំ "**ភាគបម្រុង**" ដើម្បីចងក្រងជាឯកសារ និងសម្រាប់តម្កល់ទុកជាវត្ថុអនុស្សាវរីយ៍នៅក្នុងបណ្ណាល័យ សម្រាប់មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ទៅលើរបបសន្តតិកម្មតាមមតកសាសន៍នេះ។

សារណានេះ ជាផ្នែកមួយជួយឱ្យមិត្តអ្នកអានទទួលបានចំណេះដឹងបន្ថែមខាងផ្នែកច្បាប់ ជាពិសេស គឺជួយឱ្យអ្នកទាំងអស់គ្នាទទួលបាននូវពុទ្ធិបន្ថែមដែលទាក់ទងនឹងភាគបម្រុង ដែលបញ្ហានេះកំពុងតែកើតមានឡើងនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ហើយចំណេះដឹងនេះ ជួយឱ្យអ្នកទាំងអស់គ្នាអាចដោះស្រាយរាល់បញ្ហាដែលកើតមានចំពោះខ្លួន គ្រួសារ និងសង្គមជាតិ ជាអាទិ៍។

ចំណេះដឹង គឺជាអំណាច និងជាអាវុធដ៏មុតស្រួច សម្រាប់ធ្វើឱ្យមនុស្សមិនឆាប់ចាញ់បោកគេ ធ្វើឱ្យមនុស្សមានភាពក្លាហាន និងចេះដោះស្រាយរាល់បញ្ហាដែលកើតមាន។ ចំណេះវិជ្ជាគឺជាពន្លឺបំភ្លឺផ្លូវ ដែលនាំឱ្យយើងដើរតាមផ្លូវត្រូវ និងមិនធ្លាក់ក្នុងផ្លូវខុស។ ប្រទេសជាតិមួយមានការរីកចម្រើនលូតលាស់ និងមានការអភិវឌ្ឍន៍បានលុះត្រាតែសិស្ស និស្សិត ឬប្រជាជននៃប្រទេសនោះមានចំណេះដឹងខ្ពង់ខ្ពស់ មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងបានល្អ មានសណ្តាប់ធ្នាប់ល្អ និងមានសុខ សន្តិភាព។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ យកចិត្តទុកដាក់ក្នុងការអានសៀវភៅរបស់យើងខ្ញុំ ហើយសូមជូនពរឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិ** ........................................ ២

កថាខណ្ឌទី១៖ សន្តតិកម្មតាមច្បាប់ ........................................ ២

កថាខណ្ឌទី២៖ សន្តតិជនតាមមតកសាសន៍ ........................................ ៤

ក. ការតាក់តែងមតកសាសន៍ ........................................ ៦

ខ. ទម្រង់នៃមតកសាសន៍ ........................................ ៧

កថាខណ្ឌទី៣៖ ភាពដូចគ្នា និងខុសគ្នារវាង សន្តតិកម្មតាមច្បាប់ និងមតកសាសន៍ ........................................ ១០

**ផ្នែកទី២៖ ភាគបម្រុង** ........................................ ១២

កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃភាគបម្រុង ........................................ ១២

ក. និយមន័យ ........................................ ១២

ខ. គោលបំណង ........................................ ១៣

គ. ផលប្រយោជន៍ ........................................ ១៣

កថាខណ្ឌទី២៖ អ្នកមានសិទ្ធិលើភាគបម្រុង ........................................ ១៤

ក. បច្ឆាញាតិផ្ទាល់ ........................................ ១៤

ខ. ឪពុកម្តាយ ឬជីដូនជីតា ........................................ ១៥

គ. សហព័ទ្ធរបស់មតកជនជាសន្តិជន ........................................ ១៥

កថាខណ្ឌទី៣៖ លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិ និងចំណែកមត៌ករបស់អ្នកមានសិទ្ធិនោះ ........................................ ១៦

ក. លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង ........................................ ១៦

ខ. ចំណែកនៃភាគបម្រុង ........................................ ១៧

**ជំពូកទី២**

**វិធីសាស្ត្រក្នុងការគណនាភាគបម្រុង**

**ផ្នែកទី១៖ ទ្រព្យដែលជាមូលដ្ឋានក្នុងការយកមកគណនា** ........................................ ១៩

កថាខណ្ឌទី១៖ ទ្រព្យដែលមានពេលចាប់ផ្ដើមសន្តតិកម្ម........................................................ ១៩
កថាខណ្ឌទី២៖ តម្លៃនៃផលប្រយោជន៍ពិសេស....................................................................... ១៩
កថាខណ្ឌទី៣៖ តម្លៃនៃប្រទានកម្ម.......................................................................................២០
កថាខណ្ឌទី៤៖ ចំនួនទឹកប្រាក់នៃកាតព្វកិច្ច.........................................................................២១
**ផ្នែកទី២៖ ការគណនាភាគបម្រុង**.......................................................................................២១
កថាខណ្ឌទី១៖ រូបមន្តក្នុងការគណនា ...............................................................................២១
កថាខណ្ឌទី២៖ ការកាត់នៃភាគបម្រុង ............................................................................... ២៣
ក. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ..................................២៣
ខ. ចំនួនទឹកប្រាក់នៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង .....................................................២៤
គ. ផលប្រយោជន៍នៃអ្នកមានសិទ្ធិលើភាគបម្រុង ..................................................................២៥

## ជំពូកទី៣

## នីតិវិធីនៃការកាត់បន្ថយ

## និងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**ផ្នែកទី១៖ នីតិវិធីនៃការកាត់បន្ថយ**.............................................................................៣០
កថាខណ្ឌទី១៖ ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ...........................................៣០
កថាខណ្ឌទី២៖ លំដាប់នៃការកាត់បន្ថយ ...........................................................................៣០
ក. អច្ច័យទានចំពោះសន្តតិជន.......................................................................................៣១
ខ. អច្ច័យទានចំពោះតតិយជន.......................................................................................៣២
គ. ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍.......................................................៣៣
**ផ្នែកទី២៖ ផលប្រយោជន៍ពិសេសឬប្រទានកម្ម** ....................................................................៣៤
កថាខណ្ឌទី១៖ ការកាត់បន្ថយចំពោះកិច្ចសន្យា ដែលត្រូវចាត់ទុកជាប្រទានកម្ម..........................៣៥
កថាខណ្ឌទី២៖ ការចាត់ចែងកម្មវត្ថុនៃប្រទានកម្ម..................................................................៣៥
**ផ្នែកទី៣៖ ការរលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង និង អនុភាព**..........................................................................................................៣៥
កថាខណ្ឌទី១៖ អាជ្ញាយុកាល.........................................................................................៣៥
ក. ការបោះបង់ភាគបម្រុង.............................................................................................៣៦

ខ. សហសន្តតិជននៃភាគបម្រុង ........................................................................................ ៣៦
កថាខណ្ឌទី២៖ អានុភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ............................................ ៣៧
ក. ការសងផលចែកដែលកើតចេញពីកម្មវត្ថុនៃការកាត់បន្ថយ ................................................ ៣៧
ខ. សំណងដោយបង់ថ្លៃ ................................................................................................ ៣៧
គ. បន្ទុកនៃការខាតបង់ដោយអសាធនភាព ......................................................................... ៣៨
**សេចក្តីសន្និដ្ឋាន** ...................................................................................................... ៣៩
**អនុសាសន៍** ............................................................................................................. ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ក្នុងសង្គមនាពេលបច្ចុប្បន្ន មនុស្សយើងដែលកើតមកតែងតែប្រកបមុខរបរចិញ្ចឹមជីវិត និងខិតខំប្រឹងប្រែងធ្វើការ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ ដោយបុគ្គលខ្លះ ធ្វើការងាររាជការ ឬការធ្វើអាជីវកម្មកាន់តែមានភាពរីកចម្រើន ក៏បានទិញនូវផ្ទះ ដី រថយន្តជាអាទិ៍ ប៉ុន្តែបុគ្គលខ្លះ ក៏មានបំណុល ដោយសារមុខជំនួញក្ស័យធនជាដើម។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិទទួលស្គាល់នូវកម្មសិទ្ធិឯកជនក្នុងគោលបំណងដើម្បីធានាដល់កម្មសិទ្ធិក្នុងការកាន់កាប់ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់នោះបានខិតខំស្វែងរកយ៉ាងលំបាក។ នៅពេលដែលមនុស្សម្នាក់បានស្លាប់បាត់បង់ជីវិតទៅ ដោយបានបន្សល់នូវទ្រព្យសម្បត្តិសម្រាប់ឲ្យបុគ្គលដែលមានសិទ្ធិស្នងនូវទ្រព្យសម្បត្តិទាំងអស់នោះ ប៉ុន្តែក្នុងករណីមានបុគ្គលដែលមានសិទ្ធិស្នងទ្រព្យច្រើននាក់ ឬការពិភាក្សាបែងចែកទ្រព្យមិនស្រុះស្រួលគ្នា ដែលជាហេតុធ្វើឱ្យមានបញ្ហាស្មុគស្មាញកើតឡើងចំពោះអ្នកមានសិទ្ធិទាំងអស់នោះ។ ពាក្យថាកម្មសិទ្ធិ គឺជាសិទ្ធិដែលកម្មសិទ្ធិករមានក្នុងការកាន់កាប់ អាស្រ័យផល និងការចាត់ចែង មានន័យថាកម្មសិទ្ធិករមានសិទ្ធិយ៉ាងទូលំទូលាយលើទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់ខ្លួនទាំងពេលបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងពេលទទួលមរណភាពផងដែរ។ យើងដឹងហើយ "**ភាគបម្រុង**" ជាប្រធានបទមួយដែលទទួលបានការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់សង្គមកម្ពុជានាពេលបច្ចុប្បន្ន ព្រោះកម្ពុជាពុំមានច្បាប់ណាចែងពីភាគបម្រុងនៅឡើយទេ ម្យ៉ាងវិញទៀតបញ្ហាមួយចំនួនដែលទាក់ទងនឹងភាគបម្រុងពុំសូវបានជួបប្រទះ ពុំមានសាលក្រម ឬសាលដីកាអំពីភាគបម្រុងច្រើននោះទេ។ ដោយសារតែបញ្ហាទាំងនោះហើយ ទើបធ្វើឱ្យមានការបង្កើតនូវរបបសន្តតិកម្មនៅកម្ពុជា ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គន្ថីទី៨ ជារបបមួយសម្រាប់ការពារ និងដោះស្រាយនូវបញ្ហាទាំងនេះ។

ភាគបម្រុង គឺភាគនៃមត៌កដែលត្រូវបានបម្រុងទុកអោយជនដែលមានសិទ្ធិលើភាគបម្រុង។ មិនថាសន្តតិកម្មតាមច្បាប់ ឬក៏តាមបណ្តាំឡើយ ភាគបម្រុងរបស់អ្នកមានសិទ្ធិត្រូវបានធានាមិនអោយបំពានឡើយ។ មានន័យថាជាភាគនៃទ្រព្យសម្បត្តិរបស់មតកជន ដែលបច្ឆាញាតិផ្ទាល់ ឬឪពុក ម្តាយ ឬជីដូន ជីតា និងសហព័ទ្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។

ការលើកយកប្រធានបទ ភាគបម្រុង មកធ្វើការតាក់តែងជាសារណាបញ្ចប់ការសិក្សា នេះគឺក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់ អោយកាន់តែច្បាស់ ពីការបែងចែកមត៌ក និងខ្លឹមសារនៃភាគបម្រុង ហើយលើសពីនេះទៀតដើម្បីយល់ដឹងអំពីអត្ថប្រយោជន៍របស់វាអោយកាន់តែស៊ីជម្រៅ នោះយើងត្រូវការធ្វើការសិក្សាអំពីការបែងចែកមត៌កតាមភាគបម្រុងទៅអោយអ្នកដែលមានសិទ្ធិ និងនីតិវិធីក្នុងការគណនាភាគបម្រុងដើម្បីធ្វើការបែងចែកយ៉ាងដូចម្តេច? យើងខ្ញុំនឹងធ្វើការបកស្រាយជា២ជំពូកធំៗ ដោយក្នុងជំពូកទី១ បកស្រាយអំពីសញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ ជំពូកទី២ បកស្រាយអំពីវិធីសាស្ត្រក្នុងការគណនាភាគបម្រុង ជំពូកទី៣ បកស្រាយអំពីនីតិវិធីនៃការកាត់បន្ថយនិងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

# ជំពូកទី ១
# សញ្ញាណទូទៅនៃការផ្ទេរ
# ទ្រព្យសម្បត្តិនៃញាតិ

# ជំពូកទី ១

# សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិ

សន្តតិកម្ម គឺជាការទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលមានលើទ្រព្យសម្បត្តិរបស់បុគ្គលដែលបានទទួលមរណភាព ដោយបុគ្គលផ្សេងទៀត។ សន្តតិកម្ម គឺសំដៅដល់ការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនដែលបានទទួលមរណភាពទៅឱ្យបុគ្គលដែលនៅរស់ ដែលហៅថា សន្តតិជនម្នាក់ ឬច្រើននាក់ តាមបណ្តាំ ឬតាមច្បាប់[1]។ បុគ្គលដែលមានសិទ្ធិធ្វើសន្តតិកម្ម ហៅថាសន្តតិជន ហើយបុគ្គលដែលត្រូវបានគេធ្វើសន្តតិកម្មហៅថា មតកជន។ បើយោងតាមន័យក្នុងសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពឆ្នាំ២០០៧ សន្តតិកម្ម គឺជាការផ្តល់នូវបេតិកភណ្ឌរបស់មតកជន ឱ្យទៅអ្នករស់ម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបែងចែកសន្តតិកម្មជាពីរប្រភេទធំៗរួមមានសន្តតិកម្ម ចែកចេញជាពីរគឺ សន្តតិកម្មដោយផ្អែកតាមឆន្ទៈ ដែលមានបណ្តាំធ្វើឡើងដោយមតកជន និងសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ដែលគ្មានបណ្តាំ ដូច្នេះតុលាការ គឺជាអ្នកកំណត់។

ជាគោលការណ៍រាល់សន្តតិកម្មមិនថាតែសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍នោះទេ គឺតែងតែចាប់ផ្តើមនូវពេលដែលមតកជនទទួលមរណៈភាព។ ប្រសិនបើមតកជនបានបន្សល់ទុកនូវលិខិតបណ្តាំនោះវាមិនមានចោទជាបញ្ហានោះទេ តែប្រសិនបើមតកជនមិនបានបង្ហាញឆន្ទៈណាមួយទេ ច្បាប់នឹងដើរតួនាទីក្នុងការបែងចែកនូវទ្រព្យទាំងនោះដោយកំណត់អំពីនរណាជាសន្តតិជន ថាតើមានសន្តតិកម្មរបស់សហព័ទ្ធ ឬយ៉ាងណា និងប្រសិនបើមានវត្តមាននៃផលប្រយោជន៍ពិសេស ប្រទានកម្ម អច្ច័យទាន ត្រូវមានការសម្រួលចំណែកមត៌កជាអាទិ៍។ ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ ធ្វើការបែងចែកប្រព័ន្ធសន្តតិកម្មជាពីរប្រភេទ ដែលរួមមានសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។

ខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីសន្តតិកម្មតាមច្បាប់(កថាខណ្ឌទី១) និងសន្តតិកម្មតាម មតកសាសន៍ (កថាខណ្ឌទី២) និងភាពដូចគ្នា និងខុសគ្នារវាងសន្តតិកម្មតាមច្បាប់ និងមតកសាសន៍(កថាខណ្ឌទី៣)។

### កថាខណ្ឌទី១៖ សន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ គឺជាសន្តតិកម្មដែលផ្អែកតាមច្បាប់។ ពាក្យសន្តតិកម្ម ត្រូវបានឱ្យនិយមន័យថាជាការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់ បុគ្គលណាម្នាក់ ដែលបានទទួលមរណភាព ទៅឱ្យបុគ្គលណាម្នាក់ ឬ

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២១។

ច្រើននាក់ ក្នុងឋានៈជាសន្តតិជនរបស់បុគ្គលដែលទទួលមរណភាពនោះ ដែលអាចជាការផ្ទេរតាមឆន្ទៈរបស់បុគ្គលដែលស្លាប់នោះ ឬតាមផ្លូវច្បាប់[2]។ ពាក្យ "ទ្រព្យសម្បត្តិ" នៃសន្តតិជន សំដៅទៅលើទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ អ្នកដែលទទួលមរណភាពខាងលើ ត្រូវបានហៅថា "មតកជន" រីឯអ្នកដែលត្រូវទទួលសន្តតិកម្មពីមតកជននោះ គឺជាសន្តតិជន។ មួយវិញទៀតសន្តតិជន អាចជាបុគ្គលតែម្នាក់ ឬបុគ្គលច្រើននាក់ ដែលអាចជាកូន ចៅ ប្រពន្ធ ឪពុក ម្តាយ ជីដូន ជីតា និង បងប្អូនបង្កើត។ ល។

ពាក្យ "សន្តតិកម្មតាមច្បាប់" សំដៅទៅលើការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់បុគ្គលណាម្នាក់ដែលបានទទួលមរណៈភាព ទៅឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ដែលមិនមានបន្សល់ទុកលិខិតបណ្តាំពីមតកជន ហើយរាល់ការបែងចែកចំណែកមត៌កនោះ គឺត្រូវអនុវត្តទៅតាមច្បាប់ទាំងអស់ដោយមិនពិចារណាទៅលើឆន្ទៈរបស់មតកជនកាលនៅរស់នោះទេ[3]។ មូលហេតុដែលនាំឱ្យមានសន្តតិកម្មតាមច្បាប់នោះមានពីរដូចតទៅ៖

ទី១ មតកជន ពុំបានបន្សល់ទុកលិខិតបណ្តាំដែលបង្ហាញឆន្ទៈរបស់ខ្លួន ចំពោះការបែងចែកចំណែកមត៌កទៅឱ្យសន្តតិជនណាមួយ ក្នុងទំហំ ឬកម្រិតនៃទ្រព្យសម្បត្តិប៉ុណ្ណានោះទេ អាចក្នុងករណីទទួលមរណភាពដោយគ្រោះថ្នាក់ចៃដន្យ ឬភ្លាមតែម្តង។ ទី២ ពិតជាមានករណីបានធ្វើលិខិតបណ្តាំដោយមតកជនដែរ ប៉ុន្តែលិខិតបណ្តាំនោះគ្មានសុពលភាពគតិយុត្តិអ្វីទេ ដែលបណ្តាលមកពីវាមិនត្រឹមត្រូវ ឬមិនស្របតាមច្បាប់។

សន្តតិកម្មតាមច្បាប់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានចរិតលក្ខណៈចាប់បង្ខំឱ្យអនុវត្ត និងអនុញ្ញាតឱ្យមានការគោរពទៅលើឆន្ទៈរបស់បុគ្គលឯកជនផងដែរ។ ក្នុងន័យនៃចរិកលក្ខណៈចាប់បង្ខំឱ្យអនុវត្ត សំដៅថា សន្តតិជនទាំងអស់ពុំអាចធ្វើការទាមទារសន្តតិកម្ម ឬធ្វើការផ្លាស់ប្តូរលំដាប់នៃសន្តតិកម្មដែលច្បាប់បានកំណត់រួចហើយនោះទេ គឺត្រូវគោរពតាមបញ្ញត្តិច្បាប់។ ក្នុងន័យចរិតលក្ខណៈដែលគោរពតាមឆន្ទៈនៃបុគ្គលឯកជនសំដៅសន្តតិជននៅតែមានសិទ្ធិក្នុងការទទួលបានភាគនៃវិភាគទាន ដែលខ្លួនបានជួយទំនុកបម្រុងទៅលើមតកជន ឬ បានសហការក្នុងការបង្កើន ឬ ថែរក្សាផ្នែកសេដ្ឋកិច្ចនៃមតកជនតាមការទាមទារទៅតុលាការ។ ជាងនេះទៅទៀត សន្តតិជននៅតែមានសិទ្ធិក្នុងការយល់ព្រមទទួល ឬ បដិសេធដោយការបោះបង់ក្នុងការទទួលចំណែកមត៌ករបស់មតកជន ទោះបីជាទទួលបានដោយផ្នែក ឬទាំងអស់នៃចំណែកមត៌កក៏ដោយ។ ការធ្វើបែបនេះ ដើម្បីតែធ្វើការរក្សាការពារផលប្រយោជន៍របស់សន្តតិជនព្រោះចំណែកមត៌កដែលសន្តតិជនត្រូវទទួលបានអាចជាកាតព្វកិច្ចច្រើនផលប្រយោជន៍ទៅវិញ ដែលនាំឱ្យសន្តតិជនក្ស័យធន។

[2] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២១។
[3] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១១៤៥ កថាខណ្ឌទី២។

ចំពោះលំដាប់សន្តតិជនក្នុងការទទួលបាននូវចំណែកមត៌ក តាមសន្តតិកម្មតាមច្បាប់មានតែបីលំដាប់តែប៉ុណ្ណោះ។ នៅពេលបុគ្គលណាម្នាក់ស្លាប់ដោយឥតបានធ្វើបណ្តាំ គេត្រូវស្វែងរកថាបុគ្គលណាខ្លះ ដែលមានសិទ្ធិឡើងទទួលមរតករបស់ខ្មោច។ បុគ្គលដែលមានសិទ្ធិ គឺជាបុគ្គលទាំងឡាយណា ដែលជាញាតិរបស់មតកជន។ ញាតិរបស់មតកជន សំដៅលើញាតិលោហិត ពោលគឺមិនមែនញាតិព័ន្ធទេ។ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។ កូនរបស់មតកជនមានន័យថា កូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ដូច្នេះចំពោះកូនក្រៅអាពាហពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ហេតុនេះកូននោះមិនអាចក្លាយជាសន្តតិជនរបស់មតកជនបានទេ។ កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា[4]។ បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជនជំនួស។ ប្រសិនបើមតកជនពុំមានកូនតែមានចៅនោះ ដូច្នេះចៅនោះនឹងត្រូវក្លាយជាសន្តតិជនជំនួសកូនរបស់មតកជន ហើយទទួលចំណែកមត៌កនោះ។ ប៉ុន្តែប្រសិនបើមិនមានសន្តតិជនជំនួសទេ នោះសន្តតិជនលំដាប់ទី២នឹងចូលខ្លួនមកដើម្បីទទួលចំណែកមត៌ក ដែលសន្តតិជនលំដាប់ទី២ នោះគឺបុព្វញាតិផ្ទាល់របស់មតកជន ហើយរវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងជាមុន។ ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗ ត្រូវទទួលចំណែកមត៌កស្មើៗគ្នា។ បើមត៌កជនពុំមានទាំងបច្ឆាញាតិផ្ទាល់ទាំងបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជនដែលជាសន្តតិជន ដែលមានលំដាប់ទី៣។ ប៉ុន្តែក្នុងករណីដែលមានបងប្អូនបង្កើតច្រើននាក់ បងប្អូនបង្កើតម្នាក់ៗ ត្រូវបានចំណែកមត៌កភាគស្មើៗគ្នា។ ក៏ប៉ុន្តែ ចំពោះបងប្អូនបង្កើតដែលមានឪពុក ឬមានម្តាយផ្សេងគ្នា ត្រូវបានទទួលពាក់កណ្តាលនៃចំណែករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា។ ចំណែកឯសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច មានន័យថា នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្នុងលំដាប់ណាមួយនោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននោះ ដែរ។ ក៏ប៉ុន្តែក្នុងករណីដែលជននោះជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលត្រូវផ្តាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ។

**កថាខណ្ឌទី២៖ សន្តតិជនតាមមតកសាសន៍**

មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។[5] បុគ្គលដែល

---

[4] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៥៦។

[5] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០/០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី,ទំព័រ១៧។

អាចធ្វើមតកសាសន៍បាន គឺជាបុគ្គលដែលជានិតិជន។ ដើម្បីធ្វើមតកសាសន៍ ជនទាំងនេះត្រូវមានសមត្ថភាពខាងឆន្ទះ។ ចំពោះទម្រង់នៃលិខិតមតកសាសន៍គឺមានច្រើនប្រភេទ ប៉ុន្តែយើងមិនលើយកមកសិក្សាឱ្យស៊ីជម្រៅទេ គឺយើងសិក្សាលើតែនិយមន័យនិងសញ្ញាណខ្លះៗ នៃទម្រង់ទាំងនោះតែប៉ុណ្ណោះ។

ដោយហេតុថាច្បាប់កម្ពុជា គោរពនូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ចំពោះលំដាប់សន្តតិជនក្នុងការទទួលបាននូវចំណែកមត៌ក តាមសន្តតិកម្មតាមច្បាប់មានតែបីលំដាប់តែប៉ុណ្ណោះ។ នៅពេលបុគ្គលណាម្នាក់ស្លាប់ដោយឥតបានធ្វើបណ្តាំ គេត្រូវស្វែងរកថាបុគ្គលណាខ្លះ ដែលមានសិទ្ធិឡើងទទួលមរតករបស់ខ្មោច។ បុគ្គលដែលមានសិទ្ធិ គឺជាបុគ្គលទាំងឡាយណា ដែលជាញាតិរបស់ មតកជន។ ញាតិរបស់មតកជន សំដៅលើញាតិលោហិត ពោលគឺមិនមែនញាតិព័ន្ធទេ។ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។ កូនរបស់មតកជនមានន័យថា កូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ដូច្នេះចំពោះកូនក្រៅអាពាហពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ហេតុនេះកូននោះមិនអាចក្លាយជាសន្តតិជនរបស់មតកជនបានទេ។ កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា[6]។ បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជនជំនួស។ ប្រសិនបើមតកជនពុំមានកូនតែមានចៅនោះ ដូច្នេះចៅនោះនឹងត្រូវក្លាយជាសន្តតិជនជំនួសកូនរបស់មតកជន ហើយទទួលចំណែកមត៌កនោះ។ ប៉ុន្តែប្រសិនបើមិនមានសន្តតិជនជំនួសទេ នោះសន្តតិជនលំដាប់ទី២នឹងចូលខ្លួនមកដើម្បីទទួលចំណែកមត៌ក ដែលសន្តតិជនលំដាប់ទី២ នោះគឺបុព្វញាតិផ្ទាល់របស់មតកជន ហើយរវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងជាមុន។ ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗ ត្រូវទទួលចំណែកមត៌កស្មើៗគ្នា។ បើមត៌កជនពុំមានទាំងបច្ឆាញាតិផ្ទាល់ទាំង បុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិ-ជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជនដែលជាសន្តតិជន ដែលមានលំដាប់ទី៣។ ប៉ុន្តែក្នុងករណីដែលមានបងប្អូនបង្កើតច្រើននាក់ បងប្អូនបង្កើតម្នាក់ៗ ត្រូវបានចំណែកមត៌កភាគស្មើៗគ្នា។ ក៏ប៉ុន្តែចំពោះបងប្អូនបង្កើតដែលមានឪពុក ឬមានម្តាយផ្សេងគ្នា ត្រូវបានទទួលពាក់កណ្តាលនៃចំណែករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា។ ចំណែកឯ សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច មានន័យថា នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្នុងលំដាប់ណាមួយនោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននោះ ដែរ។ ក៏ប៉ុន្តែ

[6] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៥៦។

ក្នុងករណីដែលជននោះជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលត្រូវ ផ្ដាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ។

ដូចនេះច្បាប់ទទួលស្គាល់នូវឆន្ទៈរបស់មតកជននៅពេលដែលខ្លួននៅរស់ក្នុងការចាត់ចែងដោយសេរីនូវទ្រព្យសម្បត្តិរបស់ខ្លួន។ មានន័យថានៅពេលដែលនៅរស់មតកជន មានបំណងចាត់ចែងទ្រព្យរបស់ខ្លួនតាមបែបណានោះ ក្រោយពេលដែលគាត់ទទួលមរណភាពទៅ ឆន្ទៈនោះត្រូវបានគេគោរព និងយកមកអនុវត្តតាម។ តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឱ្យការសម្ដែងឆន្ទៈរបស់មតកជនមានអានុភាព ច្បាប់ក៏បានកំណត់ផងដែរពីទម្រង់ និងបែបបទក្នុងការសម្ដែង ឆន្ទៈទាំងនោះ ក៏ដូចជាវិធីនៃការបែងចែកទ្រព្យមត៌កនោះផងដែរ។ មតកសាសន៍ គឺជាលិខិតបណ្ដាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្ដែងឆន្ទៈចុងក្រោយអំពីការចាត់ចែក(អច្ច័យទាន) ទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីខ្លួនទទួលមរណភាព។ អច្ច័យទាន គឺជាការធ្វើប្រទានកម្ម នូវទ្រព្យសម្បត្តិរបស់មតកជន តាមរយៈមតកសាសន៍[7]។ ជាទូទៅខ្លឹមសារនៃមតកសាសន៍ គឺកំណត់អំពីចំណែកមត៌ក កំណត់ពីវិធីបែងចែកមត៌ក អនុប្បទាន និងកំណត់ពីអ្នកប្រតិបត្តិមតកសាសន៍ជាដើម។ ចំពោះមតកសាសន៍ទម្រង់ដែលមានកំណត់នៅក្នុងច្បាប់មានដូចជា មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតសម្ងាត់ មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍នៃជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់ដល់ជីវិត មតកសាសន៍របស់ជនដែលជាប់ឃុំឃាំង មតកសាសន៍របស់ជនដែលមិនអាចនិយាយបាន និងទម្រង់មតកសាសន៍របស់បុគ្គលដែលមានសញ្ជាតិខ្មែរដែលរស់នៅបរទេស ជាអាទិ៍។ នៅក្នុងករណីដែលមតកសាសន៍ ត្រូវបានធ្វើឡើងខុសនឹងទម្រង់ដែលមានកំណត់ខាងលើនេះ គឺមិនមានអានុភាពតាមផ្លូវច្បាប់ឡើយ។

### ក. ការតាក់តែងមតកសាសន៍

ជាគោលការណ៍ មតកសាសន៍ត្រូវបានធ្វើឡើងដោយម្ចាស់បណ្ដាំផ្ទាល់ ហើយទាមទារឱ្យម្ចាស់បណ្ដាំនោះមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការវិនិច្ឆ័យ យល់ដឹងអំពីភាពត្រឹមត្រូវ មានបញ្ញាស្មារតីគ្រប់គ្រាន់ ជារួមគឺមិនមែនជាមនុស្សដែលត្រូវបានច្បាប់កម្រិតសមត្ថភាពឡើយ។

ការតាក់តែងមតកសាសន៍ គឺជារឿងមួយដ៏ចាំបាច់សម្រាប់ម្ចាស់បណ្ដាំ ដែលមានបំណងចង់ធ្វើលិខិតបណ្ដាំមត៌ក។ តាមរយៈក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់អំពីទម្រង់នៃការតាក់តែងមតកសាសន៍ សម្រាប់ម្ចាស់បណ្ដាំដែលចង់ធ្វើតាមទម្រង់មួយណាក៏បាន។ ទម្រង់នៃមតកសាសន៍ត្រូវបានកំណត់ជា២ធំៗ គឺទម្រង់នៃមតកសាសន៍ធម្មតា និង មតកសាសន៍ក្នុងករណីពិសេស ។

[7] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២៦។

## ខ.ទម្រង់នៃមតកសាសន៍

ទម្រង់នៃលិខិតមតកសាសន៍ គឺជាការចាំបាច់មួយនៅក្នុងរបបសន្តតិកម្ម ដែលម្ចាស់បណ្តាំត្រូវធ្វើលិខិតបណ្តាំមត៌កឱ្យបានត្រឹមត្រូវទៅតាមទម្រង់លិខិត ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ជាការពិតណាស់ មតកសាសន៍ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងរដ្ឋប្បវេណីដែលកំពុងនៅជាធរមាននេះ[8]។ ក្នុងករណីមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នា។

- **លក្ខណៈដាច់ខាតនៃទម្រង់មតកសាសន៍**

នៅក្នុងសង្គមកម្ពុជាតែងតែមានការអនុវត្តនៅទម្លាប់មួយគឺ នៅពេលដែលឪពុក ឬម្តាយរៀបនឹងស្លាប់ តែងតែហៅកូនៗ មកជុំគ្នា ដើម្បីផ្តែផ្តាំដោយផ្ទាល់មាត់អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់គាត់ក្រោយពេលមរណភាព។ តើបណ្តាំដែលធ្វើឡើងបែបនេះមានសុពលភាពដែរឬទេ?

មតកសាសន៍ពុំអាចមានអានុភាពឡើយ បើពុំបានផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ មានន័យថាមតកសាសន៍ណាដែលបានធ្វើក្រៅពីទម្រង់ដែលមានចែងក្នុងច្បាប់ត្រូវចាត់ទុកជាមោឃៈ។ ដោយឡែក មតកសាសន៍ ដែលមិនបានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាមានសុពលភាព បើមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលធ្វើឡើងដោយម្ចាស់បណ្តាំដូចគ្នា ហើយប្រសិនបើមតកសាសន៍ដែលគ្មានចុះកាលបរិច្ឆេទនោះមានចំនួនច្រើនច្បាប់ និងមតកសាសន៍នោះផ្ទុយគ្នា អានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។ ដូចនេះការធ្វើបណ្តាំដោយផ្ទាល់មាត់ជាដើម នឹងមិនបង្កើនអនុភាពឡើយ។ លើសពីនេះទៅទៀត នៅពេលធ្វើមតកសាសន៍ ត្រូវមានសាក្សី ហើយជនដែលមិនអាចក្លាយជាសាក្សី ឬជាអ្នកសង្កេតការក្នុងពេលធ្វើមតកសាសន៍រួមមាន អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ជនដែលត្រូវបានសន្មតថាជាសន្តតិជនអច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ ហើយបើជាសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីនោះ[9]។

- **ទម្រង់នៃមតកសាសន៍ទូទៅ**

ជាទូទៅទម្រង់នៃមតកសាសន៍ត្រូវបានចែកចេញជាបីប្រភេទ មានដូចខាងក្រោមៈ

- **មតកសាសន៍ជាលិខិតយថាភូត**

មតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការីតាមទម្រង់ដូចខាងក្រោម[10] ៖

[8] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧០។
[9] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧២។
[10] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៣។

- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់
- ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់
- បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សី បានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវចំពោះខ្លឹមសារនៃមតកសាសន៍
- បើក្នុងករណីម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសារការីត្រូវសរសេរបន្ថែមនូវមូលហេតុទាំងនោះ
- សារការីត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

- **មតកសាសន៍ជាលិខិតឯកជន**[11]

មតកសាសន៍ដែលធ្វើឡើងដោយលិខិតឯកជន ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានប្រើម៉ាស៊ីនដូចជាអង្គុលីលេខជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ។ ម្ចាស់បណ្តាំអាចធ្វើការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ។

- **មតកសាសន៍ដោយលិខិតសម្ងាត់**[12]

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ៖

- ម្ចាស់បណ្តាំអាចសរសេរដោយខ្លួនឯង ឬ ឱ្យអ្នកដទៃសរសេរជំនួស
- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ
- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើកបញ្ជាក់ថា ស្រោមនោះបានបើក ឬមិនបើកនៅមាត់ស្រោមលិខិតនោះ

[11] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៤។

[12] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៥។

- ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី២ (ពីរ) នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ
- សារការីត្រូវចុះ ថ្ងៃ ខែ ឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំបានប្រាប់ និងចុះហត្ថលេខាជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ។

❖ **ទម្រង់នៃមតកសាសន៍ពិសេស**

- ***សាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ***[13]

ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាននៅពេលខ្លួនសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់។ វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមនៅលើលិខិតនោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំ ពុំបានស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាព នៅក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីនោះទេ ហើយត្រូវចុះហត្ថលេខា ដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ។

- **មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**[14]

ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតដោយសារជម្ងឺ ឬហេតុផ្សេងៗមានបំណងធ្វើមតកសាសន៍ បើជាជននោះអាចធ្វើមតកសាសន៍តាមធម្មតាក៏បាន។ ក្នុងករណីដែលពុំមានសមត្ថភាព ឬ ពុំមានពេលវេលា បើសិនជាមានវត្តមានមានសាក្សីយ៉ាងតិចបីនាក់ ម្ចាស់បណ្តាំអាចនិយាយតាមមាត់ អំពីគោលគំនិតនៃមតកសាសន៍របស់ខ្លួនប្រាប់សាក្សីម្នាក់ក្នុងចំណោមនោះ ហើយសាក្សីនោះសរសេរ។ បន្ទាប់ពីបានបញ្ជាក់នូវខ្លឹមសារនៃមតកសាសន៍នោះ ហើយសាក្សីម្នាក់ៗត្រូវចុះហត្ថលេខាលើលិខិតនោះ។ សាក្សីណាម្នាក់ ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ដើម្បីទទួលបានការបញ្ជាក់អំពីភាពត្រឹមត្រូវ។ តុលាការត្រូវធ្វើការបញ្ជាក់មតកសាសន៍នោះ ប្រសិនបើឃើញថា មតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

- **មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍**[15]

[13] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៦។
[14] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៧។
[15] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៨។

ម្ចាស់បណ្តាំដែលត្រូវឃុំឃាំងដោយសារសេចក្តីសម្រេចរបស់តុលាការ អាចធ្វើលិខិតមតកសាសន៍បាន ដោយមានវត្តមាននគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ០២ (ពីរ) នាក់។ ចំពោះជនដែលត្រូវជាប់ឃុំឃាំង ឬជនដែលនៅលើនាវា ឬនៅក្នុងយន្តហោះ បើសិនជាអាចធ្វើមតកសាសន៍បាន (មតកសាសន៍ដោយលិខិតឯកជន) ជននោះអាចធ្វើមតកសាសន៍បាន ដោយត្រូវមានវត្តមានមេបញ្ជាការ ឬបរិបាលនាវា ឬបុគ្គលិកម្នាក់ និងសាក្សីយ៉ាងតិច ០២ (ពីរ) នាក់។ អាចមានករណីដែលម្ចាស់បណ្តាំមិនចេះអក្សរ ឬខូចដៃ។ នីតិវិធីនៃករណីនេះ គឺប្រហាក់ប្រហែលនឹងមតកសាសន៍ដោយលិខិតយថាភូតដែរ គឺនគរបាល ឬនាវិកនាយកជាដើម នឹងមានតួនាទីជាសារការី។ មតកសាសន៍នេះពុំមានអនុភាពឡើង បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល០៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនត្រូវបានដោះលែង។

- **មតកសាសន៍នៃជនដែលមិនអាចនិយាយបាន**[16]

នៅក្នុងករណីចំពោះជនដែលមិនអាចនិយាយបាន អាចធ្វើមតកសាសន៍បាន ដោយម្ចាស់បណ្តាំធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃផ្ទាល់ខ្លួន នៅចំពោះសារការី ឬសាក្សី។ សារការី ឬបុគ្គលផ្សេងទៀត ត្រូវអានឱ្យម្ចាស់បណ្តាំស្តាប់ ដោយមានការបកប្រែពីអ្នកបកប្រែ នៅឱ្យម្ចាស់បណ្តាំ ឬសាក្សី។ សារការី ឬបុគ្គលផ្សេងទៀត ត្រូវសរសេរអំពីហេតុនោះនៅក្នុងមតកសាសន៍។

- **មតកសាសន៍របស់អ្នកមានសញ្ជាតិខ្មែររស់នៅបរទេស**[17]

អ្នកមានសញ្ជាតិខ្មែរដែលរស់នៅបរទេស អាចធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬលិខិតសម្ងាត់ នៅទីកន្លែងដែលមានកុងស៊ុល ឬ ទូតនៃប្រទេសកម្ពុជាប្រចាំ ដោយកុងស៊ុល ឬទូតនោះ ត្រូវអនុវត្តតួនាទីជាសារការី។ ក្នុងករណីដែសារការី និងសាក្សីត្រូវចុះហត្ថលេខា សារការី និងសាក្សីអាចសរសេរឈ្មោះ ហើយអាចផ្តិតមេដៃជំនួសឱ្យការចុះហត្ថលេខាបាន។

## កថាខណ្ឌទី៣៖ ភាពដូចគ្នា និងខុសគ្នារវាង សន្តតិកម្មតាមច្បាប់ និង មតកសាសន៍

ថ្វីត្បិតតែ សន្តតិកម្មទាំងពីរគឺត្រូវបានធ្វើឡើងក្នុងស្ថានភាពពីរខុសគ្នា ដូចបានរៀបរាប់ខាងលើក៏ពិតមែន ប៉ុន្តែសន្តតិកម្មទាំងពីរក៏មានចំណុចដូចគ្នា និងខុសគ្នាផងដែរ ដូច្នេះដើម្បីកាន់តែយល់ច្បាស់ គឺយើងនឹងធ្វើការបង្ហាញអំពីចំណុចដូចគ្នា និងខុសគ្នាដូចខាងក្រោម៖

- **ចំណុចដូចគ្នា**

[16] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៩។
[17] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨១។

- សន្តតិកម្មទាំងពីរចាប់ផ្តើមនៅពេលដែលមតកជនទទួលមរណភាព ឬបាត់ខ្លួន ចំពោះការបាត់ខ្លួនក៏ត្រូវចាត់ទុកថាជាការទទួលមរណភាព[18]
- មិនថាតែការបែងចែកមត៌កតាមច្បាប់ ឬតាមមតកសាសន៍ បុគ្គលដែលមានសិទ្ធិនិងករណីកិច្ចលើទ្រព្យទាំងនោះ មានសិទ្ធិស្វ័យសម្រេច ក្នុងការមិនទទួលយកទ្រព្យរបស់មតកជនក្រោយពេលស្លាប់ ឬបាត់ខ្លួនបាន
- សន្តតិកម្ម គឺត្រូវចាប់ផ្តើមនៅលំនៅដ្ឋានរបស់មតកជនជាពេលទទួលមរណភាពមានន័យថាទ្រព្យដែលមតកជនបានបន្សល់ទុកគឺ នឹងត្រូវធ្វើការបែងចែកនៅក្នុងលំនៅដ្ឋានចុងក្រោយរបស់មតកជនដែលទទួលមរណភាព
- ប្រព័ន្ធសន្តតិកម្មទាំងពីរធ្វើការទាមទារឱ្យបុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចទាំងអស់ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានសន្តតិកម្ម ដោយបុគ្គលទាំងនោះ មិនត្រូវក្លាយទៅជាអភ័ព្វបុគ្គល ឬអ្នកដែលត្រូវផ្តាច់ចេញពីមត៌កនោះទេ

➢ **ចំណុចខុសគ្នា**

❖ **សន្តតិកម្មតាមច្បាប់**

- អ្នកទទួលបាននូវចំណែកមត៌កហៅថា សន្តតិជន
- ជាសន្តតិជនមួយដែលស្ថិតនៅក្រៅឆន្ទៈរបស់មតកជន
- បានកំណត់អំពីបុគ្គលដែលត្រូវក្លាយជាសន្តតិជន
- ការបែងចែកមត៌កត្រូវធ្វើតាមសន្តតិកម្មតាមច្បាប់
- សន្តតិជនទាំងអស់ទទួលបាននូវភាពយុត្តិធម៌
- សន្តតិកម្មតាមច្បាប់គ្មានទម្រង់ក្នុងការបង្កើតទេ
- ចំពោះសន្តតិកម្មតាមច្បាប់មិនមានការអនុវត្តដោយបង្ខង់ទេ
- ការបែងចែកមត៌កមានរយៈពេលយូរ
- ការផ្ទេរមត៌កត្រូវតែជាសាច់ញាតិ ឬសហព័ទ្ធរបស់មតកជន
- មិនចាំបាច់មានសាក្សីដើម្បីបង្ហាញអំពីការបែងចែកមត៌កទេ។

❖ **សន្តតិកម្មតាមមតកសាសន៍**

- អ្នកទទួលបានចំណែកមត៌កហៅថា អច្ច័យលាភី

[18] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៤៣។

- ជាសន្តិកម្មមួយដែលបង្កើតឡើងតាមឆន្ទៈរបស់មតកជន
- មិនមានកំណត់អំពីបុគ្គលដែលត្រូវទទួលបានសន្តតិកម្ម
- ការបែងចែកមត៌កត្រូវធ្វើតាមសន្តតិកម្មតាមមតកសាសន៍
- សន្តតិជនពេលខ្លះមិនមានភាពយុត្តិធម៌ក្នុងការបែងចែកមត៌ក
- សន្តតិជនតាមមតកសាសន៍មានទម្រង់ក្នុងការបង្កើត
- មតកជនបានបង្ហាញឆន្ទៈដើម្បីឱ្យសន្តតិជនអនុវត្តដោយបង្ខង់បាន
- មិនបានការបែងចែកមត៌កយូរទេ
- មិនមានការកំណត់ថាការប្រគល់មត៌កត្រូវតែជាសាច់ញាតិរបស់មតកជនទេ
- ទាមទារឱ្យមានសាក្សីដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃលិខិតមតកសាសន៍។

# ផ្នែកទី២៖ ភាគបម្រុង

## កថាខណ្ឌទី១៖ សញ្ញាណទូទៅនៃភាគបម្រុង

### ក. និយមន័យ

របបនៃភាគបម្រុងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺជាការធានានៃចំណែកមត៌កដែលកំណត់ដោយច្បាប់ចំពោះជនទាំងឡាយណាដែលជាសន្តតិជន ដោយមូលហេតុថា ទោះបីជាមតកជនមានសិទ្ធសេរីភាពក្នុងការបដិសេធនូវសេរីភាពក្នុងការធ្វើមតកសាសន៍នេះ ពេលដែលសន្តតិជននោះទទួលរងការរំលោភបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួន។ របបនៃភាគបម្រុងមានតួនាទីក្នុងការសម្របសម្រួល សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ និងជាការធានាកុំឱ្យមាននូវការបំពានទៅលើ សិទ្ធិលើចំណែកមត៌ក។ មូលហេតុផ្សេងៗដែលអាចធ្វើឱ្យក្លាយជាបំពានទៅលើសិទ្ធិលើចំណែកមត៌ក។ មូលហេតុផ្សេងៗដែលអាចធ្វើឱ្យក្លាយជាការបំពានលើភាគបម្រុងនោះគឺ ករណីមានអច្ច័យទាន ឬប្រទានកម្មកំណត់មួយចំនួនពេលមតកជននៅរស់ ឬការទទួលបានផលប្រយោជន៍ពិសេស ឬការកំណត់ចំណែកតាមមតកសាសន៍។

ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នមិនមានមាត្រាណាមួយ កំណត់និយមន័យឱ្យបានជាក់លាក់នោះទេអំពីអ្វីទៅជា "**ភាគបម្រុង**" នោះឡើយ។ ប៉ុន្តែបើយើងធ្វើការសិក្សាទៅលើក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ ឃើញថាគេបានឱ្យនិយមន័យថា៖ ភាគបម្រុង គឺជារបបមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ក៏មិនអាចនឹងចាត់ចែងទ្រព្យសម្បត្តិ ដោយសេរីបានឡើយ។ ទោះបីជាក្រមរដ្ឋប្បវេណីមិនបានឱ្យនិយមន័យនៃរបបភាគបម្រុងនេះក៏ដោយ តែយើងអាចកំណត់អំពីអត្ថន័យនៃរបបនេះតាមរយៈការសិក្សាលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានឱ្យនិយមន័យថា **ភាគបម្រុង** គឺជាសិទ្ធិភាគដែលទទួលបានមត៌កជាអប្បរមាដែលត្រូវ

ធានដោយច្បាប់ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង[19]។ ម្យ៉ាងទៀតអាចឱ្យនិយមន័យបានថា ភាគបម្រុង គឺជាភាគនៃមត៌កដែលត្រូវបានបម្រុងទុកឱ្យជនដែលមានសិទ្ធិលើភាគបម្រុងមិនថាតែតាមសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមបណ្តាំឡើយ។

**ខ. គោលបំណង**

បញ្ញត្តិស្តីពីភាគបម្រុង ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីធាធានូវចំណែកមត៌កអប្បបរមាចំពោះសន្តតិជនមួយចំនួន (ញាតិជិតស្និទ្ធនឹងមតកជន) និងអនុញ្ញាតឱ្យសន្តតិជនបានមួយចំនួន អ្នកមានសិទ្ធិលើភាគបម្រុងបដិសេធនូវសេរីភាពមួយផ្នែកជាឆន្ទៈរបស់មតកជននៅក្នុងមតកសាសន៍[20]។

**គ. ផលប្រយោជន៍**

ការកំណត់អំពីភាគបម្រុងមានផលប្រយោជន៍ដូចខាងក្រោម៖

ដើម្បីជាប្រយោជន៍ដល់ការសម្របសម្រួលរវាងសន្តិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ នេះមានន័យថា ជាទូទៅមិនថាសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍នោះទេ តែងតែមានការបំពាននូវភាគបម្រុង។ ដូចដែលយើងដឹងហើយថា សន្តតិកម្មតាមច្បាប់ គឺជាផ្ទេរបេតិកភណ្ឌពីមតកជនដែលឥតមានលិខិតបណ្តាំ ហើយការបែងចែកចំណែកមត៌កត្រូវផ្អែក តាមបញ្ញត្តិនៃច្បាប់ដោយមិនបានគិតពីឆន្ទៈរបស់មតកជនឡើយ ប៉ុន្តែវាអាចមានការបំពាននៅពេលដែលសន្តតិជនណាម្នាក់ ឬច្រើននាក់នោះបានទទួលនូវផលប្រយោជន៍ពិសេស ឬប្រទានកម្មជាដើមនៅមុនពេលដែលមតកជនទទួលមរណភាព ដែលជាហេតុធ្វើឱ្យសន្តតិជនដទៃទៀតទទួលចំណែកមត៌កតិចតួចដែលមិននឹងទទួល ឬ មិនទទួលបានសោះតែម្តង បើប្រៀបធៀបទៅនឹងសន្តតិជន ដែលទទួលនូវផលប្រយោជន៍ពិសេសនោះ។ ចំណែកឯសន្តតិកម្មតាមមតកសាសន៍ផ្អែកតាមឆន្ទៈ (ករណីមានលិខិតបណ្តាំ) របស់មតកជន ដែលពេលខ្លះមតកជនបានផ្ទេរនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅសន្តិជនណាម្នាក់ លើសសន្តតិជនដទៃទាំងអស់ដោយមានមូលហេតុផ្សេងៗ ឬ ក៏បានផ្ទេរនូវទ្រព្យសម្បត្តិទាំងនោះឱ្យទៅតតិយជនតាមរយៈការធ្វើអច្ច័យទានជាដើម ដែលជាហេតុធ្វើឱ្យបំពានលើសន្តតិជនដទៃទៀត។ ដូចនេះដើម្បីជៀសវាងនូវការបំពានទាំងនោះទើបមានការកំណត់ភាគបម្រុងនេះឡើង។

រក្សាទុកនូវចំណែកមត៌កជាក់លាក់លើទ្រព្យសម្បត្តិរបស់មតកជន សម្រាប់ជន ដែលបានរស់នៅក្នុងបន្ទុក ហើយជៀសវាង ឬបង្ការដើម្បីកុំឱ្យមានជម្លោះនឹងគ្នារវាងបងប្អូន ឬចងគុំនុំនឹងគ្នា។ ចំណែកឯនៅក្នុងក្រមរដ្ឋប្បវេណីបានថែងចែកថា ផលប្រយោជន៍នៃការកំណត់ភាគបម្រុងគឺរក្សានូវចំណែកមត៌កជាក់លាក់លើទ្រព្យ

[19] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០។

[20] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០។

របស់មតកជន ដើម្បីការពារប្រយោជន៍អ្នកដែលជាសន្តតិជនប៉ុណ្ណោះ ដោយមិនចង់ឱ្យទ្រព្យសម្បត្តិធ្លាក់ទៅជនដែលមិនមែនជាសាច់ញាតិរបស់មតកជន។

ដោះស្រាយនូវចំណែកមត៌កជាសក្តានុពលសម្រាប់ញាតិជិតស្និទ្ធ ដែលបានចូលរួមក្នុងការបង្កើតទ្រព្យសម្បត្តិរបស់មតកជន។ បញ្ហាមួយចំនួនតែងតែកើតឡើងនៅក្នុងការបែងចែកមត៌ក ដូច្នេះហើយ ការកំណត់ភាគបម្រុងគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការបែងចែកនូវចំណែកមត៌ក សម្រាប់ញាតិជិតស្និទ្ធ ដោយមតកសាសន៍ត្រូវធ្វើឡើងតាមឆន្ទៈរបស់មតកជន ប៉ុន្តែច្បាប់មិនអនុញ្ញាតឱ្យតតិយជនទទួលចំណែកទ្រព្យសម្បត្តិទាំងអស់ ហើយដោយមិនគិតពីសន្តតិជនឡើយ។ ដូចនេះ វិធីដោះស្រាយនូវចំណែកមត៌កជាសក្តានុពល សម្រាប់ញាតិជិតស្និទ្ធ ដែលបានចូលរួមក្នុងការបង្កើតទ្រព្យសម្បត្តិរបស់ មតកជនគឺមិនចាំបាច់ពិភាក្សាអំពីការបែងចែកមត៌ក ដោយសហសន្តតិជនទេ។

## កថាខណ្ឌទី២៖ អ្នកមានសិទ្ធិលើភាគបម្រុង

ក្រមរដ្ឋប្បវេណី បានកំណត់យកជនមួយចំនួនដែលជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមតកជនជាអ្នកមានសិទ្ធិលើភាគបម្រុង។

អ្នកមានសិទ្ធិលើភាគបម្រុង គឺបច្ឆាញាតិផ្ទាល់ ឪពុកម្តាយ ឬ ជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ មានន័យថាអ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ នឹងក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង។ លើសពីនេះទៅទៀតជាគោលការណ៍ភាគបម្រុង គឺ១/២ នៃមត៌ករបស់មតកជនលើកលែងតែឪពុក-ម្តាយ ឬជីដូនជីតា ជាសន្តតិជនដែលភាគបម្រុង គឺ ១/៣ នៃមត៌ករបស់មតកជន។ ដោយខ្សែរកបងប្អូនបង្កើត (សន្តតិជនលំដាប់ទី៣) មិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីជាត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនក៏ដោយ។

ខ្លឹមសារខាងលើនេះ គឺឆ្លុះបញ្ចាំងពីទំនាក់ទំនងនៃការកំណត់លំដាប់សន្តតិជន ដែលយើងគប្បីដឹងថាសន្តតិជនលំដាប់ណាខ្លះដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ហើយសន្តតិជនដែលនៅលំដាប់បន្ទាប់អាចទទួលសិទ្ធិលើភាគបម្រុងដែរឬទេ ?

នៅក្នុងចំណោមសន្តតិជនដែលរួមមានបច្ឆាញាតិផ្ទាល់ ឪពុក ម្តាយ ជីដូន ជីតា និងសហព័ទ្ធ គឺមានតែសន្តតិជននៅក្នុងលំដាប់ដែលត្រូវទទួលមត៌កប៉ុណ្ណោះទើបមានសិទ្ធិលើភាគបម្រុង។

### ក. បច្ឆាញាតិផ្ទាល់

បច្ឆាញាតិផ្ទាល់ជាអ្នកមានសិទ្ធិលើភាគបម្រុង មានន័យថាជាជនមួយដែលកើតចេញពីជនមួយទៀត ។ ឧទាហរណ៍ កូនជាបច្ឆាញាតិផ្ទាល់របស់ឪពុកម្តាយ ចៅជាបច្ឆាញាតិរបស់ជីដូនជីតា នៅទីនេះ យើងនឹងធ្វើការបកស្រាយអំពីកូនដែលជាបច្ឆាញាតិផ្ទាល់ឪពុកម្តាយដោយមិនលើកយកចៅមកធ្វើការបកស្រាយនោះទេ

ពីព្រោះចៅរបស់មតកជន ឬអាចនិយាយបានថាកូនរបស់កូនដែលជាសន្តតិជន ហើយត្រូវជាចៅរបស់មតកជនអាចទាមទារភាគបម្រុងបានតាមរយៈសន្តតិកម្មជំនួសដែលយើងនឹងធ្វើការពន្យល់នៅក្នុងកថាខណ្ឌទាក់ទងនឹងសន្តតិកម្មជំនួស។

### ខ. ឪពុកម្តាយ ឬ ជីដូនជីតា

ឪពុកម្តាយ ឬ ជីដូនជីតាត្រូវបានច្បាប់ចាត់ទុកជាសន្តតិជន ដែលមានសិទ្ធិលើភាគបម្រុងផងដែរ ។ ការរស់នៅប្រចាំថ្ងៃទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនមានលក្ខណៈស្មុគស្មាញរវាងឪពុកម្តាយបង្កើត និងកូនបង្កើត ឬ ឪពុកម្តាយចិញ្ចឹម និងកូនសុំ ។ តើទាំងឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹមមានសិទ្ធិលើភាគបម្រុងដូចគ្នាដែរឬទេ?

ជាការពិតណាស់ឪពុកម្តាយបង្កើតជាសន្តតិជនដែលមានសិទ្ធិលើភាគបម្រុង។ គ្មានអ្វីប្លែកទេព្រោះច្បាប់បានទទួលស្គាល់ឪពុកម្តាយជាសន្តតិជនលំដាប់ទី២តាមការកំណត់របស់ច្បាប់ដែរ។ ប៉ុន្តែ មានករណីមួយដែលឪពុកម្តាយបង្កើតមិនអាចក្លាយជាសន្តតិជននឹងគ្មានសិទ្ធិលើភាគបម្រុង ដែលយើងមិនត្រូវមើលរំលងនោះគឺឪពុកម្តាយរបស់សុំកូនពេញលេញ។ ដូចដែលយើងដឹងហើយថា ញាតិភាពរវាងកូនសុំ នឹងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះត្រូវបានបញ្ចប់ដោយសុំកូនពេញលេញ។ ចំពោះទំនាក់ទំនងឪពុកម្តាយចិញ្ចឹមវិញ ទោះបីជាឪពុកម្តាយចិញ្ចឹមរបស់កូនសុំពេញលេញ ឬធម្មតាសុទ្ធតែអាចក្លាយជាសន្តតិជននឹងមានសិទ្ធិលើភាគបម្រុងដូចគ្នា។

ពាក់ព័ន្ធនឹងជីដូនជីតា ចំពោះជីដូនជីតានៃឪពុកម្តាយបង្កើតរបស់កូនសុំពេញលេញ មិនក្លាយជាសន្តតិជនទេ ពីព្រោះការបញ្ចប់ញាតិភាពមិនមែនមានអានុភាពត្រឹមតែឪពុកម្តាយបង្កើតតែប៉ុណ្ណោះទេ គឺញាតិលោហិតទាំងអស់តែម្តង។ ផ្ទុយទៅវិញ ជីដូនជីតានៃឪពុកម្តាយរបស់កូនសុំ មិនត្រឹមតែសុំពេញលេញ ឬធម្មតាក៏ដោយគឺ ដូចគ្នានឹងឪពុកម្តាយចិញ្ចឹម។

### គ. សហព័ទ្ធរបស់មតកជនជាសន្តិជន

ជាគោលការណ៍ក្រមរដ្ឋប្បវេណីទទួលអ្នកទាំងនេះ ជាសន្តតិជនដែលត្រូវទទួលបន្តនូវមត៌ករបស់សាច់ញាតិដែលបានស្លាប់ទៅហើយនោះ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏មិនមានន័យថាអ្នកទាំងអស់គ្នានោះក៏ទទួលនូវចំណែកមត៌កមុនគេ។ ច្បាប់បានបញ្ញត្តិនូវលំដាប់នៃការទទួលទ្រព្យសម្បត្តិ ដែលជាមត៌ក នៃមតកជនដោយកំណត់យកបច្ឆាញាតិផ្ទាល់របស់មតកជន ជាអ្នកមានសិទ្ធិទទួលបានមត៌កមុនគេ។ ក្នុងករណីដែលមតកជនគ្មានបច្ឆាញាតិទាល់តែសោះ មត៌ករបស់មតកជននឹងត្រូវទទួលបន្តដោយបុព្វញាតិផ្ទាល់របស់មតកជននោះ។

ចំពោះសន្តតិជនលំដាប់ទី៣វិញ លុះត្រាតែមតកជននោះគ្មានបច្ឆាញាតិផ្ទាល់ ហើយក៏គ្មានបុព្វញាតិផ្ទាល់ដែរ នោះទើបខ្លួនអាចទទួលបានឋានៈជាសន្តតិជន។

ដោយឡែកសហព័ទ្ធរបស់មតកជនជាជនដែលមានភ័ព្វទទួលបានឋានៈជាសន្តតិជនជានិច្ច ទោះជាមានសន្តតិជនលំដាប់ណាក៏ដោយ សហព័ទ្ធនៅតែទទួលឋានៈជាសន្តតិជនដដែល ពោលគឺ មិនថាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

ចំពោះភាគបម្រុង អ្នកដែលមានសិទ្ធិ គឺមានតែសន្តតិជនលំដាប់ទី១ ទី២ (កំណត់ត្រឹមបុព្វញាតិផ្ទាល់ថ្នាក់ទី២) និងសហព័ទ្ធប៉ុណ្ណោះ (សន្តតិជនជានិច្ច)។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មិនមានន័យថា ជនទាំងនោះ ទទួលបានសិទ្ធិលើភាគបម្រុងគ្រប់គ្នានោះដែរ ពោលគឺអ្នកមានសិទ្ធិលើភាគបម្រុងត្រូវអនុវត្តតាមលំដាប់សន្តតិជនដូចខាងក្រោម ៖

- សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច។
- បើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុងហើយនោះ សន្តតិជនលំដាប់ទី២ ពុំមានសិទ្ធិទទួលឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងនោះទៀតឡើយ។

## កថាខណ្ឌទី៣៖ លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិ និងចំណែកមត៌ករបស់អ្នកមានសិទ្ធិនោះ

### ក. លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង

យើងដឹងហើយថាសន្តតិជនមានច្រើនប្រភេទ ដូចជាបច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ មានតែសន្តតិជនមួយចំនួន ដូចខាងក្រោមទេ ទើបត្រូវចាត់ទុកជាអ្នកដែលមានសិទ្ធិលើភាគបម្រុង៖

- បច្ឆាញាតិរបស់មតកជន
- ឪពុកម្ដាយរបស់មតកជន
- ជីដូនជីតារបស់មតកជន
- សហព័ទ្ធរបស់មតកជន។

លក្ខណៈក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង ពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែយើងអាចធ្វើការកត់សម្គាល់ អំពីលក្ខណៈសម្បត្តិ ដើម្បីក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌពីរយ៉ាងគឺ ទី១ អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែជាសន្តតិជនដែលកំណត់ដោយច្បាប់ ហើយលក្ខណៈក្លាយជាសន្តតិជននេះ ក៏មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។ បន្ថែមពីលើនេះទៅទៀត ជាសន្តតិជនតែមួយមុខ

មិនអាចគ្រប់គ្រាន់នៅឡើយទេ វាទាមទារឱ្យមាននូវការបំពានចំណែកមត៌កមួយទៀត ដែលជាធាតុផ្សំដែលមិនអាចខ្វះបាន។

➢ **បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន**

សន្តតិជនដែលអាចទទួលមត៌កបានលុះតែបុគ្គលនោះ ជាសន្តតិជនដែលមានជីវិតនៅរស់នៅពេលចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ។ ប្រសិនបើជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ បានទទួលមរណភាពមុនពេល ឬ តំណាលគ្នានឹងមតកជននោះ សន្តតិជនមិនអាចបំពេញលក្ខខណ្ឌមានជីវិតរស់នៅពេលចាប់ផ្តើមសន្តិកម្មទេ ដូច្នេះ មិនអាចទទួលបានសន្តតិកម្មឡើយ។ លើសពីនេះសន្តតិជនត្រូវតែមិនមែនជាអភ័ព្វបុគ្គល ហើយត្រូវផ្តាច់ចេញពីមត៌ក[21]។

➢ **មានការបំពានលើចំណែកមត៌ក**

ការបំពានលើចំណែកមត៌ករបស់សន្តតិជន គឺជាធាតុផ្សំមួយដ៏សំខាន់ ដែលមិនអាចខ្វះបានប្រសិនបើមិនមានការបំពានលើចំណែកមត៌កទេនោះ សន្តតិជនមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ។

**ឧទាហរណ៍** មតកជនមាន កូន២នាក់ និងសហព័ទ្ធដោយមតកជនបានបន្សល់ទុកនូវទ្រព្យចំនួន ១០០០០ដុល្លារ។ នៅក្នុងមតកសាសន៍បានកំណត់បែងចែកទ្រព្យសម្បត្តិ ៣០០០ដុល្លារ ឱ្យទៅសហព័ទ្ធ ហើយកូនម្នាក់ៗបាន ៣០០០ដុល្លារដែរ ចំណែក ១០០០ ដុល្លារដែលនៅសល់ត្រូវឱ្យទៅបងរបស់មតកជន។

### ខ. ចំណែកនៃភាគបម្រុង

ការកំណត់ចំណែកមត៌ករបស់អ្នកមានសិទ្ធិលើភាគបម្រុង គឺជាអ្វីដែលមិនអាចខ្វះបានព្រោះច្បាប់បានអនុញ្ញាតឱ្យអ្នកមានសិទ្ធិលើភាគបម្រុង មានសិទ្ធិទាមទារនូវចំណែកមត៌ករបស់ខ្លួន តែមិនមែនទាមទារបានដោយសេរីនោះទេ ហេតុនេះហើយច្បាប់បានកំណត់ អំពីគោលការណ៍នៃចំណែកមត៌ក។

នៅក្នុងការបែងចែកចំណែកនៃភាគបម្រុងនេះ វាពុំមានលក្ខណៈស្មើគ្នានោះទេ គឺវាអាស្រ័យទៅតាមលំដាប់ និងចំនួនសន្តតិជនប៉ុណ្ណោះ។ ខាងក្រោមនេះគឺជាចំណែកដែលសន្តតិជនម្នាក់ ទទួលបានយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា៖

- **ករណីដែលមតកជនមានតែឪពុកម្តាយ ឬ ជីដូនជីតាជាសន្តតិជន**

ក្នុងករណីដែលមតកជនមានតែឪពុកម្តាយ ឬ ជីដូនជីតាជាសន្តតិជននោះភាគបម្រុងត្រូវស្មើភាគនឹង ១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន[22]។

ឧទាហរណ៍៖ មតកជន មានទ្រព្យសម្បត្តិចំនួន ៦០០០ ដុល្លារ នោះភាគបម្រុងស្មើនឹង២០០០ដុល្លារ។

[21] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥០ និងមាត្រា ១១៥១។
[22] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ ចំណុច ក។

នៅក្នុងសន្តតិកម្មតាមច្បាប់បុព្វញាតិជាសន្តតិជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ទី ២ ប៉ុន្តែមានតែបុព្វ-ញាតិដែលជាឪពុកម្តាយ ឬ ជាជីដូនជីតាទេដែលជាមានសិទ្ធិលើភាគបម្រុង។ មានន័យថាប្រសិនបើមតកជនគ្មានប្រពន្ធ គ្មានកូន គ្មានឪពុកម្តាយ គ្មានជីដូនជីតា មានតែយាយតួត តាតួត នោះយាយតួត តាតួត គឺជាសន្តតិជន ប៉ុន្តែយាយទួត តាទួតនោះមិនមានសិទ្ធិភាគបម្រុងឡើយ។

- **ករណីមានសន្តតិជនច្រើននាក់**[23]

១/២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីផ្សេងៗ។ ក្នុងករណីដែលសន្តតិជនដែលមានសិទ្ធិម្នាក់ៗ អាចទទួលបានចំណែកលើភាគបម្រុងតាមសមាមាត្រចំណែកមត៌កដែលខ្លួនទទួលបានតាមច្បាប់។

យើងឃើញថា ច្បាប់បានកំណត់យកចំណែក១/៣ (មួយភាគបី) ជាភាគបម្រុងសម្រាប់ ឪពុក ម្តាយ ឬជាជីដូនជីតា ជីតា ប៉ុន្តែសូមពិនិត្យមើលឃ្លា "ក្នុងករណីមានតែសន្តតិជនជាឪពុក ម្តាយ ឬជីដូនជីតា"។ ចំណែក ១/២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់ មតកជនក្នុងករណីផ្សេងៗ។ មានន័យថាក្នុងករណីដែលគ្មានសន្តតិជនជាសហព័ទ្ធ ហើយមានតែឪពុក ម្តាយ ឬមានតែជីដូនជីតា នោះចំណែកភាគបម្រុងត្រូវផ្តល់ឱ្យ ១/៣ (មួយភាគបី) តែបើមានសន្តតិជនផ្សេងទៀតដូចជា កូន ឬសហព័ទ្ធនោះភាគបម្រុងនៃភាគបម្រុងត្រូវគិត ១/២ (មួយភាគពីរ)។

[23] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ ចំណុច ខ។

# ជំពូកទី២
# វិធីសាស្ត្រ
# ក្នុងការគណនាភាគបម្រុង

## ជំពូកទី២៖ វិធីសាស្ត្រក្នុងការគណនាភាគបម្រុង

បន្ទាប់ពីបានសិក្សាអំពីអ្នកមានសិទ្ធិលើភាគបម្រុង និងចំណែកមត៌ករួចមក នៅពេលនេះយើងនឹងបង្ហាញ អំពីការគណនារកនៅចំនួនទឹកប្រាក់ពិតប្រាកដ ដែលមតកជនបានបំពានលើចំណែកមត៌ករបស់សន្តតិជនដោយធ្វើការគណនាភាគបម្រុងដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងអាចទាមទារបាន ថាតើអ្នកមានសិទ្ធិអាចទាមទារបាននូវចំណែកមត៌ករបស់ខ្លួនប៉ុន្មាននោះ ជាដំបូង មុននិងឈានដល់ការគណនាយើងចាំបាច់ត្រូវស្គាល់ជាមុនសិន ថាតើប្រភេទទ្រព្យណាខ្លះដែលច្បាប់តម្រូវថាជាមូលដ្ឋានក្នុងការគណនាភាគបម្រុង រួចទើបយើងធ្វើការការគណនាទៅតាមទ្រព្យដែលមានជាក់ស្តែងនោះ។

### ផ្នែកទី១៖ ទ្រព្យដែលជាមូលដ្ឋានក្នុងការយកមកគណនា

ទ្រព្យដែលមាននៅចាប់ផ្តើមគណនារួមមាន ទ្រព្យដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម (កថាខណ្ឌទី១) តម្លៃនៃផលប្រយោជន៍ពិសេស (កថាខណ្ឌទី២) តម្លៃនៃប្រទានកម្ម (កថាខណ្ឌទី៣) មិនតែប៉ុណ្ណោះកាតព្វកិច្ចក៍ត្រូវបានចាត់ទុកជាមូលដ្ឋានក្នុងការគណនាភាគបម្រុងដែរ (កថាខណ្ឌទី៤)។

#### កថាខណ្ឌទី១៖ ទ្រព្យដែលមានពេលចាប់ផ្តើមសន្តតិកម្ម

ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម គឺទ្រព្យសម្បត្តិជាក់ស្តែងដែលបន្សល់ទុកដោយមតកជនក្រោយទទួលមរណភាព។

**ឧទាហរណ៍**: ទ្រព្យសម្បត្តិរបស់លោក **(ក)** រួមមាន ដីឡូមួយកន្លែង តម្លៃ ៥០០០០ដុល្លារ ផ្ទះល្វែង២ល្វែង តម្លៃ ៣០០០០០ ដុល្លារ ឡានមួយគ្រឿង ១០០០០០ ដុល្លារ ម៉ូតូមួយគ្រឿង តម្លៃ ៥០០០ ដុល្លារ នៅក្នុងអំឡុងពេលដែលលោក **(ក)** បានធ្លាក់ខ្លួនឈឺ គាត់បានលក់ ដីឡូមួយកន្លែង ឡានមួយគ្រឿង ម៉ូតូមួយគ្រឿង ដើម្បីយកលុយទៅព្យាបាលជម្ងឺ ក្រោយទទួលមរណភាពលោក **(ក)** នៅសល់ផ្ទះល្វែងពីរល្វែង តម្លៃ ៣០០០០០ ដុល្លារ ដែលមូលដ្ឋានត្រូវយកមកគណនាភាគបម្រុង។

#### កថាខណ្ឌទី២៖ តម្លៃនៃផលប្រយោន៍ពិសេស[24]

តម្លៃនៃផលប្រយោន៍ពិសេស គឺជាទ្រព្យដែលបុគ្គលសន្តតិជនបានទទួលជាប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការផ្សេងៗទៀត ឬ ដើម្បីមូលធននៃជីភាពរស់នៅ ឬ បានទទួលជាអច្ច័យទានពីមតកជន។

**ឧទាហរណ៍**: ប្តីប្រពន្ធពីរនាក់គឺលោក **(ក)** និង អ្នកស្រី **(ខ)** បានទិញឡានមួយគ្រឿងដែលមានតម្លៃ ៨០០០០ ដុល្លារ អោយដល់កូនស្រីទី៣ជាចំណងដៃអាពាហ៍ពិពាហ៍ ឡានដែលមានតម្លៃ ៨០០០០ ដុល្លារ គឺជាតម្លៃនៃផលប្រយោជន៍ពិសេស ដែលត្រូវយកមកធ្វើជា មូលដ្ឋានក្នុងការគណនាភាគបម្រុង។

---

[24] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣។

**ចំណាំ** ៖ ប្រទានកម្មដែលធ្វើទៅអោយសន្តតិជនជាតម្លៃនៃផលប្រយោជន៍ពិសេស។

## កថាខណ្ឌទី៣៖ តម្លៃនៃប្រទានកម្ម[25]

ប្រទានកម្មគឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់អោយភាគីម្ខាងទៀត ឬទ្រព្យសម្បត្តិដោយមិនយកថ្លៃហើយភាគីម្ខាងទៀតព្រមទទួល។

ប្រទានកម្មដែលត្រូវយកមកគណនាភាគបម្រុង ត្រូវអនុលោមតាមមាត្រា ១២៣២ ក្រមរដ្ឋប្បវេណី គឺជាប្រទានកម្ម ដែលធ្វើឡើងក្នុងអំឡុងពេល១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម និងប្រទានកម្មដែលបណ្តាលអោយខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង៖

- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម ៖ បានជាត្រូវធ្វើបែបនេះព្រោះជាគោលការណ៍ប្រទានកម្ម ដែលបានធ្វើក្នុងអំឡុងពេល ១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្មជាកម្មវត្ថុក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ កាលដែលបានកម្រិតអំឡុងពេលតែ ១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្មនេះ ក៏ព្រោះតែកុំអោយមានការបំពានភាពមិនត្រឹមត្រូវផលប្រយោជន៍អច្ច័យលាភី និងដើម្បីអោយមានសុវត្ថិភាពក្នុងកិច្ចការជំនួញ។

  **ឧទាហរណ៍** ឪពុក បានទិញម៉ូតូមួយគ្រឿង តម្លៃ ២៥០០ ដុល្លារ ជាការលើកទឹកចិត្តកូនស្រីដែលប្រឡងបានចំណាត់ថ្នាក់ល្អ។ ម៉ូតូមួយគ្រឿង តម្លៃ ២៥០០ ដុល្លារ ជាប្រទានកម្ម។
- ប្រទានកម្មដែលបណ្តាលអោយខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង៖ ក្នុងករណីដែលភាគីទាំងសងខាងបានដឹងថាប្រទានកម្មនឹងបណ្តាលអោយខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងនោះមិនចាំបាច់មានកម្រិតនៅអំឡុងពេលឡើយ ពោលគឺក្នុងករណីទាំងអស់នេះ និងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយនូវប្រទានកម្ម។ ប៉ុន្តែបើប្រទានកម្មទាំងអស់នោះមិនមែនជាការបំពានទៅលើសិទ្ធិលើភាគបម្រុងនោះទេ សន្តតិជននិងមិនអាចធ្វើការទាមទារបានឡើយ។ ដើម្បីអោយដឹងថាមានការបំពាន ឬគ្មានការបំពានទៅលើភាគបម្រុងនោះ គឺទាមទារអោយយើងធ្វើការប្រៀបធៀបទៅលើទ្រព្យសម្បត្តិសរុប ដែលមតកជនមាន នៅពេលធ្វើប្រទានកម្ម និងតម្លៃទ្រព្យដែលបានធ្វើប្រទានកម្ម។

**ឧទាហរណ៍១**: មតកជនមានប្រាក់ចំនួន ១០,០០០ ដុល្លារ ដោយនៅមុនពេលមតកជនទទួលមរណភាព ២ ខែ មតកជនបានធ្វើប្រទានកម្មដល់កូន (ក) ចំនួន ៣,០០០ដុល្លារ ដើម្បីបង្កើនមុខរបររកស៊ី ដូច្នេះ នេះមិនមែនជាការបំពានភាគបម្រុងទេ បើទោះបីក្រោយមក ប្រាក់របស់មតកជន បានថយចុះនៅត្រឹម ២,០០០ ដុល្លារ ក៏ដោយ។

[25] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣២ ចំណុចខ។

**ឧទាហរណ៍២**: មតកជនមានប្រាក់ចំនួន ១០,០០០ ដុល្លារ ដោយនៅមុនពេលមតកជនទទួលមរណភាព ២ ខែ មតកជនបានធ្វើប្រទានកម្មដល់កូន **(ក)** ចំនួន ៧,០០០ ដុល្លារ ដើម្បីបង្កើនមុខរបររកស៊ី ដូច្នេះនេះជាការបំពានភាគបម្រុង។

### កថាខណ្ឌទី៤៖ ចំនួនទឹកប្រាក់នៃភាគព្វកិច្ច

ចំនួនទឹកប្រាក់នៃកាតព្វកិច្ច គឺជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ ដោយអោយបុគ្គលម្នាក់ដែលបានកំណត់ហៅថាកូនបំណុលមានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្ខាងទៀត ដែលបានកំណត់ហៅថាម្ចាស់បំណុល។ កាតព្វកិច្ចក្នុងករណីនេះជាកាតព្វកិច្ចដែលមតកជនត្រូវទទួកខុសត្រូវនៅពេលគាត់ស្លាប់ រួមទាំងចំណាយ សម្រាប់បុណ្យសព។

**ឧទាហរណ៍**: លោក **(ក)** ជាម្ចាស់រោងចក្រដេរខោ អាវ មួយកន្លែងដើម្បីពង្រីករោងចក្រគាត់ លោក **(ក)** បានខ្ចីប្រាក់ពីលោក **(ខ)** ៣០០,០០០ ដុល្លារ ដោយដាក់នៅផ្ទះរបស់គាត់មួយកន្លែងនៅភ្នំពេញ ដើម្បីជាការធានាបំណុល។ ប្រាក់ ៣០០,០០០ ដុល្លារ ជាកាតព្វកិច្ចដែលជាមូលដ្ឋានដែលត្រូវយកមកគណនាភាគបម្រុង។

## ផ្នែកទី២៖ ការគណនាភាគបម្រុង

តើភាគបម្រុងត្រូវបានគេគណនាយ៉ាងដូចម្តេច?

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីទ្រព្យដែលត្រូវយកជាមូលដ្ឋានក្នុងការគណនាភាគបម្រុងហើយនោះយើងនឹងធ្វើការបង្ហាញ អំពីវិធីក្នុងការគណនាវិញម្តង តើត្រូវគណនាតាមរូបមន្តណាដែរ?

គួរកត់សម្គាល់ដែរថា វិធីគណនាខាងលើដើម្បីរកទឹកប្រាក់ដែលមានសិទ្ធិលើភាគបម្រុងអាចទាមទារបាននោះ នឹងមានការប្រែប្រួលដោយសារមូលហេតុ ឬស្ថានភាពមួយចំនួន នាំឱ្យទឹកប្រាក់ដែលទាមទារបានពីរការគណនានោះ ត្រូវបានពីរការកាត់បន្ថយ ហេតុនេះហើយយើងចាត់ទុកថា ជាចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

### កថាខណ្ឌទី១៖ រូបមន្តក្នុងការគណនា

រូបមន្តក្នុងការគណនាភាគបម្រុង៖

ក្នុងការគណនារកភាគបម្រុងយើងត្រូវរកទ្រព្យសម្បត្តិ ដែលជាមូលដ្ឋានក្នុងការគណនារកភាគបម្រុងជាមុនសិន[26] គឺត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស និងបូកជាមួយនឹងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ហើយដកចំនួនប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវទទួលបន្តដោយសន្តតិកម្ម។

[26] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៣១។

ដូចនេះ អាចទាញរូបមន្តដូចខាងក្រោម ៖

| |
|---|
| ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = មតិកនាពេលចាប់ផ្តើមសន្តតិកម្ម + តម្លៃនៃផលប្រយោជន៍ពិសេស + ប្រទានកម្ម - កាតព្វកិច្ច |

បន្ទាប់មកយើងត្រូវយកទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងនេះ ទៅចែកនឹងចំណែកនៃភាគបម្រុងដែលច្បាប់បានកំណត់ រួចចែកនឹងចំនួនសន្តតិជន។

$$\text{ភាគបម្រុងស្មើ} \quad \frac{\dfrac{\text{ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង}}{\text{ចំណែកនៃភាគបម្រុង}}}{\text{ចំនួនសន្តតិជន}}$$

**ឧទាហរណ៍**: មតកជនមានកូនបីនាក់ គឺ **(ក)** **(ខ)** និង **(គ)** ដោយមតកជនបានបន្សល់ទុកទ្រព្យសម្បត្តិចំនួន ៤000 ដុល្លារ ដោយប្រគល់ទៅឲ្យ **(ខ)** ទាំងអស់។ ហើយនៅពេលដែលមតកជននៅរស់បានធ្វើប្រទានកម្ម **(ក)** ចំនួន ២000 ដុល្លារ (ផលប្រយោជន៍ពិសេស) និងបានធ្វើប្រទានកម្មទៅអោយមិត្តភក្តិរបស់គាត់ ៣000 ដុល្លារ។ តើភាគបម្រុងរបស់សន្តតិជនម្នាក់ៗមានចំនួនប៉ុន្មាន?

**ដំណោះស្រាយ**

រកទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

- ដោយទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្តើមសន្តតិកម្មគឺ ៤000 ដុល្លារ
- ផលប្រយោជន៍ពិសេសគឺ ២000 ដុល្លារ
- ប្រទានកម្មគឺ ៣000 ដុល្លារ
- កាតព្វកិច្ចគឺ 0

តាមរូបមន្ត នាំឲ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = (៤000 + ២000+ ៣000) - 0 = ៩000 ដុល្លារ

រកភាគបម្រុងរបស់សន្តតិជនម្នាក់ៗ

តាមរូមន្ត

ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងនេះ ៖ ចំណែកនៃភាគបម្រុងដែលច្បាប់បានកំណត់ ៖ ចំនួនសន្តតិជន

ដូចច្នេះនាំឲ្យ ភាគបម្រុងរបស់សន្តតិជនម្នាក់ៗ ស្មើនឹង

៩០០០ ៖ ២ = ៤៥០០ ជាចំណែកភាគចម្រុងសរុប

ដោយសន្តតិជនមាន៣នាក់ ដូច្នេះត្រូវចែកនិងចំនួនសន្តតិជនទៀត

៤៥០០ ៖ ៣ = ១៥០០ ដុល្លារ ។

ដូចច្នេះភាគបម្រុងរបស់សន្តតិជនម្នាក់ៗគឺ ១៥០០ ដុល្លារ

បើយើងធ្វើការសិក្សាទៅលើឧទាហរណ៍ខាងលើ គឺមានតែសន្តតិជន (ខ) និង (គ) ដែលត្រូវបានបំពានភាគបម្រុង ។ ហើយចំនួនទឹកប្រាក់នេះ គឺ (ខ) និង (គ) បានម្នាក់គឺ ១៥០០ ដែលជាការទាមទារនេះអាធ្វើការទាមទារបានទាំងអស់។

## កថាខណ្ឌទី២៖ ការកាត់នៃភាគបម្រុង

### ក. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ដោយសារតែមានមូលហេតុមួយចំនួនទើបធ្វើឱ្យអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង។ ក្នុងករណីដែលអច្ច័យទានរបស់សន្តតិជន ការកំណត់ចំណែកមត៌ក និងការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនេះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនប៉ុណ្ណោះ ។ មានន័យថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងប្រសិនបើសន្តតិជនដែលត្រូវបានគេទាមទារឱ្យកាត់បន្ថយនោះ ត្រូវបានគេបំពានភាគបម្រុងរបស់ខ្លួនវិញ ដោយសារតែការកាត់បន្ថយនោះ សន្តតិជននោះអាចបដិសេធនូវការទាមទារនោះបាន[27]។

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុងរួមមាន៖

- អច្ច័យទាន
- ចំណែកមត៌កតាមមតកសាសន៍
- ផលប្រយោជន៍ពិសេស និង
- ប្រទានកម្ម (ប្រទានកម្មធ្វើក្នុងអំឡុងពេល ០១ ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម និង ប្រទានកម្មដោយដឹងថានឹងបណ្តាលអោយបំពានដល់សិទ្ធិរបស់អ្នកដែលមានសិទ្ធិលើភាគបម្រុង)។

[27] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣១ ។

## ខ. ចំនួនទឹកប្រាក់នៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ដោយហេតុថា មុនពេលដែល អ្នកមានសិទ្ធិលើភាគបម្រុង ទាមទារចំណែកមត៌កដែលជាភាគបម្រុងនោះ បុគ្គលនោះអាចរងនូវស្ថានភាពអ្វីមួយដែលជាមូលហេតុនាំឱ្យកាត់បន្ថយចំណែកទាមទារ។ អ្នកមានសិទ្ធិលើភាគបម្រុងត្រូវការតែមួយភាគទៀតប៉ុណ្ណោះដើម្បីបង្គ្រប់ភាគបម្រុងដែលនៅសល់ ដូចនេះ តើចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង ត្រូវគណនាដោយយោងទៅលើរូបមន្តអ្វី? (១) ហើយមានមូលហេតុអ្វីខ្លះដែលនាំឱ្យគណនារកចំនួនទឹកប្រាក់បង្គ្រប់ភាគបម្រុង? (២)

១.រូបមន្ត

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និងចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម[28]។

**យើងទាញបានរូបមន្តដូចខាងក្រោម ៖**

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងស្មើ ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម |

២.មូលហេតុដែលនាំឲ្យមានការគណនារកចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង

មានកត្តាជាជំរុញច្រើន ដែលធ្វើឱ្យចំនួនទឹកប្រាក់នៃភាគបម្រុងត្រូវបានកាត់បន្ថយ ដោយសារក្នុងនោះអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលប្រយោជន៍ពិសេស (១) ឬមួយក៏អ្នកមានសិទ្ធិលើភាគបម្រុង អាចទទួលបានទ្រព្យសម្បត្តិដោយសន្តតិកម្ម (២) ប៉ុន្តែតាមរយៈការទទួលនូវទ្រព្យសម្បត្តិតាមស្ថានភាពទាំងនោះ នូវតែអាចមាននូវការបំពាននូវចំណែកមត៌ក ហេតុនេះហើយទើបអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានចំណែកដែលនៅសល់ ក្រោយពីការដកនូវទ្រព្យទាំងអស់នោះចេញ។ ផ្ទុយទៅវិញ ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងអាចនឹងមានការកើនឡើងទៅវិញ ដោយសារតែមតកជនបានបន្សល់ទុកនូវកាតព្វកិច្ច ដែលជាហេតុនាំឱ្យចំនួនទឹកប្រាក់ភាគបម្រុងត្រូវបូកបន្ថែមនូវកាតព្វកិច្ចនេះ (៣)។

[28] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៥។

## គ.ផលប្រយោជន៍នៃអ្នកមានសិទ្ធិលើភាគបម្រុង

ក្នុងករណីខ្លះ ដោយសារអ្នកមានសិទ្ធិលើភាគបម្រុង បានទទួលផលប្រយោជន៍ពិសេសហេតុនេះហើយ ការគណនារកភាគបម្រុងតែម៉្យាងគឺមិនគ្រប់គ្រាន់ទេ។ វាទាមទារអោយមានការគណនារកទឹកប្រាក់បង្គ្រប់បន្ថែមទៀត ពីព្រោះផលប្រយោជន៍ពិសេសនេះ ត្រូវយកមកធ្វើជាមូលដ្ឋានក្នុងការគណនាភាគបម្រុងផងដែរ។

គួរសម្គាល់ថា ផលប្រយោជន៍ពិសេសនេះ ត្រូវតែជារបស់អ្នកមានសិទ្ធិលើភាគបម្រុង ពីព្រោះអ្នកមានសិទ្ធិលើភាគបម្រុងជាអ្នកធ្វើការទាមទារ។

ប្រសិនបើ វាជាផលប្រយោជន៍ពិសេសរបស់សន្តតិជនធម្មតា ដែលគ្មានសិទ្ធិលើភាគបម្រុងទេនោះ មិនចាំបាច់គណនារកទឹកប្រាក់បង្គ្រប់បន្ថែមទេ។ ចុះហេតុអ្វី បានជាអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលផលប្រយោជន៍ពិសេស ហើយនៅតែមានការបំពានលើចំណែកមត៌ក? ទាក់ទងនឹងករណីនេះ អាចដោយសារផលប្រយោជន៍ពិសេសទទួលបានមានចំនួនតិចតួចពេក ដែលជាហេតុនាំឱ្យទ្រព្យសម្បត្តិ ដែលទទួលបាននៅតែមិនអាចមានចំនួនសមាមាត្រទៅនឹងភាគបម្រុង។

**ឧទាហរណ៍:** សន្តតិជនមាន ២ នាក់ គឺ **(ក)** និង **(ខ)** ដែលជាកូនរបស់មតកជន។ កាលមតកជននៅរស់បានធ្វើប្រទានកម្ម (ផលប្រយោជន៍ពិសស) ទៅឱ្យ **(ខ)** ចំនួន ១០០០ ដុល្លារ។ ចំណែកទ្រព្យសម្បត្តិ ពេលចាប់ផ្តើមសន្តតិកម្មមាន ១០០០០ ដុល្លារ។ ហើយមតកជនបានធ្វើមតកសាសន៍ដោយផ្ទេរទ្រព្យសម្បត្តិទាំងអស់ទៅអោយកូន **(ក)**។ ដែលជាហេតុធ្វើឱ្យ **(ខ)** មិនបានទទួលនូវទ្រព្យសម្បត្តិអ្វីសោះ ទើប **(ខ)** ដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈ ទាមទារចំនួនទឹកប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី **(ក)**។

ដំណោះស្រាយ តាមរូបមន្តខាងក្រោម៖

| |
|---|
| ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា ភាគបម្រុងស្មើ ទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូកនឹងផលប្រយោជន៍ពិសេស បូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឱ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = (១០០០០ + ១០០០ + 0) - 0= ១១០០០ ដុល្លារ

- ដោយភាគបម្រុងស្មើ១/២ (១ ភាគ ២) នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះភាគបម្រុងដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង × ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុង = ១១០០០ × ១ភាគ២= ៥៥០០ ដុល្លារ

- ដោយសន្តតិជនមានគ្នា២នាក់ទើបភាគបម្រុងត្រូវធ្វើការបែងចែកជា ២ ទៀតគឺទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់មនុស្សម្នាក់ៗគឺ = ៥៥០០ ÷ ២ = ២៨៥០ ដុល្លារ

ក្នុងករណីនេះ (ខ) មានសិទ្ធិលើភាគបម្រុងចំនួន ២៧៥០ ដុល្លារ ដែលចំនួននេះ (ខ) មិនអាចទាមទារបានទាំងអស់តែម្តងពី (ក) បានទេ ពីព្រោះ (ខ) បានទទួលផលប្រយោជន៍ពិសេស។ ហេតុនេះហើយចាំបាច់គណនារកទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងទៀត

តាមរូបមន្ត

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងស្មើ ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម |

- ដោយចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា = ២៧៥០ ដុល្លារ
- **ខ** ជាអ្នកមានសិទ្ធិលើភាគបម្រុងហើយបានទទួលផលប្រយោជន៍ពិសេស = ១០០០ ដុល្លារ ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង = (២៧៥ - 0 - ១០០០) + 0 = ១៧៥០ ដុល្លារ

ដូចនេះ **ខ** អាចទាមទារចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង = ១៧៥០ ដុល្លារពី **ក**។

១. ទ្រព្យសម្បត្តិរបស់អ្នកមានសិទ្ធិលើភាគបម្រុង បានទទួលដោយសន្តតិកម្ម

ចំពោះករណីនេះវិញ វាមិនខុសគ្នាប៉ុន្មានទៅនឹងផលប្រយោជន៍ដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលនោះទេ។ បើទោះបីជាសន្តតិជន ដែលមានសិទ្ធិលើភាគបម្រុងបានទទួលទ្រព្យសម្បត្តិដោយសន្តតិកម្ម (ទាំងតាមច្បាប់ និងតាមមតកសាសន៍) ក៏ដោយក៏នៅពេលខ្លះការទទួលបាននូវចំណែកមត៌ករបស់ខ្លួននោះ គឺវានៅតែមានការបំពាន។ ប៉ុន្តែដោយសារតែសន្តតិជននោះបានទទួលទ្រព្យសម្បត្តិមួយភាគដែរ ហេតុនេះហើយទើបយើងត្រូវធ្វើការគណនារកចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងដែលនៅសេសសល់។

**ឧទាហរណ៍** មតកជនមានប្រពន្ធ (ក) និងកូន ២នាក់ គឺ (ខ) និង (គ) ដោយបន្សល់ទុកនូវទ្រព្យសម្បត្តិ ចំនួន ៦០០០ ដុល្លារ។ មុនពេលទទួលមរណភាព មតកជនបានធ្វើមតកសាសន៍ដោយ ធ្វើការបែងចែកទ្រព្យសម្បត្តិដូចខាងក្រោម ៖

- ឲ្យប្រពន្ធ (ក) ចំនួន ៥០០០ ដុល្លារ
- ឲ្យកូន (ខ) និង (គ) ក្នុងម្នាក់ៗ ចំនួន ៥០០ ដុល្លារ។

កូន (ខ) និង (គ) បានធ្វើការទាមទារនូវទឹកប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី (ក)។

ដំណោះស្រាយ

| |
|---|
| ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងស្មើទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូកនឹងផលប្រយោជន៍ពិសេសបូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឱ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង =(៦000 + 0 + 0) - 0 = ៦000 ដុល្លារ

- ដោយភាគបម្រុងស្មើ ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះ ភាគបម្រុង = ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង × ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុង = ៦000 × ១/២ = ៣000 ដុល្លារ

- ដោយសន្តតិជនមានគ្នាបីនាក់ ទើបភាគបម្រុងត្រូវធ្វើការចែកជា ៣ ទៀតគឺទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់មនុស្សម្នាក់ៗ គឺ = ភាគបម្រុង ÷ ចំនួនសន្តតិជននាំឱ្យ

  ៣000 ÷ ៣ = ១000 ដុល្លារ

ជាក់ស្តែង កូន **(ខ)** និង **(គ)** បានទទួលចំណែកមត៌កក្នុងម្នាក់ៗ តែ ៥00 ដុល្លារ ប៉ុណ្ណោះមានន័យថា **(ក)** បានបំពានចំណែកលើភាគបម្រុងរបស់ពួកគេ។ ក៏ប៉ុន្តែទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់ម្នាក់ៗ ដែលបានគណនាឃើញនោះ ចំនួន ១000 ដុល្លារ គឺមិនអាចទាមទារបានទាំងស្រុងទេ ដោយសារតែ **(ខ)** និង **(គ)** បានទទួលចំណែកទ្រព្យសម្បត្តិ ដោយសន្តតិកម្មដែរទើបពួកគេអាចទាមទារត្រឹមតែទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងដោយគណនាដូចខាងក្រោម ៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងស្មើ ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម |

- ដោយចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវគណនា = ១000 ដុល្លារ
- ទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបាន ទទួលដោយសន្តតិកម្ម **(ខ)** = **(គ)** = ៥00 ដុល្លារ

  ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងរបស់ **(ខ)** = (១000 - ៥00 -0) + 0 = ៥00 ដុល្លារ

  ដូចនេះ **(ខ)** និង **(គ)** អាចទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងចំនួនក្នុងម្នាក់ៗ ៥00 ដុល្លារ ពី **(ក)**។

២. កាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុង ត្រូវទទួលបន្ទុកដោយសន្តតិកម្ម

ពាក់ព័ន្ធទៅនឹងកាតព្វកិច្ច ដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម នាំឱ្យទឹកប្រាក់នៃភាគបម្រុងមានការកើនឡើង នៅពេលដែលធ្វើការគណនារកប្រាក់បង្គ្រប់ ព្រោះដោយសារតែទឹកប្រាក់បង្គ្រប់នេះ ត្រូវបូកបន្ថែមជាមួយកាតព្វកិច្ច ដែលសន្តតិជនត្រូវទទួលបន្ទុក។ ជាក់ស្តែងសន្តតិជន មិនមែនទទួលតែទ្រព្យសកម្មតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវទទួលបន្ទុកសងបំណុលរបស់មតកជនផងដែរ។

**ឧទាហរណ៍**: មតកជនមានកូន ២ នាក់ គឺ លោក **សុខ** និង **សៅ** ដោយទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម មានចំនួន ៨០០០ ដុល្លារ និងកាតព្វកិច្ចចំនួន ៤០០០ ដុល្លារ។ (មតកជនមិន បានបន្សល់ទុកមតក-សាសន៍ទេ) ប៉ុន្តែមុនពេលចាប់ផ្តើមសន្តតិកម្មលោក **សុខ** បានទទួល ប្រទានកម្ម ចំនួន ១៥០០០ ដុល្លារ (ផលប្រយោជន៍ពិសេស)។ លោក **សៅ** បានធ្វើការទាមទារនូវប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី លោក **សុខ**។

**ដំណោះស្រាយ**

រកទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង៖

| |
|---|
| ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ស្មើទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូក ផលប្រយោជន៍ពិសេស បូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឱ្យ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = ( ៨០០០ + ១៥០០០ + 0) - ៤០០០ = ១៩០០០ ដុល្លារ

- ដោយភាគបម្រុងស្មើ ១ ភាគ ២នៃទ្រព្យសម្បត្តិមតកជន

ដូចនេះភាគបម្រុង = ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ÷ ១ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុងស្មើ = ១៩០០០ ÷ ១ភាគ ២ = ៩៥០០ ដុល្លារ

- ដោយសន្តតិជនមានគ្នា ២ នាក់ ទើបភាគបម្រុងត្រូវធ្វើការបែងចែកជា ២ ទៀត គឺទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់ម្នាក់ៗ = ៩៥០០ ÷ ២ = ៤៧៥០ ដុល្លារ

ក្នុងករណីនេះ **សៅ** មានសិទ្ធិលើភាគបម្រុងចំនួន ៤៧៥០ ដុល្លារ ដែលចំនួននេះ **សៅ** មិនអាចទាមទារបានទាំងអស់ពី **សៅ** បានទេ ពីព្រោះ **សុខ** បានទទួលចំណែកទ្រព្យសម្បត្តិដោយសន្តតិកម្មហើយមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចទៀតផង។ ហេតុនេះហើយ ចាំបាច់គណនារកទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងទៀត ៖

ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងស្មើ ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម

- ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា = ៤៧៥០ ដុល្លារ
- ទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដោយសារតែមតកជនមិនបានបន្សល់ទុកមតកសាសន៍ទេ ហេតុនេះហើយ ទ្រព្យសម្បត្តិត្រូវបែងចែកតាមសន្តតិកម្មតាមច្បាប់ នាំឱ្យសន្តតិជនម្នាក់ៗ ទទួលបានចំណែកស្មើៗគ្នា

  = ៨០០០ ÷ ២ = ៤០០០ ដុល្លារ
- ផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង
- កាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម = ៤០០០ ÷ ២ = ២០០០ ដុល្លារ

  នាំឱ្យ ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងរបស់ **សៅ** = ៤៧៥០ - ៤០០០ - ០ + ២០០០ = ២៧៥០ ដុល្លារ។

  ដូចនេះ **សៅ** អាចធ្វើការទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួនពី **សុខ** ចំនួន ២៧៥០ ដុល្លារ ដោយចំនួននេះត្រូវបានទូទាត់កាតព្វកិច្ចរួចរាល់ហើយ។

# ជំពូកទី៣

# នីតិវិធីនៃការកាត់បន្ថយ
# និងការរំលត់សិទ្ធិតាមការ
# ឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

# ជំពូកទី៣
# នីតិវិធីនៃការកាត់បន្ថយ
# និងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

## ផ្នែកទី១៖ នីតិវិធីនៃការកាត់បន្ថយ

### កថាខណ្ឌទី១៖ ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះ អាចទាមទារឱ្យការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង បាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ[29]។ ជនដែលត្រូវបានបំពានភាគបម្រុង អាចយកសិទ្ធិ ដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារឱ្យកាត់បន្ថយអច្ច័យទានជា អាទិ៍ ហើយអ្នកមានសិទ្ធិលើភាគបម្រុង ឬប្រតិសិទ្ធិរបស់ខ្លួនមានសេរីភាពក្នុងការទាមទារ ឬមិនទាមទារ និង ប្រសិនបើមិនទាមទារ នាំឱ្យមតកសាសន៍មានសុពលភាពពេញលេញ ហើយជាគោលការណ៍ ការទាមទារឱ្យ កាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្តហេតុនេះ បើមិនទាមទារ នាំឱ្យបាត់បង់ អានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានសិទ្ធិលើភាគបម្រុង រីឯសិទ្ធិដែលអច្ច័យលាភីជាអាទិ៍ បានធ្វើ លទ្ធកម្ម ក៏ត្រូវស្ទុងពីមតកជន ទៅអ្នកដែលមានសិទ្ធិលើភាគបម្រុង ទៅតាមកម្រិតនៃភាគបម្រុង (ការទាមទារ)។ ម៉្យាងវិញទៀត ការទាមទារអោយកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ មិនចាំបាច់ធ្វើសកម្មភាពបណ្តឹងឡើយ ដោយតម្រូវអោយបង្ហាញឆន្ទៈ ជាការគ្រប់គ្រង ប៉ុន្តែបើភាគីម្ខាងទៀតមិនយល់ព្រមត្រូវដកពាក្យបណ្តឹង ហើយ ចំពោះការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងក្នុងកំឡុងពេលអាជ្ញាយុកាល (១ឆ្នាំ គិតចាប់ពីថ្ងៃដែលខ្លួនដឹងពីការចាប់ ផ្តើមសន្តតិកម្ម ឬ ០៥ឆ្នាំ គិតចាប់ពីថ្ងៃដែលសន្តតិកម្មចាប់ផ្តើម) នាំឱ្យសិទ្ធិនេះ ត្រូវបានស្ទុងដោយជន ដែល មានសិទ្ធិលើភាគបម្រុង ចាប់ពីពេលដែលបានបង្ហាញឆន្ទៈនោះ ហេតុនេះទោះបីជាដាក់ពាក្យបណ្តឹងក្រោយ ក្រោយអំឡុងពេលនេះ ក៏មិនមានបញ្ហាអ្វីឡើយ។[30]

### កថាខណ្ឌទី២៖ លំដាប់នៃការកាត់បន្ថយ

គោលគំនិតនៃភាគបម្រុង គឺធានាទុកនូវមត៌កមួយភាគសម្រាប់ឱ្យជនដែលមានសិទ្ធិលើភាគបម្រុង ប៉ុន្តែធ្វើការកម្រិតនូវកម្មវត្ថុនៃការកាត់បន្ថយត្រឹមបន្ថយមត៌ក អាចទៅជាបំពានភាគបម្រុងទៅវិញ។ កម្មវត្ថុនៃ ទ្រព្យដែលត្រូវកាត់បន្ថយ និងលំដាប់នៃការកាត់បន្ថយរួមមាន អច្ច័យទាន ចំណែកមត៌ក ប្រទានកម្ម និងផល ប្រយោជន៍ពិសេស។ ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយបើមិនបាន

[29] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៥។
[30] មេធាវី អ៊ីវ ប៉ូលី, នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប) (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១), ៣៥។

កាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ[31]។ ជាគោលការណ៍ ប្រសិនបើមត៌កដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម មានគ្រប់គ្រាន់ក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នោះប្រទានកម្ម និងការចាត់ចែងពិសេសរស់មតកជនពេលនៅរស់ មិនចាំបាច់លើកមកពិចារណាទេ។ ក្នុងករណីដែលមានការកាត់បន្ថយមត៌កនាំឱ្យទៅជាការបំពានទៅលើភាគបម្រុង ដោយសារការធ្វើប្រទានកម្មពេលនៅរស់ នាំឱ្យប្រទានកម្ម គឺជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុងផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើមត៌កដែលមាននៅពេលចាប់ផ្តើមសន្តតិកម្មមានគ្រប់គ្រាន់ដើម្បីបង្គ្រប់ភាគបម្រុងនោះ មិនចាំបាច់ពិចារណាចំពោះសកម្មភាពរបស់មតកជនកាលនៅរស់ មកបង្គ្រប់ភាគបម្រុងឡើយ។

**ការកាត់បន្ថយអច្ច័យទាន និងការកំណត់ចំណែកមត៌កតាមមតកសាសន៍**

ការកាត់បន្ថយអច្ច័យទាន គឺជាចំណុចមួយដែលត្រូវលើកយកមកពិចារណា ក្នុងករណីដែលមានការបំពានលើភាគបម្រុង ហើយចំពោះទ្រព្យសម្បត្តិមុនដំបូងគេ ដែលត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺមាន អច្ច័យទាន និងចំណែកមត៌ករបស់សន្តតិជនដែលបានកំណត់នៅក្នុងមតកសាសន៍។ ក្នុងករណី ប្រសិនបើនៅតែមិនគ្រប់ចំនួនដែលត្រូវធ្វើការកាត់បន្ថយ គឺត្រូវធ្វើការពិចារណាកាត់បន្ថយអច្ច័យទានដែលបានធ្វើចំពោះតតិយជន ដើម្បីបង្គ្រប់ចំនួនដែលត្រូវការនោះ។ ក្នុងការកាត់បន្ថយអច្ច័យទាន គឺត្រូវធ្វើទៅតាមសមាមាត្រនៃតម្លៃនៃកម្មវត្ថុនោះ។ ម្យ៉ាងវិញទៀត នេះជាគោលការណ៍ ដែលគោលបំណងដើម្បីធ្វើឱ្យមានភាពច្បាស់លាស់នៃនីតិវិធីកាត់បន្ថយអច្ច័យទាន ព្រមទាំងចំណែកមត៌កដែលបានកំណត់នៅក្នុងមតកសាសន៍ និងដើម្បីធ្វើចំណាត់ថ្នាក់ចំពោះអច្ច័យទានរបស់សន្តតិជន និងអច្ច័យទានរបស់តតិយជន។

**លំដាប់នៃការកាត់បន្ថយអច្ច័យទាន និងការកំណត់មត៌កតាមមតកសាសន៍មានពីរគឺ៖**

ទី១- ការកាត់បន្ថយអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន។

ទី២- ការកាត់បន្ថយអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះបុគ្គលដែលក្រៅពីសន្តតិជន។

ទី៣- ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍។

**ក. អច្ច័យទានចំពោះសន្តតិជន**[32]

សន្តតិជន គឺជាជនដែលត្រូវបានទទួលសន្តតិកម្មនូវឋានៈជាកូនបំណុលអច្ច័យទានពីមតកជន ដូច្នេះមុនដំបូងត្រូវធ្វើការសម្រួលផ្ទៃក្នុងចំពោះអច្ច័យទាន និងចំណែកមត៌កតាមមតកសាសន៍របស់សន្តតិជនជាមុនសិន ប្រសិនបើមានការបំពានភាគបម្រុងទៅលើសន្តតិជនណាមួយនោះ។

**ឧទាហរណ៍** សន្តតិជនមានចំនួន ២ នាក់គឺ **(ក)** និង **(ខ)** ដែលជាកូនរបស់មតកជនធ្វើការបែងចែកមត៌កទៅកូនៗនីមួយៗ ដូចខាងក្រោម ៖

[31] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៦។

[32] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧, កថាខណ្ឌទី១។

**(ក)** ទទួលបាន ១០០ ដុល្លារ

**(ខ)** ទទួលបាន ៥០០ ដុល្លារ

ហើយមតកជន បានបែងចែកទ្រព្យដែលជាមត៌កទៅឱ្យមិត្តិភក្តិ **(គ)** ចំនួន ២០០ ដុល្លារ។ ដោយទ្រព្យមាននៅពេលចាប់ផ្តើមសន្តតិកម្ម ៨០០ ដុល្លារ (១០០ + ៥០០ + ២០០) ចំណែកភាគបម្រុងដែលកំណត់ដោយច្បាប់ ១ភាគ២ នៃទ្រព្យរបស់មតកជន(៨០០÷ ២) ចំនួនសន្តតិជន២នាក់

ក្នុងករណីនេះភាគបម្រុងសរុបស្មើ $\frac{១០០ + ៥០០ + ២០០}{២}$ = ៤០០ដុល្លារ

សន្តតិជនម្នាក់ៗ = $\frac{៤០០}{២}$ = ២០០ ដុល្លារ

ដូចនេះ មានន័យថា **(ក)** ត្រូវបានបំពានភាគបម្រុងចំនួន ១០០ ដុល្លារ ដោយចំនួនទឹកប្រាក់នេះ **(ក)** អាចធ្វើការទាមទារពី **(ខ)** បានតែម្នាក់ប៉ុណ្ណោះ ដោយសារ **(ខ)** ជាសន្តតិជន រី ឯ **(គ)** វិញមិនមែនជាសន្តតិជនទេ ដូច្នេះ **(ក)** មិនមែនទាមទារពី **(គ)** បានទេ លុះត្រាតែការកាត់បន្ថយភាគបម្រុងពី **ខ** មិនទាន់គ្រប់ទៅនឹងចំនួនទ្រព្យសម្បត្តិដែលត្រូវធ្វើការទាមទារដើម្បីបង្គ្រប់ភាគបម្រុងនោះ។

### ខ.អច្ច័យទានចំពោះតតិយជន

ការកាត់បន្ថយពីអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន គឺត្រូវបានធ្វើឡើងក្នុងពេលតែមួយជាមួយគ្នា ហើយប្រសិនបើក្នុងករណីនៅតែមិនគ្រប់ ត្រូវធ្វើកាកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះតតិយជន[33]។

**ឧទាហរណ៍:** សន្តតិជនមាន ២ នាក់ **ក** និង **ខ** ដែលជាកូនរបស់មតកជន ដោយមតកជនធ្វើការបែងចែកមត៌កទៅអោយកូននីមួយៗដូចខាងក្រោម៖

**(ក)** ទទួលបាន១០០០ ដុល្លារ

**(ខ)** ទទួលបាន ២៥០០ ដុល្លារ

មតកជនបានបែងចែកទ្រព្យដែលជាមត៌កទៅឲ្យប្អូនរបស់ខ្លួន គឺ **(ឃ)** ចំនួន ៤៥០០ ដុល្លារ។ ក្នុងករណីនេះ ភាគបម្រុងសន្តតិជនម្នាក់ៗ គឺ

[33] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧, កថាខណ្ឌទី២

$$\text{ភាគបម្រុង} = \frac{\text{១០០០ ដុល្លារ} + \text{២៥០០ ដុល្លារ} + \text{៤៥០០ ដុល្លារ}}{\text{២}} = \text{៤០០០ ដុល្លារ}$$

$$\text{ភាគបម្រុងនៃសន្តតិជនម្នាក់} = \frac{\text{៤០០០}}{\text{២}} = \text{២០០០ ដុល្លារក្នុងម្នាក់}$$

ដូចនេះ មានន័យថា **(ក)** ត្រូវបានបំពានភាគបម្រុងរបស់ចំនួន ១០០០ ដុល្លារ ដោយ ចំនួនទឹកប្រាក់នេះ **(ក)** មិនអាចទាមទារពី **(ខ)** តែម្នាក់នោះទេ ទោះបីជាកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងចាប់ផ្ដើមពីអច្ច័យទានចំពោះសន្តតិជនជាមុនក៏ដោយ ព្រោះប្រសិនបើ **(ក)** ទាមទារពី **(ខ)** ១០០០ ដុល្លារ នោះ **(ខ)** នឹងត្រូវបានបំពានភាគបម្រុងលើខ្លួនវិញចំនួន ៥០០ ដុល្លារ ។ ដូចនេះ **(ក)** ត្រូវធ្វើការទាមទារឱ្យកាត់បន្ថយពីអច្ច័យទានដែលធ្វើចំពោះតតិយជនគឺ **(ឃ)** ចំនួន ៥០០ ដុល្លារ ទៀតដែលនៅសល់ ដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួន។

### គ. ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍[34]

ទោះបីជាច្បាប់បានបញ្ញត្តិអំពីលំដាប់នៃជន ដែលត្រូវបានទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយក៏ច្បាប់បានទទួលស្គាល់ផងដែរ ក្នុងករណីដែលម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈពិសេសផ្សេងក្នុងមតក-សាសន៍ មានន័យថា ច្បាប់បានទទួលនូវការកំណត់ជាមុនតាមមតកសាសន៍។

**ឧទាហរណ៍** សន្តតិជនមាន បីនាក់ គឺ (ក) (ខ) និង (គ) ដែលនៅក្នុងមតកសាសន៍បានបែងចែកទ្រព្យសម្បត្តិឱ្យសន្តតិជនដូចខាងក្រោម

**(ក)** ទទួលបាន ១២០០ ដុល្លារ

**(ខ)** ទទួលបាន ៦០០ ដុល្លារ

**(គ)** មិនទទួលបានអ្វីសោះ

នៅក្នុងមតកសាសន៍បានបន្ថែមទៀតថា ក្នុងករណីដែលមានការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ត្រូវធ្វើការកាត់បន្ថយពី **(ក)** ទាំងអស់ ។ **(គ)** ក៏បានបង្ហាញឆន្ទៈទាមទារភាគបម្រុងរបស់ខ្លួន។

**ដំណោះស្រាយ**

$$\text{ភាគបម្រុង} = \frac{\text{១២០០} + \text{៦០០}}{\text{២}} = \text{៩០០ ដុល្លារ}$$

[34] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧, កថាខណ្ឌទី៤ ។

$$\text{ភាគបម្រុង} = \frac{\text{៦០០}}{\text{២}} = \text{៣០០ ដុល្លារ}$$

ក្នុងករណីប្រសិនបើគ្មានមតកសាសន៍កំណត់ជាមុនទេ **(គ)** អាចទាមទារទឹកប្រាក់ចំនួន ២០០ ដុល្លារ ពី **(ក)** និង ១០០ ដុល្លារ ពី **(ខ)** (សរុប ៣០០ ដុល្លារ) ។ ប៉ុន្តែ ដោយសារមតកសាសន៍បានតម្រូវឲ្យអ្នក ដែលមានសិទ្ធិភាគបម្រុងធ្វើការទាមទារភាគបម្រុងរបស់ខ្លួនពី **(ក)** ដូច្នេះ **(ក)** គឺជាអ្នកដែលមានកាតព្វកិច្ចក្នុងការផ្តល់នូវភាគបម្រុងទៅឲ្យ **(គ)** ទាំងអស់ចំនួន ៣០០ ដុល្លារ ដោយ **(ខ)** មិនចាំបាច់បង់ប្រាក់ចំនួន ១០០ ដុល្លារ ទៅឲ្យ **(គ)** ទេ។

## ផ្នែកទី២៖ ផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម

ប្រសិនបើការធ្វើអច្ច័យទានមិនបណ្តាលឱ្យមានការបំពានភាគបម្រុងនោះទេ គឺយើងត្រូវធ្វើការសិក្សាទៅលើផលប្រយោជន៍ពិសេស ឬ ប្រទានកម្មប្រសិនបើយើងរកឃើញថាការផ្តល់ផលប្រយោជន៍ពិសេស ឬ ប្រទានកម្មពីសំណាក់មតកជនទៅឱ្យជនណាម្នាក់ ឬច្រើននាក់ដែលធ្វើឱ្យមានការបំពានភាគបម្រុងនោះ គឺសន្តតិជន ដែលត្រូវបានបំពានភាគបម្រុងនោះមានសិទ្ធិក្នុងការទាមទានូវភាគបម្រុងរបស់ខ្លួន។ ប៉ុន្តែការទាមទារនេះមិនមែនចេះតែធ្វើការទាមទារតាមសិទ្ធិទំនើងចិត្តរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះទេ គឺមានន័យថាការទាមទារទៅតាមលំដាប់ផលប្រយោជន៍ពិសេស ឬ ប្រទានកម្មនោះ ដោយការកាត់បន្ថយនេះត្រូវធ្វើឡើងចំពោះកិច្ចសន្យាដែលត្រូវបានចាត់ទុកប្រទានកម្មរួម និងការចាត់ចែងកម្មវត្ថុនៃប្រទានកម្មផងដែរ។

- លំដាប់នៃការកាត់បន្ថយផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម

ការកាត់បន្ថយប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសត្រូវចាប់ផ្តើមពីប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើមុនមកជាបន្តបន្ទាប់[35]។

ប៉ុន្តែបើការធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេសលើសពី ២០ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិ-កម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះបាន។

[35] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៦

**កថាខណ្ឌទី១៖ ការកាត់បន្ថយចំពោះកិច្ចសន្យា ដែលត្រូវចាត់ទុកជាប្រទានកម្ម**

របបភាគបម្រុង គឺជារបបដែលការពារជនដែលមានសិទ្ធិលើភាគបម្រុងពីការចាត់ចែងដោយគ្មានកម្រៃ ដូច្នេះកិច្ចសន្យា ដែលមានតម្លៃមិនត្រឹមត្រូវជាអាទិ៍គួរយកមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយភាគដើម្បីបង្គ្រប់ភាគបម្រុងផងដែរ។ កិច្ចសន្យា ដែលត្រូវធ្វើឡើងដោយភាគីទាំងសងខាងបានដឹងថានឹងបណ្តាលឱ្យខូតខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុងទាមទារឲ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញចំពោះការកាត់បន្ថយកិច្ចសន្យាដែលត្រូវចាត់ទុកជាប្រទានកម្មក៏ត្រូវរាប់បញ្ចូលទាំងការកាត់បន្ថយកិច្ចសន្យាដែលត្រូវចាត់ទុកជាប្រទានកម្ម ក៏ត្រូវបានរាប់បញ្ចូលទាំងការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរត្រឹមត្រូវផងដែរ[36] ។

**កថាខណ្ឌទី២៖ ការចាត់ចែងកម្មវត្ថុនៃប្រទានកម្ម**

អ្នកមានសិទ្ធិលើភាគបម្រុង អាចធ្វើបានចំពោះករណីដែលសហសន្តតិជនត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទានកម្មវត្ថុនៃប្រទានកម្មឱ្យទៅអ្នកដទៃ ឬបានបង្កើតផលុបភាគ ឬ សិទ្ធិប្រាតិភោគ ប្រត្យក្សសម្រាប់អ្នកដទៃ។ បើសហសន្តតិជន អច្ច័យលាភី បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មឱ្យទៅអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនោះ ឱ្យទៅអ្នកមានសិទ្ធិលើភាគបម្រុង។ ប៉ុន្តែបើអនុប្បទានិកនោះ បានដឹងថានឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងនៅពេលធ្វើអនុប្បទានអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឱ្យកាត់បន្ថយចំពោះករណីសហសន្តតិជន អច្ច័យលាភី បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ។ ដូច្នេះ អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តអាចធ្វើការទាមទារឱ្យកាត់បន្ថយអច្ច័យទានចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ។ ហេតុដូចនេះ លក្ខណៈតាមផ្លូវច្បាប់នូវសិទ្ធិទាមទារកាត់បន្ថយដើម្បីភាគបម្រុង គឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ហេតុនេះហើយបានជាអច្ច័យទាន ឬ ប្រទានកម្មត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិក្នុងកម្រិតដែលបានបំពាន ដល់ភាគបម្រុងនោះដោយការអនុវត្តសិទ្ធិលើភាគបម្រុងនោះ។

**ផ្នែកទី៣៖ ការរលត់សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង និងអានុភាព**

**កថាខណ្ឌទី១៖ អាជ្ញាយុកាល**

សិទ្ធិទាមទារឱ្យកាត់បន្ថយភាកបម្រុង ត្រូវរលត់ដោយអាជ្ញា បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ដោយគិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់

[36] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤២ ។

ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឱ្យកាត់បន្ថយក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស ដោយគិតចាប់ផ្ដើមសន្តតិកម្ម[37]។

ការរលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឱ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតឡើយ[38]។

ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។

### ក.ការបោះបង់ភាគបម្រុង

ភាគបម្រុងអាចបោះបង់ភាគបម្រុងចោលទាំងអស់ ឬ មួយផ្នែកបាន[39]។ ការបោះបង់ភាគបម្រុងគឺអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច។ ចំណែកឯការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្មមានអានុភាពបាន លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ។ ករណីនេះ ដើម្បីកុំឱ្យមានការបោះបង់សិទ្ធិនេះជាមុន ដោយសារតែចាញ់អំណាចឪពុកម្ដាយ ជាអាទិ៍ ប៉ុន្តែប្រសិនបើមានការបោះបង់ចាំបាច់ត្រូវមានាការវិនិច្ឆ័យដោយពិនិត្យមើលថា តើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងដែរឬទេ? តើការបោះបង់នោះមានសមហេតុសមផលដែរឬទេ?

ម៉្យាងវិញទៀត ទោះបីជាបានបោះបង់សិទ្ធិនោះ មុនពេលចាប់ផ្ដើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឱ្យតុលាការលុបចោលវិញបាន នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្ដូរក្រោយពេលបោះបង់សិទ្ធិនោះ។

### ខ.សហសន្តតិជននៃភាគបម្រុង

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬការលះបង់ភាគបម្រុង ដោយសហសន្តតិជនណាម្នាក់ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតបាននោះទេ[40] បានន័យថាទោះបីជាសន្តតិជនណាម្នាក់បានបោះបង់សិទ្ធិទាមទារលើភាគបម្រុងក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែមានសិទ្ធិរបស់ខ្លួនដដែល ។

[37] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៥ ។

[38] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៣ ។

[39] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៦ ។

[40] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៧ ។

## កថាខណ្ឌទី២៖ អានុភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

### ក. ការសងផលចែកដែលកើតចេញពីកម្មវត្ថុនៃការកាត់បន្ថយ

ជាទូទៅទ្រព្យសម្បត្តិអ្វីមួយតែងតែបានបង្កើតនូវផលផ្សេងៗ ដែលកើតចេញពីទ្រព្យនោះដូចជាដីចម្ការ ផលដែលកើតចេញពីដីចម្ការអាចមានដំណាំជាច្រើន។ ដូច្នេះ ក្រៅពីទ្រព្យសម្បត្តិនិងប្រាក់សំណងដែលត្រូវសង សន្តតិជនដែលមានសិទ្ធិទាមទារលើភាគបម្រុងអាចទាមទារនូវផលដែលកើតចេញពីកម្មវត្ថុនៃការទាមទារឱ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងផងដែរក្រោយពីថ្ងៃដែលបានទាមទារឱ្យកាត់បន្ថយ[41] បានន័យថាអាចទាមទារផលដែលកើតចេញក្រោយពីថ្ងៃដែលបានទាមទារនោះ។

**ឧទាហរណ៍** មតកជន (**ក**) បានធ្វើប្រទានកម្មនូវផ្ទះវីឡាសម្រាប់ជួលឱ្យទៅ(**ខ**) ដោយផលដែលកើតចេញពីផ្ទះវីឡានោះ មានចំនួន ២,០០០ ដុល្លារជារៀងរាល់ខែ ហើយមតកជនបានទទួលមរណភាពនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ហើយនៅថ្ងៃទី ០២ ខែ មិនា ឆ្នាំ២០២០ សន្តតិជនរបស់ (**ក**) ក៏បានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពី (**ខ**) ចំពោះផ្ទះវីឡាទាំងមូលហើយ (**ខ**) ក៏បានប្រគល់ផ្ទះនោះនៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០២០។ ដោយ (**ខ**) បានទទួលផលដែលកើតចេញពីកម្មវត្ថុនៃការទាមទារឱ្យកាត់បន្ថយនោះ គឺបានប្រាក់ឈ្នួលពីការជួលផ្ទះចំនួន ៦ខែ។

នាំឱ្យ ៦×២,០០០=១២,០០០ ដុល្លារ ដូច្នេះ (**ខ**) ត្រូវកាត់ទឹកប្រាក់ចំនួន ៣ ខែ ដែលស្មើនឹង ៦,០០០ ដុល្លារ ប្រគល់ទៅឱ្យសន្តតិជនរបស់ (**ក**) ដោយសារការទាមទារនៅថ្ងៃទី ០២ ខែមិនា ឆ្នាំ ២០២០ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៦,០០០ ដុល្លារ (**ខ**) អាចរក្សាទុក។

### ខ. សំណងដោយបង់ថ្លៃ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមត៌កដែឡបានកំណត់តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬតម្លៃនៃកម្មវត្ថុនៃប្រទានកម្មទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ[42]។

មានន័យថា អ្នកមានកាតព្វកិច្ចនៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អាចរួចផុតពីកាតព្វកិច្ចនៃការសងបានដោយបង់តម្លៃនៃកម្មវត្ថុនោះទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។

ប្រសិនបើអ្នកមានកាតព្វកិច្ចអះអាងថានឹងសងថ្លៃ ហើយបានសងថ្លៃក្រោយពីការព្រមព្រៀងគ្នា នោះសិទ្ធិទាមទារឱ្យកាត់បន្ថយនឹងរលត់ដោយស្វ័យប្រវត្តិ។ ប៉ុន្តែបើអ្នកមានកាតព្វកិច្ចមិនបានអះអាងថានឹងសងដោយ

41 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៤ ។

42 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៤។

បង់តម្លៃនោះទេ អ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឱ្យសងជាប្រាក់បានទេ គឺអាចត្រឹមតែទាមទាឱ្យសងជាវត្ថុនោះតែប៉ុណ្ណោះ ។

### គ. បន្ទុកនៃការខាតបង់ដោយអសាធនភាព

ចំពោះការខាតបង់ដែលកើតឡើងដោយអសាធនភាពរបស់សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហកដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់បន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង[43]។ នៅក្នុងការកំណត់របស់ក្រមរដ្ឋប្បវេណី ក្នុងករណីដែលភាគីម្ខាងទៀតនៃសិទ្ធិទាមទារពីបុគ្គលដែលដែលមានសិទ្ធិជាអ្នកអសាធនភាពក៏ដោយ ក៏បុគ្គលដែលមានសិទ្ធិលើភាគបម្រុងនោះ មិនអាចធ្វើការទាមទារពីបុគ្គលដែលជាអ្នកមានកាតព្វកិច្ចក្នុងលំដាប់បន្ទាប់ ឱ្យសងនូវចំណែកដែលខ្វះនោះបានឡើយ។

[43] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤០ ។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ដោយឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងបកស្រាយចំពោះប្រធានបទស្ដីពី **"ភាគបម្រុង"** រួចមក យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា ភាគបម្រុង គឺជាសិទ្ធិនៃភាគដែលទទួលបានមត៌កជាអប្បបរមា ដែលត្រូវធានាដោយច្បាប់ចំពោះអ្នកមានសិទ្ធិភាគបម្រុង។ ម៉្យាងទៀតភាគបម្រុង អាចត្រូវបានគេធ្វើឡើងទៅតាមបណ្ដាំ ឬតាមច្បាប់ដែលគេឱ្យឈ្មោះថា សន្តតិកម្មតាមច្បាប់ និងមតកសាសន៍។ របបនៃភាគបម្រុងពិតជាមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃនៃសង្គមគ្រួសារកម្ពុជាក៏ដូចជាទំនាក់ទំនងអន្តរជាតិផងដែរ។ ការប្រាស្រ័យទាក់ទង និងការរស់នៅរបស់មនុស្សមានទំនាក់ទំនង ការកំណត់អំពីរបបភាគបម្រុង មានផលប្រយោជន៍ដល់ការសម្របសម្រួលក្នុងករណីមានការបំពាននូវភាគបម្រុង មិនថាក្នុងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍នោះទេ។ យ៉ាងណាមិញរបបភាគបម្រុង គឺជារបបមួយធានាមួយភាគនៃចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលច្បាប់បានកំណត់មួយចំនួន (មិនមែនសន្តតិជនតាមច្បាប់កំណត់ទាំងអស់សុទ្ធតែជាអ្នកមានសិទ្ធិទាមទារលើភាគបម្រុងនោះទេ ជាក់ស្ដែងសន្តតិជនលំដាប់ទី៣ គឺបងប្អូនបង្កើតមិនមានសិទ្ធិទាមទារលើភាគបម្រុងក្នុងករណីដែលមានការបំពានទេ បើទោះបីជាបងប្អូនបង្កើតនោះទទួលឋានៈជាសន្តតិជនលំដាប់ទី៣ក៏ដោយ) ដែលទ្រព្យមួយភាគនៃចំណែកមត៌កនេះ គឺជាទ្រព្យក្នុងកម្រិតអប្បបរមាមួយ ដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងអាចទាមទារបានមានន័យថា ទ្រព្យដែលជាមត៌កដែលអាចទទួលតិចបំផុត ត្រូវស្មើនិងភាគបម្រុងរបស់សន្តតិជនម្នាក់ៗ គឺមិនអាចតិចជាងនេះទៀតទេលើក លែងតែករណីមួយតែប៉ុណ្ណោះគឺអ្នកដែលមានកាតព្វកិច្ចផ្ដល់ភាគបម្រុងនោះ មិនអាចសងនូវតម្លៃនៃទ្រព្យនោះបានដោយសារតែខ្លួនទទួលរងនូវអសោធនភាព ដែលបន្ទុកនោះត្រូវធ្លាក់ទៅលើអ្នកមានសិទ្ធិលើភាគបម្រុងវិញ។ ភាគបម្រុង គឺមានទំនាក់ទំនងយ៉ាងស្អិតរមួតទៅនឹងប្រព័ន្ធសន្តតិកម្ម(សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍)។ ពាក្យថាសន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរទ្រព្យសម្បត្តិរបស់បុគ្គលដែលបានទទួលមរណភាពដោយមិនបានបន្សល់ទុកនូវលិខិតបណ្ដាំ ត្រូវធ្វើការបែងចែកមត៌កទៅតាមច្បាប់ទៅអោយមតកជន។ ចំណែកឯសន្តតិកម្មតាមមតកសាសន៍ គឺជាលិខិតបណ្ដាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្ដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍។ ការបែងចែកមត៌កនេះផងដែរប្រសិនបើ គ្មានវត្តមាននៃរបបនៃភាគបម្រុងនេះទេ យើងឃើញថានឹងមានបញ្ហាកើតមានរវាងបងបងប្អូននៅក្នុងរង្វង់គ្រួសារក៏ដូចជាសង្គមដោយសារការបំពានផ្សេងៗ ពីព្រោះតែការបង្ហាញឆន្ទៈរបស់មតកជន អាចនឹងមានភាពលំអៀងមិនស្មើគ្នារវាងសន្តតិជន និងសន្តតិជនដោយវាបង្កឱ្យមានការបំពានសិទ្ធិ និងបាត់បង់ផលប្រយោជន៍ខ្លួនត្រូវទទួលបាន។ ចំពោះគ្រប់វិធានច្បាប់ទាំងអស់ ដូចជាភាគបម្រុងនេះដែរ គឺមិនមែនត្រឹមតែជា

វិធានដែលបានកំណត់នៅក្នុងអត្ថបទ ក្រដាស ក្រម ឬច្បាប់ប៉ុណ្ណោះទេ តែក៏មានគោលដៅដើម្បីការពារ និងដោះស្រាយរាល់បញ្ហាដែលកើតមានឡើងដោយសារការរំលោភបំពាន ហើយមានគោលដៅម៉្យាងទៀតដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់ សាធារណៈនៅក្នុងសង្គម។ ប៉ុន្តែអ្វីដែលគួរអោយកត់សម្គាល់មួយទៀតនោះគឺទោះបីជាមានការបំពាននូវភាគបម្រុងក៏ដោយប្រសិនបើជនដែលត្រូវបានគេបំពាននោះ មិនបានបង្ហាញឆន្ទៈក្នុងការទាមទារទេនោះក៏មិនចាំបាច់មានការបន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងនោះដែរ។

សរុបសេចក្តីមក របបភាគបម្រុងពិតជាមានសារៈសំខាន់ណាស់ក្នុងការធានាដល់ការរំលោភបំពានចំពោះសន្តតិជនដែលច្បាប់បានកំណត់ និងមិនអោយខាតបង់ប្រយោជន៍ដោយសារតែមតកជន។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវ និងស្វែងយល់ចំពោះប្រធានបទដូចដែលបានបកស្រាយខាងលើរួចមក ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមជាយោបល់ និងអនុសាសន៍មួយចំនួនដូចខាងក្រោមដើម្បីចូលរួមជាចំណែកមួយ ក្នុងការធ្វើឱ្យប្រសើរឡើងនៅការអនុវត្តន៍ជាក់ស្តែងនៃភាគបម្រុង។

សូមឱ្យស្ថាប័នផ្សេងៗដែលទាក់ទងទៅនឹងវិស័យច្បាប់ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ ពិនិត្យ និងអនុម័តនូវច្បាប់ ដើម្បីឱ្យតាមទាន់នូវការអភិវឌ្ឍប្រែប្រួលនៃសង្គម។

មួយវិញទៀត គឺយើងសូមធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ រួមទាំងរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវបទបញ្ញត្តិច្បាប់ផ្សេងៗ មួយវិញទៀតទាក់ទងនឹងភាគបម្រុង ដើម្បីឱ្យប្រជាពលរដ្ឋមានការជ្រួតជ្រាប និងយល់ដឹងក្នុងន័យចូលរួមកាត់បន្ថយ និងលុបបំបាត់ទំនាស់ផ្សេងៗ និងការបំពាននៅក្នុងសង្គមគ្រួសារ រួមទាំងសង្គមជាតិ ដោយហេតុថាសង្គមមានការអភិវឌ្ឍន៍ គឺអាស្រ័យទៅលើចំណេះដឹង និងការអនុវត្តរបស់ប្រជាជន។

ម៉្យាងវិញទៀត ប្រជាពលរដ្ឋទៀតសោតក៏ត្រូវស្វែងយល់នូវពត៌មានផ្សេងៗទាក់ទងនឹងបញ្ញត្តិច្បាប់ដើម្បីជាការយល់ដឹងមុននឹងសម្រេចចិត្តប្តឹងផ្តល់គ្នាក្នុងរង្វង់គ្រួសារខ្លួន ដើម្បីទទួលបាននូវមត៌កតែប៉ុណ្ណោះ ដោយគ្មានការយោគយល់ អធ្យាស្រ័យគ្នាក្នុងគ្រួសាររបស់ខ្លួន។ ទាក់ទងនឹងអ្នកមានសិទ្ធិលើភាគបម្រុងបានបង្ហាញថា ជនទាំងនោះសុទ្ធតែជាសន្តតិជនតាមច្បាប់កំណត់ទាំងអស់ លើកលែងតែបងប្អូនបង្កើតរបស់មតកជន ដែលជាសន្តតិជនដែលច្បាប់បានកំណត់ តែបែរជាគ្មានវត្តមាន ក្នុងនាមជាអ្នកមានសិទ្ធិលើភាគបម្រុងទៅវិញ។ នេះគឺជាបញ្ហាដែលត្រូវពិចារណា ដោយសារតែបងប្អូនបង្កើត ក៏ត្រូវបានច្បាប់ទទួលស្គាល់ ថាជាសន្តតិជនដែរ។ ប៉ុន្តែហេតុអ្វីបានជាមិនផ្តល់ឱ្យសិទ្ធិបង្កើតជាអ្នកមានសិទ្ធិលើភាគបម្រុង។ ក្នុងករណីដែលមានការបំពានលើចំណែកមត៌ករបស់គាត់ ធ្វើឱ្យបងប្អូនបង្កើតរបស់មតកជនគ្មានអ្វីជាមូលដ្ឋានច្បាស់លាស់ ដើម្បីការពារលើចំណែកមត៌ករបស់ខ្លួន ប្រការនេះហើយដែលច្បាប់ហាក់បីដូចជាមើលរំលងករណីនេះ ហើយគ្មានវិធានការណាមួយដើម្បីការពារផលប្រយោជន៍របស់បងប្អូនបង្កើតសោះ។

ហេតុនេះហើយ ទាក់ទងនឹងមាត្រាច្បាប់ដែលចែងអំពីអ្នកដែលមានសិទ្ធិលើភាគបម្រុង គួរតែត្រូវធ្វើវិសោធនកម្មដោយបើកសិទ្ធិឱ្យបងប្អូនបង្កើតរបស់មតកជនអាចទាមទារនូវភាគបម្រុងរបស់ខ្លួននៅពេលដែលមានការបំពានលើចំណែកមត៌ករបស់ពួកគាត់។

ចំពោះបញ្ហាដែលបានលើកឡើងខាងលើ ត្បិតតែមិនទាន់គ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជំរុញដល់ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ដែលទាក់ទងទៅនឹងការបែងចែកមត៌ករបស់មតកជន រួមទាំងធ្វើឱ្យមានភាពសុខសាន្ត និងសុខដុមរមនានៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

## អត្ថបទច្បាប់ ៖

- ➢ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ➢ ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។
- ➢ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានអនុម័តដោយរដ្ឋសភាពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧។
- ➢ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី ៦ គន្លីទី៨-ទី៩ ដែលត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ ដោយការិយាល័យកម្មវិធីផ្នែកច្បាប់ និងយុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ២០១០។

## ឯកសារផ្សេងៗ៖

- ➢ សាស្ត្រាចារ្យ ច្បាប់គាម ម៉ារិទ្ធិយ៉ា, ឆ្នាំ ២០១៥ នីតិរដ្ឋប្បវេណី។
- ➢ សន្ទានុក្រម ខ្មែរ អង់គ្លេស បារាំង នៃពាក្យច្បាប់ រដ្ឋប្បវេណី និងវិធីរដ្ឋប្បវេណី បោះពុម្ពដោយឧបត្ថម្ភពី ឯកឧត្តម សុខ ផេង អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ឆ្នាំ ២០០៧។
- ➢ សាស្ត្រាចារ្យ ស្រី វណ្ណធី , ឆ្នាំ២០១១ នីតិបេតិកភណ្ឌគ្រួសារ។
- ➢ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត , ឆ្នាំ២០០៥ និតិបេតិកភណ្ឌគ្រួសារ។

## ឯកសារធ្វើបទបង្ហាញ ៖

- ➢ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ២៤ តុលា ឆ្នាំ២០១៣ សិក្ខាសាលាស្តីពីអច្ច័យទាន និងភាគបម្រុង។
- ➢ សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្វី លោកស្រីសាស្ត្រាចារ្យ ប៉ូលី បញ្ញា សាស្ត្រាចារ្យ គង់ សុភ័ក្រ្ក, ២៩ មិថុនា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃសន្តតិកម្ម (ផ្នែក២)។
- ➢ មេធាវី អ៊ីវ ប៉ូលី, ឆ្នាំ២០១០ មេរៀនសង្ខេបសន្តតិកម្ម។

**គេហទំព័រ ៖**


- https://khmerlawblog.wordpress.com/2015/10/09ចូលមើលថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០២០
- https://www.youtube.com/watch?v=c4P1R6ta_UQ កម្មវិធីនាទីច្បាប់ ប្រធានបទ៖ ភាគបម្រុង របស់ទូរទស្សន៍ BTV ឬ តាម www.facecbook// BTV Cambodia. ចូលមើលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០
- http://ebooks.libraryrule.com/view_sarana/ ឯកសារសារណាបញ្ចប់ការសិក្សា ប្រធានបទ ភាគបម្រុង ចូលមើលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០។

# ឧបសម្ព័ន្ធ

# សេចក្តីពន្យល់

# មាត្រានីមួយៗ

# ក្រមរដ្ឋប្បវេណី

# (គន្ថីទី៨-គន្ថីទី៩)

# មាតិកា


**គន្ថីទី ៨ សន្តតិកម្ម** . . . . . . . . . . . . . . . . . . . . **១**

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** . . . . . . . . . . . . . . . . . . **១**

ផ្នែកទី ១ ការចាប់ផ្តើមធ្វើសន្តតិកម្ម . . . . . . . . . . . . . . . ១

ផ្នែកទី ២ អានុភាពនៃសន្តតិកម្ម . . . . . . . . . . . . . . . . ៣

ផ្នែកទី ៣ ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន . . . . . . . . . . . . ៥

**ជំពូកទី ២ សន្តតិកម្មតាមច្បាប់** . . . . . . . . . . . . . . . . **១៤**

ផ្នែកទី ១ សន្តតិជន . . . . . . . . . . . . . . . . . . . ១៤

ផ្នែកទី ២ សន្តតិកម្មរបស់សហព័ទ្ធ . . . . . . . . . . . . . . . ២០

ផ្នែកទី ៣ ការសម្រួលចំណែកមតិក . . . . . . . . . . . . . . . ២២

**ជំពូកទី ៣ សន្តតិកម្មតាមមតកសាសន៍** . . . . . . . . . . . . . . **៣០**

ផ្នែកទី ១ សមត្ថភាពក្នុងការធ្វើមតកសាសន៍ . . . . . . . . . . . . . ៣០

ផ្នែកទី ២ ទម្រង់នៃមតកសាសន៍ . . . . . . . . . . . . . . . . ៣២

ផ្នែកទី ៣ ចំណុចនៃមតកសាសន៍ . . . . . . . . . . . . . . . . ៤៥

ផ្នែកទី ៤ ការលុបចោលនូវមតកសាសន៍ . . . . . . . . . . . . . . ៥១

ផ្នែកទី ៥ អានុភាពនៃមតកសាសន៍ . . . . . . . . . . . . . . . ៥៦

ផ្នែកទី ៦ អច្ច័យទាន . . . . . . . . . . . . . . . . . . . ៦១

ផ្នែកទី ៧ ការប្រតិបត្តិមតកសាសន៍ . . . . . . . . . . . . . . . ៧៤

**ជំពូកទី ៤ ភាគបម្រុង** . . . . . . . . . . . . . . . . . . **៨៨**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ . . . . . . . . . . . . . . . . . ៨៨

ផ្នែកទី ២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង . . . . . . . . . . . ៩៦

ផ្នែកទី ៣ ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ . . . . . . . . . . . . ១០៦

**ជំពូកទី ៥ ការយល់ព្រម និង ការបោះបង់សន្តតិកម្ម** . . . . . . . . . . **១០៨**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ . . . . . . . . . . . . . . . . . ១០៨

ផ្នែកទី ២ ការយល់ព្រម . . . . . . . . . . . . . . . . . . ១១៥

ផ្នែកទី ៣ ការបោះបង់ . . . . . . . . . . . . . . . . . . ១២១

**ជំពូកទី ៦ ការគ្រប់គ្រង និង ការបែងចែកមតិក** . . . . . . . . . . . **១២៣**

ផ្នែកទី ១ ការគ្រប់គ្រងមតិក . . . . . . . . . . . . . . . . ១២៣

ផ្នែកទី ២ ការបែងចែកមតិក . . . . . . . . . . . . . . . . . ១២៧

ផ្នែកទី ៣ ការសម្រួលរវាងម្ចាស់បំណុល . . . . . . . . . . . . . . ១៤០

ផ្នែកទី ៤ ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត . . . . . ១៤២

**ជំពូកទី ៧ នត្ថិភាពនៃសន្តតិជន . . . . . . . . . . . . . . . . . . ១៥១**

**ជំពូកទី ៨ ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម . . . . . . . . . . . . . . ១៦១**

**គន្ថីទី ៩ អវសានប្បញ្ញត្តិ . . . . . . . . . . . . . . . . . . . . ១៦៦**

**ជំពូកទោល អវសានប្បញ្ញត្តិ . . . . . . . . . . . . . . . . . . ១៦៦**

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ១) |
| ឯកឧត្តម **អ៊ី ជន** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ២) |
| ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្តម **គង់ ស្រ៊ីម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្តម **ប៊ុន ហុន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ជួន តេជ** | អគ្គាធិការរង, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ផូវ សំភី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សិរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ធារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ីង ធីឫទ្ធិ** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| លោក **ទូច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក **និត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ត្រាចារ្យកិត្តិយស, សកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក **Kamata Kaoru** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |

| | |
|---|---|
| លោក **Matsumoto Tsuneo** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក **Minami Toshifumi** | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |
| លោក **Motoyama Atsushi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan |
| លោក **Niimi Ikufumi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji |
| លោក **Nomi Yoshihisa** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo |
| លោក **Nomura Toyohiro** | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin |
| លោក **Yamamoto Yutaka** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto |
| លោក **Tanamura Masayuki** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Urakawa Michitaro** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ ៖**

| | |
|---|---|
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Yamada Yoichi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Imaizumi Manabu** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោកស្រី **Homma Yoshiko** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kai Mineo** | អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kamiki Atsushi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Manabe Kana** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Terauchi Kozue** | អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kiyohara Hiroshi** | ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

**អ្នកបកប្រែ ៖**

| | |
|---|---|
| លោកស្រី **គគ បូរ៉េន** | អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **សរ សិនិរា** | អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ស សុខាន** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ជិន មុន្នី** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ស៊ឹម ធីរៈ** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

# គន្ថីទី ៨ សន្តតិកម្ម

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១ ការចាប់ផ្តើមធ្វើសន្តតិកម្ម

(កំណត់)

របបសន្តតិកម្មនៅក្នុងពិភពលោកនេះ អាចចែកជា ២ ប្រភេទបាន គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និង គោលការណ៍ជម្រះបញ្ជី ។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្ត គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុង នូវសិទ្ធិ និង ករណីយកិច្ចទាំងអស់របស់មតកជន ។ ដូច្នេះ សន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង (ក្នុង ករណីសហសន្តតិកម្ម ត្រូវធ្វើការបែងចែក) ហេតុនេះហើយ បញ្ញត្តិច្បាប់ និង នីតិវិធី មានភាពងាយស្រួល។ ក៏ប៉ុន្តែ ក្នុងករណីដែលមតកជននោះបានបន្សល់នូវកាតព្វកិច្ចច្រើនពេក ប្រសិនបើសន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះ នឹងធ្វើ ឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដោយសារសន្តតិកម្ម ដូច្នេះហើយបានជាយើងបង្កើតឱ្យមានរបបបោះបង់នូវសន្តតិកម្ម ឬ ការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ ។ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវ សិទ្ធិលើបំណុល និង កាតព្វកិច្ច របស់មតកជន ពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងទ្រព្យនោះ តែក្នុងករណីដែលមានទ្រព្យសកម្មប៉ុណ្ណោះ ហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុ ត្រូវប្រកាសធនក្ស័យ នៃមតិកនោះ ដើម្បីកុំឱ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចនោះ ។ នេះជាគោលការណ៍មួយដែលស្របទៅតាមសមភាព រវាងម្ចាស់បំណុលរបស់មតកជន និង សន្តតិជន ក៏ប៉ុន្តែ មានការលំបាកដូចជា នីតិវិធីស្មុគស្មាញ អស់សោហ៊ុយ និង ចំណាយ ពេលវេលាច្រើនផង ។ ចំពោះបញ្ហាជ្រើសរើសយកគោលការណ៍ណាមួយ ប្រជាជនធម្មតាគ្មានទ្រព្យសម្បត្តិសន្តតិកម្មច្រើន ល្មមនឹងធ្វើការជម្រះទេ ហើយចំពោះប្រជាជនដែលមានទ្រព្យសម្បត្តិសន្តតិកម្មច្រើនក៏ដោយ ក៏អាចប្រើមតកសាសន៍ ជាអាទិ៍ ធ្វើជានីតិវិធីទូទាត់ងាយស្រួលមួយ ដើម្បីសងបំណុលដោយទ្រព្យជាក់លាក់មួយដែរ ដូច្នេះហើយបានជាក្នុង ក្រមនេះ យើងបានបញ្ញត្តដោយយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកធ្វើជាមូលដ្ឋាន ។ ម្យ៉ាងទៀត ក្រម រដ្ឋប្បវេណីនៃប្រព័ន្ធច្បាប់ទ្វីប និង ក្រមរដ្ឋប្បវេណីជប៉ុន ក៏ត្រូវបានបញ្ញត្តដោយយកគោលការណ៍ទទួលបន្តដោយ ស្វ័យប្រវត្តិនេះ មកធ្វើជាមូលដ្ឋានដែរ ។

**មាត្រា ១១៤៥.-** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈ របស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់

សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

(កំណត់)

មាត្រានេះចែងអំពីមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម ។

កថាខណ្ឌទី ១ បានចែងបញ្ជាក់ច្បាស់លាស់ថា សន្តតិកម្មត្រូវចាប់ផ្តើមឡើងដោយមរណភាពរបស់មតកជន គឺមិនទទួលស្គាល់សន្តតិកម្មពេលនៅរស់ទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលបុគ្គលណាម្នាក់បានទទួលប្រកាសអំពីការបាត់ខ្លួន ត្រូវចាត់ទុកថា អ្នកនោះបានទទួលមរណភាពដោយផ្អែកលើមាត្រា ៤៣ ដូច្នេះហើយសន្តតិកម្មត្រូវចាប់ផ្តើម ។

កថាខណ្ឌទី ២ ចែងអំពីវិធីធ្វើសន្តតិកម្ម ដែលមានសន្តតិកម្មតាមមតកសាសន៍ និង សន្តតិកម្មតាមច្បាប់ក្នុងករណីដែលគ្មានមតកសាសន៍ ។ ដូច្នេះ មតកសាសន៍មិនមែនជាប្រទានកម្មមួយប្រភេទទេ គឺត្រូវចាត់ទុកជាសន្តតិកម្មតែម្តង ហេតុនេះហើយ គួរតែវាយតម្លៃថា ការធ្វើអនុប្បទាននូវទ្រព្យដោយមតកសាសន៍ ចំពោះសន្តតិជន គឺជាការកំណត់ចំណែកមតិក ព្រមទាំងកំណត់នូវវិធីបែងចែកមតិក (សូមមើលសាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩១) ហើយចំណុចនេះ មានចែងក្នុងមាត្រា ១១៨៥ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ ដូចគ្នានឹងមាត្រា ៨៨២ នៃក្រមរដ្ឋប្បវេណីជប៉ុនដែរ ។ រីឯកថាខណ្ឌទី ២ វិញ គឺជាបញ្ញត្តិមួយដែលរក្សាទុកនូវគោលគំនិតនៃមាត្រា ៤៨៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

**មាត្រា ១១៨៦.-** ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

(កំណត់)

មាត្រានេះចែងអំពីកន្លែងចាប់ផ្តើមសន្តតិកម្ម ។

មាត្រានេះចែងច្បាស់លាស់ថា ក្នុងករណីដែលចាំបាច់មានអន្តរាគមន៍របស់តុលាការចំពោះសន្តតិកម្ម ដូចជាការបោះបង់នូវសន្តតិកម្ម ការយល់ព្រមដោយមានកម្រិត ការបែងចែកមតិក ជាអាទិ៍ តុលាការដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់មតកជន នៅពេលដែលមតកជននោះបានទទួលមរណភាព ជាតុលាការដែលមានសមត្ថកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៨៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

# ផ្នែកទី ២ អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.-** ការទទួលបន្តនូវមតិក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

(កំណត់)

មាត្រានេះចែងបញ្ជាក់ថា តាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយ-កិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ។

កថាខណ្ឌទី ១ បានបញ្ជាក់ថា សន្តតិកម្មត្រូវធ្វើឡើងតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ។ យោងតាមសេចក្តីកំណត់នៅដើមគន្ថីនេះ សន្តតិកម្មអាចធ្វើឡើងតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ឬ តាមគោលការណ៍ជម្រះបញ្ជី ក៏ប៉ុន្តែ នៅក្នុងក្រមនេះ បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មិនជ្រើសរើសយកគោលការណ៍ជម្រះបញ្ជីទេ ។ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥៩៣ និង មាត្រា ៦០២ បានចែងថាកាតព្វកិច្ចសន្តតិកម្មត្រូវធ្វើការជម្រះបញ្ជីសិនមុននឹងធ្វើការបែងចែកមតិក ជាអាទិ៍ ហើយមើលទៅដូចជាគោលការណ៍ជម្រះបញ្ជីដែរ ក៏ប៉ុន្តែ នៅក្នុងមាត្រា ៦០៥ និង មាត្រា ៥៨៣ បានចែងថា សន្តតិជនដែលមានភាគបម្រុង មានករណីយកិច្ចទទួលបន្តនូវការសងបំណុល ព្រមទាំងមិនអាចបោះបង់សន្តតិកម្មបានទេ ហើយបញ្ញត្តិនេះអាចចាត់ទុកថាជាគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមួយប្រភេទដែរ ។ នៅក្នុងកថាខណ្ឌទី ១ បានចែងថា "ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម" នេះគឺដើម្បីឱ្យមាននិរន្តរភាពតាមផ្លូវច្បាប់ ។ ដូចគ្នាដែរចំពោះសន្តតិកម្មអចលនវត្ថុ សន្តតិជនអាចទទួលបន្តដោយស្វ័យប្រវត្តិនូវអចលនវត្ថុដែលជាមតិក នៅពេលដែលមតកជនទទួលមរណភាព ដោយមិនចាំបាច់មានការចុះបញ្ជីអំពីការណ៍ដែលបានធ្វើសន្តតិកម្មឡើយ ។ ក្នុងករណីនៃសន្តតិកម្មតាមមតកសាសន៍ ក៏ដូចគ្នាដែរ ។ មាត្រានេះចែងដូច្នេះព្រោះថា ប្រសិនបើតម្រូវឱ្យមានការចុះបញ្ជីជាល័ក្ខខ័ណ្ឌដើម្បីទទួលបន្តតាមសន្តតិកម្ម នោះក្នុងអំឡុងពេលមុនសន្តតិជន

ធ្វើការចុះបញ្ជី មិនមានអត្ថិភាពម្ចាស់កម្មសិទ្ធិអចលនវត្ថុឡើយ ដែលការណ៍នេះអាចកើតមានស្ថានភាពដែលទ្រព្យនោះធ្លាក់ ទៅជាទ្រព្យរដ្ឋ ។

នៅក្នុងកថាខណ្ឌទី ២ មានចែងបញ្ញត្តិពិសេសអំពីសន្តតិកម្មនៃកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន ។ ក្នុងករណីខ្លះ វត្ថុទាំងនេះ មិនត្រូវធ្វើសន្តតិកម្មដោយសន្តតិជនតាមច្បាប់ឡើយ គឺត្រូវបានទទួលបន្តដោយជនដទៃទៀត ឬក៏មានករណីមួយចំនួនដែលមានសហសន្តតិជន (ករណីនៃសហ-សន្តតិកម្ម) ប៉ុន្តែ សហសន្តតិជនណាម្នាក់ទទួលវត្ថុទាំងនោះដោយឯកឯង ដោយមិនស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ ដូចមានចែងក្នុងមាត្រា ១១៤៨ ទេ ។ ដូច្នេះហើយបានជាកំណត់ថា វត្ថុទាំងនេះត្រូវទទួលបន្ត ដោយយោងតាមឆន្ទៈរបស់មតកជន ឬ តាមទំនៀមទម្លាប់ ។ ឧទាហរណ៍ ទោះបីជាក្នុងករណីដែលប្រពន្ធ និង ឪពុកម្តាយជាសហសន្តតិជនក៏ដោយ យោងទៅតាមឆន្ទៈរបស់មតកជន ដោយសារឪពុកម្តាយចាស់ជរា ក៏អាចសុំឱ្យបងប្រុសរបស់មតកជនទទួលបន្តបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## **មាត្រា ១១៤៨.–** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

(កំណត់)

មាត្រានេះចែងអំពីការទទួលបន្តនូវសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ។

កថាខណ្ឌទី ១ ចែងអំពីការទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចរបស់មតកជន ដោយសហសន្តតិជនម្នាក់ៗ ទៅតាមសមាមាត្រនៃចំណែកមតិកដែលខ្លួនត្រូវស្នង ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ។ តាមលទ្ធផលនៃសន្តតិកម្មនេះ ក្នុងករណីដែលមតកជនមានសិទ្ធិលើបំណុលចំពោះតតិយជន ប្រសិនបើសិទ្ធិលើបំណុលនោះ ជាប្រាក់ ជាអាទិ៍ ដែលអាចបែងចែកបាន សិទ្ធិលើបំណុលនេះត្រូវបែងចែក តាមចំណែកមតិកដែលច្បាប់បានកំណត់របស់សហសន្តតិជននីមួយៗ ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រង់ចាំពេលបែងចែកមតិកទេ ។ ម្យ៉ាងទៀត ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ចំពោះតតិយជន ប្រសិនបើកាតព្វកិច្ចនោះជាប្រាក់ ជាអាទិ៍ ដែលអាចបែងចែកបាន ត្រូវបែងចែកតាមចំណែកមតិកដែលច្បាប់

បានកំណត់ ហើយប្រសិនបើសហសន្តតិជនមិនបានបោះបង់ចោលការស្នងនោះទេ ត្រូវទទួលករណីយកិច្ចសងកាតព្វកិច្ចរបស់មតកជន ទៅតាមសមាមាត្រនៃចំណែកមតិកដែលច្បាប់បានកំណត់ លើកលែងតែសហសន្តតិជនមិនបានបោះបង់សន្តតិកម្មនោះទេ ។ មាត្រា ១២៦៩ និង មាត្រា ១២៧៥ ត្រូវបានបញ្ញត្តឡើង ដោយយកគោលគំនិតនេះជាមូលដ្ឋាន ។

កថាខណ្ឌទី ២ ចែងថា មតិកត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។ ដូច្នេះ ចំពោះមតិកដែលមិនទាន់ធ្វើការបែងចែក តតិយជនអាចធ្វើកិច្ចការជំនួញ ឬ ធ្វើការរឹបអូស ដោយផ្អែកទៅលើការណ៍ដែលសហសន្តតិជននីមួយៗមានចំណែកកម្មសិទ្ធិអវិភាគតាមចំណែកមតិកដែលច្បាប់បានកំណត់ ។ បញ្ញត្តិនៃវាក្យខ័ណ្ឌទី ២ នៃកថាខណ្ឌទី ១ មាត្រា ១២៧៣ និង មាត្រា ១២៧៩ ត្រូវបានរៀបចំឡើង ដោយយកចំណុចនេះធ្វើជាមូលដ្ឋាន ។ ក៏ប៉ុន្តែ ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ក៏ដោយ ក៏មិនមែនមានន័យថា ការបែងចែកមតិកត្រូវក្លាយជាគ្មានន័យនោះឡើយ ។ បានសេចក្តីថា ចំពោះទ្រព្យនីមួយៗដែលជាកម្មសិទ្ធិអវិភាគ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ការបែងចែកមតិកត្រូវធ្វើឡើង ដោយការប្តូរគ្នាទៅវិញទៅមកនូវចំណែកកម្មសិទ្ធិអវិភាគ ។ ម្យ៉ាងទៀត មាត្រានេះមានភាពខុសគ្នានឹងមាត្រា ៥៩៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាដែលចែងថា ទ្រព្យមតិកត្រូវឱ្យនៅមូលមួយដុំជាមួយគ្នា រហូតដល់ពេលធ្វើការបែងចែក ហើយប្រសិនបើគ្មានការយល់ព្រមពីសហសន្តតិជនទាំងអស់ទេ មិនអាចធ្វើការចាត់ចែងទ្រព្យមតិកនោះបានទេ ។ ដោយសារតែបានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ដែលជាគោលការណ៍ងាយស្រួលនោះ បានជាមិនបានជ្រើសរើសយកវិធាននីតិកម្មតាមមាត្រា ៥៩៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩៩ មាត្រា ៨៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៩៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## ផ្នែកទី ៣ ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មតិកពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

(កំណត់)

មាត្រានេះចែងអំពីបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ឬ អច្ច័យលាភី ។

ជាបឋម កថាខណ្ឌទី ១ ចែងថា សន្តតិកម្មអាចធ្វើឡើងបានតែចំពោះបុគ្គលដែលមានជីវិតរស់នៅ នៅពេលចាប់ផ្ដើមសន្តតិកម្មតែប៉ុណ្ណោះ ។ ដូច្នេះ ក្នុងករណីដែលមតកជន និង ជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពព្រមជាមួយគ្នា ឬ ក្នុងករណីដែលត្រូវបានសន្មតថា បានទទួលមរណភាពព្រមជាមួយគ្នា ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៥ ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនបំពេញល័ក្ខខ័ណ្ឌមានជីវិតរស់នៅ នៅពេលចាប់ផ្ដើមសន្តតិកម្មទេ ដូច្នេះមិនអាចធ្វើសន្តតិកម្មបានឡើយ ។ បន្ទាប់ពីនេះ កថាខណ្ឌទី ១ បញ្ញត្តអំពីភាពមិនមែនជាអភ័ព្វបុគ្គល ឬ ភាពមិនមែនជាអ្នកដែលត្រូវបានផ្ដាច់មតិក ដូចដែលបានចែងនៅក្នុងមាត្រាបន្ទាប់ទៅ ក៏ប៉ុន្តែ បញ្ញត្តិនេះចែងឡើងសម្រាប់រំឭកបញ្ជាក់តែប៉ុណ្ណោះ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិដើម្បីរំឭកបញ្ជាក់នូវអាទិភាពនៃបញ្ញត្តិនៃមាត្រា ៩ កថាខណ្ឌទី ២ និង ទី ៣ ទៅលើកថាខណ្ឌទី ១ នៃមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៨ និង មាត្រា ៥៤៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន មិនមានអត្ថិភាពនៃបញ្ញត្តិដូចកថាខណ្ឌទី ១ ទេ ដោយសារបញ្ញត្តិនេះគឺជារឿងធម្មតា ប៉ុន្តែ នៅក្នុងក្រមនេះចែងឡើង ដើម្បីឱ្យស្រួលយល់ ។ ចំពោះបញ្ញត្តិដូចកថាខណ្ឌទី ២ វិញ សូមមើលមាត្រា ៨៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១១៥០.-** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ:

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-

សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

(កំណត់)

មាត្រានេះចែងអំពីអភ័ព្វបុគ្គលដែលខ្វះលក្ខណៈជាសន្តតិជន ឬ ជាអច្ច័យលាភី ។ នៅក្នុងមាត្រាខាងក្រោមនេះ មានចែងអំពីការផ្តាច់មតិកពីសន្តតិជន ក៏ប៉ុន្តែ ដោយយោងតាមច្បាប់ បុគ្គលដែលខ្វះលក្ខណៈជាសន្តតិជន ជាអាទិ៍ គ្មានលក្ខណៈក្លាយជាសន្តតិជន ឬ ជាអច្ច័យលាភីទេ ទោះជាមាន ឬ គ្មានឆន្ទៈរបស់មតកជនក្តី ។ រីឯការផ្តាច់មតិកពីសន្តតិជនវិញ ការផ្តាច់ ឬ មិនផ្តាច់មតិកពីអ្នកនោះ គឺត្រូវធ្វើទៅតាមឆន្ទៈរបស់មតកជន ។ ការចាត់ចែងតាមករណីណាមួយ តាមបញ្ញត្តិណា មួយ ត្រូវបែងចែកទៅតាមភាពផ្ទុយនឹងសង្គមរបស់ទង្វើ ជាអាទិ៍ ។

ចំណុច ក ចែងថា បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាង ឬ លំដាប់ស្មើគ្នា ជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ។ នេះមានរួមទាំងករណីដែលបានធ្វើផ្ទាល់ និង ករណីដែលត្រូវផ្តន្ទាទោស ដោយសារបានជួយ ឬ សមគំនិតក្នុងការធ្វើឃាតនោះផងដែរ ។ ការធ្វើឃាតសន្តតិជនដែលមានលំដាប់ខ្ពស់ជាង ជាអាទិ៍ ក៏ត្រូវបានបញ្ចូលជាមូលហេតុនៃអភ័ព្វបុគ្គលផងដែរ ព្រោះថា ការធ្វើឃាតជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាងដោយជនដែលមិនត្រូវក្លាយជាសន្តតិជនសោះ ក្នុងគោលបំណងក្លាយជាមានលក្ខណសម្បត្តិជាសន្តតិជន ឬ ការធ្វើឃាតជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានលំដាប់សន្តតិកម្មដូចគ្នា ក្នុងគោលបំណងបង្កើនចំណែកមតិក គឺជាទង្វើផ្ទុយនឹងសង្គមយ៉ាងធ្ងន់ធ្ងរ ។

ចំណុច ខ ចែងថា ជាគោលការណ៍ បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹងទេ ក៏ជាអភ័ព្វបុគ្គលដែរ ។ ការចែងកម្រិតត្រឹមតែការសម្លាប់មតកជន គឺដោយសារតែក្នុងករណីដែលមិនបានធ្វើសេចក្តីរាយ-ការណ៍ ជាអាទិ៍ អំពីការធ្វើឃាតបុគ្គលផ្សេងពីមតកជនដែលមានចែងក្នុងចំណុច ក នោះមតកជនអាចធ្វើការវិនិច្ឆ័យថា តើត្រូវផ្តាច់ ឬ មិនផ្តាច់នូវមតិកពីបុគ្គលនោះ ដោយសារមូលហេតុនេះ ។ ក្នុងករណីនេះ អាចស្របនឹងចំណុច ង នៃមាត្រាបន្ទាប់ ។

ចំណុច គ ដល់ចំណុច ង ចែងអំពីករណីធ្វើ កែប្រែ ឬ លុបចោលនូវមតកសាសន៍ ដោយមិនត្រឹមត្រូវ រួមទាំងករណីដែលមិនឱ្យធ្វើមតកសាសន៍ដោយមិនត្រឹមត្រូវផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៨៩ មាត្រា ៤៩០ មាត្រា ៥៤៩ នៃក្រមរដ្ឋប្បវេណីចាស់

របស់កម្ពុជា

**មាត្រា ១១៥១.–** ការផ្ដាច់មត៌កពីសន្ដតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្ដតិជននោះ មិនឱ្យទទួលសន្ដតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្ដតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្ដែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្ដាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្ដតិជនដែលបានទទួលការទាមទារផ្ដាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្ដាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

(កំណត់)

មាត្រានេះចែងអំពីការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្ដតិជន មិនឱ្យទទួលសន្ដតិកម្មដោយឆន្ទៈរបស់មតកជន ។

កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ចែងអំពីនីតិវិធីផ្ដាច់មត៌កពីសន្ដតិជន ។ មតកជនដែលចង់ផ្ដាច់មត៌កពីសន្ដតិជនដោយសារតែជនដែលត្រូវបានសន្មតថាជាសន្ដតិជន មានមូលហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌនេះ អាចដាក់ពាក្យសុំទៅតុលាការកុំឱ្យបុគ្គលនោះធ្វើសន្ដតិកម្មបាន ។ ដូច្នេះ ការផ្ដាច់មត៌កពីសន្ដតិជន ចាំបាច់ត្រូវមានឆន្ទៈរបស់មតកជន និង ការពិនិត្យរបស់តុលាការ ជាល័ក្ខខ័ណ្ឌ ។ ការតម្រូវឱ្យមានការពិនិត្យដោយតុលាការ គឺដើម្បីឱ្យតុលាការដែលជាតតិយជន ធ្វើការវិនិច្ឆ័យមើលថា តើជនដែលត្រូវបានសន្មតថាជាសន្ដតិជន ហើយដែលត្រូវបានគេបង្ហាញឆន្ទៈផ្ដាច់មត៌កនោះ ជាបុគ្គលដែលមានលក្ខណៈដូចដែលមានចែងក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ដែរឬទេ ។ ជាពិសេស ល័ក្ខខ័ណ្ឌ "ប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ" ឬ "ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់" ជាអាទិ៍ គឺជា

ការចែងឡើងដោយយកទស្សនៈនៃតម្លៃមកធ្វើជាមូលដ្ឋាន ដូច្នេះហើយ ត្រូវចាំបាច់ឱ្យតុលាការធ្វើការថ្លឹងថ្លែងថា តើអំពើប្រមាថ ឬ អំពើល្មើសនោះ មានទម្ងន់ដែលត្រូវផ្ដាច់មតិកដែរឬទេ ។ មានករណីច្រើនដែលមតកជនមានអាយុច្រើនហើយសមត្ថភាពនៃការវិនិច្ឆ័យ ក៏ត្រូវចុះអន់ថយ ហើយមតកជននោះ បានខឹងយ៉ាងខ្លាំងចំពោះកំហុសតូចតាចរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន ហើយបានសុំឱ្យផ្ដាច់មតិកពីបុគ្គលនោះ ហេតុនេះហើយ ចាំបាច់ត្រូវមានការវិនិច្ឆ័យរបស់តុលាការ ។ ការអនុញ្ញាតឱ្យផ្ដាច់មតិកពីសន្តតិជនតាមមតកសាសន៍ គឺជាការត្រៀមសម្រាប់ករណីដែលមតកជនផ្ដាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជនពេលនៅរស់ ហើយដែលការផ្ដាច់នេះអាចធ្វើឱ្យមតកជននោះទទួលគ្រោះថ្នាក់ ដោយការធ្វើបាបរបស់បុគ្គលនោះ ឬ ខ្លាចបុគ្គលនោះបោះបង់ចោលមតកជន ។ម្យ៉ាងទៀត មាត្រានេះចែងតែអំពីការផ្ដាច់មតិកពីសន្តតិជនតែប៉ុណ្ណោះ ។ ចំពោះការផ្ដាច់អច្ច័យទានពីអច្ច័យលាភីវិញ គ្រាន់តែប្ដូរមតកសាសន៍ជាការស្រេច ហេតុនេះហើយ មិនចាំបាច់មានបញ្ញត្តិនេះទេ ។

ពីចំណុច ក ដល់ចំណុច គ និង ចំណុច ង ជាទស្សនៈនៃតម្លៃ ហើយមូលដ្ឋានដើម្បីធ្វើការវិនិច្ឆ័យ គឺជាភាពត្រឹមត្រូវសមរម្យនៃការផ្ដាច់មតិកពីសន្តតិជនដោយសារអំពើនោះ ។

ចំពោះចំណុច ឃ វិញ នៅក្នុងមាត្រា ៨៨៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បុគ្គលដែលមានទោសជាប់ពន្ធនាគារមួយជីវិត ជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ។ ក៏ប៉ុន្តែ ដោយគិតឃើញថា អាចប្រើមតិកនោះ ដើម្បីសងនូវសំណងនៃការខូចខាតឱ្យជនរងគ្រោះបាន ហេតុនេះហើយបានជាក្នុងនេះ មិនចាត់ទុកអ្នកនោះជាអភ័ព្វបុគ្គលទេ ដោយឱ្យមតកជនជាអ្នកធ្វើសេចក្ដីសម្រេចទៅវិញ ។ បញ្ញត្តិដែលមានក្នុងចំណុចនេះ មិនមែនជាទស្សនៈនៃតម្លៃទេ ឱ្យតែមតកជនបង្ហាញឆន្ទៈផ្ដាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជន ដែលត្រូវជាប់ពន្ធនាគារមួយជីវិត តុលាការត្រូវទទួលស្គាល់ការសុំផ្ដាច់នោះ ។

កថាខណ្ឌទី ២ ដែលមានប្រភពពីមាត្រា ៥៤៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បញ្ញត្តអំពីនីតិវិធីនៃការធ្វើសេចក្ដីសម្រេចផ្ដាច់មតិកពីសន្តតិជន ។ បញ្ញត្តិនេះចែងថា ជនដែលត្រូវបានសន្មតថាជាសន្តតិជន ហើយដែលត្រូវបានទទួលការទាមទារផ្ដាច់មតិក អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការផ្ដាច់មតិកនេះ នៅក្នុងនីតិវិធីនៃកាសម្រេចសេចក្ដី ។ វិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃការបង្ហាញឆន្ទៈសុំផ្ដាច់នោះ ក៏អាចធ្វើបានដែរ ក៏ប៉ុន្តែ តាមភាពជាក់ស្ដែង ជននោះធ្វើជាវិវាទចំពោះអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ចំណុច គ និង ចំណុច ង និង វិវាទអំពីភាពសមស្រប ឬ មិនសមស្របក្នុងការផ្ដាច់មតិក ទោះជាសន្មតថា មានមូលហេតុនៃអំណះអំណាងរបស់មតកជនក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩២ នៃក្រមរដ្ឋប្បវេណីជប៉ុន និងមាត្រា ៤៩០ មាត្រា ៥៤២ ដល់ ៥៤៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៥២.-** ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីផ្តាច់មតិកពីសន្តតិជន ក្នុងករណីដែលមតកជនបានបង្ហាញឆន្ទៈនៃការផ្តាច់មតិក ដោយមតកសាសន៍ ។

វាក្យខណ្ឌទី ១ ចែងថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំផ្តាច់មតិកពីសន្តតិជនទៅតុលាការ ។ ជាពិសេសក្នុងករណីដែលសហសន្តតិជនមិនបានព្រមព្រៀងក្នុងការបែងចែកមតិក ហើយទាមទារឱ្យតុលាការធ្វើការបែងចែក ដោយយោងតាមមាត្រា ១២៧០ ឬ ក្នុងករណីដែលមានការផ្លាស់ប្តូរលំដាប់សន្តតិកម្ម (ឧទាហរណ៍ ករណីដែលសន្តតិកម្មត្រូវធ្វើឡើងដោយសន្តតិជនតែម្នាក់ តែសន្តតិជននោះត្រូវបានផ្តាច់មតិក ឬ ក្នុងករណីដែលមានកូនម្នាក់ និង សហព័ទ្ធជាសន្តតិជន ហើយកូននោះត្រូវបានផ្តាច់មតិក) អ្នកប្រតិបត្តិមតកសាសន៍ចាំបាច់ត្រូវដាក់ពាក្យសុំផ្តាច់មតិកពីសន្តតិជនទៅតុលាការ ។ ម្យ៉ាងទៀត ប្រសិនបើមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ទេ ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមមាត្រា ១២១៨ ។ ផ្ទុយទៅវិញ ទោះបីជាមានការផ្តាច់បុគ្គលមួយចំនួននៃសហសន្តតិជនដោយមតកសាសន៍ក៏ដោយ ក្នុងករណីដែលការផ្តាច់មតិកនេះមិនបានផ្លាស់ប្តូរនូវលំដាប់សន្តតិកម្ម ប្រសិនបើសហសន្តតិជនទាំងអស់បានដឹងអំពីការផ្តាច់នៃមតិកនោះ ព្រមទាំងបានព្រមព្រៀងគ្នាក្នុងការបែងចែកមតិក នោះមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មតិកពីសន្តតិជនឡើយ ។ ក្នុងករណីនេះ ប្រសិនបើតុលាការមិនទទួលស្គាល់ការផ្តាច់មតិកទេ គឺគ្មានបញ្ហាអ្វីឡើយ តែទោះជាតុលាការទទួលស្គាល់ការផ្តាច់មតិកក៏ដោយ ក៏អាចចាត់ទុកថា បានទទួលប្រទានកម្មពីសហសន្តតិជនផ្សេងទៀតដែរ ។

ដោយសារតែសន្តតិកម្មត្រូវបានចាប់ផ្តើមពីពេលដែលមតកជនបានទទួលមរណភាព ដូច្នេះហើយបានជាការផ្តាច់មតិកពីសន្តតិជនត្រូវមានអានុភាពប្រតិសកម្មពីពេលនោះទៅ ហេតុនេះហើយបានជាចាំបាច់ត្រូវបញ្ញត្តចំណុចនេះ នៅក្នុងវាក្យខណ្ឌទី ២ នេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៥៣.-** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

(កំណត់)

ក្នុងករណីដែលអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ កំពុងកាន់កាប់មតិក ការកាន់កាប់នោះ គឺជាការកាន់កាប់ដោយគ្មានសិទ្ធិ ហើយក្លាយជាការកាន់កាប់ដោយទុច្ចរិត ហេតុដូច្នេះ មាត្រានេះចែងថា ការកាន់កាប់ដោយទុច្ចរិតនេះ សន្មតថាចាប់ផ្តើមពីពេលចាប់ផ្តើមសន្តតិកម្ម ។

លទ្ធផលនៃការអនុវត្តមាត្រានេះ គឺអភ័ព្វបុគ្គល ជាអាទិ៍ ដែលកាន់កាប់មតិក ត្រូវមានករណីយកិច្ចសងនូវសំណងនៃការខូចខាតទាំងស្រុង ចំពោះការបាត់បង់ ឬ ខូចខាត ជាអាទិ៍ នៃវត្ថុកាន់កាប់នោះ ដែលកើតមានឡើងចាប់ពីពេលមតកជនបានទទួលមរណភាព (មាត្រា ១៩៧) ។ ម្យ៉ាងទៀត ចំពោះការអនុវត្តបញ្ញត្តិមាត្រា ១៩៦ និង មាត្រា ១៩៨ ជាអាទិ៍ អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ នោះ ក៏ត្រូវបានវាយតម្លៃថាជាអ្នកកាន់កាប់ដោយទុច្ចរិតផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៥៤.-** ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន ។

(កំណត់)

មាត្រានេះចែងអំពីការអាចលុបចោលនូវការផ្តាច់មតិកពីសន្តតិជន ដោយមតកជន ព្រមទាំងនីតិវិធីនៃការលុបចោល

នោះ ។

កថាខណ្ឌទី ១ ចែងថា ទោះជាមតកជន កាលនៅរស់ បានដាក់ពាក្យសុំឱ្យផ្ដាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជន ហើយតុលាការបានទទួលស្គាល់នូវការផ្ដាច់មតិកនោះហើយក៏ដោយ ក៏អាចសុំឱ្យលុបចោលវិញបាននូវការផ្ដាច់មតិកនោះដែរ ។ តុលាការដែលត្រូវបានទាមទារឱ្យលុបចោលការផ្ដាច់មតិក គ្រាន់តែធ្វើការវិនិច្ឆ័យថា តើការសុំលុបចោលនូវការផ្ដាច់មតិកនោះ ជាឆន្ទៈពិតប្រាកដរបស់អ្នកដាក់ពាក្យសុំមែនឬយ៉ាងណាប៉ុណ្ណោះ ហើយប្រសិនបើការសុំលុបចោលនោះ ជាឆន្ទៈពិតប្រាកដរបស់អ្នកដាក់ពាក្យសុំមែន តុលាការត្រូវលុបចោលនូវការផ្ដាច់មតិកនោះ ដោយមិនចាំបាច់ធ្វើការពិនិត្យនូវអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការផ្ដាច់មតិកឡើយ ។ នេះក៏ព្រោះថាការផ្ដាច់មតិកពីជនដែលត្រូវបានសន្មតថាជាសន្តតិជន គឺអាស្រ័យលើឆន្ទៈរបស់មតកជន ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិទទួលស្គាល់ការលុបចោលនូវការផ្ដាច់មតិកពីសន្តតិជនដែលបានធ្វើឡើងនៅពេលមតកជននៅរស់ ដោយមតកសាសន៍ ។ នៅក្នុងករណីនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវសុំឱ្យតុលាការ លុបចោលនូវការផ្ដាច់មតិកពីសន្តតិជននោះ ។ ម្យ៉ាងទៀត ចំពោះករណីដែលបានផ្ដាច់មតិកពីសន្តតិជន តាមមតកសាសន៍ ដើម្បីលុបចោលនូវការផ្ដាច់មតិកនេះ គ្រាន់តែធ្វើតាមនីតិវិធីលុបចោលមតកសាសន៍នេះ ដូចដែលមានចែងចាប់ពី មាត្រា ១១៨៨ ទៅ ជាការគ្រប់គ្រាន់ហើយ មិនចាំបាច់ដាក់ពាក្យសុំទៅតុលាការទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៥៥.–** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មតិកត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមតិក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមតិក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់

នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះ ត្រូវក្លាយជាមតិក ហើយនីតិបុគ្គលមតិកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានផ្ទេរសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះ នីតិបុគ្គលមតិកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិពិសេស ដែលចែងអំពីករណីដែលសន្តតិជន ជាអាទិ៍ ជាជនជាតិបរទេស ហើយដែលក្នុងចំណោមមតិកនោះមានដីធ្លី ។

យោងតាមច្បាប់ភូមិបាលកម្ពុជា ជនជាតិបរទេសមិនអាចមានកម្មសិទ្ធិទៅលើដីធ្លីទេ ក៏ប៉ុន្តែ មានករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស ។ ឧទាហរណ៍ សហព័ទ្ធជាជនជាតិបរទេស ឬ កូនរបស់មតកជនបានចូលសញ្ជាតិបរទេស ។ ម្យ៉ាងទៀត អាចមានករណីដែលអច្ច័យលាភីបានចូលសញ្ជាតិបរទេស ក្រោយពីបានធ្វើមតកសាសន៍រួច ក៏ប៉ុន្តែ មតកជនបានភ្លេចប្តូរមតកសាសន៍នោះ ដូច្នេះបានជាបញ្ញត្តិនេះចែងផងដែរថា "បើបុគ្គលដែលទទួលទ្រព្យសម្បត្តិ តាមមតកសាសន៍ពុំមានសញ្ជាតិជាខ្មែរទេ" ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិគ្រើនរំលឹក ។

កថាខណ្ឌទី ២ ចែងថា ទោះបីជាក្នុងចំណោមសហសន្តតិជន មានសន្តតិជនខ្លះជាជនជាតិបរទេសក៏ដោយ ក៏ជនដែលមានសញ្ជាតិខ្មែរអាចធ្វើលទ្ធកម្ម ឬ អាចចាត់ចែងដីធ្លីនោះបានដែរ ហេតុដូច្នេះ ការបែងចែកមតិកត្រូវគិតគូរពិចារណាលើចំណុចនេះ ។

ចាប់ពីកថាខណ្ឌទី ៣ ទៅ ចែងអំពីករណីដែលសន្តតិជនទាំងអស់ពុំមានសញ្ជាតិជាខ្មែរ ដែលក្នុងករណីនេះ ត្រូវប្តូរដីធ្លីនោះជាប្រាក់ ហើយធ្វើការបែងចែកមតិកនោះ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ដោយហេតុថា សន្តតិជនមិនអាចមានកម្មសិទ្ធិលើដីធ្លី នោះសន្តតិជនមិនអាចចាត់ចែងលើដីធ្លីបានដែរ ដូច្នេះ ករណីនេះ ក៏ដូចជាករណីដែលពុំមានអត្ថិភាពសន្តតិជនដែរ គឺគេផ្តល់មូលដ្ឋានគតិយុត្តដល់ការចាត់ចែងលើដីធ្លី ដោយចាត់ទុកថាដីធ្លីដែលជាមតិកនោះជានីតិបុគ្គល ហើយនីតិបុគ្គលនោះ

មានកម្មសិទ្ធិទៅលើដីធ្លី និង សន្តតិជនមានសិទ្ធិគ្រប់គ្រងចាត់ចែងដីនោះដែរ ។ បើមិនធ្វើដូច្នេះទេ ដីធ្លីនោះនឹងក្លាយទៅជាដីធ្លីគ្មានម្ចាស់ ហើយនឹងក្លាយជាទ្រព្យសម្បត្តិរដ្ឋ ។ ប៉ុន្តែ ការដែលដាក់ដីធ្លីក្រោមកម្មសិទ្ធិនីតិបុគ្គល ដែលត្រូវបានចាត់ទុក ដោយមិនមានពេលកំណត់នោះ មិនមែនជាការត្រឹមត្រូវឡើយ ។ ដូច្នេះ ត្រូវកម្រិតអំឡុងពេលម្តង ៣ ខែ ជាអំឡុងពេលចាត់ចែង បន្ទាប់ពីសន្តតិជនទាំងអស់ដែលមានលំដាប់ខ្ពស់ជាងគេបានយល់ព្រមទាំងស្រុង ឬ យល់ព្រមដោយកម្រិត ។ ហើយប្រសិនបើក្នុងអំឡុងពេលនោះ មិនមានការចាត់ចែងដីធ្លីនេះទេ សន្តតិជនដែលមានលំដាប់បន្ទាប់ជាសន្តតិជនទៅវិញ ។ ក្នុងករណីដែលសន្តតិជនមានលំដាប់បន្ទាប់ទាំងអស់សុទ្ធតែគ្មានសញ្ជាតិខ្មែរក៏ដោយ ក៏ត្រូវធ្វើតាមនីតិវិធីដូចគ្នានេះដែរ ។

# ជំពូកទី ២ សន្តតិកម្មតាមច្បាប់

## ផ្នែកទី ១ សន្តតិជន

**មាត្រា ១១៥៦.-** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមតិកស្មើៗគ្នា ។

(កំណត់)

មាត្រានេះចែងថា សន្តតិជនដែលមានលំដាប់ទី ១ គឺកូនរបស់មតកជន ។

កថាខណ្ឌទី ១ បានកំណត់ថា កូនរបស់មតកជនជាសន្តតិជនលំដាប់ទី ១ ។ នៅក្នុងនេះ "កូនរបស់មតកជន" មានន័យថា កូនដែលមានបុត្តភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ។ ដូច្នេះ ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ដូច្នេះ កូននោះមិនអាចក្លាយជាសន្តតិជនរបស់ឪពុកបានទេ ។ ហើយចំពោះកូនដែលត្រូវបានសុំតាមសុំកូនពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើត ត្រូវបានបញ្ចប់ ដោយយោងតាមមាត្រា ១០១៤ ដូច្នេះ កូននោះមិនអាចទទួលសន្តតិកម្មបានទេ ពោលគឺគេអាចទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ ។ រីឯកូនសុំតាមសុំកូនធម្មតាវិញ អាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និង ពីឪពុកម្តាយចិញ្ចឹមផង (មាត្រា ១០២៦) ។ ម្យ៉ាងទៀត សហព័ទ្ធរបស់មតកជន នឹងក្លាយជាសន្តតិជនដោយស្វ័យប្រវត្តិ (មាត្រា ១១៦១ កថាខណ្ឌទី ១) ហើយចំណែកមតិក នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង កូនរបស់មតកជន ជាសន្តតិជន មានចែងក្នុងមាត្រា ១១៦២ ។

កថាខណ្ឌទី ២ ចែងថា កូនរបស់មតកជន ទោះជាកូនបង្កើតក៏ដោយ កូនសុំក៏ដោយ ក៏មានចំណែកមតិកស្មើគ្នាដែរ ។

កូនក្រៅអាពាហ៍ពិពាហ៍ក៏ត្រូវមានចំណែកមត៌កស្មើគ្នា នឹងកូនកើតដោយមានអាពាហ៍ពិពាហ៍ដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៩៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៥៧ ថ្មី .-** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់ បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។ [១]

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ កូនរបស់ជននោះត្រូវក្លាយទៅជាសន្តតិជនជំនួស ។

កថាខណ្ឌទី ១ បានចែងជាបឋមថា ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព មុនពេលចាប់ផ្តើមសន្តតិកម្ម កូនរបស់ជននោះត្រូវក្លាយទៅជាសន្តតិជន ។ ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព ក្រោយពេលចាប់ផ្តើមសន្តតិកម្ម ជននោះទទួលសន្តតិកម្មរបស់មតកជន ហើយកូនរបស់ជននោះនឹងទទួលសន្តតិកម្មបន្តទៀត ដោយសារតែមរណភាពរបស់ជននោះ ។ ចំពោះចំណុចនេះ ការណ៍ដែលចៅរបស់មតកជនអាចទទួលសន្តតិកម្មជាក់ស្តែង ឬ មិនអាច ដោយអាស្រ័យលើពេលមុន ឬ ពេលក្រោយនៃមរណភាពរបស់កូនមតកជន មិនមានភាពសមរម្យទេ ហេតុនេះហើយបានជាចាំបាច់បង្កើតរបបសន្តតិកម្មជំនួសនេះ ។ ក្នុងករណីដែលកូនរបស់មតកជនបានបាត់បង់សិទ្ធិជាសន្តតិជន

[១] កថាខណ្ឌទី ១ នៃមាត្រា ១១៥៧ នេះ ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ដោយសារបានក្លាយជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ត្រូវបានផ្ដាច់មតិកពីសន្តតិជន ជាអាទិ៍ ទោះបីជាចំពោះសាមីខ្លួននេះ ការបាត់បង់សិទ្ធិ ជារឿងដែលមិនអាចជៀសវាងបានក៏ដោយ តែចំពោះកូនរបស់សាមីជននោះ ការបាត់បង់សិទ្ធិជាសន្តតិជនជាក់ស្ដែង ដោយគ្មានកំហុសអ្វីសោះនោះ ហាក់ដូចជាធ្ងន់ធ្ងរពេក ហេតុនេះហើយបានជាយើងទទួលស្គាល់ការធ្វើសន្តតិកម្មជំនួសនេះ ។ ការចែងថា "បានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្ម" គឺដើម្បីបញ្ចូលការទទួលមរណភាពព្រមគ្នាផងដែរ ។ ក្នុងករណីដែលបានទទួលមរណភាពព្រមគ្នា មិនអាចធ្វើសន្តតិកម្មទៅវិញទៅមកបានទេ (សូមមើលសេចក្ដីកំណត់នៅក្នុងមាត្រា ១១៤៥) ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលមតកជនសុំជនដែលមានកូន តាមសុំកូនធម្មតា កូនរបស់កូនសុំធម្មតានោះ មិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ ។ តែប្រសិនបើកូនរបស់កូនសុំធម្មតានោះបានកើតក្រោយការសុំកូនវិញ កូនដែលកើតនោះ ត្រូវជាបច្ឆាញាតិផ្ទាល់របស់មតកជន ហេតុនេះហើយ អាចទទួលសន្តតិកម្មជំនួសបាន ដោយយោងតាមបញ្ញត្តិនេះ ។

កថាខណ្ឌទី ២ ក្នុងករណីដែលអ្នកទទួលសន្តតិកម្មជំនួសមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌនេះ ឧទាហរណ៍ករណីដែលបុគ្គលទទួលសន្តតិកម្មជំនួសបានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្ម នោះគេអាចធ្វើសន្តតិកម្មជំនួសបន្តទៀត ហើយប្រសិនបើកូន និង ចៅរបស់មតកជនបានទទួលមរណភាព ចៅទួតនឹងទទួលសន្តតិកម្មជំនួស ។ ប្រសិនបើចៅទួតនេះមានមូលហេតុដូចគ្នា គេអាចទទួលស្គាល់សន្តតិកម្មជំនួសបន្តបន្ទាប់ទៀត ហេតុនេះហើយបានជាបន្ថែមពាក្យ "អនុវត្តជាបន្តបន្ទាប់" ។ម្យ៉ាងទៀត សន្តតិកម្មជំនួសជាបន្តបន្ទាប់នេះ អាចអនុវត្តចំពោះតែសន្តតិជនដែលជាកូនរបស់មតកជនប៉ុណ្ណោះ ។ ក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជនជាសន្តតិជនវិញ អាចទទួលស្គាល់នូវការធ្វើសន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ (សូមមើលសេចក្ដីកំណត់នៃមាត្រា ១១៦០) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៧ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៩៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៥៨.- ចំណែកមតិក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមតិក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមតិកដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមតិកដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួននោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

(កំណត់)

មាត្រានេះចែងថា ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស ត្រូវចែកស្មើភាគគ្នារវាងជនដែលទទួលសន្តតិកម្មជំនួស ។

មាត្រានេះបញ្ញត្តថា ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់ត្រូវទទួលបាន ហើយប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយនោះចំពោះចំណែកមត៌កដែលបុព្វញាតិផ្ទាល់នៃបច្ឆាញាតិនីមួយៗនោះត្រូវទទួលបាន ។ ឧទាហរណ៍ បើយើងពិចារណាលើករណីដែលមតកជនមានកូន ៣ នាក់ គឺ A B និង C ហើយ A បានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្ម ហើយ A មានកូនពីរនាក់គឺ D និង E ។ ក្នុងករណីនេះ ចំណែកមត៌ករបស់ A B C យោងតាមមាត្រា ១១៥៦ គឺទទួលសន្តតិកម្មស្មើគ្នាម្នាក់ ១ ភាគ ៣ ដូច្នេះ D និង E ដែលជាកូនរបស់ A ត្រូវទទួលនូវចំណែកស្មើៗគ្នាចំពោះចំណែកមត៌ក ១ ភាគ ៣ របស់ A ពោលគឺត្រូវជា ១ ភាគ ៦។ បានសេចក្ដីថា B និង C ទទួលសន្តតិកម្មម្នាក់ ១ ភាគ ៣ ហើយ D និង E ទទួលសន្តតិកម្មម្នាក់ ១ ភាគ ៦ ពីមតកជន ។ ម្យ៉ាងទៀត ប្រសិនបើ B បានទទួលមរណភាពដែរ ហើយមានកូនបីនាក់គឺ F G H កូនទាំងបីនាក់នេះ ត្រូវទទួលនូវចំណែកស្មើៗគ្នានៃចំណែកមត៌ក ១ ភាគ ៣ របស់ B ពោលគឺ F G និង H ម្នាក់ៗនឹងទទួលសន្តតិកម្មជំនួស ១ ភាគ ៩ ពីមតកជន។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៩៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៥៩.–** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

(កំណត់)

មាត្រានេះបញ្ញត្តថា បុព្វញាតិផ្ទាល់របស់មតកជនជាសន្តតិជនលំដាប់ទី ២ ។

ក្នុងករណីដែលមតកជនគ្មានឪពុកម្ដាយជាសន្តតិជន មានបញ្ហាមួយគឺ តើគួរឱ្យអាទិភាពទៅលើជីដូនជីតា ឬ បងប្អូនបង្កើត ។ ក្រមរដ្ឋប្បវេណីជប៉ុន ក៏ដូចក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាដែរ គេឱ្យអាទិភាពទៅលើជីដូនជីតា ។ ក៏ប៉ុន្តែ ប្រសិនបើយកតាមគោលគំនិតរបស់សន្តតិកម្មជំនួសវិញ ចំពោះឪពុកម្ដាយ ជាបឋម បងប្អូនបង្កើតរបស់មតកជន ទទួលសន្តតិកម្ម ក្នុងនាមជាកូនរបស់ឪពុកម្ដាយនោះ ហើយប្រសិនបើគ្មានបងប្អូនបង្កើតទេ នោះឪពុកម្ដាយរបស់ឪពុកម្ដាយ

នោះដែលជាជីដូនជីតារបស់មតកជន ត្រូវទទួលសន្តតិកម្ម ដូច្នេះ គេក៏អាចឱ្យបងប្អូនបង្កើតមានអាទិភាពក្នុងការទទួលសន្តតិកម្មបានដែរ (សូមបញ្ជាក់ថា ក្នុងមាត្រា ៧៥០ នៃក្រមរដ្ឋប្បវេណីបារាំង គេឱ្យឪពុកម្តាយ និង បងប្អូនបង្កើតមានលំដាប់ដូចគ្នា ហើយបងប្អូនបង្កើតមានអាទិភាពជាងជីដូនជីតា ។ ក្នុងមាត្រា ១៩២៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក៏ដូចក្រមរដ្ឋប្បវេណីបារាំងដែរ) ។ ប៉ុន្តែ នៅក្នុងមាត្រានេះ បុព្វញាតិផ្ទាល់គឺជាអ្នកដែលត្រូវគោរពបូជា ហេតុនេះហើយបានជាឱ្យអាទិភាពទៅលើជីដូនជីតាវិញ ។ ម្យ៉ាងទៀត ក្នុងករណីដែលឪពុករបស់មតកជនបានទទួលមរណភាព ហើយទោះបីជាជីដូនជីតាខាងឪពុកនោះនៅរស់ក៏ដោយ ប្រសិនបើម្តាយរបស់មតកជននោះនៅរស់ ម្តាយនោះជាអ្នកជិតជាងគេក្នុងថ្នាក់ញាតិ ដូច្នេះ ម្តាយគឺជាសន្តតិជនលំដាប់ទីពីរតែម្នាក់ឯង ។ ជីដូនជីតាខាងឪពុកមិនទទួលសន្តតិកម្មជំនួសឡើយ ។ ក្នុងករណីដូចគ្នានេះ ប្រសិនបើម្តាយរបស់មតកជនក៏បានទទួលមរណភាពដែរ នោះជីដូនជីតាខាងម្តាយ និង ជីដូនជីតាខាងឪពុក ត្រូវទទួលសហសន្តតិកម្ម ។ ប្រសិនបើជីដូន ឬ ជីតាខាងម្តាយណាម្នាក់បានទទួលមរណភាព បីនាក់ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា ។ ពេលធ្វើសន្តតិកម្មដោយបុព្វញាតិផ្ទាល់ គួរតែធ្វើការវិនិច្ឆ័យទៅតាមចំនួនអ្នកដែលចាំបាច់ត្រូវមានអាហារកាតព្វកិច្ចទើបសមរម្យ ដូច្នេះ មិនត្រូវធ្វើការបែងចែកចំណែកមត៌កដែលត្រូវបានធ្វើសន្តតិកម្មជំនួសទេ គឺត្រូវចែកមត៌កស្មើភាគគ្នាទៅតាមចំនួនមនុស្ស ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៩៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៦០.-** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

(កំណត់)

មាត្រានេះបញ្ញត្តថា បងប្អូនបង្កើតរបស់មតកជនជាសន្តតិជនលំដាប់ទី ៣ ហើយប្រសិនបើបងប្អូនបង្កើតបានទទួលមរណភាពហើយ នោះគេទទួលស្គាល់សន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ ។

ចំពោះកថាខណ្ឌទី ១ មិនចាំបាច់ពន្យល់ទេ ។

កថាខណ្ឌទី ២ បញ្ញត្តថា ក្នុងករណីដែលមានបងប្អូនបង្កើតច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ក៏ប៉ុន្តែ បងប្អូនបង្កើតដែលមានម្ដាយ ឬ មានឪពុកផ្សេងគ្នា ត្រូវបានទទួលពាក់កណ្ដាលនៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយទាំងសងខាងដូចគ្នា ។ ឧទាហរណ៍ ក្នុងករណីដែលមតកជន A គ្មានកូនទេ ហើយឪពុកម្ដាយឈ្មោះ B និង C បានទទួលមរណភាពហើយ ។ ឪពុកម្ដាយនេះ មានកូនឈ្មោះ D និង E ពីរនាក់ទៀត ក្រៅពី A ។ លើសពីនេះទៀត B មានកូនមួយផ្សេងទៀត ឈ្មោះ F មុននឹងរៀបអាពាហ៍ពិពាហ៍ជាមួយ C ។ ដូច្នេះ សន្តតិជនរបស់ A គឺ D E និង F ហើយចំណែកមត៌ករបស់ F គឺស្មើនឹងពាក់កណ្ដាលនៃចំណែករបស់ D និង E ហេតុនេះហើយ D និង E បានទទួលមត៌ក ម្នាក់ ២ ភាគ ៥ រីឯ F វិញ បានទទួលមត៌ក ១ ភាគ ៥ ។ ប្រសិនបើ F ជាកូនស្មុំធម៌តារបស់ C វិញ (ស្មុំកូនដែលជាកូនរបស់សហព័ទ្ធ) នោះ C ក្លាយជាម្ដាយរបស់ F តាមផ្លូវច្បាប់ដែរ ។ ដូច្នេះ F មានឪពុកម្ដាយរួមគ្នាជាមួយ D និង E ហេតុនេះហើយ D E និង F ត្រូវទទួលនូវចំណែកមត៌កស្មើគ្នា ។

កថាខណ្ឌទី ៣ បញ្ញត្តថា ក្នុងមាត្រា ១១៥៧ ស្ដីពីសន្តតិកម្មជំនួសនៃកូនរបស់មតកជន មានតែកថាខណ្ឌទី ១ ប៉ុណ្ណោះ ដែលត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនជាសន្តតិជន ។ រីឯកថាខណ្ឌទី ២ នៃមាត្រាដដែលនេះ ដែលទទួលស្គាល់នូវសន្តតិកម្មជំនួសជាបន្តបន្ទាប់វិញ មិនយកមកអនុវត្តចំពោះករណីនេះទេ ។ ដូច្នេះ សន្តតិកម្មជំនួសក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជនជាសន្តតិជន ត្រូវបានទទួលស្គាល់តែមួយតំណប៉ុណ្ណោះ ។ គេអាចទទួលស្គាល់សន្តតិកម្មជំនួសនោះ ដរាបណាមានបច្ចាញាតិផ្ទាល់ដែរ ក៏ប៉ុន្តែ ដោយសារសាច់ឈាមកាន់តែឆ្ងាយ ហើយមានការពិបាកនឹងរកសន្តតិជននោះផង ហេតុនេះហើយបានជាក្នុងនេះ យើងទទួលស្គាល់តែមួយតំណប៉ុណ្ណោះ ។

នៅក្នុងគន្លីនេះ ជនក្រៅពីនេះ ឧទាហរណ៍ ដូចជាពូមីង ឬ បងប្អូនជីដូនមួយ របស់មតកជនគ្មានសិទ្ធិទទួលសន្តតិកម្មទេ ។ នេះគឺដោយសារថា យោងតាមភាពជាក់ស្ដែង ទំនាក់ទំនងតាមអាពាហ៍ពិពាហ៍ជាក់ស្ដែង (មិនមែនតាមផ្លូវច្បាប់) ឬ ទំនាក់ទំនងបុគ្គភាពជាក់ស្ដែង មានចំនួនច្រើន ដូច្នេះ មិនគួរទទួលស្គាល់សន្តតិកម្មដោយយោងតែទៅលើទំនាក់ទំនងតាមផ្លូវច្បាប់មួយមុខនោះទេ គឺគួរតែចាត់ចែងការចែកមត៌កទៅដល់ជនដែលមាននិស្ស័យពិសេស ដែលអាចចាត់ចែងមត៌កដោយយោងតាមទំនាក់ទំនាក់ជាក់ស្ដែងជាមួយនឹងមតកជន (មាត្រា ១២៩៩) ផងដែរ ទើបជាការសមរម្យ ។

ម្យ៉ាងទៀត អាចមានករណីដែលមានលក្ខណសម្បត្តិជាឋានៈសន្តតិជនជាន់គ្នា ។ ឧទាហរណ៍ មតកជន A គ្មានកូនទេ ហើយ B ដែលជាឪពុក និង C ដែលជាម្ដាយរបស់ A នោះ មានកូន D និង E ពីរនាក់ទៀត ក្រៅពី A ។ ហើយ D មានកូនពីរ គឺ G និង H ក៏ប៉ុន្តែ G បានក្លាយជាកូនស្មុំធម៌តារបស់ B និង C ។ ប្រសិនបើឪពុក B ម្ដាយ C ព្រមទាំង D

បានទទួលមរណភាព សន្តតិជនរបស់ A គឺបងប្អូនបង្កើត D E និង G តែ D បានទទួលមរណភាពហើយ ដូច្នេះ G និង H ដែលត្រូវជាកូនរបស់ D ជាអ្នកទទួលសន្តតិកម្មជំនួស ។ ដូច្នេះ G ត្រូវទទួលសន្តតិកម្មពីមតកជនA ក្នុងឋានៈជាអ្នកមានលក្ខណសម្បត្តិជាបងប្អូនបង្កើត ព្រមទាំងលក្ខណសម្បត្តិជាសន្តតិជនជំនួសរបស់បងប្អូនបង្កើត ។ ហើយចំណែកមតិកដែលម្នាក់ៗបានទទួលគឺ E បាន ១ ភាគ ៣, H បាន ១ ភាគ ៦, G បាន ១ ភាគ ៣ បូកនឹង ១ ភាគ ៦ ត្រូវជា ៣ ភាគ ៦ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ សូមមើលមាត្រា ៨៨៩ កថាខណ្ឌទី ១ និង មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៩៦ កថាខណ្ឌទី ១ និង មាត្រា ៥០២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះកថាខណ្ឌទី ៣ សូមមើល មាត្រា ៨៨៩ កថាខណ្ឌទី ២ និង មាត្រា ៩០១ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## ផ្នែកទី ២ សន្តតិកម្មរបស់សហព័ន្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ន្ធ

១-សហព័ន្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ន្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ន្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ន្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

(កំណត់)

មាត្រានេះបញ្ញត្តទទួលស្គាល់នូវសិទ្ធិសន្តតិកម្មរបស់សហព័ន្ធ ទោះបីជាមាន ឬ គ្មានសន្តតិជនផ្សេងទៀតក៏ដោយ ។

កថាខណ្ឌទី ១ ទទួលស្គាល់ថា សហព័ន្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬ គ្មានសន្តតិជនផ្សេងទៀតក៏ដោយ ។ ក៏ប៉ុន្តែ ទោះបីជាសហព័ន្ធរបស់មតកជនក៏ដោយ ក្នុងករណីដែលជននោះជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ជាបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ ។ ពាក្យថា "ជានិច្ច" នៅក្នុងនេះមានន័យថា គ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេង ព្រមទាំងលំដាប់សន្តតិកម្មទេ ។ម្យ៉ាងទៀត នៅក្នុងមាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ទទួលស្គាល់សហព័ន្ធជាសន្តតិជន តែក្នុងករណីដែលមតកជនគ្មានបុព្វញាតិផ្ទាល់ បងប្អូនបង្កើត និង បច្ឆាញាតិផ្ទាល់របស់បងប្អូននោះតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ដោយយោងទៅតាមទស្សនៈសមភាពរវាងបុរស និង ស្ត្រី ជាអាទិ៍ មាត្រានេះទទួលស្គាល់ថា សហព័ន្ធជាសន្តតិជនជានិច្ច ។

បញ្ញត្តិនៃកថាខណ្ឌទី ២ មានន័យថា ក្រៅពីសហព័ន្ធ ប្រសិនបើមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ទី n សហព័ន្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននេះ ។ ឧទាហរណ៍ ក្នុងករណីដែលមតកជនមានកូន ឬ មានសន្តតិជន

ជំនួសកូននោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយបុគ្គលនោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលបុព្វញាតិផ្ទាល់របស់មតកជននោះ ដែលជាសន្តតិជនលំដាប់ទី ២ ទទួលសន្តតិកម្ម ក៏សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយបុគ្គលនោះដែរ ។ មាត្រានេះបញ្ញត្តសង្ខេបអំពីចំណុចទាំងអស់នេះ ។ ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនពីលំដាប់ទី ១ ដល់លំដាប់ទី ៣ ទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង ដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៦២.- ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីចំណែកមតិករបស់សន្តតិជន ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ។

ចំណុច ក បញ្ញត្តថា ក្នុងករណីដែលសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហព័ទ្ធ និង

កូននីមួយៗរបស់មតកជននោះ ត្រូវទទួលចំណែកមតិកស្មើគ្នា ។ ការកំណត់ឱ្យសហព័ទ្ធ និង កូនទាំងអស់មានចំណែកមតិកស្មើគ្នានេះ គឺដោយសារតែគិតពិចារណាទៅដល់ការចំណាយសម្រាប់ការរស់នៅ ជាអាទិ៍ ក្រោយពេលដែលមតកជនបានទទួលមរណភាព ។ ក្នុងករណីដែលកូនបានទទួលមរណភាព ហើយបុគ្គលទទួលសន្តតិកម្មជំនួសជាសន្តតិជន ចំណែកមតិកក៏ត្រូវបែកចែកស្មើគ្នាទៅតាមចំនួនកូនដែរ ។ ម្យ៉ាងទៀត ក្នុងក្រមរដ្ឋប្បវេណីជប៉ុន សហព័ទ្ធត្រូវទទួលចំណែក ១ ភាគ ២ នៃមតិក ដោយមិនគិតអំពីចំនួនកូនរបស់មតកជនទេ នេះគឺដោយសារតែ តាមច្បាប់ជប៉ុន ទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងទទួលបានក្នុងនាមខ្លួនផ្ទាល់ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាកម្មសិទ្ធិផ្ទាល់របស់អ្នកនោះ ហេតុនេះហើយទើបពេលទទួលមតិក សហព័ទ្ធត្រូវទទួលបានពាក់កណ្ដាល ។រីឯនៅក្នុងមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាវិញ ទ្រព្យសម្បត្តិដែលប្ដីប្រពន្ធរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាទ្រព្យសម្បត្តិរួម ម្ល៉ោះហើយ ទោះបីជាសហព័ទ្ធណាមួយបានទទួលមរណភាពក៏ដោយ ក៏ចំណែកនៃទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធដែលនៅរស់នោះ មិនត្រូវបានសន្តតិជនផ្សេងទៀតទទួលសន្តតិកម្មបានទេ ដោយសារតែទ្រព្យសម្បត្តិនេះជាទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលនៅរស់នោះ ។ ហេតុនេះហើយ ទោះបីជាការបែងចែកមតិកតាមវិធីខាងលើនេះក៏ដោយ ក៏គ្មានបញ្ហាអ្វីដែរ បើសិនជាគិតអំពីសមភាពរវាងភេទទាំងពីរ ជាអាទិ៍ ។

ចំណុច ខ ចែងអំពីការចែកមតិក ក្នុងករណីដែលសហព័ទ្ធ និង ឪពុកម្ដាយរបស់មតកជន ជាសន្តតិជន ។ តាមធម្មតាឪពុកម្ដាយរបស់មតកជនមានតែពីរនាក់ទេ ដូច្នេះ ការចែងឱ្យបានទទួលស្មើភាគគ្នា ជាការគ្រប់គ្រាន់ហើយ ក៏ប៉ុន្តែ ក្នុងករណីដែលមតកជនជាកូនសុំតាមស្មុំកូនធម្មតា មតកជនអាចមានទាំងឪពុកម្ដាយបង្កើត និង ឪពុកម្ដាយចិញ្ចឹមថែមទៀត ប៉ុន្តែ ទោះជាក្នុងករណីបែបនេះក៏ដោយ ក៏សហព័ទ្ធគួរទទួលបានយ៉ាងតិច ១ ភាគ ៣ ដែរ ទើបជាការសមរម្យ ហេតុនេះហើយបានជាត្រូវបញ្ញត្តដូចចំណុច ខ នេះ ។

ចំណុច គ ចែងអំពីការចែកមតិកក្នុងករណីដែលសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបងប្អូនបង្កើត ជាសន្តតិជន ។ ក្នុងករណីនេះ សហព័ទ្ធត្រូវទទួលបាន ១ ភាគ ២ ហើយ ១ ភាគ ២ ទៀត ត្រូវបែងចែកឱ្យសន្តតិជនផ្សេងទៀត ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ការសម្រួលចំណែកមតិក

**មាត្រា ១១៦៣.–** ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃ

ជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

(កំណត់)

មាត្រានេះចែងឡើងក្នុងគោលបំណងសម្រួលនូវចំណែកមតិកសម្រាប់អ្នកទទួលផលប្រយោជន៍ពិសេស ក្នុងករណីដែលក្នុងចំណោមសន្តតិជនទាំងអស់ មានជនដែលបានទទួលទ្រព្យដោយប្រទានកម្ម ជាអាទិ៍ នៅពេលដែលមតកជននៅរស់ ដើម្បីធ្វើឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងរវាងសហសន្តតិជន ។

កថាខណ្ឌទី ១ ចែងយ៉ាងច្បាស់លាស់អំពីចំណែកមតិក ក្នុងករណីដែលមានបុគ្គលទទួលផលប្រយោជន៍ពិសេស ។ ឧទាហរណ៍ ក្នុងករណីដែលសន្តតិជន A B និង C ត្រូវទទួលចំណែកស្មើភាគគ្នាពីក្នុងមតិកចំនួន ១000 ដុល្លារ ក៏ប៉ុន្តែ A បានទទួល ២00 ដុល្លារដោយប្រទានកម្ម ពេលដែលមតកជននៅរស់ ដូច្នេះ "ទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិក" គឺមតិកចំនួន ១000 ដុល្លារ ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម និង ២00 ដុល្លារ ដែល A បានទទួលដោយប្រទានកម្ម សរុបទៅ ១២00 ដុល្លារ ។ A B និងC ត្រូវទទួលបានស្មើភាគគ្នា គឺ ១ ភាគ ៣ នៃទ្រព្យ ចំនួន ១២00 ដុល្លារ ដែលត្រូវបានចាត់ទុកថាជាមតិកនោះ ត្រូវជា ៤00 ដុល្លារម្នាក់ ។ ក៏ប៉ុន្តែ A បានទទួល ២00 ដុល្លារដោយប្រទានកម្មរួចហើយ ដូច្នេះ A អាចទទួលតែ ២00 ដុល្លារ ថែមទៀតប៉ុណ្ណោះ ។ ដូច្នេះ ក្នុងករណីនេះ មតិកដែលមតកជនមានពេលចាប់ផ្តើមសន្តតិកម្ម ១000 ដុល្លារនោះ ត្រូវបែងចែកទៅឱ្យ A ចំនួន ២00 ដុល្លារ ហើយ B និង C ចំនួន ៤00 ដុល្លារម្នាក់ ។ ម្យ៉ាងទៀត ក្នុងកថាខណ្ឌទី ១ មានប្រើពាក្យ "អច្ច័យទាន" ប៉ុន្តែ ពាក្យនេះអាចអនុវត្តបានតែក្នុងករណីដែលមានភាពជាក់ច្បាស់ថា បំណងនៃអច្ច័យទានជាអច្ច័យទានដែលមានភ្ជាប់នូវបន្ទុក ជាអាទិ៍ ប៉ុណ្ណោះ ព្រោះថា ក្នុងករណីដែលមានមតកសាសន៍កំណត់ឱ្យធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់មួយចំនួន ចំពោះសន្តតិជនមតកសាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមតិករួចហើយ (មាត្រា ១១៨៥) ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើតម្លៃនៃផលប្រយោជន៍ពិសេស ស្មើ ឬ លើសតម្លៃនៃចំណែកមតិក សហសន្តតិជននោះមិនអាចទទួលនូវចំណែកមតិកនោះបានទេ ។ ចំពោះឧទាហរណ៍ខាងលើនេះ ប្រសិនបើ A បានទទួលប្រទានកម្មលើស ៥00 ដុល្លារ តម្លៃនៃផលប្រយោជន៍ពិសេសស្មើ ឬ លើសចំណែកមតិក (ក្នុងករណីដែលតម្លៃនៃប្រទានកម្មនោះស្មើនឹង ៥00 ដុល្លារ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិកនោះ គឺ ១៥00 ដុល្លារ ដូច្នេះ ចំណែកនៃមតិក

ដែលត្រូវបានចាត់ទុកនោះ គឺ ៥០០ ដុល្លារម្នាក់ ដែលស្មើនឹងទឹកប្រាក់ប្រទានកម្មមុនពេលទទួលមរណភាព) ដូច្នេះ A មិនអាចទទួលចំណែកមតិកទៀតទេ ។ ចំពោះចំណែកមតិកជាក់ស្តែងសម្រាប់សហសន្តតិជនផ្សេងទៀត ក្នុងករណីដែលតម្លៃនៃផលប្រយោជន៍ពិសេសលើសតម្លៃនៃចំណែកមតិក មានចែងក្នុងមាត្រា ១១៦៥ ។

ឧទាហរណ៍ខាងលើនេះមិនជាស្មុគស្មាញទេ ក៏ប៉ុន្តែ ឥឡូវយើងពិចារណាថា បើសន្តតិជន រួមមានសហព័ទ្ធរបស់មតកជនដែលនៅរស់ A ព្រមទាំងបងប្អូនបង្កើតរបស់មតកជន B និង C ហើយមតកជនមានមតិក ១០០០ ដុល្លារ នៅពេលចាប់ផ្តើមសន្តតិកម្ម ហើយ A បានទទួលផលប្រយោជន៍ពិសេស ៥០០ ដុល្លារ រីឯ B វិញ បានទទួលផលប្រយោជន៍ពិសេស ១០០ ដុល្លារ ។ ក្នុងករណីនេះ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិកទាំងអស់មាន ១៦០០ ដុល្លារ ដូច្នេះចំណែកមតិកចំពោះមតិកដែលត្រូវបានចាត់ទុកនេះ គឺ A បាន ១ ភាគ ២ ត្រូវជា ៨០០ ដុល្លារ ហើយ B និង C បានចំណែកស្មើភាគគ្នានៃ ១ ភាគ ២ ត្រូវជា ៤០០ ដុល្លារម្នាក់ ។ បន្ទាប់មក ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ពិសេស ត្រូវដកតម្លៃនៃផលប្រយោជន៍ពិសេសនោះ ដូច្នេះចំណែកមតិកជាក់ស្តែង គឺ A បាន ៣០០ ដុល្លារ B បាន ៣០០ ដុល្លារ ហើយ C បាន ៤០០ ដុល្លារ ។

ម្យ៉ាងទៀត មតកជនអាចកំណត់ចំណែកមតិកផ្សេងពីមាត្រានេះបាន ដោយមតកសាសន៍ (សូមមើលមាត្រា ១១៨២ និង សេចក្តីកំណត់នៃមាត្រានោះ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៩៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៦៤.–** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

(កំណត់)

មាត្រានេះចែងអំពីវិធីគណនាតម្លៃនៃប្រទានកម្ម ក្នុងករណីដែលអ្នកទទួលផលប្រយោជន៍ពិសេសបានចាត់ចែងទ្រព្យដែលបានទទួលដោយប្រទានកម្ម មុនពេលចាប់ផ្តើមសន្តតិកម្ម ឬ ក្នុងករណីដែលទ្រព្យនោះបានបាត់បង់ មុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ ។ ក្នុងករណីនេះ ត្រូវគណនាទៅតាមតម្លៃនៅពេលចាត់ចែង ឬ នៅពេលដែលបាត់ទ្រព្យនោះ ជាអាទិ៍ ។

ម្យ៉ាងទៀត តម្លៃកម្មវត្ថុនៃប្រទានកម្ម ឬ តម្លៃរូបិយវត្ថុអាចមានការផ្លាស់ប្តូរ ក៏ប៉ុន្តែ ក្នុងនេះ មិនមានចែងនូវវិធីគណនាក្នុងករណីនេះទេ ។ បញ្ហាទាំងនេះ មិនមែនជាបញ្ហាពិសេសពាក់ព័ន្ធនឹងសន្តតិកម្មទេ គឺអាចទាក់ទងទៅនឹងបញ្ហាផ្សេងទៀត ដូច្នេះ ត្រូវអាស្រ័យទៅលើការបកស្រាយ ។ នៅប្រទេសជប៉ុន ក្នុងករណីដែលតម្លៃនៃកម្មវត្ថុដែលបានទទួលដោយប្រទានកម្ម មានការផ្លាស់ប្តូរ មតិភាគច្រើនអះអាងថា ត្រូវគណនាទៅតាមតម្លៃដែលមាន នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ម្យ៉ាងទៀត យោងតាមសាលដីកានៃតុលាការកំពូលជប៉ុន ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៦ ប្រទានកម្មជាប្រាក់ ត្រូវគណនាដោយប្តូរតម្លៃប្រាក់នៅពេលទទួលប្រទានកម្មនោះ ទៅតាមតម្លៃរូបិយវត្ថុពេលចាប់ផ្តើមសន្តតិកម្ម ។

## **មាត្រា ១១៦៥.-** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសដែលសហសន្តតិជនបានទទួល លើសចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលទ្រព្យដែលទាក់ទងនឹងប្រទានកម្មនោះវិញដែរ ព្រមទាំងចែងច្បាស់លាស់នូវចំណែកមត៌ក

ជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀត ក្នុងករណីនេះផងដែរ ។

កថាខណ្ឌទី ១ ចែងថា ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសដែលសហសន្តតិជនបានទទួលលើសពីតម្លៃនៃចំណែកមតិកក៏ដោយ ក៏មិនចាំបាច់បង្វិលទ្រព្យដែលទាក់ទងនឹងប្រទានកម្មនោះវិញដែរ ។ មាត្រា ៦០០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាចែងថា ប្រសិនបើចំណែកមតិកតិចជាងតម្លៃនៃទ្រព្យដែលត្រូវបង្វិលទៅវិញ ត្រូវបង្វិលសងវិញនូវចំនួនដែលខ្វះ ។ ក៏ប៉ុន្តែ កថាខណ្ឌទី ១ នេះ បានជ្រើសរើសយកគោលនយោបាយនីតិកម្មផ្ទុយពីនេះ ។ ចំពោះការបង្វិលនូវចំណែកលើស ត្រូវប្រគល់ទៅឱ្យរបបកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោះស្រាយ ដោយគោរពតាមឆន្ទៈរបស់មតកជនកាលនៅរស់ ឬ ឆន្ទៈរបស់សហសន្តតិជន ។ សូមបញ្ជាក់ផងដែរថា មាត្រា ២០៥៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ក៏ចែងថាមិនចាំបាច់បង្វិលភាគលើសវិញដែរ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលមិនចាំបាច់ឱ្យបង្វិលនូវភាគលើសវិញទេ តម្លៃនៃចំណែកមតិកជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀត ដែលបានកំណត់នៅក្នុងមាត្រា ១១៦៥ កថាខណ្ឌទី ១ មានលើសតម្លៃមតិកដែលមាននៅពេលសន្តតិជនចាប់ផ្តើមសន្តតិកម្ម ដូច្នេះ ត្រូវគណនានូវតម្លៃនៃចំណែកមតិកជាក់ស្តែង ដោយបែងចែកមតិកដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មនោះ តាមសមាមាត្រនៃចំណែកមតិករបស់សន្តតិជនម្នាក់ៗ ។ ឧទាហរណ៍ សន្តតិជនមានបីនាក់គឺ A B និង C ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា នូវមតិកចំនួន ១០០០ ដុល្លារ ហើយប្រសិនបើនៅពេលដែលមតកជននៅរស់ A បានទទួល ១០០០ ដុល្លារ ហើយ B ក៏បានទទួល ៤០០ ដុល្លារដែរ តាមប្រទានកម្ម "ទ្រព្យដែលត្រូវបានជាត់ទុកថាជាមតិក" មានទាំងអស់ ២៤០០ ដុល្លារ ដូច្នេះ ចំណែកមតិកដែលសន្តតិជនម្នាក់អាចទទួលបាន គឺ ១ ភាគ ៣ នៃមតិកនោះ ដែលត្រូវជា ៨០០ ដុល្លារនៃទ្រព្យដែលត្រូវបានជាត់ទុកដថាជាមតិក ។ ក៏ប៉ុន្តែ A បានទទួល ១០០០ ដុល្លារ តាមប្រទានកម្មហើយ ដូច្នេះចំណែកមតិករបស់ A គឺ 0 ចំណែករបស់ B គឺ ៤០០ ដុល្លារ (៨០០-៤០០) ហើយចំណែករបស់ C គឺ ៨០០ ដុល្លារ ។ បូកសរុបទៅគឺ ១២០០ ដុល្លារ ហើយចំនួននេះ លើសចំនួនមតិក ១០០០ ដុល្លារដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ។ ហេតុនេះហើយ B និង C ត្រូវទទួលបាននូវចំណែកតាមសមាមាត្រ ៤០០ : ៨០០ នៃចំនួន ១០០០ ដុល្លារ ។ បានសេចក្តីថា B បានទទួលមតិក ៣៣៣ ដុល្លារ ហើយ C បានទទួលមតិក ៦៦៧ ដុល្លារ ។ម្យ៉ាងទៀត ក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើមានតែ A ទេ ដែលបានទទួល ៣០០០ ដុល្លារ ដោយប្រទានកម្ម ពេលមតកជននៅរស់ នោះ "ទ្រព្យដែលជាត់ទុកថាជាមតិក" ត្រូវមាន ៤០០០ ដុល្លារ ។ ដូច្នេះ A B និង C ត្រូវទទួលបាន ១៣៣៣ ដុល្លារម្នាក់ ។ ក្នុងករណីនេះ B និង C ត្រូវទទួលបាននូវចំណែកដែលជាសមាមាត្រ ១៣០០ : ១៣០០ នៃចំនួន ១០០០ ដុល្លារ គឺម្នាក់ៗអាចទទួលបាន ៥០០ ដុល្លារ ។ ក្នុងករណីនេះ ភាគបម្រុងគឺ ៦៦៧ ដុល្លារ (មាត្រា ១២៣៣) ដូច្នេះ B និង C អាចទាមទារឱ្យ A កាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ១៦៧ ដុល្លារ សម្រាប់ម្នាក់ៗបាន ។ ក្នុងករណីនេះ A ត្រូវបង្វិលសងវិញ ក៏ប៉ុន្តែ ប្រសិនបើ B ឬ C មិនបានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទេនោះ A មិនបាច់បង្វិលវិញក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៦០០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៦៦.-** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

(កំណត់)

មាត្រានេះចែងអំពីភាគនៃវិភាគទាន ។ ភាគនៃវិភាគទាននេះ ត្រូវបានចែងឡើងដើម្បីសម្រួលនូវចំណែកមតិក ។

ជាបឋម កថាខណ្ឌទី ១ ចែងអំពីមូលហេតុនៃកំណើតរបស់ភាគនៃវិភាគទានថាជាការដែល "បានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត" ។ ត្រឹមតែការផ្តល់វិភាគទានពិសេស (ឧទាហរណ៍ ការថែទាំព្យាបាល) ចំពោះមតកជនប៉ុណ្ណោះ គឺមិនគ្រប់គ្រាន់ឡើយ គឺទាមទារឱ្យមានការរក្សា ឬ កំណើននៃទ្រព្យរបស់មតកជននោះ ដោយសារវិភាគទាននោះផងដែរ (ឧទាហរណ៍ថា ដោយសារការថែរក្សាព្យាបាលនោះ មតកជនអាចបន្ថយការចំណាយក្នុងការជួលអ្នកមើលថែរក្សា ហើយនេះជាកត្តាមួយដែលអាចរក្សាទ្រព្យសម្បត្តិរបស់មតកជនបាន) ។ និយាយសង្ខេបទៅវិញគឺ យ៉ាងហោចណាស់ក៏ត្រូវមានវិភាគទានពិសេសកម្រិតដូចនេះដែរ ។ម្យ៉ាងទៀត ទោះជាបានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជនក៏ដោយ តែប្រសិនបើបានទទួលនូវតម្លៃថ្នូរវិញចំពោះសេវាកម្ម នោះមិនអាចចាត់ទុកជាវិភាគទានពិសេសបានទេ ។

បន្ទាប់មក កថាខណ្ឌទី ១ បានចែងអំពីវិធីសម្រួលនូវចំណែកនៃមតិក ក្នុងករណីដែលក្នុងចំណោមសហសន្តតិជនទាំងអស់ មានអ្នកធ្វើវិភាគទានពិសេស ។ ក្នុងករណីនេះ តម្លៃនៃមតិកដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយដកនឹងភាគនៃវិភាគទាន ត្រូវចាត់ទុកថាជាមតិក ហើយចំនួនទឹកប្រាក់នៃចំណែកមតិកដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងវិភាគទាន ត្រូវជាចំណែកមតិករបស់ជនដែលបានធ្វើវិភាគទានពិសេសនោះ ។ ឧទាហរណ៍ ក្នុងករណីដែលមានសន្តតិជន ៣ នាក់ A B និង C ដែលត្រូវទទួលសន្តតិកម្មស្មើភាគគ្នា ទៅលើមតិកចំនួន ១000 ដុល្លារ ប្រសិនបើ A បានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជនដែលមានតម្លៃស្មើនឹង ៤00 ដុល្លារ ពេលនោះ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិកគឺ ៦00 ដុល្លារ (១000-៤00) ហើយត្រូវបែងចែកមតិកនោះស្មើភាគគ្នា ។ ចំពោះចំណែកមតិកជាក់ស្តែងរបស់ A ត្រូវបូកបន្ថែមនូវភាគនៃវិភាគទានចំនួន ៤00 ដុល្លារទៀត ដូច្នេះ A បាន ៦00 ដុល្លារ B និង C បាន ២00 ដុល្លារម្នាក់ ។

កថាខណ្ឌទី ២ ចែងថា សហសន្តតិជនត្រូវកំណត់តម្លៃនៃភាគវិភាគទានដោយការពិភាក្សា នៅពេលបែងចែកមតិក ក៏ប៉ុន្តែ ប្រសិនបើក្នុងករណីដែលការពិភាក្សានេះមិនចុះសម្រុងគ្នា ជាអាទិ៍ ត្រូវឱ្យតុលាការកំណត់ ។ ចំពោះករណីនេះភាគច្រើន ការបែងចែកមតិក ជាអាទិ៍ នេះ ក៏មិនសូវមានការចុះសម្រុងគ្នាទេ ដូច្នេះ ជាទូទៅ ពេលដាក់ពាក្យសុំឱ្យធ្វើការវិនិច្ឆ័យនូវការបែងចែកមតិក គេច្រើនតែសុំឱ្យតុលាការកំណត់តម្លៃនៃភាគវិភាគទានព្រមគ្នាដែរ ដោយយោងតាមកថាខណ្ឌទី ២ ។ ក្នុងករណីដែលសហសន្តតិជនទាំងអស់អាចធ្វើការបែងចែកមតិកបានដោយខ្លួនឯង បន្ទាប់ពីបានកំណត់តម្លៃនៃភាគនៃវិភាគទានរួចរាល់ នោះគេអាចដាក់ត្រឹមតែពាក្យសុំក្នុងកថាខណ្ឌទី ២ ឱ្យតុលាការកំណត់បាន ក៏ប៉ុន្តែករណីបែបនេះ កម្រមានណាស់ ។ ចំពោះក្រមរដ្ឋប្បវេណីជប៉ុន មានបញ្ញត្តិថា មិនឱ្យធ្វើការទាមទារឱ្យតុលាការធ្វើការកំណត់តែភាគនៃវិភាគទានដាច់ដោយឡែកទេ ( មាត្រា ៩0៤-២ កថាខណ្ឌទី ៤ ) ។

កថាខណ្ឌទី ៣ ចែងអំពីការកម្រិតនៃតម្លៃនៃភាគវិភាគទាន ក្នុងករណីដែលមានមតកសាសន៍ ។ យោងតាម

បញ្ញត្តិនេះ តម្លៃនៃភាគវិភាគទាននេះ មិនអាចលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន ជាអាទិ៍ពីចំនួនតម្លៃនៃមតិកដែលមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ គឺមតកសាសន៍មានអាទិភាពជាងភាគនៃវិភាគទាន ។ ឧទាហរណ៍ ចំពោះករណីខាងលើនេះ ប្រសិនបើមតកជនបានទុកមតកសាសន៍ឱ្យ B ស្នងទ្រព្យស្មើនឹង ៣០០ ដុល្លារ ហើយឱ្យ C ស្នងទ្រព្យស្មើនឹង ៤០០ ដុល្លារ ហើយទោះបីជាតម្លៃនៃភាគវិភាគទានរបស់ A មាន ៤០០ ដុល្លារ ក៏ដោយ ក៏មិនអាចគិតឱ្យលើស ៣០០ ដុល្លារ ដែលជាចំនួនគណនាដោយយក ១០០០ ដុល្លារ ដកនឹង ៣០០ ដុល្លារ ហើយដកនឹង ៤០០ ដុល្លារទេ ។ ភាគនៃវិភាគទានមាននាទីសម្រួលក្នុងការបែងចែកមតិក ដូច្នេះប្រសិនបើមានមតកសាសន៍កំណត់នូវម្ចាស់នៃទ្រព្យ ទ្រព្យនោះត្រូវផ្ទេរទៅម្ចាស់នោះ ព្រមជាមួយគ្នានឹងពេលដែលមតកសាសន៍បង្កើតអានុភាព (មាត្រា ១១៩៥ ជាដើម) ។ ដូច្នេះ ទ្រព្យនោះលែងជាកម្មវត្ថុនៃការបែងចែកមតិកហើយ ហេតុនេះបានជាកថាខណ្ឌទី ៣ ចែងឱ្យមតកសាសន៍មានអាទិភាពជាងភាគនៃវិភាគទាននោះ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៩០៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ម្យ៉ាងទៀត នៅក្នុងមាត្រា ៦០៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មានចែងអំពីភាគនៃវិភាគទាននេះ ជាសិទ្ធិទាមទារឱ្យបង្វិលវិញ ។ ក្នុងករណីដែលចែងជាសិទ្ធិទាមទារឱ្យបង្វិលមកវិញនោះ ប្រសិនបើអ្នកបានធ្វើវិភាគទានមិនមែនជាជនត្រូវបានសន្មតថាជាសន្តតិជនទេ ក៏មានបញ្ហាថា តើគួរឱ្យអ្នកនោះមានសិទ្ធិទាមទារឱ្យបង្វិលវិញដែរ ឬទេ ដូច្នេះបញ្ញត្តិនេះ ត្រូវបានរៀបចំឡើង ក្នុងផ្នែកស្តីពីការសម្រួលចំណែកមតិក ដើម្បីកុំឱ្យមានបញ្ហានេះកើតមានឡើង ។

## មាត្រា ១១៦៧.– ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

(កំណត់)

មាត្រានេះចែងច្បាស់លាស់ថា ចំពោះការសម្រួលនៃចំណែកមតិក ប្រសិនបើគ្មានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមតិកដោយផ្អែកលើការសម្រួលនោះទេ មិនអាចតតាំងនឹងតតិយជនបានឡើយ ។

ដូចដែលបានពន្យល់ក្នុងមាត្រា ១១៤៨ រួចមកហើយ ចំពោះទំនាក់ទំនងនឹងតតិយជន សហសន្តតិជនត្រូវទទួលសន្តតិកម្ម ទៅតាមសមាមាត្រនៃចំណែកមតិកដែលកំណត់ដោយច្បាប់ ។ ម្យ៉ាងវិញទៀត ការសម្រួលនៃចំណែកមតិកដោយផ្អែកលើផ្នែកទី ៣ នេះ ត្រូវបានបង្កើតឡើងដើម្បីឱ្យមានសមភាពពិតប្រាកដរវាងសហសន្តតិជនទាំងអស់ នៅពេលធ្វើការបែងចែកមតិក ។ ប៉ុន្តែ តតិយជនសឹងតែមិនអាចដឹងនូវសមាមាត្រជាក់ស្តែងនេះទេ ហេតុនេះហើយបានជាក្នុងនេះ

ចាំបាច់ចែងថា ប្រសិនបើគ្មានល័ក្ខខ័ណ្ឌតតាំងនឹងលទ្ធផលនៃការបែងចែកមតិកទេ មិនអាចតតាំងនឹងតតិយជនបានឡើយ ។ ចំពោះលទ្ធផលនៃការបែងចែកមតិក បញ្ញត្តិនៃមាត្រា ១២៧៣ ក៏ដូចនឹងបញ្ញត្តិនៃមាត្រានេះដែរ ក៏ប៉ុន្តែ មាត្រានេះបញ្ញត្តផ្ទាល់អំពីចំណែកមតិកជាក់ស្តែង ដែលជាបុរេល័ក្ខខ័ណ្ឌនៃការបែងចែកមតិក ។ ជាលទ្ធផលនៃមាត្រានេះ ប្រសិនបើសហសន្តតិជនណាម្នាក់បានទទួលចំណែកមតិកស្មើនឹងសូន្យ ដោយសារតែបានទទួលប្រទានកម្មច្រើន នៅពេលដែលមតកជននៅរស់ ហើយបានចាត់ចែងលក់ឱ្យតតិយជននូវចំណែកមតិកដែលត្រូវបានកំណត់តាមច្បាប់ ប្រសិនបើមានការចុះបញ្ជី ឬ ល័ក្ខខ័ណ្ឌតតាំងអំពីការចាត់ចែងនេះ មុនការចុះបញ្ជី ឬ ល័ក្ខខ័ណ្ឌតតាំងអំពីលទ្ធផលនៃការបែងចែកមតិក តតិយជននោះនឹងទទួលនូវចំណែករួមនោះ ដោយមានអាទិភាព ។ ក្នុងករណីនេះ សហសន្តតិជននេះ ត្រូវតែទទួលខុសត្រូវសងសំណងចំពោះសន្តតិជនផ្សេងទៀត ។

## ជំពូកទី ៣ សន្តតិកម្មតាមមតកសាសន៍

## ផ្នែកទី ១ សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

(កំណត់)

មាត្រានេះចែងថា បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

ជាបឋម កថាខណ្ឌទី ១ ចែងថា បុគ្គលដែលជានីតិជនអាចធ្វើមតកសាសន៍បាន ។ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកនៅក្រោមហិតូបត្ថម្ភ ដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាល ឬ ហិតូបត្ថម្ភក៏ដោយ (មាត្រា ២៤, មាត្រា ២៨) ក៏អាចធ្វើមតកសាសន៍បានដែរ ។ ក៏ប៉ុន្តែ ដើម្បីធ្វើមតកសាសន៍ ជនទាំងនេះត្រូវមានសមត្ថភាពខាងឆន្ទៈ (មាត្រាបន្ទាប់) ហើយចំពោះការធ្វើមតកសាសន៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅដោយផ្អែកទៅតាមមាត្រា ១១៧៦ ជននោះត្រូវសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ នាក់ ។ ការទទួលស្គាល់ឱ្យអ្នកដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ឱ្យធ្វើមតកសាសន៍នេះ ដោយសារតែមតក-

សាសន៍នោះនឹងមានអានុភាព ក្រោយពេលដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះបានទទួលមរណភាព ដូច្នេះ អានុភាពនៃមតកសាសន៍នោះ មិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ ម្យ៉ាងទៀត មតកសាសន៍ ធ្វើឡើងដើម្បីចាត់ចែងទ្រព្យសម្បត្តិដែលមាន គឺមិនមែនដើម្បីឱ្យខ្ចីទ្រព្យថ្មីទៀត ជាអាទិ៍ ទេ ។ បន្ទាប់មក កថាខណ្ឌទី ១ ចែងថា អនីតិជនដែលបានអគ្គាធិនភាពរួចផុតពីអាណាព្យាបាល ឬ ពីអំណាចមេបា ក៏អាចធ្វើមតកសាសន៍បានដែរ ។ មាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន ចែងថា អនីតិជនដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ អាចធ្វើមតកសាសន៍បាន ក៏ប៉ុន្តែ ក្នុងក្រមនេះចែងទៅតាមមាត្រា ៥៣១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

ដោយសារជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើមតកសាសន៍បាន ដូច្នេះ កថាខណ្ឌទី ២ ចែងថា អ្នកអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈមិនអាចលុបមតកសាសន៍ចោលបានទេ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ សូមមើលមាត្រា ៥៣១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា រីឯចំពោះ កថាខណ្ឌទី ២ វិញ សូមមើលមាត្រា ៩៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ មាត្រា ៥៣២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងផ្ទុយនឹងវាក្យខ័ណ្ឌទី ១ នៃកថាខណ្ឌទី ១ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាង អំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបាន កំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃ ក្រមនេះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈនៅពេលធ្វើមតកសាសន៍ ហើយចែងអំពីការទទួលខុស ត្រូវក្នុងការបញ្ជាក់អំពីសមត្ថភាពនោះ ។

កថាខណ្ឌទី ១ ចែងថា ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ នៅពេលធ្វើមតកសាសន៍ ។ ឧទាហរណ៍ ក្នុងករណី ដែលម្ចាស់បណ្តាំគ្មានសមត្ថភាពខាងឆន្ទៈពេលធ្វើមតកសាសន៍ ដោយសារតែអ្នកនោះស្រវឹងស្រាខ្លាំង ឬ ដោយសារ អ្នកនោះមានជម្ងឺវង្វេងដោយភាពចាស់ជរា មតកសាសន៍ត្រូវជាមោឃៈ ។

កថាខណ្ឌទី ២ ចែងថា បុគ្គលដែលបានអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់អំពីកាខ្វះ សមត្ថភាពនោះ ។ ក្នុងករណីដែលបានក្លាយជានីតិជន ហើយមិនបានទទួលការប្រកាសឱ្យចាប់ផ្តើមអាណាព្យាបាលទេ

ត្រូវសន្មតថា អ្នកនោះមានសមត្ថភាពខាងឆន្ទៈ ។ ដូច្នេះ បុគ្គលណាដែលអះអាងថា មានបញ្ហាអំពីសមត្ថភាពខាងឆន្ទៈនេះ ត្រូវធ្វើការបញ្ជាក់ចំពោះការអះអាងនោះ ។ ប៉ុន្តែ ចំពោះជនដែលទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលវិញ ត្រូវសន្មតថា ជននោះស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមាននិបត្តិផ្នែកបញ្ញាស្មារតី ( មាត្រា ២៤) ហើយដើម្បីធ្វើមតកសាសន៍ ត្រូវបំពេញល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១១៧៦ ហេតុនេះហើយ បុគ្គលដែលបានអះអាងថា ជននោះមានសមត្ថភាពខាងឆន្ទៈ ឬ បានអះអាងថា បានបំពេញល័ក្ខខ័ណ្ឌនៃមាត្រា ១១៧៦ ពេលធ្វើមតកសាសន៍ ត្រូវធ្វើការបញ្ជាក់ ។

( មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ហើយចំពោះកថាខណ្ឌទី ២ វិញ សូមមើលមាត្រា ៩៣៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## ផ្នែកទី ២ ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.-** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

( កំណត់)

មាត្រានេះចែងអំពីភាពចាំបាច់នៃទម្រង់មតកសាសន៍ ដែលតម្រូវឱ្យធ្វើតាមទម្រង់ណាមួយដែលកំណត់ដោយក្រមនេះ ។

កថាខណ្ឌទី ១ ចែងថា មតកសាសន៍អាចធ្វើបានតែក្នុងករណីដែលបានធ្វើតាមទម្រង់ដែលមានចែងក្នុងក្រមនេះប៉ុណ្ណោះ ។ ចំពោះមតកសាសន៍ ការកំណត់ឱ្យធ្វើតាមទម្រង់ដូចនេះ ក៏ព្រោះថា ប្រសិនបើអានុភាពនៃមតកសាសន៍នឹងក្លាយជាបញ្ហា ក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព គេមិនអាចធ្វើការបញ្ជាក់ចំពោះម្ចាស់បណ្តាំថា តើ

មតកសាសន៍នោះបានធ្វើដោយសាមីខ្លួនមែន ឬ យ៉ាងណា ឬ ថាតើមានការផ្លាស់ប្តូរ ឬ ការលុបចោល ជាអាទិ៍ នូវមតកសាសន៍នោះ ឬ យ៉ាងណានោះទេ ។ ហេតុនេះហើយបានជាចាំបាច់ត្រូវធ្វើការកំណត់ថា មតកសាសន៍អាចធ្វើបានតែក្នុងករណីដែលបានធ្វើឡើងតាមទម្រង់មួយដែលអាចវិនិច្ឆ័យជាស្វ័យប្រវត្តិថា សាមីខ្លួនបានធ្វើ បើទោះជានៅក្រោយពេលដែលសាមីខ្លួនបានទទួលមរណភាពហើយក្តី ។

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២ ចែងឡើងដើម្បីបញ្ជាក់នូវលទ្ធផលដែលនឹងកើតមានឡើងតាមទ្រឹស្តីបញ្ញត្តិក្នុងកថាខណ្ឌទី ១ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ចែងថា ចំពោះមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ តែត្រឹមត្រូវតាមចំណុចផ្សេងៗទៀតនៃទម្រង់ ត្រូវចាត់ទុកថា មានសុពលភាព ដោយមានល័ក្ខខ័ណ្ឌកំណត់មួយ ។ "មតកសាសន៍គ្មានចុះថ្ងៃខែឆ្នាំ" មានរួមទាំងមតកសាសន៍ដែលគ្មានថ្ងៃខែឆ្នាំសោះ ឬ ខ្វះថ្ងៃ ឬ ខែ ឬ ឆ្នាំ (មតកសាសន៍ដែលចុះថា ថ្ងៃដ៏ល្អមួយ ខែ 00 ឆ្នាំ 0000 ក៏ជាមតកសាសន៍ខ្វះថ្ងៃខែឆ្នាំដែរ) ឬ មតកសាសន៍ដែលចុះថ្ងៃទី ២៩ កុម្ភៈ ឆ្នាំ 0000 ក៏ប៉ុន្តែ ឆ្នាំនោះមានត្រឹមតែ ២៨ ថ្ងៃ ជាអាទិ៍ ។ ចំពោះមតកសាសន៍ទាំងនោះ ប្រសិនបើមានតែមួយទេ មតកសាសន៍នោះមានសុពលភាព ហើយក្នុងករណីដែលមានច្រើនក៏ដោយ ប្រសិនបើមតកសាសន៍ទាំងនោះគ្មានចំណុចផ្ទុយគ្នាទៅវិញទៅមកទេ ក៏មានសុពលភាពទាំងអស់ដែរ ។ ក៏ប៉ុន្តែ ប្រសិនបើមានមតកសាសន៍ច្រើនដែលគ្មានចុះថ្ងៃខែឆ្នាំ ហើយដែលមានចំណុចផ្ទុយនឹងគ្នា ដោយសារតែមិនដឹងថា មួយណាធ្វើមុន មួយណាធ្វើក្រោយ ដូច្នេះ អានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។ ប្រសិនបើមានមតកសាសន៍ដែលមានថ្ងៃខែឆ្នាំ និង មតកសាសន៍ដែលគ្មានថ្ងៃខែឆ្នាំ មតក-សាសន៍ដែលមានថ្ងៃខែឆ្នាំ មានអាទិភាពជាង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥៤ និង ៥៦១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ សូមមើលមាត្រា ៥៦០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## មាត្រា ១១៧១.- សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលមតកសាសន៍ត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ មតកសាសន៍នោះត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់នោះ ។

ឧទាហរណ៍ ម្ចាស់បណ្តាំចង់ធ្វើមតកសាសន៍សម្របទៅនឹងទម្រង់ណាមួយ ដូចជាទម្រង់នៃមតកសាសន៍ដោយលិខិត

សម្ងាត់ ក៏ប៉ុន្តែ ខ្វះល័ក្ខខ័ណ្ឌ ដូច្នេះ មកតសាសន៍នោះ នឹងគ្មានសុពលភាពចំពោះទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ទេ ។ ក៏ប៉ុន្តែ ប្រសិនបើមតកសាសន៍នោះ ស្របនឹងល័ក្ខខ័ណ្ឌនៃទម្រង់ផ្សេងទៀត ឧទាហរណ៍ដូចជាមតកសាសន៍ដោយលិខិតឯកជនវិញ មតកសាសន៍នោះត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

(មាត្រាពាក់ព័ន្ធ)

នេះជាបញ្ញត្តិថែងទូទៅ តាមខ្លឹមសារនៃមាត្រា ៩៧១ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិត របស់សារការីនោះ ។

(កំណត់)

មាត្រានេះចែងថា បុគ្គលដែលមានទំនាក់ទំនងកំណត់មួយនឹងជនដែលត្រូវបានសន្មតថាជាសន្តតិជន មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍ទាក់ទងនឹងមតកសាសន៍បានឡើយ ។

ចំណុច ក ចែងថា បុគ្គលដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ជាអ្នកខ្វះលក្ខណសម្បត្តិធ្វើជាសាក្សីជាអាទិ៍ ។ សាក្សីជាអ្នកធ្វើការបញ្ជាក់ថា តើមតកជនសាមីខ្លួនបានធ្វើមតកសាសន៍ពិតមែន ឬទេ ដូច្នេះ អនីតិជនព្រមទាំងជននៅក្រោមអាណាព្យាបាលទូទៅ ខ្វះលក្ខណសម្បត្តិជានិច្ច ដោយសារជនទាំងនោះមានបញ្ហាខាងសមត្ថភាពក្នុងការធ្វើការបញ្ជាក់នេះ ។

ចំណុច ខ ចែងថា ជនដែលនឹងទទួលនូវផលប្រយោជន៍ផ្ទាល់ដោយមតកសាសន៍ និង សហព័ទ្ធរបស់ជននោះព្រមទាំងញាតិលោហិតខ្សែផ្ទាល់របស់ជននោះ ជាជនខ្វះលក្ខណសម្បត្តិធ្វើជាសាក្សី ជាអាទិ៍ ។ តាមមតកសាសន៍ ជនដែលត្រូវបានសន្មតថាជាសន្តតិជន អាចទទួលមតិកច្រើនជាងចំណែកមតិករបស់ខ្លួនដែលកំណត់ដោយច្បាប់ ឬ ផ្ទុយទៅវិញអាចទទួលតិចជាង រីឯអច្ច័យលាភីវិញ អាចក្លាយជាអ្នកទទួលមតិក ដូច្នេះ ដោយសារតែទំនាក់ទំនងផលប្រយោជន៍ទាំងនេះ នឹងអាចបង្កើតឱ្យមានបញ្ហាចំពោះសុក្រឹតភាពនៃចម្លើយជាកសិណសាក្សី ។ ដូច្នេះហើយ បានជាចំណុច ខ ចែងថា

ជនទាំងនេះជាអ្នកខ្វះលក្ខណសម្បត្តិជាសាក្សី ជាអាទិ៍ ទាំងអស់ ។ ម្យ៉ាងទៀត ចំពោះសហព័ទ្ធ ព្រមទាំងញាតិលោហិតខ្សែផ្ទាល់របស់ជននោះ ក៏មានបញ្ហាដូចគ្នាដែរ ដូច្នេះ បញ្ញត្តិនេះចែងថាជាអ្នកខ្វះលក្ខណសម្បត្តិដែរ ។ ម្យ៉ាងទៀត មុននឹងដាច់ដង្ហើម ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍តាមមាត្រា ១១៧៧ ដែលចែងអំពីមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតបាន ។ ក្នុងករណីនេះ នៅជុំវិញមតកជន អាចមានជនដែលត្រូវបានសន្មតថាជាសន្តតិជនច្រើននាក់នៅជួបជុំគ្នា ។ ក៏ប៉ុន្តែ ទោះជាក្នុងករណីនេះក៏ដោយ ក៏ត្រូវអនុវត្តតាមបញ្ញត្តិនៃចំណុច ខ ដែរ គឺជនដែលត្រូវបានសន្មតថាជាសន្តតិជនមិនអាចធ្វើជាសាក្សី ឬ អ្នកអង្កេតការណ៍បានទេ ។ ប្រសិនបើអនុញ្ញាតឱ្យជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍ សរសេរបណ្តាំដោយអះអាងថា ស្តាប់ដោយត្រឹមត្រូវនូវសម្តីរបស់មតកជន ដែលនឹងដាច់ដង្ហើមមែននោះ ហើយឱ្យបញ្ជាក់ថា ម្ចាស់បណ្តាំពិតជាបានផ្តាំដូចក្នុងមតកសាសន៍ នោះគឺជាការណ៍មួយប្រកបដោយគ្រោះថ្នាក់ធំធេងណាស់ ដូច្នេះ មិនអាចទទួលស្គាល់បានឡើយ ។ ក្នុងករណីដែលមិនមានវត្តមានតតិយជន សហសន្តតិជនទាំងអស់គួរត្រឹមតែយកសម្តីរបស់មតកជន៍នោះមកពិចារណាបានហើយ នៅពេលធ្វើការបែងចែកមតិក ។

ចំណុច គ ចែងថា ក្នុងករណីដែលសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិតរបស់សារការីនោះ ជាអ្នកខ្វះលក្ខណសម្បត្តិធ្វើជាសាក្សី ។ ពេលដែលសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ ចាំបាច់ត្រូវមានវត្តមានរបស់តតិយជនក្រៅពីសារការីនោះ ដើម្បីធានានូវភាពសុក្រឹត ។ ប្រសិនបើបុគ្គលដែលមានទំនាក់ទំនងកំណត់មួយនឹងសារការីនោះ ក្លាយជាសាក្សី នោះនឹងមានបញ្ហាអំពីភាពគ្មានលក្ខណៈជាតតិយជន ដូច្នេះ ចំណុច គ ចែងថា ជនទាំងនោះ ជាអ្នកខ្វះលក្ខណសម្បត្តិជាសាក្សី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៧៣.– មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្ដាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

(កំណត់)

មាត្រានេះចែងអំពីវិធីធ្វើមតកសាសន៍តាមលិខិតយថាភូត ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិប្រកាស ហើយកថាខណ្ឌទី ២ គឺជាបញ្ញត្តិស្ដីពីនីតិវិធីជាក់ស្ដែង ។

ចំពោះកថាខណ្ឌទី ២ ស្ដីពីនីតិវិធីជាក់ស្ដែងនេះ មិនចាំបាច់ពន្យល់ទេ ក៏ប៉ុន្តែ បញ្ញត្តិពិសេសស្ដីពីការធ្វើមតកសាសន៍ដោយលិខិតយថាភូត ក្នុងករណីដែលមតកជនជាមនុស្សមិនអាចនិយាយបាន ឬ ស្ដាប់មិនឮ មានចែងក្នុងមាត្រា ១១៧៩។ ម្យ៉ាងទៀត ចំពោះការ "ប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍" ដែលមានចែងក្នុងចំណុច ខ នេះ ជាទូទៅគឺជាការនិយាយប្រាប់សារការីនូវខ្លឹមសារនៃបណ្ដាំ ដែលម្ចាស់បណ្ដាំបានសរសេរព្រាង ជាអាទិ៍ រួចសារការីសរសេរបញ្ចូលក្នុងលិខិតយថាភូតនូវខ្លឹមសារទាំងនោះឱ្យមានន័យតាមផ្លូវច្បាប់ ។ យោងតាមក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥៥៧ ក្រមនេះទទួលស្គាល់ថា អនក្ខរជនក៏មានលក្ខណសម្បត្តិធ្វើជាសាក្សីដែរ ហើយវិធីចុះហត្ថលេខាក្នុងករណីនេះ មានចែងក្នុងមាត្រា ១១៨០ ។ ប៉ុន្តែ ដើម្បីឱ្យសាក្សីទទួលស្គាល់ថា កំណត់ត្រាជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវ ដោយយោងតាមចំណុច ឃ សាក្សីនោះមិនត្រឹមតែស្ដាប់តែខ្លឹមសារនៃមតកសាសន៍ដែលសារការីសូត្រឱ្យម្ចាស់បណ្ដាំ និង សាក្សីនោះស្ដាប់ ដូចបញ្ញត្តិក្នុងចំណុច គ ប៉ុណ្ណោះទេ គឺគួរតែពិនិត្យមើលនូវខ្លឹមសារដែលបានសរសេរនោះដែរ ។ ដូច្នេះហើយ គួរឱ្យអ្នកចេះអក្សរធ្វើសាក្សីទើបជាការប្រសើរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥៦ កថាខណ្ឌទី ១ និង មាត្រា ៥៥៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៧៤.–** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-

សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

(កំណត់)

មាត្រានេះចែងអំពីវិធីធ្វើមតកសាសន៍ដោយលិខិតឯកជន ។

កថាខណ្ឌទី ១ ចែងថា ដើម្បីធ្វើមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្ដាំត្រូវសរសេរមតកសាសន៍ទាំងមូល ព្រមទាំងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយចុះហត្ថលេខា ។ ពេលដែលមានបញ្ហាអំពីសុក្រឹតភាពនៃមតកសាសន៍នោះកើតឡើង ពេលនោះសាមីខ្លួនបានទទួលមរណភាពហើយ ដូច្នេះ គេមិនអាចទាមទារឱ្យម្ចាស់បណ្ដាំនោះធ្វើសេចក្ដីថ្លែងការណ៍បានទេ ហេតុនេះហើយពេលនោះចាំបាច់ត្រូវផ្ទៀងមើលអក្សរ ដោយធ្វើការប្រៀបធៀបនឹងអក្សររបស់សាមីខ្លួន ដែលបានសរសេរក្នុងលិខិតផ្សេងៗពេលនៅរស់ (ដូចជាសំបុត្រ ឬ សៀវភៅកំណត់ហេតុ ជាអាទិ៍) ។ ហេតុនេះហើយបានជាតម្រូវឱ្យម្ចាស់បណ្ដាំសរសេរខ្លឹមសារនៃមតកសាសន៍ និង ទាមទារឱ្យចុះហត្ថលេខា ជាអាទិ៍ ដោយសាមីខ្លួនផ្ទាល់ ។ ដូច្នេះ ប្រសិនបើសាមីខ្លួនចុះហត្ថលេខាដោយខ្លួនឯង មិនមានការអនុវត្តតាមមាត្រា ១១៨០ ទេ ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គ្រាន់តែចែងដើម្បីបញ្ជាក់តែប៉ុណ្ណោះ ។

កថាខណ្ឌទី ២ ចែងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា ដោយហេតុថា អាចមានករណីដែលតតិយជនផ្លាស់ប្ដូរ ដូចជាសរសេរបន្ថែម ឬ លុបចោលពាក្យខ្លះក្នុងមតកសាសន៍ ហេតុនេះហើយក្នុងករណីដែលម្ចាស់បណ្ដាំខ្លួនឯង ចង់ផ្លាស់ប្ដូរ ដូចជាសរសេរបន្ថែម ឬ លុបពាក្យខ្លះចោល ត្រូវសរសេរបញ្ជាក់នូវការផ្លាស់ប្ដូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខាផងដែរ ដើម្បីបញ្ជាក់មើលដោយផ្ទៀងប្រៀបធៀបនឹងលិខិតផ្សេងថា តើការផ្លាស់ប្ដូរ ដូចជាសរសេរបន្ថែម ឬ ការលុបចោល ជាអាទិ៍ ធ្វើដោយសាមីខ្លួនមែនឬទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

(កំណត់)

មាត្រានេះចែងអំពីវិធីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ ។

មតកសាសន៍ដោយលិខិតសម្ងាត់ គឺជាវិធីមតកសាសន៍មួយដែលអនុញ្ញាតឱ្យអ្នកចេះអក្សរធ្វើមតកសាសន៍ដោយរក្សាខ្លឹមសារនោះជាសម្ងាត់ទាំងស្រុង ហើយដែលអាចការពារកុំឱ្យមានការលុបចោល ឬ ការលួចកែប្រែដោយតតិយជន ។ ចំពោះមតកសាសន៍ដោយលិខិតឯកជន ក៏ដូចគ្នាដែរ គឺអាចបិទដោយប្រថាប់ត្រា ហើយប្រសិនបើតតិយជនបានបើកដោយមិនឆ្លងកាត់បញ្ជាក់តាមនីតិវិធីរបស់តុលាការទេ ត្រូវទទួលពិន័យស៊ីវិល ដូច្នេះ អាចលាក់ការសម្ងាត់បានខ្លះ ក៏ប៉ុន្តែអាចមានការលុបចោល ឬ កែប្រែដោយតតិយជនដែរ ។ ក៏ប៉ុន្តែ ចំពោះមតកសាសន៍ដោយលិខិតសម្ងាត់វិញ សារការីជាអ្នករក្សាទុក ដូច្នេះ ការបើក ការលុបចោល ការកែប្រែ មិនអាចកើតមានឡើងទេ ។

ដើម្បីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ ចាំបាច់ត្រូវអនុលោមតាមបញ្ញត្តិពីចំណុច ក ដល់ ចំណុច ឃ ។ វិធីនេះខុសពីមតកសាសន៍ដោយលិខិតឯកជន គឺម្ចាស់បណ្ដាំមិនចាំបាច់សរសេរនូវខ្លឹមសារនៃមតកសាសន៍ដោយខ្លួនឯងទេ គឺអាចពឹងឱ្យអ្នកផ្សេងដែលខ្លួនជឿទុកចិត្ត សរសេរជំនួស ឬ អាចប្រើម៉ាស៊ីនអង្គុលីលេខ ជាអាទិ៍ បាន ។ ក៏ប៉ុន្តែ ប្រសិនបើសរសេរដោយខ្លួនឯង និង ចុះថ្ងៃខែឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនផ្ទាល់ ទោះបីជាមិនស្របនឹងល័ក្ខខ័ណ្ឌនៃវិធីធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏មានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ (មាត្រា ១១៧១) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៧៦.-** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

(កំណត់)

មាត្រានេះចែងអំពីវិធីធ្វើមតកសាសន៍ក្នុងករណីដែលម្ចាស់បណ្ដាំជាជននៅក្រោមអាណាព្យាបាលទូទៅ ។

ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចមានពេលដែលបុគ្គលនោះបានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែរ ដូច្នេះ បញ្ញត្តិនេះទទួលស្គាល់នូវការធ្វើមតកសាសន៍ នៅពេលនោះ ។ មាត្រា ៩៥៤ ទទួលស្គាល់នូវអាពាហ៍ពិពាហ៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ ដូច្នេះ ចំពោះការធ្វើមតកសាសន៍ ក៏ត្រូវទទួលការពិចារណាដូចគ្នាដែរ ។ តែចាំបាច់ត្រូវមានគ្រូពេទ្យយ៉ាងតិច ២ នាក់ នៅពេលធ្វើមតកសាសន៍ ដើម្បីធ្វើការបញ្ជាក់មើលថា ម្ចាស់បណ្ដាំពិតជាបានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពធ្វើមតកសាសន៍ ដើម្បីជៀសវាងជម្លោះនៅពេលអនាគត ។ ប៉ុន្តែ ក្នុងករណីដែលអនីតិជនបានត្រូវប្រកាសឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ តាមមាត្រា ២៤ ហើយបានក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅ ជននោះមិនអាចអនុវត្តតាមមាត្រានេះបានទេ រហូតដល់ខ្លួនបានក្លាយជានីតិជន (សូមមើលមាត្រា ១១៦៨) ។

កថាខណ្ឌទី ២ ចែងអំពីកាតព្វកិច្ចរបស់គ្រូពេទ្យ ដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ។ នេះគឺដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការអនុវត្តតាមនីតិវិធី នៅក្នុងមតកសាសន៍នោះ ។ ម្យ៉ាងទៀត ចំពោះករណីដែលចាំបាច់មានវត្តមានរបស់សាក្សី ដូចជាការធ្វើមតកសាសន៍ដោយលិខិតយថាភូត ជាអាទិ៍ ត្រូវមានវត្តមានសាក្សីផ្សេង ក្រៅពីគ្រូពេទ្យផងដែរ ។ ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដោយលិខិតឯកជន ឬ ធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ នៅក្នុងករណីនីមួយៗនេះ ចាំបាច់ត្រូវមានវត្តមានរបស់គ្រូពេទ្យដែលមានចែងក្នុងកថាខណ្ឌទី ១ នៅពេលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នៅពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឱ្យសារការី ។

ម្យ៉ាងទៀត ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ ត្រូវអនុវត្តតាមមាត្រា ១១៩៧ ហើយប្រសិនបើបានធ្វើមតកសាសន៍ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍ គឺត្រូវមានកម្រិត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិពិសេសសម្រាប់ករណីដែលជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ធ្វើមតក-សាសន៍ ។

ទោះជាកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតក៏ដោយ ប្រសិនបើមានសមត្ថភាពធ្វើមតកសាសន៍ដោយលិខិតឯកជន ជននោះអាចធ្វើបាន ។ ម្យ៉ាងទៀត ប្រសិនបើមានពេលអាចហៅសារការីបាន ក៏អាចធ្វើមតកសាសន៍ដោយលិខិតយថាភូតដែរ ។ ក៏ប៉ុន្តែ អាចមានករណីដែលគ្មានសមត្ថភាព ឬ គ្មានពេលវេលា ពេលនោះម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់ ចំពោះមុខអ្នកមានវត្តមានបានដែរ ។ នីតិវិធីនេះមានចែងក្នុងកថាខណ្ឌទី ១ ។ គួរបញ្ជាក់

ផងដែរថា ក្នុងករណីនេះក៏ដោយ ជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍ មិនអាចធ្វើជាសាក្សី ឬ អ្នកសង្កេតការណ៍បានឡើយ (សូមមើលមាត្រា ១១៧២) ។

ដោយសារតែការធ្វើមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត គឺធ្វើតាមវិធីពិសេស កថាខណ្ឌទី ២ តម្រូវឱ្យមានការបញ្ជាក់ពីតុលាការក្នុងអំឡុងពេល ១ ខែ គិតពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ។ រីឯកថាខណ្ឌទី ៣ វិញ ជាបញ្ញត្តិចែងអំពីបទដ្ឋាននៃការវិនិច្ឆ័យរបស់តុលាការ ក្នុងករណីនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧៦ កថាខណ្ឌទី ១, ទី ៤ និង ទី ៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៧៨.–** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុង

ពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

(កំណត់)

មាត្រានេះចែងថា ជនដែលត្រូវជាប់ឃុំឃាំង ឬ នៅក្នុងនាវា ជាអាទិ៍ អាចធ្វើមតកសាសន៍ដោយវិធីដូចគ្នានឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូតដែរ ។ ជនទាំងនេះអាចធ្វើមតកសាសន៍ដោយលិខិតឯកជន ដោយយោងតាមមាត្រា ១១៧៤ បានដែរ ប៉ុន្តែ មានករណីខ្លះដែលមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ដោយសារជននោះជាអនក្ខរជន ឬ មានរបួសដៃ ហេតុនេះហើយបានជាចាំបាច់មានបញ្ញត្តិនេះ ។

កថាខណ្ឌទី ១ និង ទី ២ ចែងថា ជនដែលត្រូវជាប់ឃុំឃាំង ឬ ជនដែលនៅក្នុងនាវាអាចធ្វើមតកសាសន៍ តាមបញ្ញត្តិនៃមាត្រានេះបាន ហើយមាត្រានេះក៏ចែងអំពីជនដែលមានទំនាក់ទំនងនឹងករណីនេះដែរ ។

កថាខណ្ឌទី ៣ និង ទី ៤ ចែងថា ចំពោះករណីដែលបានធ្វើមតកសាសន៍តាមវិធីដែលបានបញ្ញត្តក្នុងមាត្រានេះ ជាគោលការណ៍ ត្រូវធ្វើតាមវិធីដូចគ្នានឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូត ដែលចែងក្នុងមាត្រា ១១៧៣ ហើយក្នុងករណីនេះ នគរបាល ជាអាទិ៍ មានតួនាទីជាសារការី ។ ម្យ៉ាងទៀត ក្នុងមាត្រានេះបានចែងថា ត្រូវអនុវត្តដូចគ្នានឹងមាត្រា ១១៧៣ ក៏ប៉ុន្តែ នគរបាល ជាអាទិ៍ មិនមែនជាសារការីទេ ដូច្នេះ មតកសាសន៍ដែលធ្វើឡើងតាមបញ្ញត្តិនៃមាត្រានេះ មិនមែនជាមតកសាសន៍ដោយលិខិតយថាភូតទេ ។ នេះគឺគ្រាន់តែអនុវត្តតាមវិធីធ្វើមតកសាសន៍ ដែលចែងក្នុងមាត្រា ១១៧៣ ប៉ុណ្ណោះ ។

កថាខណ្ឌទី ៥ ចែងអំពីអំឡុងពេលដែលមតកសាសន៍ធ្វើឡើងតាមមាត្រានេះមានសុពលភាព ។ មតកសាសន៍ដែលធ្វើឡើងតាមបញ្ញត្តិនៃមាត្រានេះ គឺជាមតកសាសន៍បណ្តោះអាសន្នតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត សភាពនេះក៏អាចមានដូចគ្នាចំពោះការធ្វើមតកសាសន៍ដែលមានចែងក្នុងមាត្រា ១១៧៧ ស្តីពីមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតដែរ ក៏ប៉ុន្តែ ដោយសារតែជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតនោះ មានការពិបាកនឹងរស់បានជាង ៦ ខែ ហើយម្យ៉ាងទៀត មានល័ក្ខខ័ណ្ឌទាមទារឱ្យមានការបញ្ជាក់ដោយតុលាការក្នុងអំឡុងពេល ១ ខែ។ ដូច្នេះហើយបានជានៅក្នុងមាត្រា ១១៧៧ គ្មានបញ្ញត្តិដូចគ្នានឹងបញ្ញត្តិក្នុងកថាខណ្ឌទី ៥ នេះទេ ។ ម្យ៉ាងទៀត កថាខណ្ឌនេះមិនបាននិយាយអំពីមតកសាសន៍ដោយលិខិតឯកជនទេ ។ នេះក៏ព្រោះថា តាមរយៈមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្តាំអាចលុបចោល ឬ ផ្លាស់ប្តូរនូវមតកសាសន៍ទាំងអស់ពេលណាក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧៧ និង មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

(កំណត់)

មាត្រានេះចែងអំពីបញ្ញត្តិពិសេស ជាអាទិ៍ ក្នុងការធ្វើមតកសាសន៍របស់បុគ្គលដែលមិនអាចនិយាយបាន ។

កថាខណ្ឌទី ១ ជាបញ្ញត្តិពិសេសសម្រាប់ករណីធ្វើមតកសាសន៍ដោយលិខិតយថាភូត ជាអាទិ៍ ដោយបុគ្គលដែលមិនអាចនិយាយបាន ហើយការប្រាប់នូវឆន្ទៈរបស់សាមីខ្លួនដល់សារការី អាចធ្វើឡើងដោយមានអ្នកបកប្រែភាសាសញ្ញា ឬ សរសេរដោយដៃខ្លួនផ្ទាល់ ដើម្បីជំនួសការប្រាប់សេចក្តីថ្លែងការណ៍ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិពិសេសសម្រាប់ករណីដែលម្ចាស់បណ្តាំ ឬ សាក្សី ជាមនុស្សថ្លង់ស្តាប់មិនឮ ។ ក្នុងករណីនេះ សារការី ឬ ជនផ្សេងទៀត ដែលត្រូវបានកំណត់ក្នុងក្រមនេះ ក្រោយពីបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍រួចរាល់ អាចប្រាប់អំពីខ្លឹមសារដែលបានសរសេរនោះ តាមរយៈការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ដើម្បីជំនួសការអានឱ្យស្តាប់ ។

កថាខណ្ឌទី ៣ ចែងអំពីការសរសេរនូវហេតុការណ៍ក្នុងលិខិតខាងលើនេះ ក្នុងករណីដែលបានធ្វើតាមនីតិវិធីទាំងនេះ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦៩-២, មាត្រា ៩៧២, មាត្រា ៩៧៦ កថាខណ្ឌទី ៣ និង មាត្រា ៩៧៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៨០.- ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្ដិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្ដិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

( កំណត់)

ដោយយោងទៅតាមទំនៀមទម្លាប់កម្ពុជា មាត្រានេះចែងថា អាចសរសេរនាមត្រកូល និង នាមខ្លួន និង ផ្ដិតម្រាមដៃ ជំនួសការចុះហត្ថលេខាបាន ក្នុងករណីដែលសារការី និង សាក្សីត្រូវចុះហត្ថលេខា ។

ដោយសារតែមានការចាំបាច់ត្រូវធ្វើការពិនិត្យផ្ទៀងមើលហត្ថលេខាសាមីខ្លួន ហេតុនេះហើយបានជាមិនអនុញ្ញាតឱ្យម្ចាស់បណ្ដាំផ្ដិតម្រាមដៃដែលជាវិធីសម្រួលនេះទេ ។

## មាត្រា ១១៨១.- បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតសម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

( កំណត់)

មាត្រានេះជាបញ្ញត្តិពិសេសចំពោះករណីដែលជនជាតិខ្មែរដែលរស់នៅបរទេសធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ ដោយលិខិតសម្ងាត់ ក្នុងចំណោមវិធីធ្វើមតកសាសន៍របស់កម្ពុជា ។

ជនជាតិខ្មែរ ទោះបីជានៅបរទេសក៏ដោយ ក៏អាចធ្វើមតកសាសន៍ដោយលិខិតឯកជន តាមមាត្រា ១១៧៤ បានដែរ។ ម្យ៉ាងទៀត គេក៏អាចធ្វើមតកសាសន៍តាមវិធីដែលប្រទេសនោះមាន នៅចំពោះមុខសារការីនៃប្រទេសនោះបានដែរ ហើយតាមផ្លូវច្បាប់ឯកជនអន្តរជាតិ វិធីមួយណាក៏នឹងត្រូវមានសុពលភាពដូចគ្នា ។ ក៏ប៉ុន្តែ ដើម្បីធ្វើមតកសាសន៍ នៅ

ចំពោះមុខសារការីបរទេសនោះ ជាទូទៅច្រើនតែត្រូវធ្វើដោយប្រើភាសាប្រទេសនោះ ហេតុនេះហើយ ដើម្បីអនុញ្ញាតឱ្យជនដែលមិនចេះភាសាបរទេស អាចមានលទ្ធភាពធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ ដោយលិខិតសម្ងាត់ជាភាសាខ្មែរបាន កុងស៊ុលកម្ពុជាត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តមុខនាទីរបស់សារការី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្ដីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

(កំណត់)

មាត្រានេះចែងថា មតកជនអាចធ្វើការកំណត់នូវចំណែកមតិកនៃសហសន្តតិជន ជាអាទិ៍ ដោយមតកសាសន៍ បាន ។

ជាបឋម កថាខណ្ឌទី ១ ចែងថា មតកជនអាចធ្វើការកំណត់នូវចំណែកមតិកនៃសន្តតិជន ដោយមតកសាសន៍បាន ។ ឧទាហរណ៍ ករណីដែលជនដែលត្រូវសន្មតថាជាសន្តតិជន គឺជាប្រពន្ធ និង កូនពីរនាក់ ចំណែកមតិកតាមផ្លូវច្បាប់គឺ ១ ភាគ ៣ ម្នាក់ ក៏ប៉ុន្តែ មតកជនអាចកំណត់ឱ្យអ្នកណាម្នាក់ ក្នុងចំណោមអ្នកទាំងនោះ ទទួលចំណែក ១ ភាគ ២ បាន ។ ចំណែកមតិកនៃសន្តតិជនដែលមតកជនកំណត់នេះ អាចហៅថា "ចំណែកមតិកតាមការកំណត់" ។ ការកំណត់ចំណែកមតិកអាចធ្វើដោយវិធីកំណត់នូវសមាមាត្រ ដូចជា ១ ភាគ ២ ជាអាទិ៍ ឬ ដោយវិធីកំណត់នូវទ្រព្យជាក់ស្ដែងណាមួយ (ឧទាហរណ៍ មតិកមានសរុបទាំងអស់ ១000 ដុល្លារ ហើយកំណត់ឱ្យសន្តតិជន A ទទួលសន្តតិកម្មជាដីដែលមានតម្លៃ ស្មើនឹង ៣៥0 ដុល្លារ និង ចលនទ្រព្យដែលមានតម្លៃស្មើនឹង ១៥0 ដុល្លារ ជាអាទិ៍) ។ ម្យ៉ាងទៀត មតកជនអាចបង្ហាញឆន្ទៈផ្សេងពីបញ្ញត្តិនៃមាត្រា ១១៦៣ ដែលចែងអំពីចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេសបាន ។ ឧទាហរណ៍ A, B និង

C ទទួលមតិកស្មើភាគគ្នា ហើយនៅពេលចាប់ផ្ដើមសន្តតិកម្ម មតិកមាន ១០០០ ដុល្លារ ប៉ុន្តែ A បានទទួលផលប្រយោជន៍ពិសេសចំនួន ៥០០ ដុល្លាររួចទៅហើយ ។ ដូច្នេះ ប្រសិនបើមិនមានមតកសាសន៍ទេ ចំណែកមតិកដែល A អាចទទួលបាន ជាក់ស្ដែងគឺ 0 ក៏ប៉ុន្តែ មតកជនអាចកំណត់ឱ្យ A ស្នងមតិកថែម ៣០០ ដុល្លារទៀតបាន ។ ក្នុងករណីនេះ ចំណែកមតិកជាក់ស្ដែងគឺ A បាន ៣០០ ដុល្លារ ហើយ B និង C ទទួលចំណែក ៣៥០ ដុល្លារម្នាក់ (សូមមើលមាត្រា ១១៦៥) ។ ក៏ប៉ុន្តែ តាមការកំណត់នេះ ក្នុងចំណោមសហសន្តតិជន អាចមានបុគ្គលខ្លះត្រូវគេបំពានទូវភាគបម្រុងរបស់ខ្លួន ។ ក្នុងករណីនេះ បុគ្គលដែលត្រូវគេបំពាននោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ដោយយោងតាមបញ្ញត្តិស្ដីពីភាគបម្រុង ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌនេះ ចែងបញ្ជាក់អំពីចំណុចនេះ ។

កថាខណ្ឌទី ២ ចែងអំពីវិធីកំណត់ចំណែកមតិកសម្រាប់សន្តតិជនផ្សេងទៀត ក្នុងករណីដែលមតកជនបានធ្វើការកំណត់ចំណែកមតិកសម្រាប់សហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់នោះ ។ វិធីកំណត់នេះ ត្រូវបានកំណត់ដោយបញ្ញត្តិនៃជំពូកទី ២ ផ្នែកទី ៣ ស្ដីពី "ការសម្រួលចំណែកមតិក" ។ ឧទាហរណ៍ សន្តតិជនមាន ៣ នាក់ គឺ A, B និង C រីឯមតិកមាន ១០០០ ដុល្លារ ហើយ A បានទទួលផលប្រយោជន៍ពិសេសចំនួន ៥០០ ដុល្លារ ហើយមតកជនបានកំណត់ចែកមតិកឱ្យ B ចំនួន ៨០០ ដុល្លារ ។ ក្នុងករណីនេះ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិក គឺ ១៥០០ ដុល្លារ (១០០០+៥០០) ហើយចំណែកមតិកគឺ ១៥០០÷៣=៥០០ ហេតុដូច្នេះ ភាគដែលត្រូវបានចាត់ទុកថាជាចំណែកមតិករបស់ A និង B គឺ 0 រីឯ C នឹងបាន ៥០០ ដុល្លារ (នេះក៏ព្រោះថា A បានទទួលផលប្រយោជន៍ពិសេសចំនួន ៥០០ ដុល្លារ រួចទៅហើយ ហើយ B នឹងបានទទួលចំណែកមតិកតាមការកំណត់ ចំនួន ៨០០ ដុល្លារ) ។ ក៏ប៉ុន្តែ ទ្រព្យដែលនៅសល់ ក្រោយពីដកចំណែកដែលកំណត់សម្រាប់ B នោះ មានតែ ២០០ ដុល្លារទេ ហេតុនេះហើយ C បានទទួលមតិកជាក់ស្ដែងតែ ២០០ ប៉ុណ្ណោះ (= ២០០×{(៥០០÷(៥០០+0+0)}) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៨៣.- ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្មនោះ បាន ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់ឱ្យមតកជនធ្វើការកំណត់ អំពីវិធីបែងចែកមតិក ជាអាទិ៍ ដោយមតកសាសន៍ ។

ជាបឋម មាត្រានេះចែងថា មតកជនអាចធ្វើការកំណត់នូវវិធីបែងចែកមតិកបាន ។ មតកជនអាចកំណត់ឱ្យ

សហសន្តតិជន A ស្នងដី a, ឱ្យ B ស្នងដី b, ឱ្យ C ស្នងប្រាក់ ឱ្យបានប្រហាក់ប្រហែលនឹងចំណែកមតិកដែលកំណត់ដោយច្បាប់ ជាអាទិ៍ បាន ។ ម្យ៉ាងទៀត មតកជនអាចធ្វើការកំណត់នូវវិធីបែងចែកមតិក និង កំណត់នូវចំណែកមតិក ព្រមគ្នាបាន ។ ទោះបីជាសហសន្តតិជន A, B និង C អាចទទួលសន្តតិកម្មតាមផ្លូវច្បាប់ ១ ភាគ ៣ ម្នាក់ក៏ដោយ ក៏អាចធ្វើការកំណត់ឱ្យ A ទទួលសន្តតិកម្មដីដែលមានតម្លៃស្មើនឹង ១០០០ ដុល្លារ ឱ្យ B ទទួលសន្តតិកម្មជាប្រាក់ ៥០០ ដុល្លារ និង ឱ្យ C ទទួលសន្តតិកម្មទ្រព្យនៅសល់ផ្សេងទៀត (ដែលមានតម្លៃស្មើនឹង ៨០០ ដុល្លារ) បាន ។

បន្ទាប់មក មាត្រានេះចែងទទួលស្គាល់នូវការប្រគល់អាណត្តិឱ្យតតិយជន កំណត់នូវការបែងចែកមតិក ។ ឧទាហរណ៍ ក្នុងករណីដែលកូនមិនទាន់គ្រប់អាយុជានីតិជន ការប្រគល់អាណត្តិឱ្យឪពុកបង្កើត (ត្រូវជាជីតារបស់សន្តតិជន) ធ្វើការកំណត់ការបែងចែកមតិក ។ ក៏ប៉ុន្តែ មិនអនុញ្ញាតឱ្យប្រគល់អាណត្តិ ឱ្យសហសន្តតិជនណាមួយបានទេ ។ ហេតុនេះហើយក្នុងនេះបានប្រើពាក្យ "តតិយជន" ។

ម្យ៉ាងទៀត មតកជនអាចហាមឃាត់មិនឱ្យបែងចែកមតិកក្នុងអំឡុងពេលមួយ ដែលមិនលើស ៥ ឆ្នាំបាន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ឧទាហរណ៍ដូចជា ការហាមឃាត់មិនទាន់ឱ្យបែងចែកមតិក ក្នុងករណីដែលកូនមួយចំនួនមិនទាន់គ្រប់អាយុជានីតិជន ជាដើម ។ អំឡុងពេលនេះត្រូវបានកំណត់ត្រឹម ៥ ឆ្នាំ ដោយសារតែដើម្បីតម្រូវទៅនឹងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ២១១ ស្តីពីការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៨៤.- អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់នូវការធ្វើប្រទានកម្មទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក តាមមតកសាសន៍(អច្ច័យទាន) ។

ម្ចាស់បណ្តាំអាចធ្វើអនុប្បទានទ្រព្យសម្បត្តិរបស់ខ្លួនឱ្យជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬ តតិយជនដែលមិនមែនជាសន្តតិជន តាមមតកសាសន៍បាន ។ ក្នុងនោះ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជន ត្រូវបានសន្មតថាជាការកំណត់នូវវិធីបែងចែកមតិក ឬ កំណត់នូវចំណែកមតិក ដោយអនុលោមតាមមាត្រាបន្ទាប់ ។ ចំណុចនេះនឹងបកស្រាយនៅក្នុងមាត្រាបន្ទាប់ ។ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ចំពោះតតិយជន ហៅថា

អច្ច័យទាន (មាត្រា ១១៩៩) ។ ប្រទានកម្មដោយមូលហេតុមរណភាព ក៏ប្រហាក់ប្រហែលនឹងអច្ច័យទានដែរ ក៏ប៉ុន្តែ អច្ច័យទាន គឺជាអនុប្បទាននៃទ្រព្យសម្បត្តិដោយការបង្ហាញឆន្ទៈរបស់មតកជនតែម្ខាង រីឯប្រទានកម្មដោយមូលហេតុមរណភាព គឺជាអនុប្បទានទ្រព្យសម្បត្តិតាមកិច្ចសន្យារវាងទាយក និង បដិគ្គាហក ។ សកម្មភាពពីរនេះមានចំណុចរួមមួយ គឺការកើតមានឡើងនូវអានុភាពនៃការផ្ទេរទ្រព្យសម្បត្តិដោយមរណភាពរបស់ទាយក ហេតុនេះហើយ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីអច្ច័យទាន( មាត្រា ៥៧៧ កថាខណ្ឌទី ២) ។

ក្នុងមាត្រានេះបានចែងថា "ក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង" ។ នេះគឺជាបញ្ញត្តិបញ្ជាក់ប៉ុណ្ណោះ ហើយប្រសិនបើលទ្ធផលនៃអច្ច័យទាន បំពានភាគបម្រុងរបស់សន្តតិជន អច្ច័យទាននោះអាចត្រូវបានកាត់បន្ថយទាំងអស់ ឬ មួយផ្នែក តាមការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិសន្មតអំពីអត្ថន័យតាមផ្លូវច្បាប់នៃមតិកសាសន៍ដែលធ្វើអនុប្បទានទ្រព្យជាក់លាក់មួយ ចំពោះសន្តតិជន ដោយមតកជន ។

កថាខណ្ឌទី ១ សន្មតថា ករណីដូចខាងលើនេះគឺជាករណីធ្វើការកំណត់វិធីបែងចែកមតិក ឬ ធ្វើការកំណត់ចំណែក

មតិក ។ ក្នុងករណីដែលមតកសាសន៍នោះបានធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់មួយ ដល់បុគ្គលណាមួយក្រៅពីសន្តតិជន អាចដឹងបានភ្លាមថានេះគឺជាអច្ច័យទាន ក៏ប៉ុន្តែ ប្រសិនបើករណីធ្វើអនុប្បទានចំពោះសន្តតិជនវិញ ភាគច្រើនមិនអាចដឹងថា នេះជាការកំណត់នូវវិធីបែងចែកមតិក ជាអាទិ៍ ឬ ជាអច្ច័យទានទេ ។ ក្នុងចំណោមសន្តតិជន A, B និង C ប្រសិនបើមតកជនបានធ្វើមតកសាសន៍មួយកំណត់ឱ្យ A ទទួលសន្តតិកម្មដីជាក់លាក់ណាមួយ ឱ្យ B ទទួលសន្តតិកម្មសិទ្ធិលើបំណុលជាប្រាក់បញ្ញើក្នុងធនាគារណាមួយ ហើយចំពោះ C ឱ្យទទួលសន្តតិកម្មទ្រព្យសម្បត្តិទាំងអស់ដែលនៅសល់ ក្នុងករណីនេះ គួរគិតថា ឆន្ទៈរបស់មតកជន មិនមែនជាការធ្វើអច្ច័យទានទេ តែជាការកំណត់នូវវិធីបែងចែកមតិក ជាអាទិ៍ទៅវិញ ជាការសមរម្យជាង ។ ដូច្នេះ ទោះបីជាមតកសាសន៍នោះកំណត់តែឱ្យ A ដីធ្លីជាក់លាក់មួយក៏ដោយ ក៏ត្រូវគិតថា ឆន្ទៈរបស់មតកជន គឺជាការកំណត់ចំណែកមតិក ជាអាទិ៍ ។ ដោយសារតែអត្រាពន្ធក្នុងករណីប្រទានកម្ម និង ករណីសន្តតិកម្មខុសគ្នា ហេតុនេះហើយ បានជាចាំបាច់មានបញ្ញត្តិសន្មតនេះ (ជាទូទៅ អត្រាពន្ធលើប្រទានកម្មខ្ពស់ជាង) ។ ក៏ប៉ុន្តែ ក្នុងទំហំក្រមរដ្ឋប្បវេណី កថាខណ្ឌទី ២ នៃមាត្រានេះ និង មាត្រា ១១៩៥ ត្រូវបានបញ្ញត្តឡើងដើម្បីបំបាត់នូវភាពខុសគ្នារវាងប្រទានកម្ម និង អច្ច័យទាន ទោះបីជាបានវាយតម្លៃថា មតកសាសន៍ធ្វើអនុប្បទានទ្រព្យជាក់លាក់ណាមួយឱ្យសន្តតិជននោះ ជាការកំណត់នូវវិធីបែងចែកមតិកក៏ដោយ ឬ បានវាយតម្លៃថា មតកសាសន៍នោះជាអច្ច័យទានក៏ដោយ លើកលែងតែករណីដែលសន្តតិជនដែលត្រូវទទួលទ្រព្យសម្បត្តិនោះបានទទួលមរណភាព ជាអាទិ៍ ។ ក្នុងករណីដែលសន្តតិជននោះបានទទួលមរណភាព ជាអាទិ៍ ប្រសិនបើបានធ្វើមតកសាសន៍ដើម្បីកំណត់នូវវិធីបែងចែកមតិក ការកំណត់នេះនឹងមានអានុភាពទៅលើទំនាក់ទំនងការធ្វើសន្តតិកម្មជំនួសនៃសន្តតិជននោះ (មាត្រា ១១៩៦) ក៏ប៉ុន្តែ ប្រសិនបើជាអច្ច័យទានវិញ នឹងគ្មានអានុភាព (មាត្រា ១២០០) ។ ម្យ៉ាងទៀត ក្នុងកថាខណ្ឌទី ១ ឃ្លា "បើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមតិករបស់សន្តតិជន នោះត្រូវសន្មតថា បានកំណត់ចំណែកមតិកផងដែរ" បានបញ្ជាក់ច្បាស់លាស់អំពីចំណុចដូចតទៅ : ចំពោះឧទាហរណ៍ខាងលើនេះ ក្នុងករណីដែលចំណែកមតិកតាមផ្លូវច្បាប់របស់សន្តតិជនបីនាក់ A, B និង C មាន ១ ភាគ ៣ ម្នាក់ តម្លៃនៃដីដែលបានធ្វើអនុប្បទានដល់ A គឺស្មើនឹង ១០០០ ដុល្លារ សិទ្ធិលើបំណុលទ្រព្យជាប្រាក់បញ្ញើដែលបានធ្វើអនុប្បទានដល់ B គឺមាន ៣០០ ដុល្លារ ហើយតម្លៃនៃទ្រព្យនៅសល់ដែល C បានទទួលនោះ គឺស្មើនឹង ៥០០ ដុល្លារ បូកសរុបទាំងអស់ទៅគឺ ១៨០០ ដុល្លារ ។ ដូច្នេះចំណែកមតិកសម្រាប់សន្តតិជនម្នាក់ៗតាមផ្លូវច្បាប់គឺ ៦០០ ដុល្លារ ហើយការកំណត់ឱ្យ A នោះ គឺច្បាស់ជាការកំណត់ឱ្យលើសចំណែកមតិកតាមផ្លូវច្បាប់ ។

ក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើមតកសាសន៍នោះបានកំណត់តែឱ្យ A ទទួលសន្តតិកម្មដីធ្លីដែលមានតម្លៃ ១០០០ ដុល្លារ និង B ទទួលសន្តតិកម្មសិទ្ធិលើបំណុលដែលជាប្រាក់បញ្ញើនៅធនាគារចំនួន ៣០០ ដុល្លារប៉ុណ្ណោះ ។ ក្នុងករណីនេះ នឹងមានបញ្ហាថា តើមតិកដែលនៅសល់មានតម្លៃស្មើនឹង ៥០០ ដុល្លារនោះ ត្រូវបានទៅអ្នកណា ។ ហេតុនេះហើយបានជាចាំបាច់ត្រូវមានកថាខណ្ឌទី ២ ដើម្បីធ្វើការសន្មត ។ ក្នុងករណីនេះ A បានទទួលលើសចំណែកមតិកតាមផ្លូវច្បាប់ហើយ ដូច្នេះមិនអាចទទួលសន្តតិកម្មមតិកផ្សេងទៀតបានទេ ប៉ុន្តែ តាមបញ្ញត្តិសន្មតនៃកថាខណ្ឌទី ២ នេះ

B និង C ត្រូវទទួលទ្រព្យក្រៅពីដី ចំនួន ៨00 ដុល្លារ ស្មើគ្នា ។ ហេតុដូច្នេះ ដោយសារ B បានទទួលតែប្រាក់បញ្ញើនៅធនាគារតែ ៣00 ដុល្លារទេ ដូច្នេះ B អាចទទួលថែម ១០០ ដុល្លារទៀត ពីទ្រព្យនៅសល់ ហើយ C អាចទទួល ៤00 ដុល្លារ ពីទ្រព្យនៅសល់ ។ ម្យ៉ាងទៀត ប្រសិនបើ "មានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍" ត្រូវអនុលោមតាមឆន្ទៈនោះ ។ ហេតុដូច្នេះ ឧទាហរណ៍ នៅក្នុងមតកសាសន៍មានសរសេរថា "B អាចទទួលតែប្រាក់បញ្ញើនៅធនាគារចំនួន ៣00 ដុល្លារប៉ុណ្ណោះ មិនអាចទទួលមតិកផ្សេងទៀតទេ" ក្នុងករណីនេះ C នឹងទទួលបាន ៥00 ដុល្លារដែលជាមតិកសល់ទាំងអស់នោះ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលសាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩១ ។

## មាត្រា ១១៨៦.– ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

(កំណត់)

មាត្រានេះចែងថា មតកជនអាចធ្វើការចាត់តាំងអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ បាន ។

មតកជនអាចចាត់តាំងសហសន្តតិជនណាម្នាក់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ ជាពិសេស ក្នុងករណីដែលបានធ្វើមតកសាសន៍កំណត់ឱ្យសហសន្តតិជនណាម្នាក់ទទួលសន្តតិកម្មនូវមតិកទាំងអស់ ហើយព្រមជាមួយគ្នានេះ ចាត់តាំងអ្នកនោះឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ជាការមួយងាយស្រួល ។ ចំពោះការប្រគល់អាណត្តិឱ្យតតិយជនកំណត់ ឧទាហរណ៍ ក្នុងករណីដែលប្រគល់អាណត្តិទ្រព្យឱ្យនីតិបុគ្គលមតិកដែលជាតតិយជនគ្រប់គ្រង មតកជនអាចផ្តល់អាណត្តិឱ្យនីតិបុគ្គលនោះ ធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ បាន ។

ម្យ៉ាងទៀត ក្នុងមាត្រា ១២១៤ បានចែងអំពីមុខងាររបស់តតិយជនដែលបានទទួលអាណត្តិដើម្បីធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយនៅក្នុងមាត្រា ១២១៦ បានចែងអំពីការទទួលយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍របស់ជនដែលត្រូវបានកំណត់ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៧៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៨៧.– ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំ

អាចធ្វើមតកសាសន៍ដោយផ្ដល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

(កំណត់)

មាត្រានេះចែងថា ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ដោយផ្ដល់ជាយោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេង១ទៀត ជាអាទិ៍ បាន ។ មាត្រានេះចែងថា ក្រៅពីការផ្ទេរទ្រព្យសម្បត្តិ ឬ ការទទួលស្គាល់កូន (មាត្រា ៩៩៧) មតកជនអាចធ្វើមតកសាសន៍ដែលមានន័យពាក់ព័ន្ធនឹងទំនៀមទម្លាប់ក្នុងសង្គមបាន ហើយចែងអំពីករណីយកិច្ចគោរពតាមមតកសាសន៍ បែបនេះផងដែរ ។ មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បានចែងថា បណ្ដាំប្រភេទនេះត្រូវទុកជាច្បាប់សម្រាប់គ្រួសារ ក៏ប៉ុន្តែ ក្នុងក្រមថ្មីនេះ បានចែងត្រឹមតែឱ្យមានករណីយកិច្ចគោរពប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៥ និង មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## ផ្នែកទី ៤ ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.-** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្ដាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

(កំណត់)

មាត្រានេះបញ្ជាក់ច្បាស់លាស់ថា អាចលុបចោលនូវមតកសាសន៍មួយភាគ ឬ ទាំងមូលបាន ។

មាត្រានេះចែងថា ការលុបចោល គឺជាសកម្មភាពដែលតម្រូវឱ្យស្របទៅតាមទម្រង់កំណត់ ហើយទម្រង់នៃការលុបចោល ត្រូវធ្វើតាមបញ្ញត្តិនៃផ្នែកនេះ ។ មាត្រាបន្តបន្ទាប់នៃផ្នែកនេះ ទទួលស្គាល់នូវការលុបមតកសាសន៍ ដោយទម្រង់បីយ៉ាង ។ ម្យ៉ាងទៀត ចំពោះពេលវេលាដែលអាចលុបមតកសាសន៍បានវិញ មានប្រើពាក្យ "នៅពេលណាក៏បាន" មានន័យថា ក្រោយពីបានធ្វើមតកសាសន៍រហូតដល់ពេលបានទទួលមរណភាព មតកជនអាចលុបចោលនូវមតកសាសន៍របស់ខ្លួនពេលណាក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥២៤ មាត្រា ៥៦៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៨៩.–** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតក-សាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

(កំណត់)

មាត្រានេះចែងអំពីការលុបចោលដោយទម្រង់នៃមតកសាសន៍ ។

កថាខណ្ឌទី ១ ចែងថា ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។ លើសពីនេះ មិនមានល័ក្ខខ័ណ្ឌកម្រិតអ្វីផ្សេងឡើយ ។ ដូច្នេះ ទោះបីជាមតកសាសន៍នោះ ជាមតកសាសន៍ដោយលិខិតយថាភូតក៏ដោយ ក៏គេអាចលុបចោលនូវមតកសាសន៍នោះមួយភាគ ឬ ទាំងមូល តាមទម្រង់មតកសាសន៍ដោយលិខិតឯកជនក៏បាន ឬ តាមមតកសាសន៍របស់ជនដែលកំពុងតែជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា ១១៧៧) ក៏បានដែរ ។ ដើម្បីលុបចោលនូវមតកសាសន៍មុនដោយទម្រង់នៃមតកសាសន៍ គឺត្រូវធ្វើមតកសាសន៍ថ្មីមួយទៀតតាមវិធីធ្វើមតកសាសន៍ ដោយប្រើវិធីពីរ មួយគឺសរសេរក្នុងមតកសាសន៍ថ្មីបញ្ជាក់ឱ្យបានច្បាស់អំពីការលុបចោល ឧទាហរណ៍ "លុបចោលនូវមតកសាសន៍ ដែលចុះនៅថ្ងៃទី ០០ ខែ ០០ ឆ្នាំ ០០ ទាំងស្រុង (ឬ ខទី ១)" និងវិធីមួយទៀតដែលមានចែងក្នុងកថាខណ្ឌទី ២ គឺធ្វើមតកសាសន៍ក្រោយដែលមានខ្លឹមសារផ្ទុយនឹងមតកសាសន៍មុន ។

កថាខណ្ឌទី ២ ជាបញ្ញត្តិមួយសម្រាប់ករណីដែលមតកសាសន៍ក្រោយមានខ្លឹមសារផ្ទុយនឹងមតកសាសន៍មុន ។ ឧទាហរណ៍ ក្នុងមតកសាសន៍មុន មានខ្លឹមសារថា ឱ្យ A ទទួលសន្តតិកម្មនូវទ្រព្យទាំងអស់ ក៏ប៉ុន្តែ នៅក្នុងមតកសាសន៍ក្រោយ ឱ្យ A ទទួលសន្តតិកម្មនូវដីធ្លីជាក់លាក់មួយ ហើយឱ្យ B ទទួលសន្តតិកម្មនូវសិទ្ធិលើបំណុលដែលជាប្រាក់បញ្ញើនៅធនាគារ ហើយឱ្យ C ទទួលទ្រព្យផ្សេងដែលនៅសល់ទាំងអស់ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថា មតកជនបានលុបចោលនូវមតកសាសន៍មុន ដោយមតកសាសន៍ក្រោយ ហើយមានតែមតកសាសន៍ក្រោយទេ ដែលមានអានុភាព ។ ម្យ៉ាងទៀត កថាខណ្ឌទី ២ នៃមាត្រា ១១៧០ បានចែងថា "ក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំមានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក" ។ ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ បើមានមតកសាសន៍ពីរ ដែលមានខ្លឹមសារផ្ទុយគ្នាទៅវិញទៅមក ហើយប្រសិនបើមតកសាសន៍ទាំងពីរនេះ គ្មានចុះថ្ងៃខែឆ្នាំត្រឹមត្រូវទេ ត្រូវអនុវត្តកថាខណ្ឌទី ២ នៃមាត្រា ១១៧០ ដោយមានអាទិភាពជាងកថាខណ្ឌទី ២ នៃមាត្រានេះ ។ តាមឧទាហរណ៍ខាងលើ មានតែចំណុចដែលថា A ទទួលសន្តតិកម្មដីប៉ុណ្ណោះ ដែលមិនផ្ទុយគ្នានឹងមតកសាសន៍មុន ដូច្នេះ ចំណុចនេះមានសុពលភាពជាមតកសាសន៍ ។ ក្នុងករណីដែលមតក-

សាសន៍មុនមានចុះថ្ងៃខែឆ្នាំគ្រប់គ្រាន់ តែមតកសាសន៍ក្រោយមានចុះតែខែ និង ឆ្នាំ មិនមានចុះថ្ងៃ តែឆ្នាំនោះគឺក្រោយមតកសាសន៍មុន ពេលនោះនឹងមានបញ្ហាថា តើត្រូវអនុវត្តមតកសាសន៍ណាមួយ ។ ក្នុងករណីនេះ ដោយសារតែអាចដឹងយ៉ាងច្បាស់លាស់ថា តើមតកសាសន៍ណាមួយជាមតកសាសន៍មុន ណាមួយជាមតកសាសន៍ក្រោយ ដូច្នេះការអនុវត្តតាមកថាខណ្ឌទី ២ នៃមាត្រានេះ ជាការសមរម្យ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៦៤ និង មាត្រា ៥៦៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៩០.- ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលម្ចាស់បណ្តាំខ្លួនឯងបានធ្វើអនុប្បទាន ជាអាទិ៍ នូវវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ ត្រូវចាត់ទុកថា មតកជនបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលមានភាពផ្ទុយគ្នានោះ ។

ឧទាហរណ៍ តាមមតកសាសន៍ ចលនវត្ថុជាក់លាក់មួយត្រូវឱ្យជាអច្ច័យទានដល់ A ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បណ្តាំបានធ្វើប្រទានកម្មនូវចលនវត្ថុនោះឱ្យ B នៅពេលដែលខ្លួននៅរស់ ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលនូវផ្នែកនេះនៃមតកសាសន៍ ។ ផ្ទុយទៅវិញ ប្រសិនបើវត្ថុដែលជាកម្មវត្ថុនោះ ត្រូវបានតតិយជនធ្វើឱ្យបែកបាក់ នោះមិនអាចចាត់ទុកថា បានលុបចោលនូវផ្នែកនេះនៃមតកសាសន៍បានទេ ។ ដូច្នេះ ទោះបីជា A មិនបានធ្វើលទ្ធកម្មវត្ថុដែលជាកម្មវត្ថុនោះក៏ដោយ ក៏អាចទទួលនូវសិទ្ធិទាមទារនូវសំណងនៃការខូចខាត ចំពោះតតិយជននោះ ជំនួសវត្ថុដែលជាកម្មវត្ថុនោះដែរ (មាត្រា ១២០៩) ។ ក្នុងមាត្រានេះ បានចែងថា "ចំពោះផ្នែកដែលផ្ទុយ" បានសេចក្តីថា ចំពោះករណីដែលក្នុងចំណោមសន្តតិជនបីនាក់ គឺ A, B និង C មតកជនបានធ្វើមតកសាសន៍ឱ្យ A ទទួលសន្តតិកម្មដីធ្លីជាក់លាក់មួយ ឱ្យ B ទទួលសន្តតិកម្មសិទ្ធិលើបំណុលដែលជាប្រាក់បញ្ញើនៅធនាគារ ហើយឱ្យ C ទទួលសន្តតិកម្មចលនវត្ថុជាក់លាក់មួយ ប្រសិនបើដីនោះ ត្រូវបានធ្វើអនុប្បទានដល់តតិយជន នោះមានតែផ្នែកដែលពាក់ព័ន្ធនឹងដីនោះប៉ុណ្ណោះដែលត្រូវចាត់ទុកថា មតកជនបានលុបចោល ហើយខ្លឹមសារនៃមតកសាសន៍ចំពោះ B ឬ C នឹងមិនមានការប៉ះពាល់ឡើយ ។ម្យ៉ាងទៀត មាត្រានេះជាបញ្ញត្តិចែងឡើងក្នុងន័យគោរពនូវឆន្ទៈរបស់ម្ចាស់បណ្តាំ ដូច្នេះ ប្រសិនបើម្ចាស់បណ្តាំនោះបានលក់ដីធ្លីនោះ ដើម្បីឱ្យ A ធ្វើលទ្ធកម្មប្រាក់ជំនួសដីធ្លី ពេលនោះមិនត្រូវចាត់ទុកថា បានលុបចោលនូវមតកសាសន៍នោះទេ គឺគួរតែឱ្យ A ធ្វើលទ្ធកម្មប្រាក់ដែលបានមកពីការលក់នោះ តាមអានុភាពនៃមតកសាសន៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៩១.- ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្ដាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្ដាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

(កំណត់)

មាត្រានេះចែងអំពីការចាត់ទុកជាការលុបចោលនូវមតកសាសន៍ ប្រសិនបើមានការបំផ្លាញមតកសាសន៍ ឬ ការបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយម្ចាស់បណ្ដាំ ។

លិខិតមតកសាសន៍គឺជាភស្តុតាងតែមួយគត់ដែលអាចបញ្ជាក់ថា មានមតកសាសន៍នោះ ។ ដូច្នេះ ប្រសិនបើម្ចាស់បណ្ដាំបានបំផ្លាញលិខិតនោះដោយចេតនា ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលមតកសាសន៍ត្រង់ផ្នែកដែលខ្លួនបានបំផ្លាញនោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់បណ្ដាំបានបំផ្លាញកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា គឺត្រូវចាត់ទុកថាសាមីខ្លួនបានលុបចោលនូវមតកសាសន៍របស់ខ្លួន ដូចការចាត់ចែងវត្ថុនោះពេលនៅរស់ដែរ ។ ក្នុងករណីដែលលិខិតមតកសាសន៍ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬ ដោយប្រធានសក្តិ អានុភាពនៃការលុបចោល មិនកើតឡើងទេ ក៏ប៉ុន្តែ ប្រសិនបើលិខិតមតកសាសន៍នោះមើលលែងដាច់ គ្មានវិធីអ្វីផ្សេងក្រៅពីចាត់ទុកថា ផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១១៩២.- ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្ដាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាម្ចាស់បណ្ដាំបានបោះបង់សិទ្ធិលុបចោលមតកសាសន៍ក៏ដោយ ក៏សកម្មភាពនេះត្រូវជាមោឃៈដែរ ។

មូលហេតុដែលមិនអាចឱ្យបោះបង់សិទ្ធិលុបចោលមតកសាសន៍ ដោយសារតែទីមួយគឺ របបមតកសាសន៍មាន

គោលបំណង គោរពនូវឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំ ទីពីរគឺ ស្ថានភាពអាចមានការផ្លាស់ប្តូរ ក្រោយពីបានធ្វើលិខិតមតកសាសន៍ ដូច្នេះ ការចងឆន្ទៈដំបូងរបស់ម្ចាស់បណ្តាំជារៀងរហូតជាការធ្វើជ្រុលពេក ទីបីគឺ ការលុបចោលនូវមតកសាសន៍ មិនធ្វើឱ្យខូចប្រយោជន៍ដល់បុគ្គលណាម្នាក់ទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៩៣.–** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

(កំណត់)

មាត្រានេះចែងអំពីការលុបចោលនូវអច្ច័យទាន ក្នុងករណីដែលបុគ្គលដែលត្រូវទទួលអច្ច័យទានដែលភ្ជាប់នូវបន្ទុកមិនបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវបុគ្គលនោះអនុវត្ត ។

ក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើអច្ច័យទានដែលភ្ជាប់នូវបន្ទុក ម្ចាស់បណ្តាំនោះច្រើនតែរំពឹងទៅលើការអនុវត្តបន្ទុកនោះ ។ ក៏ប៉ុន្តែ មតកសាសន៍ជាសកម្មភាពឯកតោភាគី មិនមែនជាកិច្ចសន្យាអញ្ញមញ្ញទេ ហេតុនេះហើយ ទោះបីជាអច្ច័យលាភីមិនអនុវត្តបន្ទុកនោះក៏ដោយ ក៏មិនអាចលុបបំបាត់នូវឆន្ទៈនៃអច្ច័យទាន តាមរយៈការលុបចោលនូវកិច្ចសន្យាបានដែរ ។ ដូច្នេះ ក្នុងករណីដែលបុគ្គលដែលបានទទួលអច្ច័យទានដែលភ្ជាប់បន្ទុកនោះ មិនបានអនុវត្តករណីយកិច្ចដែលតម្រូវឱ្យធ្វើនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ ត្រូវធ្វើការដាស់តឿនឱ្យបុគ្គលនោះអនុវត្ត ហើយប្រសិនបើនៅតែមិនអនុវត្តទេ អាចទាមទារឱ្យតុលាការលុបចោលអច្ច័យទាននោះបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

# ផ្នែកទី ៥ អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.–** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

(កំណត់)

មាត្រានេះចែងអំពីពេលដែលមតកសាសន៍បង្កើតអានុភាព ។

មតកសាសន៍ត្រូវបានបង្កើតឡើងដោយការធ្វើលិខិតមតកសាសន៍តាមវិធីដែលមានចែងក្នុងផ្នែកទី ៣ ។ ក៏ប៉ុន្តែ ជាគោលការណ៍ មតកសាសន៍នោះនឹងមានអានុភាពនៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព (កថាខណ្ឌទី ១) ។ នេះគឺដោយសារតែមតកសាសន៍គឺជាឆន្ទៈរបស់ម្ចាស់បណ្ដាំ ក្នុងការសម្រេចនូវកម្មសិទ្ធិទ្រព្យសម្បត្តិ ជាអាទិ៍ ក្រោយពេលដែលសាមីខ្លួនទទួលមរណភាព ។ ក្នុងករណីដែលបានទទួលនូវកម្មវត្ថុជាក់លាក់មួយដោយអច្ច័យទាន អច្ច័យលាភីនឹងទទួលលទ្ធកម្មនូវកម្មសិទ្ធិនៃកម្មវត្ថុនោះ នៅពេលមរណភាពរបស់ម្ចាស់បណ្ដាំ ដោយផ្អែកទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១។ អច្ច័យលាភីបានទទួលនូវកម្មសិទ្ធិលើកម្មវត្ថុនោះពីម្ចាស់បណ្ដាំផ្ទាល់ ដោយគ្មានឆ្លងកាត់តាមដំណាក់កាលនៃការផ្ទេរសិទ្ធិពីម្ចាស់បណ្ដាំទៅអ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជន ហើយទទួលបន្តពីអ្នកនោះទេ ។ ចំពោះកម្មសិទ្ធិលើអចលនវត្ថុ ក៏ដូចគ្នាដែរ គឺអច្ច័យលាភីនឹងទទួលកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន នៅពេលម្ចាស់បណ្ដាំទទួលមរណភាព ដោយមិនចាំបាច់ចុះបញ្ជី ។ ហើយការសម្រេចឱ្យជាក់លាក់នូវទំនាក់ទំនងនៃសិទ្ធិនោះ ដោយការចុះបញ្ជី ឬ ការប្រគល់កម្មវត្ថុនោះ ជាការងារជាក់ស្ដែងរបស់អ្នកប្រតិបត្តិមតកសាសន៍ ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលមតកសាសន៍ភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ ។ ឧទាហរណ៍ដូចជា ការធ្វើអច្ច័យទាននូវដីធ្លីដែលមានផ្ទះ ដោយតម្រូវឱ្យមានអាពាហ៍ពិពាហ៍នៃអច្ច័យលាភីជាល័ក្ខខ័ណ្ឌបង្អង់ ។ ចំពោះករណីនេះ អានុភាពនៃមតកសាសន៍នេះនឹងកើតឡើងនៅពេលមានអាពាហ៍ពិពាហ៍ ក្រោយពេលម្ចាស់បណ្ដាំទទួលមរណភាព ។ ក្នុងករណីនេះ អាចសន្និដ្ឋានថា អច្ច័យលាភីបានទទួលលទ្ធកម្មនូវសិទ្ធិដែលមានភ្ជាប់នូវល័ក្ខខ័ណ្ឌ នៅពេលមរណភាពរបស់ម្ចាស់បណ្ដាំ ។ ផ្ទុយទៅវិញ ប្រសិនបើអច្ច័យលាភីបានរៀបអាពាហ៍ពិពាហ៍មុនពេលម្ចាស់បណ្ដាំទទួលមរណភាព ល័ក្ខខ័ណ្ឌបង្អង់នោះបានសម្រេចមុនពេលម្ចាស់បណ្ដាំទទួលមរណភាព ហេតុនេះហើយ អាចបកស្រាយថា គ្មានភ្ជាប់នូវល័ក្ខខ័ណ្ឌនោះទេ (សូមមើលមាត្រា ១៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន) ។ ដូច្នេះ អានុភាពនៃមតកសាសន៍នោះនឹងកើតឡើងពីពេលដែលម្ចាស់

បណ្តាំបានទទួលមរណភាព ដោយយោងតាមកថាខណ្ឌទី ១ ។

ម្យ៉ាងទៀត កថាខណ្ឌទី ២ នៃមាត្រានេះ ហាក់ដូចជាមានភាពផ្ទុយនឹងកថាខណ្ឌទី ២ នៃមាត្រាបន្ទាប់ ក៏ប៉ុន្តែ មាត្រានេះ ចែងករណីទូទៅនៃមតកសាសន៍ដែលមានភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ រីឯមាត្រាបន្ទាប់វិញ គឺជា "បញ្ញត្តិចាត់ទុក" ដោយពិចារណាផងដែរទៅលើអានុភាពប្រតិសកម្មនៃការបែងចែកមតិក ដូច្នេះ គឺមិនផ្ទុយគ្នាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៨៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៩៥.– អានុភាពនៃការកំណត់ចំណែកមតិក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមតិក ឬ វិធីបែងចែកមតិក ដោយធ្វើអនុប្បទាន ទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួល ទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌ នោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេល ដែលមតកជននោះ បានទទួលមរណភាព ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្តីពីពេលដែលអានុភាពនៃការកំណត់ចំណែកមតិក ជាអាទិ៍ កើតឡើង ដោយការធ្វើអនុប្បទាន ទ្រព្យសម្បត្តិជាក់លាក់ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិចែងអំពីពេលដែលទ្រព្យជាក់លាក់មួយត្រូវបានធ្លាក់ទៅលើបុគ្គលណាម្នាក់ ក្នុងករណីដែល បានកំណត់ចំណែកមតិក ឬ វិធីបែងចែកមតិក ដោយការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់នោះ ។ ទោះបីជាមាន ការកំណត់នូវវិធីបែងចែកមតិកក៏ដោយ ប្រសិនបើសហសន្តតិជនមិនបានយល់ព្រមអំពីការបែងចែកមតិកនោះទេ អាច នៅមានមន្ទិលថា មតិកមិនទាន់បែងចែកទេ គឺមតិកនោះស្ថិតនៅក្នុងស្ថានភាពកម្មសិទ្ធិអវិភាគដដែល ឬយ៉ាងណា ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការកំណត់នូវវិធីបែងចែកមតិក តាមមតកសាសន៍ នោះគេអាចគិតថា មតិកត្រូវបានបែងចែក តាមវិធីដែលបានកំណត់នោះ ដោយមិនចាំបាច់ឆ្លងកាត់តាមការពិភាក្សាអំពីការបែងចែកមតិកដោយសហសន្តតិជនទេ ។ ដូចគ្នាដែរ ចំពោះការកំណត់ចំណែកមតិក ដោយការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់ ។ ហើយអានុភាពនៃការបែង

ចែក នឹងមានជាប្រតិសកម្ម ពីពេលចាប់ផ្ដើមសន្តតិកម្មទៅ (មាត្រា ១២៧៣) ដូច្នេះ គេអាចវិនិច្ឆ័យដោយចំពោះតែម្ដងថា ទ្រព្យជាក់លាក់នោះ ត្រូវធ្លាក់ដោយស្វ័យប្រវត្តិ ទៅសន្តតិជនពីពេលដែលមតកសាសន៍នោះមានអានុភាព ។ ចំពោះកម្មសិទ្ធិលើអចលនទ្រព្យ ក៏ដូចគ្នាដែរ សន្តតិជនធ្វើលទ្ធកម្មលើកម្មសិទ្ធិនោះ ស្របពេលដែលអានុភាពនៃមតក-សាសន៍ ត្រូវកើតឡើង (បានសេចក្ដីថា ព្រមគ្នានឹងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ សូមមើលកថាខណ្ឌទី ១ នៃមាត្រា ១១៩៤) ។ ដូច្នេះ តាមលទ្ធផលនៃកថាខណ្ឌទី ១ បុគ្គលក្រៅពីសន្តតិជនដែលត្រូវបានកំណត់ថា នឹងទទួលសន្តតិកម្មនូវទ្រព្យជាក់លាក់នោះ គ្មានសិទ្ធិទាត់ចែងចំពោះទ្រព្យជាក់លាក់នោះទេ ទោះបីជាចំពោះចំណែកមត៌កតាមផ្លូវច្បាប់ក៏ដោយ ។ ក្នុងករណីដែលទទួលសន្តតិកម្មតាមផ្លូវច្បាប់ដោយមិនមានមតកសាសន៍ ជាដំបូង សហសន្តតិជនត្រូវធ្វើលទ្ធកម្មសិទ្ធិទៅតាមចំណែកមត៌ក រួចត្រូវផ្ទេរក្នុងចំណោមសន្តតិជននូវចំណែកអវិភាគនៃមត៌កជាក់ស្ដែង ទៅតាមរយៈការបែងចែកនោះ ក៏ប៉ុន្តែ ចំណុចនេះគឺជាចំណុចខុសគ្នាចម្បង ចំពោះករណីសន្តតិកម្មតាមមតកសាសន៍ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិចែងសម្រាប់ករណីដែលមតកសាសន៍មានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ហើយល័ក្ខខ័ណ្ឌនោះត្រូវបានសម្រេច ក្រោយពេលមរណភាពរបស់ម្ចាស់បណ្ដាំ ។ ឧទាហរណ៍ ករណីដែលបានកំណត់ថា ប្រសិនបើទារកនៅក្នុងគភ៌កើតមក ត្រូវបែងចែកមត៌កតាមវិធីមួយ ហើយប្រសិនបើកូននោះស្លាប់រួចទៅហើយនៅពេលកើត ត្រូវបែងចែកមត៌កតាមវិធីមួយផ្សេងទៀត ។ ប្រសិនបើល័ក្ខខ័ណ្ឌបង្អង់នោះ ត្រូវបានសម្រេចក្រោយពេលមរណភាពរបស់ម្ចាស់បណ្ដាំ តាមទ្រឹស្ដី ពីពេលដែលមតកជនបានទទួលមរណភាព ដល់ពេលដែលល័ក្ខខ័ណ្ឌនោះបានសម្រេច មត៌កស្ថិតនៅក្រោមស្ថានភាពកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ហើយទ្រព្យជាក់លាក់នេះ ត្រូវធ្លាក់ទៅលើសហសន្តតិជនដែលបានទទួលតាមការកំណត់ចំណែកមត៌ក ឬ តាមការកំណត់វិធីបែងចែកមត៌កនេះ ដោយសារល័ក្ខខ័ណ្ឌបង្អង់នោះបានសម្រេច (សូមមើលមាត្រាមុន) ប៉ុន្តែ ករណីនេះ មានលក្ខណៈដូចគ្នានឹងអានុភាពប្រតិសកម្មនៃការបែងចែកមត៌ក (មាត្រា ១២៧៣) ដូច្នេះ ត្រូវចាត់ទុកថា កម្មសិទ្ធិត្រូវធ្លាក់ទៅលើសន្តតិជនដែលត្រូវបានកំណត់ ពីពេលដែលមតកជនបានទទួលមរណភាព ។
(មាត្រាពាក់ព័ន្ធ)

សាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩១ និង សាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

**មាត្រា ១១៩៦.-** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយ

ការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការកំណត់ចំណែកមតិករបស់សន្តតិជន ឬ ការកំណត់នូវវិធីបែងចែកមតិក ដោយមតកសាសន៍ ក្នុងករណីជនដែលត្រូវសន្មតថាជាសន្តតិជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ ។

ក្នុងករណីនេះ អាចគិតថា មតកជនមានឆន្ទៈចង់ឱ្យអ្នកធ្វើសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទទួលនូវចំណែកមតិកដែលបានកំណត់នោះ ហេតុនេះហើយបានជា ក្នុងកថាខណ្ឌទី ១ បានចែងថា ការកំណត់នោះត្រូវចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជនទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនត្រូវបង្កើតអានុភាព ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌនេះ ជាបញ្ញត្តិស្វ័យប្រវត្តិដែលមានខ្លឹមសារថា ក្នុងករណីដែលសន្តតិជនបានបោះបង់នូវសន្តតិកម្ម ការកំណត់នេះក៏គ្មានអានុភាពដែរ ។

កថាខណ្ឌទី ៣ បានចែងបញ្ជាក់ថា ប្រសិនបើនៅក្នុងមតកសាសន៍មានការបង្ហាញឆន្ទៈពិសេស ដោយមតកជនត្រូវអនុលោមតាមឆន្ទៈពិសេសនោះ ដោយសារតែកថាខណ្ឌទី ១ និង ទី ២ ជាបញ្ញត្តិចែងឡើង ដោយគោរពតាមឆន្ទៈរបស់មតកជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១១៩៧.-** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាល

នោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិថា អ្នកនៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើមតកសាសន៍ ដែលផ្តល់ផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ជាអាទិ៍ ទេ ព្រមទាំងមានបញ្ញត្តិករណីលើកលែងផងដែរ ។

អ្នកនៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន នៅពេលដែលសាមីខ្លួនបានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន (មាត្រា ១១៧៦) ។ ក៏ប៉ុន្តែ សមត្ថភាពរបស់គាត់មិនគ្រប់គ្រាន់ពេញលេញទេ ហើយមានការបារម្ភថា អ្នកអាណាព្យាបាលរបស់គាត់អាចបោកប្រាស់គាត់ឱ្យធ្វើមតកសាសន៍សម្រាប់ជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាលនោះ ឬ អ្នកនៅជុំវិញរបស់ខ្លួននោះ ហេតុនេះហើយបានជាកថាខណ្ឌទី ១ បានចែងថា មតកសាសន៍នេះត្រូវទុកជាមោឃៈ ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិអញ្ញត្រកម្មសម្រាប់ករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាល ដែលភាគច្រើន អ្នកនៅក្រោមអាណាព្យាបាលមានបំណងឱ្យមតិកខ្លួនទៅជនទាំងនោះ ហេតុនេះហើយបានជាកថាខណ្ឌនេះចែងថា មតកសាសន៍ចំពោះបុគ្គលទាំងនេះមានសុពលភាព ទោះបីជាមតកសាសន៍នោះបានផ្តល់ផលប្រយោជន៍ដល់អ្នកទាំងនោះក៏ដោយ ។ ដូច្នេះ អាចយល់ឃើញថា មាត្រានេះមានគោលបំណងកម្រិតអំពីខ្លឹមសារនៃមតកសាសន៍ ចំពោះករណីដែលអ្នកជំនាញវិជ្ជាជីវៈដូចជាមេធាវី ជាអាទិ៍ ឬ ពូ មីងរបស់សាមីខ្លួន ជាអ្នកអាណាព្យាបាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៩៨.-** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះចែងយ៉ាងច្បាស់ថា ជាគោលការណ៍ ក្នុងករណីដែលអច្ច័យទានត្រូវជាមោឃៈ ជាអាទិ៍ ទ្រព្យដែលអច្ច័យ-លាភីត្រូវទទួលនោះ នឹងធ្លាក់ទៅសន្តតិជនវិញ ។

ប្រសិនបើអច្ច័យលាភីជាអភ័ព្វបុគ្គល (មាត្រា ១១៥០) ឬ ប្រសិនបើអច្ច័យលាភីបានទទួលមរណភាព (មាត្រា ១២០០) អានុភាពនៃអច្ច័យទានមិនកើតឡើងទេ ។ "ហេតុផ្សេងទៀត" មានដូចជា ការបោះបង់អច្ច័យទានដោយអច្ច័យលាភី (មាត្រា ១២០១) ហើយក្នុងករណីនេះ អានុភាពនៃអច្ច័យទានមិនកើតឡើងទេ ។ ចំពោះករណីទាំងនេះ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ មិនធ្លាក់ទៅលើជនណាម្នាក់ដែលបានកំណត់តាមឆន្ទៈមតកជនទេ ដូច្នេះ ទ្រព្យនេះត្រូវធ្លាក់ទៅលើសន្តតិជនវិញ ។ ចំពោះចំណុចនេះ មានហេតុផលច្បាស់លាស់ ឧទាហរណ៍ ក្នុងករណីដែលមតកជនបានធ្វើអច្ច័យទានសកល ឱ្យ A និង B ម្នាក់ ១ ភាគ ២ ហើយនៅពេលដែល A បានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្មនោះ B មិនមែនបានទទួលលទ្ធកម្មទាំងអស់ទេ គឺ B បានទទួល ១ ភាគ ២ ហើយចំណែក ១ ភាគ ២ ទៀតដែល A ត្រូវទទួល ត្រូវធ្វើលទ្ធកម្មដោយសន្តតិជនតាមផ្លូវច្បាប់ ។ ក៏ប៉ុន្តែ ឧទាហរណ៍ ប្រសិនបើមតកជនបានបង្ហាញឆន្ទៈពិសេសក្នុងមតកសាសន៍ថា "A និង B អាចទទួលអច្ច័យទាន ១ ភាគ ២ ម្នាក់ ។ ក៏ប៉ុន្តែ ប្រសិនបើបុគ្គលណាម្នាក់បានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្ម ទ្រព្យទាំងអស់ត្រូវធ្វើអច្ច័យទានទៅឱ្យជនដែលនៅរស់" ជាអាទិ៍ ក្នុងករណីនេះ ត្រូវគោរពតាមឆន្ទៈនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥០ និង មាត្រា ៥៥១នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## ផ្នែកទី ៦ អច្ច័យទាន

**មាត្រា ១១៩៩.–** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

(កំណត់)

អច្ច័យទាន គឺជាប្រទានកម្មនូវទ្រព្យសម្បត្តិដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ ដោយមតកសាសន៍។ មាត្រានេះបានចែងបញ្ជាក់ថា អច្ច័យទានមានពីរប្រភេទ គឺអច្ច័យទានសកល និង អច្ច័យទានមានកំណត់ ។

ដូចដែលបានពន្យល់ក្នុងសេចក្ដីកំណត់នៃមាត្រា ១១៨៤ ហើយ អច្ច័យទានគឺជាការផ្ទេរទ្រព្យសម្បត្តិដោយសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្ដាំ ដូច្នេះ មានភាពខុសគ្នានឹងប្រទានកម្មដែលផ្ទេរទ្រព្យសម្បត្តិពីទាយកទៅឱ្យបដិគ្គាហក តាម

កិច្ចសន្យាដែលធ្វើឡើងរវាងទាយក និង បដិគ្គាហក ។ ក្នុងចំណោមវិធីធ្វើអច្ច័យទាន មានដូចជាអច្ច័យទានដោយវិធីធ្វើប្រទានកម្មដោយកំណត់ឱ្យទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់តាមអត្រា ដូចជា ១ ភាគ ២ ជាអាទិ៍ ទៅឱ្យបុគ្គលជាក់លាក់ណាមួយ ឬ វិធីធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិជាក់លាក់ណាមួយឱ្យបុគ្គលជាក់លាក់ណាម្នាក់ ដូចជាធ្វើប្រទានកម្មនូវដីធ្លីណាមួយឱ្យ A ហើយដីធ្លីដែលនៅសល់ឱ្យ B ជាអាទិ៍ ។ វិធីទីមួយ គឺអច្ច័យទានសកល រីឯវិធីទីពីរ គឺអច្ច័យទានមានកំណត់ ។ ចំពោះអច្ច័យទានមានកំណត់ ទ្រព្យសម្បត្តិនោះត្រូវធ្លាក់ទៅលើអច្ច័យលាភី ព្រមជាមួយគ្នានឹងកំណើតនៃអានុភាពនៃមតកសាសន៍ ក៏ប៉ុន្តែ ចំពោះអច្ច័យទានសកលទៅលើទ្រព្យមួយភាគដែលកំណត់ទៅតាមអត្រាវិញ អច្ច័យលាភីសកល ជាអាទិ៍ ទាំងអស់ចាំបាច់ត្រូវពិភាក្សាគ្នា ដើម្បីកំណត់នូវកម្មសិទ្ធិនៃទ្រព្យសម្បត្តិនីមួយៗនោះ ។ ដូច្នេះ ក្នុងមាត្រា ១២១២ មានចែងថា អច្ច័យលាភីសកលមានសិទ្ធិ និងករណីយកិច្ច ដូចសន្តតិជនដែរ ហេតុនេះហើយ ត្រូវធ្វើការបែងចែកមតិកនេះ ។

ដោយឡែក ក្នុងករណីដែលតតិយជនក្រៅពីសន្តតិជនបានទទួលអច្ច័យទានមានកំណត់ កម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុក៏ត្រូវផ្ទេរទៅឱ្យអច្ច័យលាភី ស្របពេលដែលមតកសាសន៍បង្កើតអានុភាពដែរ ។ ដូចគ្នាដែរ ចំពោះករណីនៃអចលនវត្ថុ គឺមិនមានល័ក្ខខ័ណ្ឌទាមទារឱ្យមានការចុះបញ្ជីដើម្បីផ្ទេរឡើយ ព្រោះថា អច្ច័យទានក៏ជាសណ្ឋានមួយរបស់សន្តតិកម្មដែរ ។
(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥២៧ មាត្រា ៥៧០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២០០.–** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

(កំណត់)

មាត្រានេះបានចែងច្បាស់លាស់ថា ក្នុងករណីដែលអច្ច័យលាភីបានទទួលមរណភាព មុន ឬ ព្រមគ្នានឹងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ជាគោលការណ៍ អច្ច័យទានមិនបង្កើតអានុភាពទេ ។

កថាខណ្ឌទី ១ បានចែងថា ក្នុងករណីដែលអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ព្រមគ្នានឹងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព បច្ចាញាតិផ្ទាល់ ជាអាទិ៍ របស់អច្ច័យលាភីមិនអាចទទួលអច្ច័យទានជំនួសបានឡើយ ដោយសារតែជាធម្មតា អច្ច័យទានត្រូវបានធ្វើឡើងដោយផ្ដោតទៅលើទំនាក់ទំនងផ្ទាល់ខ្លួនរវាងម្ចាស់បណ្ដាំ និង អច្ច័យលាភី ។

ដោយសារតែកថាខណ្ឌទី ១ ជាបញ្ញត្តិគោរពឆន្ទៈរបស់ម្ចាស់បណ្ដាំ ហេតុនេះហើយបានជាក្នុងកថាខណ្ឌទី ២ នេះបានចែងច្បាស់លាស់ថា ប្រសិនបើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈពិសេសផ្សេងទៀតនៅក្នុងមតកសាសន៍ ត្រូវគោរពតាមឆន្ទៈនោះ ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិបញ្ជាក់បន្ថែម ដើម្បីជៀសវាងនូវការជ្រួលច្របល់អត់ប្រយោជន៍ ក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអច្ច័យលាភី ។ មតកសាសន៍ដែលមានខ្លឹមសារផ្ទេរទ្រព្យសម្បត្តិ ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជន ត្រូវសន្មតថាជាការកំណត់នូវវិធីបែងចែកមតិក ឬ ការកំណត់នូវចំណែកមតិក (មាត្រា ១១៨៥) ហើយក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាសន្តតិជននោះបានទទួលមរណភាព ត្រូវចាត់ទុកថាជាការកំណត់ចំពោះជនដែលធ្វើសន្តតិកម្មជំនួសបុគ្គលនោះ ដោយយោងតាមមាត្រា ១១៥៦ ដូច្នេះ មានភាពខុសគ្នានឹងមាត្រានេះ ហេតុនេះហើយបានជាកថាខណ្ឌទី ៣ នេះ បានចែងបញ្ជាក់ឱ្យអាទិភាពទៅមាត្រានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៤៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## **មាត្រា ១២០១.-** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

(កំណត់)

មាត្រានេះចែងយ៉ាងច្បាស់លាស់ថា អច្ច័យលាភីអាចបោះបង់អច្ច័យទានបាន ។

អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិដោយសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្ដាំ ហើយអានុភាពនៃអច្ច័យទាននឹងកើតឡើងដោយស្វ័យប្រវត្តិ ដោយមរណភាពរបស់ម្ចាស់បណ្ដាំ ដោយគ្មានទាក់ទងនឹងឆន្ទៈរបស់អច្ច័យលាភីទេ ។

ក៏ប៉ុន្តែ ទោះបីជាអច្ច័យទាននេះមានផលប្រយោជន៍ដល់អច្ច័យលាភីក៏ដោយ វាជាការមិនសមរម្យឡើយ ប្រសិនបើបង្ខំឱ្យអច្ច័យលាភីទទួលអច្ច័យទាននោះ ដោយគ្មានទាក់ទងនឹងឆន្ទៈរបស់អច្ច័យលាភីនោះ ។ ហេតុនេះហើយបានជា កថាខណ្ឌទី ១ បានចែងទទួលស្គាល់ឱ្យអច្ច័យលាភីអាចបោះបង់អច្ច័យទាននេះបាន ។ ក្នុងនេះ មិនមានកំណត់ពេលវេលានៃការបោះបង់នូវអច្ច័យទានមានកំណត់ទេ ។ ដោយឡែក ដោយសារតែមុនពេលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនទាន់បានទទួលសិទ្ធិអ្វីនៅឡើយទេ ហេតុនេះហើយ ការបោះបង់មុនពេលមរណភាពរបស់ម្ចាស់បណ្តាំមិនមានន័យអ្វីទេ ។ម្យ៉ាងទៀត ក្នុងករណីដែលសន្តតិជនជាអច្ច័យលាភី ប្រសិនបើសន្តតិជននោះបានបោះបង់សន្តតិកម្ម មានន័យថាបានបោះបង់អច្ច័យទានដែរ (មាត្រា ១២០៥) ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ជាបញ្ញត្តិបញ្ជាក់បន្ថែមថា ចំពោះករណីអច្ច័យទានសកល អច្ច័យលាភី មានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងសន្តតិជនដែរ (មាត្រា ១២១២) ដូច្នេះ ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម ។ បានសេចក្តីថា ដើម្បីបោះបង់នូវអច្ច័យទានសកល អច្ច័យលាភីនៃអច្ច័យទានសកលនោះ ត្រូវដាក់ពាក្យសុំការបោះបង់ទៅតុលាការ ក្នុងអំឡុងពេល ៣ ខែ បន្ទាប់ពីបានដឹងថា មានអច្ច័យទានសកលនេះ (មាត្រា ១២៦០) ។

កថាខណ្ឌទី ២ ចែងឡើងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា ក្នុងករណីដែលអច្ច័យលាភីបានបោះបង់អច្ច័យទានអានុភាពនោះត្រូវកើតឡើងដោយប្រតិសកម្ម ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ហើយកម្មវត្ថុនៃអច្ច័យទាននោះត្រូវធ្លាក់ទៅលើសន្តតិជនពីពេលនោះទៅ (មាត្រា ១១៩៨) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

(កំណត់)

មាត្រានេះចែងថា បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះអច្ច័យទាន អាចធ្វើការដាស់តឿនឱ្យអច្ច័យ-លាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ។

បុគ្គលដែលអាចធ្វើការដាស់តឿន គឺជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន (សន្តតិជន អច្ច័យលាភីសកល

ឬ នីតិបុគ្គលមតិក) ហើយក្រៅពីនេះ គឺជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ។ ម្ចាស់បំណុលរបស់បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬ B ដែលជាអច្ច័យលាភីនៃមតកសាសន៍ ដែលមានខ្លឹមសារថា "ធ្វើអច្ច័យទានដីធ្លីមួយកន្លែងទៅឱ្យ A ប៉ុន្តែ ប្រសិនបើ A បោះបង់នូវអច្ច័យទាននេះ ធ្វើអច្ច័យទានទៅឱ្យ B" ជាអាទិ៍ សុទ្ធតែជាជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ។ ភាគីដែលអច្ច័យលាភីត្រូវឆ្លើយឱ្យច្បាស់លាស់អំពីការដាស់តឿននោះ គឺជាបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ដូច្នេះហើយ ពេលដែលជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ធ្វើការដាស់តឿន គួរតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីចំណុចនេះ ។

វាក្យខ័ណ្ឌទី ២ នៃមាត្រានេះចែងថា ប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈរបស់ខ្លួនចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ក្នុងអំឡុងពេលដែលបានកំណត់ក្នុងការដាស់តឿនទេ ត្រូវចាត់ទុកថា បានទទួលស្គាល់អច្ច័យទាន ។ អច្ច័យទាននោះត្រូវបន្តមានអានុភាព លុះត្រាតែអច្ច័យលាភីមិនបានបោះបង់អច្ច័យទានទេ ដូច្នេះបានជាមានការចាត់ទុកដូចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២០៣.– ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលស្គាល់ ឬ ការបោះបង់ដោយសន្តតិជនរបស់អច្ច័យលាភី ក្នុងករណីដែលអច្ច័យលាភីបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬ មិនបានបោះបង់អច្ច័យលាភី ។

ប្រសិនបើអច្ច័យលាភីបានទទួលមរណភាពមុនម្ចាស់បណ្តាំ យោងតាមមាត្រា ១២០០ អច្ច័យទានមិនត្រូវបង្កើតអានុភាពទេ ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បណ្តាំបានទទួលមរណភាពមុនពេលអច្ច័យលាភីបានទទួលមរណភាព អច្ច័យទាននឹងបង្កើតអានុភាព ។ ក្នុងករណីនេះ សន្តតិជនរបស់អច្ច័យលាភីនឹងទទួលសន្តតិកម្មនូវអច្ច័យទាននោះ ។ ក៏ប៉ុន្តែ ប្រសិនបើអច្ច័យលាភីបានទទួលមរណភាពដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទាន សន្តតិជននៃអច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់បានត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។

វាក្យខណ្ឌទី ២ នៃមាត្រានេះ ចែងឡើងដើម្បីគោរពឆន្ទៈរបស់ម្ចាស់បណ្តាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០៤.-** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

(កំណត់)

មាត្រានេះចែងថា អច្ច័យលាភីដែលបានទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទានម្តងហើយ ជាគោលការណ៍ មិនអាចលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់ដែលបានធ្វើនោះទេ ។

កថាខណ្ឌទី ១ ចែងថា អ្នកទទួលសិទ្ធិលើកម្មវត្ថុនៃអច្ច័យទានត្រូវបានកំណត់ដោយការទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទាននេះ ហេតុនេះហើយ ដើម្បីការពារបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ក្នុងកថាខណ្ឌនេះមានចែងថា អច្ច័យលាភីដែលបានទទួលស្គាល់ ឬ បានបោះបង់នូវអច្ច័យទានម្តងហើយ មិនអាចលុបចោលវិញបានទេ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិអញ្ញត្រកម្មនៃកថាខណ្ឌទី ១ ដោយចែងថា ការទទួលស្គាល់ ឬ ការបោះបង់នូវអច្ច័យទានដែលធ្វើឡើងដោយផ្អែកលើការបង្ហាញឆន្ទៈដែលមានវិការៈ អាចលុបចោលវិញបាន ។ ឧទាហរណ៍ ក្នុងករណីដែលអច្ច័យលាភីបានបោះបង់នូវអច្ច័យទាន ដោយសារតែមានការគម្រាមកំហែង ពីជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន អច្ច័យលាភីអាចលុបចោលនូវការបោះបង់អច្ច័យទាននោះវិញបាន ។ កថាខណ្ឌទី ២ តម្រូវឱ្យយកកថាខណ្ឌទី ២ នៃមាត្រា ១២៥២ ស្តីពីការលុបចោលនូវការទទួលស្គាល់ ឬ បោះបង់នូវសន្តតិកម្ម មកអនុវត្តដូចគ្នា រួមទាំងអំឡុងពេលដែលអាចលុបចោលផងដែរ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៩៨៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០៥.-** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួល

ស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិពិសេសស្ដីពីការទទួលស្គាល់ ឬ បោះបង់នូវអច្ច័យទាន ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន ។

ក្នុងកថាខណ្ឌទី ១ ឧទាហរណ៍ថា ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ក៏ប៉ុន្តែ បានធ្វើអច្ច័យទានដោយបញ្ជាក់ថា "ធ្វើអច្ច័យទាន" ឱ្យសន្តតិជននូវទ្រព្យជាក់លាក់មួយ ប្រសិនបើទទួលស្គាល់ឱ្យសន្តតិជនទទួលយកតែអច្ច័យទាន ដោយបោះបង់នូវសន្តតិកម្ម ជននោះនឹងមិនទទួលបន្ទុកនូវកាតព្វកិច្ចទេ គឺទទួលយកតែផលប្រយោជន៍ប៉ុណ្ណោះ ។ ការណ៍នេះគ្មានសមធម៌ទេ ហេតុនេះហើយបានជាចាំបាច់មានបញ្ញត្តិដូចកថាខណ្ឌទី ១ ដើម្បីកុំឱ្យមានការយកតែចំណេញរួចខ្លួននោះ ។ បញ្ញត្តិនេះត្រូវរៀបចំឡើង ដោយពិចារណាផងដែរទៅលើតុល្យភាពជាមួយនឹងចំណុចដែលថា ក្នុងមតកសាសន៍ដែលមានខ្លឹមសារធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាក់លាក់មួយឱ្យសន្តតិជន ត្រូវសន្មតថា បានកំណត់នូវវិធីបែងចែកមតិក ជាអាទិ៍ (មាត្រា ១១៨៥) ដូច្នេះ ប្រសិនបើមិនទទួលស្គាល់សន្តតិកម្មទេ សន្តតិជនមិនអាចធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះទេ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន ទោះបីជាបានទទួលស្គាល់សន្តតិកម្មក៏ដោយ ក៏អាចបោះបង់នូវអច្ច័យទានមានកំណត់ដែរ ។

## មាត្រា ១២០៦.- សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិទទួលផលនៃអច្ច័យទានមានកំណត់ របស់អច្ច័យលាភី ។

"ពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យទាន" តាមធម្មតា សំដៅលើពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ហើយចំពោះករណីអច្ច័យទានដែលមានល័ក្ខខ័ណ្ឌបង្អង់វិញ គឺសំដៅទៅលើពេលដែលសម្រេចល័ក្ខខ័ណ្ឌនោះ ។ វត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាន ត្រូវបានផ្ទេរទៅឱ្យអច្ច័យលាភីនៅពេលនោះ ហេតុដូច្នេះ អច្ច័យលាភីត្រូវធ្វើលទ្ធកម្មសិទ្ធិទទួលផលនៅពេលនោះ ។ សូមបញ្ជាក់ថា "ផល" មានរួមទាំងផលស៊ីវិល ដូចជាការប្រាក់នៃប្រាក់បញ្ញើនៅធនាគារ និងផលធម្មជាតិ ដូចជាផ្លែឈើ ជាអាទិ៍ ។

វាក្យខណ្ឌទី ២ នៃមាត្រានេះ បានចែងច្បាស់លាស់ថា ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ដែលមានខ្លឹមសារផ្សេងពី

វាក្យខណ្ឌទី ១ ។ ឧទាហរណ៍ ប្រសិនបើក្នុងមតកសាសន៍បានចែងថា ផលដែលកើតឡើងមុនពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មិនចាំបាច់ឱ្យទៅអច្ច័យលាភីទេ នោះត្រូវគោរពតាមឆន្ទៈនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០៧.-** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមត៌ក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌ក នៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

(កំណត់)

មាត្រានេះបានបញ្ជាក់ច្បាស់លាស់ថា ចំពោះអច្ច័យទាននៃសិទ្ធិដែលមិនស្ថិតក្នុងមតិក គ្មានអានុភាពទេ ។

អច្ច័យទានគឺជាសកម្មភាពចាត់ចែងមតិក ហេតុនេះហើយ ប្រសិនបើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ មិនស្ថិតនៅក្នុងមតិកនៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាពទេ នោះអានុភាពមិនត្រូវកើតឡើយ ។ ឧទាហរណ៍ ចំនួនសរុបនៃមតិកមាន ១០០០ ដុល្លារ ពេលនោះ ទោះបីជាបានធ្វើមតកសាសន៍ឱ្យទិញដីដែលមានតម្លៃ ៣០០០ ដុល្លារ ឱ្យទៅ A ដែលបានជួយថែរក្សាខ្លួនក៏ដោយ ក៏មិនមានអានុភាពដែរ ។ ជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន មិនចាំបាច់ចេញលុយខ្លួនឯង ដើម្បីប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ទេ ។ ផ្ទុយទៅវិញ ប្រសិនបើមតកសាសន៍ចែងថា ឱ្យលក់ដីជាក់លាក់មួយ ហើយយក ៥០០ ដុល្លារ ពីប្រាក់ដែលបានមកពីការលក់ដីនោះ ឱ្យទៅ A មតកសាសន៍នោះនឹងមានសុពលភាព ។ ទោះបីជានៅក្នុងមតិកគ្មានទ្រព្យជាសាច់ប្រាក់ ឬ ជាប្រាក់បញ្ញើនៅធនាគារក៏ដោយ ក៏មានដីនោះដែរ ដូច្នេះក្នុងករណីនេះ មិនត្រូវអនុវត្តតាមមាត្រានេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩៦ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០៨.-** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

(កំណត់)

មាត្រានេះត្រូវបានចែងឡើងក្នុងគោលបំណងដូចមាត្រាមុនដែរ គឺក្នុងករណីដែលជាអច្ច័យទាននូវវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះ ចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

ឧទាហរណ៍ ក្នុងករណីដែលកម្មវត្ថុនៃអច្ច័យទាន ជាដីដែលត្រូវបានបង្កើតហ៊ីប៉ូតែក អច្ច័យលាភីមិនអាចទាមទារចំពោះសន្តតិជនដែលជាជនមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឱ្យរំលត់ហ៊ីប៉ូតែកនោះ ដោយសងកាតព្វកិច្ចដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះទេ ។ ប្រសិនបើនៅក្នុងមតកសាសន៍មានខ្លឹមសារថា ត្រូវយកប្រាក់បញ្ញើណាមួយមកសងកាតព្វកិច្ចដែលត្រូវបានធានាដោយហ៊ីប៉ូតែក ហើយប្រសិនបើអាចប្រតិបត្តិតាមចំណុចនេះបាន អច្ច័យលាភីអាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍ឱ្យប្រតិបត្តិបាន ។ ក៏ប៉ុន្តែ ប្រសិនបើគ្មានសរសេរដូចខាងលើនេះទេ អច្ច័យលាភីត្រូវទទួលដីដែលមានជាប់នូវបន្ទុកនៃហ៊ីប៉ូតែកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០០ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២០៩.-** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្តាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្តាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

(កំណត់)

មាត្រានេះចែងអំពីការសន្មតឆន្ទៈរបស់ម្ចាស់បណ្តាំ ក្នុងករណីដែលកម្មវត្ថុនៃអច្ច័យទានបានត្រូវបាត់បង់ដោយសារអំពើរបស់តតិយជន ក៏ប៉ុន្តែ ម្ចាស់បណ្តាំមិនបានកែលិខិតមតកសាសន៍នោះទេ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិសម្រាប់ករណីដែលតតិយជនបានធ្វើឱ្យបាត់បង់កម្មវត្ថុនៃអច្ច័យទាន ឬ លួចលក់វត្ថុ

នោះឱ្យអ្នកដទៃ ហើយអ្នកដទៃនោះបានធ្វើលទ្ធកម្មដោយសុចរិត ជាអាទិ៍ ។ ក្នុងករណីដូចនេះ ម្ចាស់បណ្ដាំមានសិទ្ធិទាមទារនូវប្រាក់សំណង ដូចជាសំណងនៃការខូចខាត ជាអាទិ៍ ពីតតិយជននោះ ដូច្នេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានធ្វើអច្ច័យទាននូវសិទ្ធិនោះ ។

កថាខណ្ឌទី ២ ចែងសម្រាប់ករណីវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាបានជាប់គ្នា លាយគ្នា ឬ ច្របល់គ្នានឹងវត្ថុផ្សេងទៀត ។ ចំពោះករណីដូចនេះ អាចមានករណីដែលម្ចាស់បណ្ដាំអាចក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុជាប់គ្នា ជាអាទិ៍ ហើយក៏អាចមានករណីដែលម្ចាស់បណ្ដាំបាត់បង់នូវកម្មសិទ្ធិលើវត្ថុនោះដែរ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ ឬ មាត្រា ១៩៨ ។ ចំពោះករណីទី ១ នេះ កថាខណ្ឌទី ២ នេះបានសន្មតថា កម្មវត្ថុនៃអច្ច័យទាននោះគឺកម្មសិទ្ធិលើវត្ថុទាំងនោះ ឬ ចំណែកកម្មសិទ្ធិអវិភាគ ។ ម្យ៉ាងទៀត ក្នុងករណីដែលបានបាត់បង់កម្មសិទ្ធិលើកម្មវត្ថុនៃអច្ច័យទាននោះ ដោយសារតែលទ្ធផលនៃការភ្ជាប់គ្នានឹងវត្ថុផ្សេង ប្រសិនបើអាចទាមទារនូវប្រាក់សំណងពីតតិយជននោះត្រូវអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ។ ក្នុងករណីដែលម្ចាស់បណ្ដាំបានបាត់បង់នូវកម្មសិទ្ធិលើកម្មវត្ថុនៃអច្ច័យទានដែលត្រូវបានភ្ជាប់ជាផ្នែកមួយនៃវត្ថុផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ខ្លួន ត្រូវចាត់ទុកថា សាមីខ្លួនបានលុបមតកសាសន៍នោះដោយយោងតាមមាត្រា ១១៩០ ។

ដោយហេតុថា មាត្រានេះជាបញ្ញត្តិសន្មត ហេតុនេះហើយ ប្រសិនបើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេង ត្រូវអនុវត្តតាមឆន្ទៈនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមត៌ក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

(កំណត់)

មាត្រានេះចែងអំពីការសន្មតឆន្ទៈរបស់ម្ចាស់បណ្ដាំ ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ហើយម្ចាស់បណ្ដាំបានទទួលការសងចំពោះសិទ្ធិលើបំណុលនោះ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិសម្រាប់ករណីធ្វើអច្ច័យទាននូវសិទ្ធិលើបំណុល ក្រៅពីសិទ្ធិលើបំណុលជាប្រាក់ (ដូចជា សិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) ។ ប្រសិនបើម្ចាស់បណ្តាំបានទទួលការសង (ទទួលការប្រគល់) ពេលដែលនៅរស់ ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថា បានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

កថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់ករណីដែលធ្វើអច្ច័យទាននូវសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ (ឧទាហរណ៍ ប្រាក់បញ្ញើនៅធនាគារ) ។ ប្រសិនបើម្ចាស់បណ្តាំបានទទួលសំណងពេលនៅរស់ ត្រូវសន្មតថា បានយកប្រាក់ និង ប្រាក់បញ្ញើនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានទទួលការសង ។ ប្រសិនបើបានប្រើប្រាស់ប្រាក់ដែលបានទទួលពីការសងនោះទាំងអស់ ភាគច្រើនគឺជាករណីដែលបានចែងក្នុងមាត្រា ១១៩០ ។ ក៏ប៉ុន្តែ ប្រាក់មិនអាចបែងចែកថា ប្រាក់នេះជាប្រាក់ណាមួយទេ ដូច្នេះ តាមច្បាប់រដ្ឋប្បវេណី ការដេញដោលថា ម្ចាស់បណ្តាំបានចំណាយប្រាក់អ្វីមួយនោះ វាគ្មានន័យអ្វីទេ ។ រីឯប្រាក់បញ្ញើក៏អាចចាត់ទុកដូចប្រាក់ដែរ ហេតុនេះហើយបានជា ក្នុងនេះបានសន្មតថា ម្ចាស់បណ្តាំបានយកប្រាក់ទាំងនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមានក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើក្រោយពេលបានទទួលការសង ។

មាត្រានេះជាបញ្ញត្តិសន្មតដែរ ហេតុនេះហើយ ប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង ត្រូវអនុវត្តតាមឆន្ទៈនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១១.–** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងអំពីការទទួលខុសត្រូវរបស់អច្ច័យលាភី ក្នុងករណីដែលមានអច្ច័យទានភ្ជាប់បន្ទុក ។

អច្ច័យទានភ្ជាប់បន្ទុក គឺជាអច្ច័យទានដែលអច្ច័យលាភីត្រូវទទួលបន្ទុកនូវករណីយកិច្ចកំណត់មួយតាមផ្លូវច្បាប់ ។ ឧទាហរណ៍ ប្រសិនបើម្ចាស់បណ្ដាំ A បានធ្វើមតកសាសន៍ដែលមានខ្លឹមសារថា "ធ្វើអច្ច័យទាននូវដីធ្លីមួយឱ្យ B ។ ក៏ប៉ុន្តែ B ត្រូវបង់ឱ្យ C ១000 ដុល្លារ" នេះគឺជាអច្ច័យទានភ្ជាប់បន្ទុក ។

កថាខណ្ឌទី ១ ជាបញ្ញត្តិកំណត់ថា តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន គឺជាកម្រិតនៃការទទួលខុសត្រូវរបស់អច្ច័យលាភីដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុកនោះ ព្រោះថា ជាគោលការណ៍ អច្ច័យទានត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍របស់អច្ច័យលាភី ។ ក្នុងឧទាហរណ៍ខាងលើនេះ ពេលធ្វើមតកសាសន៍ ដីដែលជាកម្មវត្ថុនោះ មានតម្លៃ ២000 ដុល្លារ ហើយ A បានធ្វើមតកសាសន៍ដោយឱ្យ B ទទួលបន្ទុកតែ ១000 ដុល្លារទេ ។ ក៏ប៉ុន្តែ ពេលចាប់ផ្ដើមសន្តតិកម្ម តម្លៃដីនោះបានធ្លាក់ចុះនៅត្រឹមតែ ៨00 ដុល្លារតែប៉ុណ្ណោះ ។ ក្នុងករណីនេះ ប្រសិនបើ B បានបង់ទៅឱ្យ C ជាប្រាក់ចំនួន ៨00 ដុល្លារទៅ នឹងអាចធ្វើលទ្ធកម្មដីនោះហើយ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិចែងអំពីការទទួលខុសត្រូវរបស់អច្ច័យលាភី ចំពោះករណីដែលតម្លៃនៃកម្មវត្ថុនៃអច្ច័យទានដែលមានភ្ជាប់បន្ទុក ត្រូវបានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ឧទាហរណ៍ ដោយសារតែបានទទួលស្គាល់សន្តតិកម្មដោយមានកម្រិត បានជាត្រូវយកសំណងពីកម្មវត្ថុនៃអច្ច័យទានដែលភ្ជាប់បន្ទុកទៅសង ហើយតម្លៃនៃអច្ច័យទាននោះត្រូវធ្លាក់ ។ ប្រសិនបើម្ចាស់បណ្ដាំ A បានធ្វើមតកសាសន៍មួយដែលមានខ្លឹមសារថា "ធ្វើអច្ច័យទានចំពោះ B នូវប្រាក់បញ្ញើនៅធនាគារចំនួន ១000 ដុល្លារ ។ ក៏ប៉ុន្តែ B ត្រូវបង់ឱ្យ C ក្នុងមួយខែ ១0 ដុល្លារ ក្នុងរយៈពេល ៥ ឆ្នាំ ពេលដែល C នៅរស់" ក៏ប៉ុន្តែ ប្រសិនបើបានយក ៥00 ដុល្លារ ពីប្រាក់បញ្ញើនៅធនាគារនោះទៅសងកាតព្វកិច្ចនៅក្នុងមតិក ហើយនៅសល់តែ ៥00 ដុល្លារនោះ ក្នុងករណីនេះ អាចបង់ឱ្យ C ត្រឹមតែកម្រិតនៃ ៥00 ដុល្លារ ជាការគ្រប់គ្រាន់ហើយ ។ ម្យ៉ាងទៀត ចំពោះករណីដែលសន្តតិជនដែលត្រូវបានបំពានភាគបម្រុងរបស់ខ្លួន បានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ចំពោះកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកនោះ ដែលធ្វើឱ្យតម្លៃនៃអច្ច័យទាននោះចុះថយ ក៏ត្រូវអនុវត្តដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១00២ កថាខណ្ឌទី ១ និង មាត្រា ១00៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១២.–** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមតិកទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

(កំណត់)

មាត្រានេះជាបញ្ញត្តិស្តីពីសិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល ។

កថាខណ្ឌទី ១ ចែងថា អច្ច័យលាភីសកលមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងសន្តតិជនដែរ ។ ក្នុងករណីដែលបានធ្វើអច្ច័យទានសកលនូវទ្រព្យសម្បត្តិទាំងអស់ដល់ជនណាម្នាក់ ជននោះអាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិទាំងអស់ នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ហើយជននោះត្រូវទទួលបន្ទុកនូវកាតព្វកិច្ចទាំងអស់ដែលមតកជនមាន ដូច្នេះ ជាក់ស្តែងគឺមិនខុសអ្វីពីការទទួលសន្តតិកម្មដោយសន្តតិជនតែម្នាក់ឯងនោះទេ ។ ម្យ៉ាងទៀត ក្នុងករណីអច្ច័យទានសកល ដោយកំណត់នូវអត្រានោះចាំបាច់ត្រូវធ្វើការបែងចែកមតិកនោះរវាងអច្ច័យលាភីសកលផ្សេងទៀត ឬ សន្តតិជន ហេតុដូច្នេះ ការកំណត់ថាមានសិទ្ធិ និង ករណីយកិច្ចដូចសន្តតិជនដែរនោះ នឹងមានការងាយស្រួល ចំពោះទំនាក់ទំនងតាមផ្លូវច្បាប់ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិបញ្ជាក់ថា ចំពោះករណីអច្ច័យទានសកលឱ្យមតិកទាំងអស់ទៅឱ្យបុគ្គលក្រៅពីសន្តតិជននោះនឹងមានចម្ងល់ថា តើសន្តតិជនត្រូវទទួលបន្ទុកនូវកាតព្វកិច្ចដែលមតកជននោះមាន ឬ យ៉ាងណា ហេតុនេះហើយបានជាត្រូវជាត់ទុកថា សន្តតិជនមិនបានទទួលសន្តតិកម្មទេ ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីការមិនទទួលនូវបន្ទុកនូវកាតព្វកិច្ចនោះ ។ ក៏ប៉ុន្តែ សន្តតិជនមានភាគបម្រុងរបស់ខ្លួន ហេតុដូច្នេះ ចំពោះសិទ្ធិលើភាគបម្រុងនោះ សន្តតិជនអាចអនុវត្តសិទ្ធិក្នុងនាមជាសន្តតិជនបាន ។ ឧទាហរណ៍ ក្នុងករណីដែលឪពុកមានកូន A និង B ក៏ប៉ុន្តែ បានធ្វើអច្ច័យទានសកលនូវមតិកទាំងអស់ឱ្យទៅប្រពន្ធក្រៅច្បាប់ C (ទ្រព្យសកម្មមាន ១០០០ ដុល្លារ បំណុលមាន ២០០ ដុល្លារ) នោះ C នឹងទទួលបន្តទាំងអស់ រីឯ A និង B វិញ មិនទទួលបន្តអ្វីសោះ ។ ក៏ប៉ុន្តែ A និង B មានភាគបម្រុងរបស់ខ្លួន គឺ (១០០០-២០០)÷២÷២=២០០ ដុល្លារម្នាក់ ហេតុនេះហើយ អាចទាមទារឱ្យ C កាត់បន្ថយមតិកអច្ច័យទានដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួនចំពោះចំនួន ២០០ ដុល្លានោះ ។ ដោយឡែក ចំពោះមតកសាសន៍ដែលឱ្យជនម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទទួលសន្តតិកម្មនូវទ្រព្យទាំងអស់ គ្មានបញ្ញត្តិចែងពិសេសអ្វីឡើយ ។ ក៏ប៉ុន្តែ ចំពោះករណីដែល A និង B ជាសន្តតិជន ហើយមតិកសកម្មមាន ១០០០ ដុល្លារ បំណុលមាន ២០០ ដុល្លារ ប្រសិនបើគិតដល់ករណីដែលធ្វើអច្ច័យទានសកលឱ្យ A នោះ B ត្រូវបានបំពានសិទ្ធិលើភាគបម្រុងចំនួន (១០០០-២០០)÷ ២÷២+២០០÷២ = ២០០ ដុល្លារ ដោយយោងតាមមាត្រា ១២៣១ និង មាត្រា ១២៣៤ ដូច្នេះ ដូចករណីខាងលើដែរ គឺ B អាចទាមទារឱ្យកាត់បន្ថយ ២០០ ដុល្លារ ដែលជាភាគបម្រុងរបស់ខ្លួនបាន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩៩០ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

# ផ្នែកទី ៧ ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

(កំណត់)

មាត្រានេះបញ្ញត្តឡើងដើម្បីកំណត់នូវនីតិវិធីនៃការពិនិត្យបញ្ជាក់ក្នុងតុលាការ នូវមតកសាសន៍ ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត។

ចំពោះមតកសាសន៍ដែលធ្វើឡើងក្រៅពីលិខិតយថាភូត ចាំបាច់ត្រូវធ្វើការពិនិត្យបញ្ជាក់លិខិតមតកសាសន៍នោះ ។ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ធ្វើឡើងដើម្បីឱ្យជនដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍បញ្ជាក់ដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះត្រឹមពេលនោះ ជៀសវាងកុំឱ្យមានការលួចកែប្រែក្រោយការពិនិត្យបញ្ជាក់នោះ ។ ដូច្នេះ ទោះជាមានបញ្ហាទាក់ទងនឹងទម្រង់ ឬ ខ្លឹមសារ នៃមតកសាសន៍ក៏ដោយ ក៏នីតិវិធីបញ្ជាក់ត្រូវបានអនុវត្តដែរ ។

កថាខណ្ឌទី ១ ចែងអំពីជនដែលមានករណីយកិច្ចដាក់ពាក្យសុំ និង ពេលវេលាដែលត្រូវដាក់ពាក្យសុំធ្វើការពិនិត្យបញ្ជាក់ ។ ជនដែលមានករណីយកិច្ច គឺជាអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ឬ សន្តតិជនដែលបានរកឃើញលិខិតនោះ ឬ ជនពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត ។ បញ្ញត្តិនេះបានចែងថា អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំឱ្យធ្វើការពិនិត្យបញ្ជាក់ នៅពេលចាប់ផ្តើមសន្តតិកម្ម មានន័យថា ក្រោយពីបានដឹងថា ម្ចាស់បណ្តាំបានទទួលមរណភាព រីឯជនដែលបានរកឃើញលិខិតមតកសាសន៍វិញ ត្រូវដាក់ពាក្យសុំក្រោយពេលដែលរកឃើញលិខិតនោះដោយគ្មានការយឺតយ៉ាវ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលជាលិខិតមតកសាសន៍ដោយលិខិតយថាភូត មិនចាំបាច់ធ្វើការពិនិត្យបញ្ជាក់ ទេ។ នេះគឺដោយសារតែលិខិតមតកសាសន៍ដោយលិខិតយថាភូតមិនសូវមានការលួចកែប្រែទេ ។

កថាខណ្ឌទី ៣ ចែងថា ចំពោះមតកសាសន៍ដែលបិទដោយប្រថាប់ត្រាវិញ ត្រូវបើកនៅក្នុងនីតិវិធីនៃការពិនិត្យបញ្ជាក់នៅតុលាការ ដើម្បីការពារកុំឱ្យមានការលួចកែប្រែ ។ ម្យ៉ាងទៀត កថាខណ្ឌទី ៤ ត្រូវបានចែងឡើងដើម្បីធានាឱ្យមានការគោរពតាមកថាខណ្ឌទី ៣ ហើយបញ្ញត្តអំពីការពិន័យស៊ីវិលជាប្រាក់ ក្នុងករណីដែលបានប្រព្រឹត្តផ្ទុយនឹងកថាខណ្ឌទី ៣ ដោយបានបើកលិខិតនោះដោយឯកឯង ។

កថាខណ្ឌទី ៥ ជាបញ្ញត្តិដើម្បីបញ្ជាក់ថា ទោះជាមានអ្នកណាធ្វើខុសនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ដោយបើកលិខិតមតកសាសន៍ ក្រៅនីតិវិធីពិនិត្យបញ្ជាក់របស់តុលាការក៏ដោយ ក៏លិខិតមតកសាសន៍មិនអាចក្លាយជាមោឃៈដោយមូលហេតុនេះដែរ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៧១ និង វាក្យខណ្ឌទី ៣ មាត្រា ៥៧៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១២១៤.- ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃករណីដែលម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមមាត្រា ១១៨៦ ។

កថាខណ្ឌទី ១ ចែងថា ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។ ម្យ៉ាងទៀត ប្រសិនបើម្ចាស់បណ្តាំមិនបានហាមទេ ជនដែលបានទទួលអាណត្តិនេះ អាចកំណត់យកខ្លួនឯងធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ក៏បានដែរ ។

ទោះបីជាបានទទួលអាណត្តិពីម្ចាស់បណ្តាំឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ក៏ដោយ ក៏មិនមែនបានសេចក្តីថា ជនដែលបានទទួលអាណត្តិនោះ មានករណីយកិច្ចត្រូវតែទទួលមុខងារនេះដោយស្វ័យប្រវត្តិដែរ ពោលគឺជននោះអាចបដិសេធមិនទទួលអាណត្តិបាន ។ កថាខណ្ឌទី ២ ត្រូវបានបញ្ញត្តឡើងដោយយកគំនិតនេះជាមូលដ្ឋាន ។ ក៏ប៉ុន្តែ ក្នុងករណីដែលម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ប្រសិនបើតតិយជននោះមិនបានលុបចោលនូវអាណត្តិនេះវិញទេ មិនអាចយកនីតិវិធីផ្សេងណាមួយ ដើម្បីធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ហេតុនេះហើយ ប្រសិនបើជនដែលបានទទួលអាណត្តិនោះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

ម្យ៉ាងទៀត ក្នុងករណីដែលជនដែលបានទទួលអាណត្តិមិនបានធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងមិនបង្ហាញឆន្ទៈលាឈប់ពីអាណត្តិនេះទេ នីតិវិធីនៃការដាស់តឿន នឹងត្រូវបានធ្វើឡើង ដោយយោងតាមមាត្រា ១២១៦ កថាខណ្ឌទី ២ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១៥.–** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

(កំណត់)

មាត្រានេះចែងអំពីការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍ ។

ម្ចាស់បណ្តាំអាចធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍បាន ដោយយោងតាមមាត្រា ១១៨៦ ក៏ប៉ុន្តែ អ្នកដែលត្រូវបានកំណត់ឱ្យបំពេញមុខងារជាអ្នកប្រតិបត្តិមតកសាសន៍នោះ ទទួលកាន់មុខងារនោះ ឬ យ៉ាងណា គឺត្រូវគោរពតាមឆន្ទៈរបស់ជននោះ ។ ហេតុនេះហើយបានជាចាំបាច់មានបញ្ញត្តិនេះ ។

ម្យ៉ាងទៀត ជនដែលត្រូវបានប្រគល់អាណត្តិឱ្យធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការកំណត់អ្នកប្រតិបត្តិ

មតកសាសន៍តាមបញ្ញត្តិនៃមាត្រាមុននេះ ហើយក្រៅពីនេះ តុលាការក៏អាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមមាត្រា ១២១៨ ដែរ ។ ក្នុងករណីនេះ តាមធម្មតា ត្រូវសួរយោបល់អ្នកដែលត្រូវបានកំណត់ ឬ នឹងត្រូវបានជ្រើសតាំងនោះសិន មុននឹងធ្វើការកំណត់ ឬ ជ្រើសតាំង ហើយបើអ្នកដែលបានទទួលនូវការកំណត់ ឬ ជ្រើសតាំង ជាអ្នកប្រតិបត្តិមតកសាសន៍នោះ បានយល់ព្រមកាន់មុខងារនេះហើយ ត្រូវអនុវត្តភារកិច្ចនោះជាបន្ទាន់ ។

ម្យ៉ាងទៀត ប្រសិនបើបានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ មិនអាចដកការយល់ព្រមនោះវិញបានទេ ។ ដើម្បីលាឈប់ ត្រូវមានការអនុញ្ញាតពីតុលាការ ដោយយោងតាមមាត្រា ១២២៧ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១៦.–** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីសម្រាប់ករណីដែលអ្នកដែលត្រូវបានកំណត់ឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ឬ តតិយជនដែលត្រូវបានប្រគល់អាណត្តិឱ្យធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ មិនមានធ្វើអ្វីឡើយ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិសម្រាប់ករណីដែលអ្នកដែលត្រូវបានកំណត់ឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ មិនបានបង្ហាញឆន្ទៈឱ្យបានច្បាស់លាស់ថា យល់ព្រម ឬ បដិសេធនូវការកាន់មុខងារនេះ ។ ការកាន់ ឬ មិនកាន់មុខងារនេះ ជាការណ៍មួយដែលសន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មានការចាប់អារម្មណ៍ខ្លាំងណាស់ ។ ម្យ៉ាងទៀត ប្រសិនបើគ្មាន

អ្នកប្រតិបត្តិមតកសាសន៍ទេ មិនអាចប្រតិបត្តិមតកសាសន៍នោះបានឡើយ ហេតុនេះហើយបានជាបញ្ញត្តឱ្យអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចធ្វើការដាស់តឿន ដើម្បីឱ្យអ្នកនោះឆ្លើយបញ្ជាក់ថា តើយល់ព្រមកាន់មុខងារនោះ ឬយ៉ាងណា ។ ហើយប្រសិនបើជនដែលត្រូវបានកំណត់ឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍នោះ នៅតែមិនឆ្លើយតបនឹងការដាស់តឿននោះ ត្រូវចាត់ទុកថា ជននោះបានបដិសេធមិនកាន់មុខងារនេះ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់ករណីដែលតតិយជនដែលត្រូវបានប្រគល់អាណត្តិឱ្យធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ មិនបានធ្វើការកំណត់នេះឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ ក៏ដូចគ្នាដែរ គឺឱ្យជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចធ្វើការដាស់តឿនបាន ។

ប្រសិនបើបានចាត់ទុកថា អ្នកនោះបានបដិសេធការកាន់មុខងារ តាមនីតិវិធីទាំងនេះ តុលាការត្រូវធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមមាត្រា ១២១៨ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២១៧.- បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជនធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីមូលហេតុនៃការខ្វះលក្ខណសម្បត្តិធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ។

អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកធ្វើសកម្មភាពគតិយុត្ត នៅពេលប្រតិបត្តិមតកសាសន៍ ហេតុនេះហើយ ការដែលកំណត់ថា ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព មិនមានលក្ខណសម្បត្តិធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ គឺជាការសមរម្យ ។ នេះគឺជាទស្សនៈដូចគ្នានឹងមាត្រា ៦៤៩ ដែលចែងអំពីមូលហេតុនៃការបញ្ចប់អាណត្តិដែរ ។ម្យ៉ាងទៀត ទោះជាគ្មានមូលហេតុកង្វះលក្ខណសម្បត្តិជាអ្នកប្រតិបត្តិមតកសាសន៍នៅពេលចូលកាន់មុខងារក៏ដោយ តែប្រសិនបើមានមូលហេតុដូចដែលមានចែងក្នុងមាត្រា ៦៤៩ កថាខណ្ឌទី ១ បានកើតឡើងក្រោយការកាន់មុខងារ នោះក៏ត្រូវបាត់បង់ឋានៈជាអ្នកប្រតិបត្តិមតកសាសន៍នេះដែរ ។ ព្រោះថា យោងតាមមាត្រា ១២២៩ បញ្ញត្តិស្តីពីអាណត្តិ ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកប្រតិបត្តិមតកសាសន៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១៨.–** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

(កំណត់)

មាត្រានេះចែងថា តុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ ។

ម្ចាស់បណ្តាំអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ដោយមតកសាសន៍បាន ។ ក៏ប៉ុន្តែ ក្នុងករណីដែលមិនបានធ្វើមតកសាសន៍ស្តីពីបញ្ហានេះ ឬ ក្នុងករណីដែលអ្នកត្រូវបានជ្រើសតាំងនោះបដិសេធមិនព្រមកាន់មុខងារទេ នោះមានន័យថា អ្នកប្រតិបត្តិមតកសាសន៍គ្មានវត្តមានតាំងពីដើមមក ។ ម្យ៉ាងទៀត អាចមានករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានកាន់មុខងារហើយ តែក្រោយមក បានទទួលការអនុញ្ញាតពីតុលាការឱ្យលាឈប់ ឬ ក៏បានទទួលមរណភាព ឬ ក៏មានមូលហេតុនៃការខ្វះលក្ខណសម្បត្តិចំពោះជនដដែលនោះកើតមានឡើង ។ ចំពោះករណីទាំងនេះ តុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមការទាមទាររបស់សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍បាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២១៩.–** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

(កំណត់)

មាត្រានេះចែងថា ក្រោយពីបានកាន់មុខងារហើយ ដំបូងបំផុត អ្នកប្រតិបត្តិមតកសាសន៍ត្រូវរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ភ្លាម ។

បញ្ជីសារពើភ័ណ្ឌមតិកនេះចាំបាច់មាន ដើម្បីកំណត់ច្បាស់លាស់នូវកម្មវត្ថុនៃសិទ្ធិគ្រប់គ្រងចាត់ចែងមតិក (មាត្រា

១២២០) របស់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃករណីយកិច្ចប្រគល់ ( មាត្រា ១២២៩ និង មាត្រា ៦៤២) ករណីយកិច្ចរាយការណ៍ ( មាត្រា ១២២៩ និង មាត្រា ៦៤១) ព្រមទាំងករណីយកិច្ចសងសំណង ( មាត្រា ១២២៩ និង មាត្រា ៦៤៣) របស់អ្នកប្រតិបត្តិមតកសាសន៍ ។ ដូច្នេះ កថាខណ្ឌទី ១ បានចែងថា អ្នកប្រតិបត្តិមតកសាសន៍ ដំបូងបំផុត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌមតិក ហើយត្រូវប្រគល់បញ្ជីនោះទៅឱ្យសន្តតិជន ។

កថាខណ្ឌទី ២ ចែងអនុញ្ញាតឱ្យសន្តតិជនមានវត្តមានក្នុងពេលធ្វើបញ្ជីសារពើភ័ណ្ឌមតិកនេះ ដើម្បីឱ្យមានភាពច្បាស់លាស់ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១០១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២២០.– សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

( កំណត់)

មាត្រានេះចែងបញ្ជាក់ថា អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចដែលចាំបាច់ដើម្បីធ្វើរាល់សកម្មភាពក្នុងការប្រតិបត្តិមតកសាសន៍ នៅក្នុងសិទ្ធិអំណាច និង មុខនាទីរបស់ខ្លួន ។

អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកដែលត្រូវបានជ្រើសតាំងដើម្បីប្រតិបត្តិមតកសាសន៍ ហេតុនេះហើយ ត្រូវផ្តល់សិទ្ធិ និង ករណីយកិច្ច ដើម្បីគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍តាមបញ្ញត្តិនៃមាត្រានេះ ។ អ្នកប្រតិបត្តិមតកសាសន៍នៃមតិកទាំងអស់អាចសងនូវកាតព្វកិច្ចដែលជាមតិក រីឯម្ចាស់បំណុលរបស់មតកជនវិញ ក៏អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នេះសងបំណុលបានដែរ ។ ម្យ៉ាងទៀត ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍មិនអនុវត្តអច្ច័យទានតាមការចែងក្នុងមតកសាសន៍ទេ អច្ច័យលាភីអាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នោះអនុវត្តបាន ។

( មាត្រាពាក់ព័ន្ធ)

មាត្រា១០១២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៧៧ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១២២១.– ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនគ្មានសិទ្ធិចាត់ចែងមតិកទេ ។

មតិកត្រូវធ្លាក់ទៅលើសន្តតិជន ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា ១១៤៧ កថាខណ្ឌទី ១) ។ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ ក៏ដូចគ្នាដែរ ។ ចំពោះករណីអច្ច័យទានមានកំណត់ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ត្រូវក្លាយជារបស់អច្ច័យលាភី ព្រមគ្នានឹងពេលដែលមតកសាសន៍បង្កើតអានុភាព ក៏ប៉ុន្តែ ករណីយកិច្ចចុះបញ្ជីស្តីពីការផ្ទេរកម្មសិទ្ធិ និង ករណីយកិច្ចប្រគល់នូវវត្ថុដែលជាកម្មវត្ថុ ជាដើម គឺក្លាយទៅជាបន្ទុករបស់សន្តតិជន ។ អ្នកប្រតិបត្តិមតកសាសន៍មានតែសិទ្ធិគ្រប់គ្រងចាត់ចែងមតិកប៉ុណ្ណោះ មិនមែនជាប្រធាននៃសិទ្ធិ និង ករណីយកិច្ចទេ ។ ក៏ប៉ុន្តែ ទោះជាសន្តតិជនជាប្រធាននៃសិទ្ធិ និង ករណីយកិច្ចក៏ដោយ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ ប្រសិនបើសន្តតិជនមានសិទ្ធិចាត់ចែងផងដែរ នោះអាចមានករណីដែលការចាត់ចែងរបស់អ្នកប្រតិបត្តិមតកសាសន៍ និង របស់សន្តតិជន មិនស៊ីគ្នា ហើយធ្វើឱ្យអ្នកប្រតិបត្តិមតកសាសន៍មិនអាចបំពេញមុខនាទីបានពេញលេញ (ឧទាហរណ៍ ដូចជាការអនុវត្តករណីយកិច្ចចុះបញ្ជីស្តីពីការផ្ទេរកម្មសិទ្ធិ ដែលត្រូវជាបន្ទុករបស់សន្តតិជន ក្នុងករណីអច្ច័យទានមានកំណត់ជាដើម) ។ ដូច្នេះហើយបានជាមាត្រានេះបានដកហូតសិទ្ធិចាត់ចែងពីសន្តតិជន ។

កថាខណ្ឌទី ២ ជាបញ្ញត្តិបញ្ជាក់ឱ្យបានច្បាស់លាស់នូវគោលគំនិតនៃកថាខណ្ឌទី ១ ។ សូមមើលសាលដីការបស់តុលាការកំពូលជប៉ុនចាស់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៣០ និង សាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៨៧ ។ ម្យ៉ាងទៀត ប្រសិនបើកូនបំណុលរបស់មតកជនបានសងបំណុលចំពោះសន្តតិជន ដោយមិនបានដឹងនូវវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ អាចអនុវត្តតាមមាត្រា ៤៣៩ បាន ហើយប្រសិនបើជនណាបានទិញចលនវត្ថុដែលជាមតិកពីសន្តតិជន អាចអនុវត្តតាមមាត្រា ១៩៣ បាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២២.-** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១ (ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែ

ទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលខ្លឹមសារនៃមតកសាសន៍មានតែចំពោះមតិកមួយភាគ មិនមែនទាំងអស់ បញ្ញត្តិស្តីពីសិទ្ធិ និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវអនុវត្តតែចំពោះភាគនៃមតិកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១២២៣.-** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងរវាងអ្នកប្រតិបត្តិមតកសាសន៍ និង មតិក ព្រមទាំងសន្តតិជនដែលជាប្រធាននៃមតិកនោះ ។

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិគ្រប់គ្រងចាត់ចែងមតិក (មាត្រា ១២២០) ប៉ុន្តែ សន្តតិជនជាប្រធាននៃមតិក ។ ដូច្នេះ មានចម្ងល់ថា នៅក្នុងបណ្តឹង ជាអាទិ៍ តើគួរសរសេរថា "អ្នកប្រតិបត្តិមតកសាសន៍ ដែលជាអ្នកតំណាងរបស់សន្តតិជន ០០" ដែរឬទេ ។ ហេតុនេះហើយបានជាកថាខណ្ឌទី ១ បានបញ្ជាក់ច្បាស់លាស់ថា អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិក ។ ឧទាហរណ៍ជាក់ស្តែង គឺអ្នកប្រតិបត្តិមតកសាសន៍ A ត្រូវធ្វើសកម្មភាពគតិយុត្តក្នុងនាមសាមីខ្លួនជា A នោះ ដោយបញ្ជាក់សរសេរថា "អ្នកប្រតិបត្តិមតកសាសន៍របស់មតកជនឈ្មោះ ០០" ។

កថាខណ្ឌទី ២ ចែងថា សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានអនុវត្តក្នុងនាមមុខនាទីរបស់ខ្លួន ត្រូវមានអានុភាព ចំពោះសន្តតិជនដែលជាប្រធាននៃមតិក ដូចជាករណីដែលសកម្មភាពរបស់អ្នកតំណាង មានអានុភាពផ្ទាល់ចំពោះម្ចាស់សិទ្ធិដែរ ។ ហេតុដូច្នេះ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ អនុវត្តអច្ច័យទាន គេវាយតម្លៃថា សន្តតិជនដែលជាអ្នកមានករណីយកិច្ចធ្វើអច្ច័យទាន បានអនុវត្តអច្ច័យទាននោះដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន បានចាត់ទុកថា អ្នកប្រតិបត្តិមតកសាសន៍ ជាអ្នកតំណាងរបស់សន្តតិជន

ក៏ប៉ុន្តែ ដោយមានការរិះគន់ច្រើន ហេតុនេះហើយបានជាត្រូវចែងបញ្ជាក់ឱ្យច្បាស់ ។

**មាត្រា ១២២៤.-** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលអ្នកប្រតិបត្តិមតកសាសន៍ឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួន ។

កថាខណ្ឌទី ១ ជាបញ្ញត្តិចែងច្បាស់លាស់ថា ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍មិនអាចឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួនបានឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុដែលពុំអាចជៀសវាងបានទេ ព្រមទាំងក្នុងករណីដែលមានការចែងអនុញ្ញាតទុកជាមុនក្នុងលិខិតមតកសាសន៍ អាចឱ្យតតិយជនអនុវត្តកិច្ចការនោះបាន ។ ការមិនអនុញ្ញាតឱ្យតតិយជនអនុវត្តកិច្ចការនេះ ជាគោលការណ៍ គឺដោយសារតែមតកជនបានជឿទុកចិត្តទៅលើចំណេះដឹង និង សមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ហើយបានជ្រើសតាំងអ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ដោយប្រគល់សិទ្ធិដែលមានលក្ខណៈជាផ្តាច់មុខ ដូច្នេះ គឺមានន័យដូចគ្នានឹងអ្នកតំណាងដែលបានធ្វើកិច្ចសន្យាជាមួយម្ចាស់សិទ្ធិដែរ (មាត្រា ៣៧៦) ។

កថាខណ្ឌទី ២ ចែងអំពីការទទួលខុសត្រូវរបស់អ្នកប្រតិបត្តិមតកសាសន៍ ក្នុងករណីដែលបានឱ្យតតិយជនអនុវត្តកិច្ចការរបស់ខ្លួន ។ ជាបឋម ក្នុងករណីដែលអាចឱ្យតតិយជនអនុវត្តកិច្ចការនោះដោយយោងតាមកថាខណ្ឌទី ១ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និង សន្តតិជន ក្នុងការជ្រើសតាំង និង ត្រួតពិនិត្យតតិយជននោះ ។ ការទទួលខុសត្រូវនេះ ដូចគ្នានឹងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាង (មាត្រា ៣៧៧ កថាខណ្ឌទី ១) ។ បន្ទាប់មក ក្នុងករណីដែលបានជ្រើសតាំងឱ្យតតិយជនអនុវត្តកិច្ចការ ដោយខុសនឹងកថាខណ្ឌទី ១ នេះ នោះនឹងក្លាយជាការមិនបានបំពេញករណីយកិច្ច ហេតុនេះហើយត្រូវសងនូវសំណងនៃការខូចខាតទាំងស្រុង ដែលមិនអាច

កើតឡើង ប្រសិនបើមិនបានឱ្យតតិយជននោះអនុវត្តកិច្ចការជំនួសនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

(កំណត់)

មាត្រានេះចែងអំពីការប្រតិបត្តិកិច្ចការ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ ។

ក្រមនេះគ្មានបញ្ញត្តិណាមួយធ្វើការកម្រិតនូវចំនួនអ្នកប្រតិបត្តិមតកសាសន៍ទេ ដូច្នេះ ម្ចាស់បណ្តាំ ឬ តុលាការអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់បាន ។ កថាខណ្ឌទី ១ ចែងថា ក្នុងករណីនេះ ការប្រតិបត្តិកិច្ចការត្រូវធ្វើដោយមតិភាគច្រើន ។ នេះគឺជាគោលគំនិតដូចក្នុងមាត្រា ២០៨ ស្តីពីការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ និងមាត្រា ៧០២ ស្តីពីវិធីអនុវត្តកិច្ចការរបស់ក្រុមហ៊ុនដែរ ។ ក៏ប៉ុន្តែ ប្រសិនបើលិខិតមតកសាសន៍មានចែងថា បើមានការខ្វែងគំនិតគ្នារវាងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ ត្រូវស្តាប់យោបល់បុគ្គលពិសេសណាម្នាក់ ត្រូវគោរពតាមឆន្ទៈនោះ ។ ម្យ៉ាងទៀត ពេលធ្វើបណ្តឹង សហអ្នកប្រតិបត្តិមតកសាសន៍ទាំងអស់ត្រូវបំពេញកិច្ចការជាមួយគ្នា ។ ការដែលសហអ្នកប្រតិបត្តិមតកសាសន៍ណាម្នាក់ទទួលនូវសាលក្រមតែម្នាក់ឯង គឺមានភាពផ្ទុយនឹងគោលគំនិតដែលហាមមិនឱ្យសហអ្នកប្រតិបត្តិមតកសាសន៍ណាម្នាក់ចាត់ចែងមតិកតែម្នាក់ឯង ក្នុងករណីដែលមានសហអ្នកប្រតិបត្តិមតកសាសន៍ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការកំណត់នូវមុខងារ និង សិទ្ធិរបស់សហអ្នកសហប្រតិបត្តិមតកសាសន៍ម្នាក់ៗ តាមមតកសាសន៍ (ឧទាហរណ៍ A មានសិទ្ធិសម្រេចអ្វីៗស្តីពីអចលនទ្រព្យ ហើយ B មានសិទ្ធិសម្រេចអ្វីៗស្តីពីសិទ្ធិលើបំណុលជាអាទិ៍) ចំពោះចំណុចនោះ អាចចាត់ចែងដោយឯកឯងបាន ហើយអាចក្លាយជាភាគីនៃបណ្តឹងតែឯងបាន ។

កថាខណ្ឌទី ២ មានចែងបញ្ជាក់ថា ចំពោះសកម្មភាពរក្សាទុកវិញ អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ៗ អាចធ្វើតែឯងបាន ។ នេះមានគោលគំនិតដូចក្នុងមាត្រា ២០៦ ស្តីពីការថែទាំវត្ថុកម្មសិទ្ធិអវិភាគដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

(កំណត់)

មាត្រានេះជាបញ្ញត្តិចែងអំពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ ។

ការប្រតិបត្តិមតកសាសន៍ ក៏ដូចការងារអាណត្តិដែរ អាចមានពីរយ៉ាង គឺការប្រតិបត្តិដោយយកកម្រៃ និង ការប្រតិបត្តិដោយមិនយកកម្រៃ ។ ក៏ប៉ុន្តែ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និងធ្វើរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ ម្យ៉ាងទៀត ពេលប្រតិបត្តិកិច្ចការនោះ ត្រូវចាត់ចែងកិច្ចការដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត (មាត្រា ៦៤០) ហើយបន្ទុកមុខងារនេះធ្ងន់ធ្ងរណាស់ ដូច្នេះគួរតែទទួលកម្រៃ ។ ជាពិសេស ក្នុងករណីដែលបានជ្រើសតាំងតតិយជនដែលមិនមែនជាសន្តតិជន ឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ គួរតែមានកម្រៃ ។

រីឯចំនួនទឹកប្រាក់នៃកម្រៃនោះវិញ យោងតាមកថាខណ្ឌទី ១ ប្រសិនបើមានកំណត់នៅក្នុងលិខិតមតកសាសន៍ ត្រូវអនុវត្តតាមមតកសាសន៍នោះ ។ ប្រសិនបើក្នុងមតកសាសន៍កំណត់ថា ពុំមានកម្រៃទេ នោះមិនមានសិទ្ធិទាមទារកម្រៃទេ ដូច្នេះ បើមិនពេញចិត្ត អាចបដិសេធមិនកាន់មុខងារនេះបាន ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ។ នៅក្នុងកថាខណ្ឌដដែលនេះ មានប្រើឃ្លា "បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ" គឺដោយសារថា អាចមានករណីដែលសន្តតិជនធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ហើយដែលការប្រតិបត្តិនោះមានភាពងាយស្រួល ដូច្នេះ មិនចាំបាច់ឱ្យកម្រៃក៏បានដែរ ។ ក្នុងករណីដែលតតិយជនជាអ្នកប្រតិបត្តិមតកសាសន៍ ទោះជាតិចក៏ដោយ ក៏តុលាការគួរតែកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះដែរ ។ ពេលកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះ ត្រូវពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងស្ថានភាពផ្សេងៗទៀត ។ ឧទាហរណ៍ដូចជា ប្រសិនបើតុលាការបានជ្រើសតាំងមេធាវី ជាអាទិ៍ ដែលជាអ្នកមានជំនាញខាងច្បាប់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ជាពិសេស ក្នុងករណីដែលបានធ្វើបណ្តឹង ដើម្បីប្រតិបត្តិមតកសាសន៍នោះ ត្រូវផ្តល់កម្រៃឱ្យបានសមរម្យតាមនោះដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២៧.-** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្ដីពីការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ដោយមានខ្លឹមសារថា ដើម្បីលាឈប់ ឬ បញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវមានការសម្រេចដោយតុលាការ ។

កថាខណ្ឌទី ១ បានបញ្ជាក់ថា ដើម្បីលាឈប់ពីមុខងាររបស់ខ្លួន អ្នកប្រតិបត្តិមតកសាសន៍ត្រូវមានមូលហេតុត្រឹមត្រូវ ហើយចាំបាច់មានការអនុញ្ញាតពីតុលាការ ។ នេះគឺដោយសារតែមុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍ គឺធ្វើឱ្យបានសម្រេចនូវឆន្ទៈរបស់មតកជនដែលបានទទួលមរណភាពហើយ ហេតុនេះហើយ មានន័យដូចជាការងារអាណាព្យាបាលមួយប្រភេទដែរ ។ មូលហេតុត្រឹមត្រូវនោះមានដូចជា មានជម្ងឺ ទៅបំពេញបេសកកម្មនៅឆ្ងាយរយៈពេលវែង កាន់កាប់មុខងារមួយថ្មីដែលមមាញឹកហួសហេតុ ជាអាទិ៍ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ។ បញ្ញត្តិនេះចែងថា ប្រសិនបើមានមូលហេតុត្រឹមត្រូវ ជនដែលទាក់ទងនឹងផលប្រយោជន៍ ដូចជាសន្តតិជន ឬ អច្ច័យលាភី ជាអាទិ៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍នោះបាន ។ មូលហេតុនៃការបញ្ឈប់មានដូចជា ភាពខ្ជិលច្រអូសបំពេញមុខងារ ការបាត់ខ្លួនរបស់អ្នកប្រតិបត្តិមតកសាសន៍ មានជម្ងឺរយៈពេលវែងដែលជាឧបសគ្គក្នុងការប្រតិបត្តិ ជាអាទិ៍ ។ម្យ៉ាងទៀត ក្នុងករណីដែលមានមូលហេតុដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ បានកើតឡើង ដូចមានចែងក្នុងមាត្រា ១២១៧ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវបាត់បង់ដោយស្វ័យប្រវត្តិនូវឋានៈរបស់ខ្លួន ហេតុនេះហើយ សន្តតិជន ឬ ជនដែលទាក់ទងនឹងផលប្រយោជន៍ផ្សេងទៀត អាចដាក់ពាក្យសុំទៅតុលាការឱ្យជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ថ្មី តាមមាត្រា ១២១៨ បាន ដោយមិនចាំបាច់មាននីតិវិធីសុំឱ្យបញ្ឈប់ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

(កំណត់)

មាត្រានេះចែងថា សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ ជាបន្ទុកមួយនៃមតិក ហេតុនេះហើយ អាចកាត់ពីមតិកនោះបាន ។

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់សម្រាប់នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមតិក សោហ៊ុយគ្រប់គ្រងមតិក កម្រៃអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ ។ អ្នកប្រតិបត្តិមតកសាសន៍ អាចកាត់សោហ៊ុយទាំងនេះពីមតិកបាន ។

វាក្យខណ្ឌទី ២ នៃមាត្រានេះចែងថា ការកាត់សោហ៊ុយប្រតិបត្តិមតកសាសន៍នេះមិនអាចបន្ថយភាគបម្រុងបានទេ ។ ដូច្នេះ ភាគនៃសោហ៊ុយដែលអាចបន្ថយភាគបម្រុងនោះ ជាបន្ទុករបស់អច្ច័យលាភី ។ ឧទាហរណ៍ មតិកមាន ១០០០ ដុល្លារ ហើយសន្តតិជន A និង B ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា ។ មតកជនបានធ្វើមតកសាសន៍ ដោយគិតដល់ភាគបម្រុងរបស់ B (២៥០ ដុល្លារ) ហើយបានកំណត់ឱ្យ A ៧៣០ ដុល្លារ ។ រីឯសោហ៊ុយប្រតិបត្តិមតកសាសន៍វិញ ត្រូវចំណាយអស់ ៥០ ដុល្លារ ។ ក្នុងករណីនេះ តាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ សោហ៊ុយ ៥០ ដុល្លារ ត្រូវយកពីមតិក ២៧០ ដុល្លារដែលនៅសល់ បន្ទាប់ពីផ្តល់ឱ្យA ចំនួន ៧៣០ ដុល្លាររួច ក៏ប៉ុន្តែ តាមវាក្យខណ្ឌទី ២ វិញ អាចកាត់យកត្រឹមតែ ២០ ដុល្លារ ដែលនៅសល់ពីភាគបម្រុងតែប៉ុណ្ណោះ នៅសល់ ៣០ ដុល្លារទៀត ជាបន្ទុករបស់ A ដែលបានទទួលលទ្ធកម្ម ៧៣០ ដុល្លារ តាមមតកសាសន៍ ។ ប្រសិនបើ B មិនទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទេ ត្រូវកាត់សោហ៊ុយពី ២៧០ ដុល្លារ ដែលជាមតិកសល់នោះ ដោយយោងតាមវាក្យខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ ប្រសិនបើមិនមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះទេ ។

បញ្ញត្តិស្តីពីអាណត្តិ ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ដោយយោងតាមមាត្រានេះ មានដូចជា មាត្រា ៦៤០ ស្តីពីករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក, មាត្រា ៦៤១ ស្តីពីករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក, មាត្រា ៦៤២ ស្តីពីករណីយកិច្ចប្រគល់របស់អាណត្តិគាហក, មាត្រា ៦៤៣ ស្តីពីករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់, មាត្រា ៦៤៥ ស្តីពីករណីយកិច្ចបង់សោហ៊ុយជាមុនរបស់អាណត្តិទាយក, មាត្រា ៦៤៦ ស្តីពីសិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក, មាត្រា ៦៤៩ ស្តីពីមូលហេតុនៃការបញ្ចប់អាណត្តិ, មាត្រា ៦៥០ ស្តីពីករណីយកិច្ចសង្គ្រោះបន្ទាន់របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ ។

# ជំពូកទី ៤ ភាគបម្រុង

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

(កំណត់)

របបភាគបម្រុង គឺជារបបធានាមួយភាគនៃចំណែកមតិកកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់ ។ មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏ប៉ុន្តែ របបនេះទទួលស្គាល់ឱ្យសន្តតិជនដែលកំណត់ដោយច្បាប់មួយចំនួន ធ្វើការបដិសេធនូវសេរីភាពនេះមួយភាគ ។ របបភាគបម្រុងនេះ មានតួនាទីសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ ហេតុនេះហើយបានជាបន្ទាប់ពី "ជំពូកទី ២ ស្តីពីសន្តតិកម្មតាមច្បាប់" និង "ជំពូកទី ៣ ស្តីពីសន្តតិកម្មតាមមតកសាសន៍" មានដាក់ "ជំពូកទី ៤ ស្តីពីភាគបម្រុងនេះ" ។ ម្យ៉ាងទៀត នៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥២៨ និង មាត្រា ៥២៩ មានឱ្យនិយមន័យនៃភាគបម្រុង ក៏ប៉ុន្តែ នៅក្នុងក្រមនេះ អាចយល់ន័យបានដោយមើលបញ្ញត្តិទាំងអស់នេះ ហេតុនេះហើយមិនចាំបាច់មាននិយមន័យទេ ។

ក្នុងរបបភាគបម្រុងនេះ មានវិធីធានានូវភាគបម្រុងដោយការបដិសេធមតកសាសន៍ ជាអាទិ៍ ដោយសន្តតិជនដែលត្រូវគេបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួន និង វិធីហាមមិនឱ្យមតកជនយកមតិកមួយចំនួនទៅធ្វើជាកម្មវត្ថុនៃមតកសាសន៍ ជាអាទិ៍ ។ ក្រមរដ្ឋប្បវេណីជប៉ុន ជាអាទិ៍ បានជ្រើសរើសយកវិធីទី ១ រីឯក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ឬក្រមរដ្ឋប្បវេណីបារាំងវិញ បានជ្រើសរើសយកវិធីទី ២ ។ ក្នុងក្រមនេះ យើងជ្រើសរើសយកវិធីទី ១ ។ នេះគឺដោយសារតែប្រសិនបើបុគ្គលដែលមានសិទ្ធិលើភាគបម្រុង មិនបានអះអាងនូវភាគបម្រុងរបស់ខ្លួនទេ គួរតែគោរពនូវឆន្ទៈរបស់មតកជន តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

**មាត្រា ១២៣០.-** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្ដាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្ដាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិកំណត់នូវជនដែលមានសិទ្ធិលើភាគបម្រុង ព្រមទាំងចំណែករបស់អ្នកនោះ ។

ជាបឋម កថាខណ្ឌទី ១ ចែងថា ក្នុងចំណោមសន្តតិជនដែលកំណត់ដោយច្បាប់ មានតែបច្ឆាញាតិផ្ទាល់ ឬ ឪពុកម្ដាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជនទេ ដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ។ មានន័យថា សន្តតិជន ក្រៅពីបងប្អូនបង្កើតរបស់មតកជន និង ជនទទួលសន្តតិកម្មជំនួសបងប្អូនបង្កើតនោះ ជាអ្នកមានសិទ្ធិលើភាគបម្រុង ។ម្យ៉ាងទៀត ក្នុងករណីដែលបច្ឆាញាតិផ្ទាល់របស់មតកជន បានទទួលមរណភាព មុនពេលមតកជនទទួលមរណភាព ជនដែលទទួលសន្តតិកម្មជំនួស ក៏ត្រូវមានភាគបម្រុង ដោយបញ្ញត្តិនៃកថាខណ្ឌទី ៣ ដែរ ។ បន្ទាប់មក កថាខណ្ឌទី ១ ចែងថា ជាគោលការណ៍ ភាគបម្រុង គឺ ១ ភាគ ២ នៃមតិករបស់មតកជន ហើយចំពោះករណីដែលមានតែឪពុកម្ដាយ ឬ មានតែជីដូនជីតាជាសន្តតិជន ភាគបម្រុង គឺ ១ ភាគ ៣ នៃមតិករបស់មតកជន ។ ឧទាហរណ៍ ក្នុងករណីដែលមានតែកូនម្នាក់ និង សហព័ទ្ធរបស់មតកជន ជាសន្តតិជន ភាគបម្រុងសម្រាប់អ្នកទាំងនោះ គឺ ១ ភាគ ២ នៃមតិករបស់មតកជន ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានច្រើននាក់ ត្រូវធ្វើការបែងចែកទ្រព្យដែលត្រូវបានចាត់ទុកជាភាគបម្រុងនោះ ទៅតាមសមាមាត្រនៃចំណែកមតិក ។ ចំពោះឧទាហរណ៍ខាងលើនេះ ចំណែកមតិកមានស្មើភាគគ្នា ហេតុនេះហើយ ភាគបម្រុងរបស់កូន ព្រមទាំងសហព័ទ្ធនោះ គឺ ១ ភាគ ៤ នៃមតិកសម្រាប់ម្នាក់ៗ ។ ក្នុងករណីដែលឪពុកម្ដាយ និង សហព័ទ្ធ រួមទាំងអស់ ៣ នាក់ជាសន្តតិជន ចំណែកមតិកសន្តតិកម្មរបស់សហព័ទ្ធគឺ ១ ភាគ ៣ ហើយមតិកដែលសល់ត្រូវចែកស្មើភាគគ្នាទៅឱ្យឪពុកម្ដាយ (មាត្រា ១១៦២ ចំណុច ខ) ដូច្នេះ ម្នាក់បានទទួល ១

ភាគ ៣ ។ ហេតុនេះហើយ ភាគបម្រុងគឺ ១ ភាគ ៦ សម្រាប់ម្នាក់ៗ ។ ម្យ៉ាងទៀត ក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជន និង សហព័ទ្ធ ជាសន្តតិជន យោងតាមកថាខណ្ឌទី ១ ចំណុចទី ខ ភាគបម្រុង មាន ១ ភាគ ២ នៃមតិក ក៏ប៉ុន្តែ ក្នុងករណីដែលមានបងប្អូនបង្កើត ចំណែកមតិករបស់សហព័ទ្ធគឺ ១ ភាគ ២ (មាត្រា ១១៦២ ចំណុច គ) ដូច្នេះ សហព័ទ្ធ ត្រូវទទួលភាគបម្រុងស្មើនឹង ១ ភាគ ៤ នៃមតិកទាំងអស់ ។

កថាខណ្ឌទី ៣ ចែងថា ក្នុងករណីសន្តតិកម្មជំនួស ភាគបម្រុងក៏ត្រូវចែកស្មើភាគគ្នារវាងជនដែលទទួលសន្តតិកម្មជំនួសដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២៨ និង មាត្រា ១០៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៣០ មាត្រា ៥៣៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ និង មាត្រា ៥៣៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២៣១.-** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

(កំណត់)

មាត្រានេះចែងអំពីទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ។ ការគណនាភាគបម្រុង ត្រូវធ្វើឡើងដោយមាត្រានេះ ជាមួយនឹងមាត្រា ១២៣៤ ស្តីពីចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងជាអាទិ៍ ។

កថាខណ្ឌទី ១ បានកំណត់ថា ទ្រព្យសកម្មដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង មានទ្រព្យដែលមានពេលចាប់

ផ្ដើមសន្តតិកម្ម ផលប្រយោជន៍ពិសេស ព្រមទាំងប្រទានកម្មដែលយកមកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុង ។ "ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមធ្វើសន្តតិកម្ម" នេះ មិនចាំបាច់ពន្យល់ទេ ។ ចំពោះ "តម្លៃនៃផលប្រយោជន៍ពិសេស" វិញ សូមមើលសេចក្ដីកំណត់នៅក្នុងមាត្រា ១១៦៣ ។ តម្លៃសរុបនៃទ្រព្យដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្ម និង តម្លៃនៃផលប្រយោជន៍ពិសេស ស្មើនឹងទ្រព្យដែលត្រូវបានចាត់ទុកថាជាមតិក ។ នេះគឺដើម្បីឱ្យមានសមភាពជាក់ស្ដែងរវាងសហសន្តតិជន ។ លើសពីនេះ ក៏មានបូកថែមទាំងតម្លៃនៃទ្រព្យប្រទានកម្មដែលបានកំណត់ក្នុងមាត្រាបន្ទាប់ផងដែរ ព្រោះថា ទ្រព្យដែលបានធ្វើប្រទានកម្មចំពោះតតិយជនក្រៅពីសន្តតិជន ក៏អាចក្លាយទៅជាកម្មវត្ថុនៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដែរ ។ ចំពោះចំណុចនេះ សូមមើលសេចក្ដីកំណត់លម្អិតនៅក្នុងមាត្រាបន្ទាប់ ។ បន្ទាប់មក ត្រូវដកនូវតម្លៃសរុបនៃកាតព្វកិច្ចរបស់មតកជន ពីតម្លៃសរុបនៃទ្រព្យសកម្មទាំងអស់ ព្រោះថា ត្រូវយកទ្រព្យសុទ្ធមកធ្វើជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ។ ឧទាហរណ៍ ក្នុងករណីដែលសហព័ទ្ធ A របស់មតកជន ព្រមទាំងកូន B និង C ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា ។ នៅពេលចាប់ផ្ដើមសន្តតិកម្ម មតិករបស់មតកជនមានទ្រព្យ ១000 ដុល្លារ B បានទទួលផលប្រយោជន៍ពិសេស ៥00 ដុល្លារ ហើយកាតព្វកិច្ចដែលត្រូវធ្វើសន្តតិកម្មមាន ៣00 ដុល្លារ ក្រៅពីនេះ មតកជនមាននារីកំណាន់ឈ្មោះ D ហើយបានធ្វើប្រទានកម្មទ្រព្យ ១000 ដុល្លារទៅឱ្យនារីនោះ នៅ ៦ ខែ មុនពេលមរណភាព ។ ក្នុងករណីនេះ ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង គឺ ១000+៥00+១000-៣00=២២00 ដុល្លារ ។ ដូច្នេះ យោងតាមមាត្រាមុន ២២00÷២÷៣=៣៦៧ ដុល្លារ គឺជាទ្រព្យសុទ្ធដែលជាភាគបម្រុងរបស់ម្នាក់ៗ (ចំនួនប្រាក់ដែលម្នាក់ៗអាចទាមទារដើម្បីបង្គ្រប់ភាគបម្រុង គឺផ្សេងពីនេះ ។ សូមមើលមាត្រា ១២៣៤) ។

កថាខណ្ឌទី ២ ជាបញ្ញត្តិស្ដីពីវិធីវាយតម្លៃអំពីសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ។

កថាខណ្ឌទី ៣ ជាបញ្ញត្តិចែងថា ក្នុងចំណោមកាតព្វកិច្ចដែលត្រូវបានទទួលបន្តដោយសន្តតិកម្ម ត្រូវរាប់បញ្ចូលផងដែរនូវសោហ៊ុយបុណ្យសព តាមឋានៈរបស់មតកជន ។ តាមធម្មតា កាតព្វកិច្ចដែលត្រូវបានទទួលបន្តដោយសន្តតិកម្ម សំដៅទៅលើកាតព្វកិច្ចដែលមតកជនមាន មុនពេលទទួលមរណភាព ប៉ុន្តែ ក៏មានរាប់បញ្ចូលទាំងសោហ៊ុយបុណ្យសព តាមឋានៈរបស់មតកជននោះ ជាអាទិ៍ ដែរ ។ ដោយឡែក មិនត្រូវរាប់បញ្ចូលនូវកាតព្វកិច្ចដែលសន្តតិជនត្រូវទទួលបន្ទុកដោយអច្ច័យទានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១0២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ចំពោះកថាខណ្ឌទី ៣ សូមមើលមាត្រា ១៩៤៧ មាត្រា ១៩៦៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

**មាត្រា ១២៣២.–** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ៖

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

(កំណត់)

មាត្រានេះចែងអំពីប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង ។ ប្រទានកម្មនេះក៏ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយយោងតាមមាត្រា ១២៣៣ ខាងក្រោមដែរ ។

ចំពោះប្រទានកម្មពេលនៅរស់ យោងទៅតាមកថាខណ្ឌទី ១ ចំណុច ក ជាគោលការណ៍ ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេលមួយឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្ម ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ការដែលបានកម្រិតអំឡុងពេលតែមួយឆ្នាំមុនពេលចាប់ផ្ដើមសន្តតិកម្មនេះ គឺដោយសារតែដើម្បីកុំឱ្យមានការបំពានមិនត្រឹមត្រូវដល់ផលប្រយោជន៍របស់អច្ច័យលាភី និង ដើម្បីឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ ។ ក៏ប៉ុន្តែ ក្នុងករណីដែលភាគីទាំងសងខាងបានដឹងថា ប្រទានកម្មនឹងបណ្ដាលឱ្យមានការខូចខាតដល់ជនដែលមានសិទ្ធិលើភាគបម្រុង នោះមិនចាំបាច់មានការកម្រិតនូវអំឡុងពេលដូចនេះឡើយ ពោលគឺគ្រប់ករណីទាំងអស់នេះ នឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយ ដូចបានចែងក្នុងកថាខណ្ឌទី ២ ។ ការទទួលស្គាល់ថាជា អំពើបំពាន ឬ មិនមែននោះ ត្រូវធ្វើឡើងដោយប្រៀបធៀបទ្រព្យសម្បត្តិសរុបដែលមតកជនមានពេលធ្វើប្រទានកម្ម និង តម្លៃទ្រព្យដែលបានធ្វើប្រទានកម្ម ។ ឧទាហរណ៍ ប្រសិនបើពេលនោះមតកជនមានជាង ១០ ម៉ឺនដុល្លារ ហើយបានឱ្យ ១000 ដុល្លារ ទៅជនដែលបានធ្វើវិភាគទានដល់កិច្ចការជំនួញរបស់ខ្លួន នេះមិនមែនជាការបំពានទេ ។ ហើយបើក្រោយមកទៀត ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជនបានធ្លាក់ចុះខ្លាំងនៅសល់តែ ៣000 ដុល្លារ ក៏ដោយ ក៏មិនមែនជាការបំពានដូចគ្នា ។

កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ មានចែងលើកលែងចំពោះផលប្រយោជន៍ពិសេស ។ នេះគឺដោយសារថា ក្នុងបញ្ញត្តិ

មាត្រាមុន មានការកំណត់រួចទៅហើយថា យកផលប្រយោជន៍ពិសេសមកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុង ។ ម្យ៉ាងទៀត ប្រសិនបើមតកជនមានកូនបីនាក់ គឺ A, B និង C ហើយ A បានទទួលប្រទានកម្មនូវទ្រព្យសម្បត្តិ ជាច្រើន សម្រាប់ជាទុនក្នុងកិច្ចការជំនួញរបស់ខ្លួន ហើយប្រសិនបើ A បានបោះបង់នូវសិទ្ធិសន្តតិកម្ម ដូច្នេះករណីនេះ A មិនមែន ជាសន្តតិជនទេ ហេតុនេះហើយ ប្រទានកម្មដែលពាក់ព័ន្ធនេះ មិនមែនជាផលប្រយោជន៍ពិសេសទេ ។ ដូច្នេះ ក្នុងករណីនេះ ដើម្បីកំណត់ថា ត្រូវយកប្រទានកម្មនេះ មកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុង ឬ យ៉ាងណានោះ ត្រូវមើលថា តើករណីនេះស្របនឹងកថាខណ្ឌទី ១ នៃមាត្រានេះដែរឬទេ ។ ទោះជាប្រទានកម្មនេះ ត្រូវបានធ្វើជាង ១ ឆ្នាំ មុនពេល ចាប់ផ្តើមសន្តតិកម្មក៏ដោយ ប្រសិនបើពិនិត្យលើទំនាក់ទំនងរវាងភាគីទាំងនោះទៅ ឃើញថា មានការងាយស្រួលនឹង កំណត់ថាជាអំពើដែលបានដឹងថាមានការបំពាន ។

កថាខណ្ឌទី ២ បានចាត់ទុកថា ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ជាប្រទានកម្ម ។ ចំពោះគំនិតនេះ ប្រហែលជាគ្មានមតិប្រឆាំងទេ ។ ចំពោះការលើកលែងកាតព្វកិច្ចដោយមានតម្លៃថ្នូរមិនសមរម្យ ជាអាទិ៍ មានចែងក្នុង មាត្រា ១២៤២ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ១០៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង សាលដីកាតុលាការកំពូលជប៉ុន ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ១៩៩៨។

**មាត្រា ១២៣៣.–** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជា មូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែក មត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹក ប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

ទ្រព្យសម្បត្តិដែលបានចែងក្នុងមាត្រានេះ គឺជាផ្នែកមួយនៃទ្រព្យសម្បត្តិដែលយកមកធ្វើជាមូលដ្ឋានដើម្បីគណនា ភាគបម្រុងដែលបានចែងក្នុងមាត្រា ១២៣១ ។ មានន័យថា ក្នុងចំណោម "ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ ផ្តើមសន្តតិកម្ម" ទ្រព្យដែលត្រូវយកមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺមានទ្រព្យដែលបានធ្វើ

ប្រទានកម្ម និង ទ្រព្យដែលបានកំណត់ជាចំណែកមតិកតាមមតកសាសន៍ ព្រមទាំងផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានចែងក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ។ ដោយឡែក ចំពោះទ្រព្យសម្បត្តិដែលនៅសល់ពីទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម តាមធម្មតា ត្រូវធ្វើការបែងចែកទៅឱ្យជនដែលមានសិទ្ធិលើភាគបម្រុង ។

ឧទាហរណ៍ ក្នុងករណីដែលសន្តតិជនមានបីនាក់ គឺ A, B និង C ហើយមតិកមាន ១000 ដុល្លារ ហើយ A បានទទួលផលប្រយោជន៍ពិសេស ៥000 ដុល្លារ ដូច្នេះ ចំណែកមតិករបស់ A គឺ 0 ដុល្លារ, B និង C ទទួល ៥00 ដុល្លារម្នាក់ ។ ក៏ប៉ុន្តែ ភាគបម្រុងដែលអាចទាមទារបានគឺ (១000+៥000)÷២÷៣ = ១000 ដុល្លារ ដូច្នេះ B និង C ត្រូវ A បំពានភាគបម្រុងរបស់ខ្លួន ៥00 ដុល្លារម្នាក់ ។

ក្នុងករណីដែលសន្តតិជនមានបីនាក់ គឺ A, B និង C ហើយមតិកមាន ១000 ដុល្លារ និង បំណុលមាន ៣00 ដុល្លារ, A បានទទួលផលប្រយោជន៍ពិសេស ៥00 ដុល្លារ, ចំណែកមតិកដែលមតកជនបានកំណត់ទៅឱ្យ B មាន ៨00 ដុល្លារ នោះ A នឹងទទួលបាន 0 ដុល្លារ (ក្រៅពីនេះ បានទទួលផលប្រយោជន៍ពិសេស ៥00 ដុល្លាររួចហើយ) B នឹងទទួល ៨00 ដុល្លារ ហើយ C នឹងទទួល ២00 ដុល្លារ (ក្រៅពីនេះ សន្តតិជនទាំងនោះត្រូវទទួលបន្ទុកនូវកាតព្វកិច្ច ១00 ដុល្លារ ម្នាក់) ។ ក្នុងករណីនេះ ភាគបម្រុងដែលអាចទាមទារបានគឺ (១000+៥00-៣00)÷២÷៣+៣00÷៣ = ៣00 ដុល្លារ (សូមមើលមាត្រា ១២៣៤) ដូច្នេះមានតែ C ទេដែលត្រូវគេបំពានភាគបម្រុងរបស់ខ្លួនចំនួន ១00 ដុល្លារ ។ ដូច្នេះ អាចទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះពី B (មាត្រា ១២៣៦) ។

ករណីមួយទៀត គឺសន្តតិជនមានបីនាក់ គឺ A, B និង C, មតិកមាន ១000 ដុល្លារ និង បំណុល ៩00 ដុល្លារ, ៥ ឆ្នាំមុន A បានទទួលផលប្រយោជន៍ពិសេស ៥00 ដុល្លារ ។ ក្នុងករណីនេះ ចំណែកមតិករបស់ A គឺ 0 ដុល្លារ, B និង C ម្នាក់ ៥00 ដុល្លារ (ប្រសិនបើគិតអំពីកាតព្វកិច្ចថែមទៀត គឺ A បាន -៣00 ដុល្លារ ហើយ B និង C បានម្នាក់ ២00 ដុល្លារ) ហេតុនេះហើយ មិនមានអ្នកណាម្នាក់ត្រូវគេបំពានភាគបម្រុងរបស់ខ្លួនទេ ។ ក៏ប៉ុន្តែ ប្រសិនបើ A បានបោះបង់សិទ្ធិសន្តតិកម្មរបស់ខ្លួន ហើយផលប្រយោជន៍ពិសេសត្រូវបានផ្ដល់ ដោយដឹងថា មានការបំពានភាគបម្រុង នោះភាគបម្រុងរបស់ B និង C គឺ (១000+៥00-៩00)÷២÷៣+៩00÷២ = ៥៥0 ដុល្លារ ។ ក៏ប៉ុន្តែ ម្នាក់ៗបានទទួលតែ ៥00 ដុល្លារប៉ុណ្ណោះ ដូច្នេះ ម្នាក់ៗត្រូវ A បំពានភាគបម្រុង ៥0 ដុល្លារ ។ ប្រសិនបើ A មិនបានបំពានដោយទុច្ចរិតទេ ភាគបម្រុងរបស់ B និង C គឺ (១000-៩00)÷២÷៣+៩00÷២ = ៤៦៧ ដុល្លារ ដូច្នេះ ក្នុងករណីនេះ មិនមានការបំពានទៅលើភាគបម្រុងទេ ។

ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ជាអាទិ៍ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ប្រសិនបើសន្តតិជនដែលត្រូវគេទាមទារឱ្យកាត់បន្ថយនោះ ត្រូវបានបំពានភាគបម្រុងរបស់ខ្លួនទៅវិញ ដោយសារការកាត់បន្ថយនោះនឹងមានបញ្ហា ។ ហេតុនេះហើយបានជាត្រូវមានបញ្ញត្តិដែលមានចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះ ដើម្បីការពារភាគបម្រុង ។ ឧទាហរណ៍ សន្តតិជនមានបីនាក់ គឺ A, B និង C, មតិកមាន ៣00 ដុល្លារ, ផលប្រយោជន៍ពិសេសចំពោះ

A គឺ ៩០០ ដុល្លារ ហើយមតកជនបានកំណត់តាមមតកសាសន៍ឱ្យ B ទទួលសន្តតិកម្ម ២០០ ដុល្លារ ។ ដូច្នេះ ចំណែកមតិកជាក់ស្តែង គឺ A បាន 0, B បាន ២០០ ដុល្លារ ហើយ C បាន ១០០ដុល្លារ ។ ក៏ប៉ុន្តែ ភាគបម្រុង គឺ (៣០០+៩០០)÷២÷៣ = ២០០ ដុល្លារ ដូច្នេះ C ត្រូវគេបំពានភាគបម្រុងរបស់ខ្លួន ១០០ ដុល្លារ ។ ក្នុងករណីនេះ យោងតាមមាត្រា ១២៣៦ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវធ្វើជាដំបូង ចំពោះ B ដែលជាសន្តតិជនដែលបាន ទទួលសន្តតិកម្មតាមការកំណត់ ក៏ប៉ុន្តែ ប្រសិនបើកាត់បន្ថយពី B ទៅ B នេះនឹងត្រូវគេបំពានភាគបម្រុងរបស់ខ្លួនទៅវិញ ហេតុនេះហើយ យោងទៅតាមវាក្យខណ្ឌនេះ ចំណែកមតិករបស់ B មិនមែនជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ ភាគបម្រុងទេ ហើយ C អាចទាមទារឱ្យកាត់បន្ថយ ១០០ ដុល្លារ ពី ៩០០ ដុល្លារ ដែលជាផលប្រយោជន៍ពិសេសចំពោះ A វិញ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង ចំពោះវាក្យខណ្ឌទី ២ សូមមើលសាលដីកានៃតុលាការកំពូល ជប៉ុនថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។

**មាត្រា ១២៣៩.-** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារ បានដោយការកាត់ បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួន ទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុង បានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវ ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

(កំណត់)

មាត្រានេះចែងអំពីចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

មាត្រានេះមានការពិបាកនឹងយល់ ដោយសារតម្រូវឱ្យ "បូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវ ទទួលបន្ទុក" ។ ក៏ប៉ុន្តែ នៅក្នុងមាត្រា ១២៣១ កថាខណ្ឌទី ១ ចំនួនទ្រព្យសុទ្ធដែលដកនឹងចំនួនសរុបនៃកាតព្វកិច្ច ត្រូវយកមកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុង ហេតុនេះហើយ ប្រសិនបើមិនគិតដល់កាតព្វកិច្ចដែលជនមានសិទ្ធិលើ ភាគបម្រុង បានទទួលដោយសន្តតិកម្មទេ មិនអាចធានានូវចំនួននៃភាគបម្រុងរបស់ជននោះទេ ។ ម្យ៉ាងទៀត នៅក្នុង មាត្រា ១២៣១ កថាខណ្ឌទី ១ នេះ អាចចែងបានដែរថា យកចំនួនសរុបនៃទ្រព្យសកម្មមកធ្វើជាមូលដ្ឋាន នៃការគណនា ភាគបម្រុងបាន ដោយមិនគិតដល់កាតព្វកិច្ចដែលបានទទួលដោយសន្តតិកម្មទេ ។ ក៏ប៉ុន្តែ ចំនួនទឹកប្រាក់ដែលត្រូវទទួល បន្ទុកចំពោះកាតព្វកិច្ចនេះ អាចខុសគ្នាទៅតាមជនដែលមានសិទ្ធលើភាគបម្រុង ដូច្នេះហើយបានជានៅក្នុងក្រមនេះ

មិនបានយកគំនិតនេះមកចែងទេ ។ ឧទាហរណ៍ សន្តតិជនមានសហព័ទ្ធ A ជីដូន B និង ជីតា C, មតិកមាន ១000 ដុល្លារ និង បំណុល ៣00 ដុល្លារ, ផលប្រយោជន៍ពិសេសចំពោះ A មាន ១000 ដុល្លារ ហើយមានការកំណត់នូវចំណែកមតិកឱ្យទៅ A ៥00 ដុល្លារ ។ ក្នុងករណីនេះ តាមសន្តតិកម្ម A បានទទួល ៥00 ដុល្លារ (ក្រៅពីនេះ បានទទួលផលប្រយោជន៍ពិសេស ១000 ដុល្លារ រួចហើយ) B និង C បានទទួល ២៥0 ដុល្លារម្នាក់ (ក្រៅពីនេះ A ត្រូវទទួលសន្តតិកម្មនូវកាតព្វកិច្ច ១៥0 ដុល្លារ ហើយ B និង C ត្រូវទទួលសន្តតិកម្មនូវកាតព្វកិច្ច ៧៥ ដុល្លារម្នាក់) ។ ក្នុងករណីនេះ ចំនួនទឹកប្រាក់ដែល B និង C អាចទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួនគឺ (១000+១000-៣00)÷២÷២÷២+៧៥ = ២៨៧.៥ ដុល្លារ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ទ្រព្យសកម្មដែលត្រូវយកមកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុងវិញ គឺ (១000+១000)÷២÷២÷២ = ២៥0 ដុល្លារ ។ ដូច្នេះ ចំនួនប្រាក់ដែលអាចទាមទារនោះខុសគ្នារវាងវិធីគណនាទាំពីរនោះ ។

## ផ្នែកទី ២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.–** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិស្តីពីការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដែលមានខ្លឹមសារថា ជនដែលត្រូវបានបំពានភាគបម្រុង អាចយកសិទ្ធិដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារឱ្យកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ។

ខ្លឹមសារលម្អិតនៃការទាមទារឱ្យកាត់បន្ថយនេះ បានចែងពីមាត្រាបន្ទាប់នេះ រីឯមាត្រានេះវិញ គឺជាមាត្រាមូលដ្ឋាននៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ ។ មាត្រានេះបានចែងថា "អាចទាមទារ" មានន័យថា អ្នកមានសិទ្ធិលើភាគបម្រុង និងប្រតិសិទ្ធិរបស់អ្នកនោះ មានសេរីភាពក្នុងការទាមទារ ឬ មិនទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប្រសិនបើមិនបានអនុវត្តសិទ្ធិនេះទេ មតកសាសន៍មានសុពលភាពពេញលេញ ។ លក្ខណៈតាមផ្លូវច្បាប់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺជា "សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត" ទេ ហេតុនេះហើយ តាមរយៈការអនុវត្តសិទ្ធិនេះ ដោយជនដែលមានសិទ្ធិលើភាគបម្រុង អច្ច័យទាន និង ប្រទានកម្ម ជាអាទិ៍ ត្រូវបាត់បង់នូវអានុភាព

ដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានភាគបម្រុង រីឯសិទ្ធិដែលអច្ច័យលាភី ជាអាទិ៍ បានធ្វើលទ្ធកម្ម ក៏ត្រូវធ្លាក់ពីមតកជន ទៅជនដែលមានសិទ្ធិលើភាគបម្រុងដែលទទួលសន្តតិកម្មនេះ ទៅតាមកម្រិតនៃភាគបម្រុងនេះដែរ ។ ក្នុងករណីដែលកម្មសិទ្ធិលើអចលនវត្ថុ បានក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង តាមរយៈការកាត់បន្ថយនេះ ផ្នែកដែលស្មើនឹងភាគបម្រុងត្រូវធ្លាក់ទៅលើជនដែលមានសិទ្ធិលើភាគបម្រុង ដោយមិនចុះបញ្ជី ។

ម្យ៉ាងទៀត ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ មិនចាំបាច់ធ្វើដោយដាក់ពាក្យបណ្ដឹងទេ គឺគ្រាន់តែបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ហើយ ។ ក៏ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតមិនយល់ព្រមទេ មានតែដាក់ពាក្យបណ្ដឹង ។ ប៉ុន្តែ ប្រសិនបើបានបង្ហាញឆន្ទៈក្នុងអំឡុងពេលនៃអាជ្ញាយុកាល ដែលបានចែងក្នុងមាត្រា ១២៤៥ សិទ្ធិនេះត្រូវធ្លាក់ទៅលើជនដែលមានសិទ្ធិលើភាគបម្រុងពីពេលនោះទៅ ហេតុនេះហើយទោះជាបានដាក់ពាក្យបណ្ដឹងក្រោយអំឡុងពេលនេះ ក៏មិនមានបញ្ហាដែរ បើបានបង្ហាញឆន្ទៈក្នុងអំឡុងពេលនោះ ។ ចំណុចនេះ មានភាពខុសគ្នានឹងមាត្រា ៥៤០ និង មាត្រា ៥៥២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៣៦.– លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

(កំណត់)

មាត្រានេះចែងថា តើត្រូវយកទ្រព្យណាមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយមុន ក្នុងចំណោមទ្រព្យដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយយោងតាមមាត្រា ១២៣៣ ។

មាត្រានេះបានកំណត់ថា ត្រូវយកអច្ច័យទាន និង ចំណែកមតិកដែលបានកំណត់តាមមតកសាសន៍ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ មុនប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ។ នេះគឺដោយសារតែគោលគំនិតនៃរបបភាគបម្រុង គឺដើម្បីធានាទុកនូវមតិកមួយភាគសម្រាប់ឱ្យជនដែលមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើធ្វើការកម្រិតនូវកម្មវត្ថុនៃការកាត់បន្ថយ ត្រឹមតែមតិក អាចទៅជាបំពានទៅលើភាគបម្រុងទៅវិញ ដោយសារការធ្វើប្រទានកម្មពេលនៅរស់ ។ ហេតុដូច្នេះ ប្រទានកម្ម ជាអាទិ៍ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយ ក្នុងទំហំដែលបានចែងក្នុងមាត្រា ១២៣២ ដែរ ។ ផលប្រយោជន៍ពិសេសក៏ជាប្រទានកម្មពេលនៅរស់មួយប្រភេទដែរ ។ ក៏ប៉ុន្តែ ការយកផលប្រយោជន៍ពិសេសទាំងអស់ មកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយ នាំឱ្យមានសមភាពមួយរវាងសហសន្តតិជន ហេតុនេះហើយបានជា

មាត្រា ១២៣៣ បានចែងដូចនេះ ។ ក៏ប៉ុន្តែ ប្រសិនបើមតិកដែលមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម មានគ្រាប់គ្រាន់ដើម្បីបង្គ្រប់ភាគបម្រុង នោះមិនចាំបាច់លើកការចាត់ចែងពេលមតកជននៅរស់មកបង្គ្រប់ភាគបម្រុងទេ ។ ដូច្នេះ គោលគំនិតនេះត្រូវបានចែងក្នុងមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៣៧.–** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។ បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃការកាត់បន្ថយអច្ច័យទាន និង ការកាត់បន្ថយចំណែកមតិកដែលបានកំណត់តាមមតកសាសន៍ ។

កថាខណ្ឌទី ១ មានចែងថា ត្រូវបែងចែកច្បាស់លាស់អច្ច័យទាន ជាអាទិ៍ សម្រាប់សន្តតិជន ពីអច្ច័យទានផ្សេងទៀត ហើយត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន ជាអាទិ៍ សម្រាប់សន្តតិជន ជាមុន ។ នេះគឺដោយសារតែសន្តតិជនត្រូវទទួលសន្តតិកម្មនូវឋានៈជាកូនបំណុលនៃអច្ច័យទាន ពីមតកជន ដូច្នេះ ដំបូងត្រូវសម្រួលផ្ទៃក្នុងសន្តតិជនជាមុនសិន ហើយ

ប្រសិនបើមិនគ្រប់គ្រាន់ទេ ទើបអាចកាត់បន្ថយពីរបស់អ្នកខាងក្រៅ ។

កថាខណ្ឌទី ២ មានចែងលម្អិតអំពីវិធីកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ។ ឧទាហរណ៍ មានសន្តតិជន គឺកូនរបស់មតកជន A និង B ហើយមតិកមាន ១000 ដុល្លារ តែដីដែលមានតម្លៃស្មើនឹង ៩00 ដុល្លារ ត្រូវបានធ្វើអច្ច័យទានទៅឱ្យជនក្រៅពីសន្តតិជន គឺជា C ។ ភាគបម្រុងរបស់ A និង B គឺ ២៥0 ដុល្លារម្នាក់ តែបានទទួលសន្តតិកម្មទ្រព្យដែលនៅសល់ ៥0 ដុល្លារ ម្នាក់ប៉ុណ្ណោះ ដូច្នេះ គឺអច្ច័យទានទៅឱ្យ C នោះ បំពានភាគបម្រុងរបស់ A និង B ២00 ដុល្លារម្នាក់ ។ ដូច្នេះ A និង B អាចទាមទារពី C ឱ្យកាត់បន្ថយ ២00 ដុល្លារ (មានន័យថា ចំណែកនៃកម្មសិទ្ធិអវិភាគគឺ ២ ភាគ ៩) សម្រាប់ម្នាក់ ពីដីនោះបាន ។ ប្រសិនបើដីដែលជាកម្មវត្ថុនោះមានច្រើន គឺមួយមានតម្លៃ ៦00 ដុល្លារ ហើយមួយទៀតតម្លៃ ៣00 ដុល្លារ ក្នុងករណីនេះ ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃនៃកម្មវត្ថុនោះ ឧទាហរណ៍ ចំពោះដីដែលមានតម្លៃ ៦00 ដុល្លារ គឺអាចទាមទារឱ្យកាត់បន្ថយ ២ ភាគ ៣ នៃ ២00 ដុល្លារ ដែលត្រូវជា ១៣៣ ដុល្លារ (ដូច្នេះ ចំណែកនៃកម្មសិទ្ធិអវិភាគគឺ ២ ភាគ ៩ ដែរ) ។ ក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើបានកំណត់ចំណែកមតិកឱ្យ A ទទួលសន្តតិកម្មនូវដីដែលមានតម្លៃ ៩00 ដុល្លារ ហើយបើទោះជា B ធ្វើលទ្ធកម្មនូវចំណែកមតិកដែលនៅសល់ ១00 ដុល្លារ ក៏ដោយ ក៏នៅតែត្រូវបានបំពានភាគបម្រុង ១៥0 ដុល្លារ ដែរ ដូច្នេះ អាចទាមទារឱ្យកាត់បន្ថយ ១៥0 ដុល្លារនេះ ពីការកំណត់ចំណែកមតិកសន្តតិកម្មនេះបាន ។ ក្នុងករណីដែលដីមាន ២ ឡូត៍វិញ ចំពោះដីដែលមានតម្លៃ ៦00 ដុល្លារ អាចទាមទារឱ្យកាត់បន្ថយ ២ ភាគ ៣ នៃ ១៥0 ដុល្លារ ពោលគឺ ១00 ដុល្លារ ហើយឱ្យកាត់បន្ថយ ៥0 ដុល្លារ ចំពោះដីតម្លៃ ៣00 ដុល្លារ ។

ក្នុងមាត្រា ១២៣៥ នៅពេលកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតមិនត្រូវបានបំពានទេ ។ វិធីកាត់បន្ថយនៃករណីនេះមានចែងក្នុងកថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ។ ឧទាហរណ៍ សន្តតិជនមាន ៣នាក់ គឺ A, B និង C, មតិកមាន ១៥00 ដុល្លារ ហើយក្នុងមតកសាសន៍ បានកំណត់ឱ្យ A ទទួលសន្តតិកម្មនូវចំណែក ១២00 ដុល្លារ ហើយ B ទទួលសន្តតិកម្មនូវចំណែក ៣00 ដុល្លារ ។ ក្នុងករណីនេះ សន្តតិជនម្នាក់ៗមានភាគបម្រុង ១៥00÷២÷៣ = ២៥0 ដុល្លារ ដូច្នេះ មានតែ C ទេ ដែលត្រូវបានបំពានភាគបម្រុងទាំងអស់ ។ ក្នុងករណីនេះ A និង B ត្រូវកាត់បន្ថយតាមសមាមាត្រ ៩៥0:៥0 ដែលជាតួលេខបានមកពីការដក ២៥0 ដុល្លារ ពីចំណែកដែលខ្លួនបានទទួលតាមមតកសាសន៍ (ដូច្នេះ A ត្រូវកាត់បន្ថយ ២៣៧,៥ ដុល្លារ រីឯ B វិញ ត្រូវបានកាត់បន្ថយ ១២,៥ ដុល្លារ) ។

កថាខណ្ឌទី ៣ មានចែងអំពីវិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ក្នុងករណីដែលមានការកំណត់នូវចំណែកសន្តតិកម្មតាមសមាមាត្រដោយមតកសាសន៍ ។ ឧទាហរណ៍ ក្នុងករណីដែលសន្តតិជនមាន ៣ នាក់ គឺ A, B និង C ហើយទ្រព្យទទួលសន្តតិកម្មរបស់ A គឺ ៤ ភាគ ៥ ហើយ B គឺ ១ ភាគ ៥ ការកាត់បន្ថយពីចំណែកមតិករបស់ A គឺ ២៣៧,៥ ភាគ ១៥00 ហើយការកាត់បន្ថយពីចំណែកមតិករបស់ B គឺ ១២,៥ ភាគ ១៥00 ។ តាមលទ្ធផលនេះ C បានទទួលសន្តតិកម្ម (២៣៧,៥+១២,៥) ភាគ ១៥00 បានសេចក្តីថា ១ ភាគ ៦ ។

កថាខណ្ឌទី ៤ ជាបញ្ញត្តិទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍ នូវវិធីធ្វើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយមតកជន ។ ឧទាហរណ៍ខាងលើនេះ ដែលមានសន្តតិជន ៣ នាក់ គឺ A, B និង C ហើយមតកជនបានកំណត់ឱ្យទៅ A ១២០០ ដុល្លារ, ឱ្យទៅ B ៣០០ ដុល្លារ ហើយក្រៅពីនេះ មានកំណត់ថា ប្រសិនបើត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់ C ត្រូវកាត់បន្ថយ ២៥០ ដុល្លារ ពី A ។ ក្នុងករណីនេះ ត្រូវអនុវត្តតាមមតកសាសន៍នេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៣៨.– លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្ដើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងអំពីលំដាប់ ជាអាទិ៍ នៃការកាត់បន្ថយប្រទានកម្ម ឬ ផលប្រយោជន៍ពិសេស ក្នុងករណីដែលមិនអាចធ្វើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ដោយត្រឹមតែពីទ្រព្យដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ។

កថាខណ្ឌទី ១ បានចែងថា ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្មនូវទ្រព្យជាច្រើន ដល់ជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍ ពេលខ្លួននៅរស់ ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្ដើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ ។ ប៉ុន្តែ ប្រសិនបើជនដែលត្រូវបានធ្វើការកាត់បន្ថយ ជាសន្តតិជន ហើយសាមីខ្លួនត្រូវបានបំពានដោយសារការកាត់បន្ថយនេះ ការកាត់បន្ថយនេះត្រូវធ្វើឡើងដោយដកនូវភាគបម្រុងរបស់សន្តតិជននេះសិន (មាត្រា ១២៣៣) ។ ឧទាហរណ៍ ក្នុងករណីដែលមតកជនមានសហព័ទ្ធ A និង កូន B និង C ហើយ ៣ ឆ្នាំមុនពេលទទួលមរណភាព មតកជនបានធ្វើប្រទានកម្មឱ្យ B ដើម្បីធ្វើជាទុនសម្រាប់មុខជំនួញ ១១០០ ដុល្លារ ហើយកន្លះឆ្នាំមុននឹងទទួលមរណភាព បានធ្វើប្រទានកម្មឱ្យ A ចំនួន ៣០០ ដុល្លារ ។ ជាលទ្ធផល មតិកនៅសល់តែ ១០០ ដុល្លារប៉ុណ្ណោះ ។ ក្នុងករណីនេះ ទោះបីជា C ទទួលយកទាំងអស់ក៏ដោយ ក៏នៅតែ

ត្រូវបានបំពានភាគបម្រុងរបស់ខ្លួន ១៥០ ដុល្លារទៀត ។ ដូច្នេះ C នឹងទាមទារពី A ដែលបានទទួលប្រទានកម្ម ក្រោយនោះ កាត់បន្ថយពីការទទួលប្រទានកម្ម ដើម្បីបង្គ្រប់ភាគប្រមុងនោះ ។ ក៏ប៉ុន្តែ កាត់បន្ថយបានតែ ៥០ ដុល្លារ ដោយដកពីភាគបម្រុងរបស់ A ប៉ុណ្ណោះ ហើយ ១០០ ដុល្លារដែលនៅខ្វះនោះ C អាចទាមទារឱ្យកាត់បន្ថយពី B បាន ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសនោះ ត្រូវបានធ្វើឡើងយូរយារណាស់ហើយ បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស អាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។ នេះជាគោលគំនិតដូចអាជ្ញាយុកាលនៃការរលត់សិទ្ធិដែរ ក៏ប៉ុន្តែ ប្រសិនបើយកអំឡុងពេល ១០ ឆ្នាំនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិនោះ មកអនុវត្តក្នុងនេះ ដូចជាខ្លីពេក ។ ឧទាហរណ៍ ពេលមានអាយុ ៦៥ ឆ្នាំ មតកជនបានធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនស្ទើរតែទាំងអស់ទៅឱ្យជនដែលត្រូវបានសន្មតថាជាសន្តតិជនពិសេសណាម្នាក់ ហើយបានទទួលមរណភាពពេលមានអាយុ ៧៦ ឆ្នាំ សន្តតិជនផ្សេងទៀតលែងបានទទួលនូវភាគបម្រុងរបស់ខ្លួនទៅ ឃើញថា មិនមានសមភាពរវាងសន្តតិជន ដូច្នេះហើយបានជាក្នុងនេះ អំឡុងពេលនេះ ត្រូវបានកំណត់ ២០ ឆ្នាំទៅវិញ ។ ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើប្រទានកម្មចំពោះ B ដើម្បីកិច្ចការជំនួញរបស់ខ្លួននោះ បានកន្លងផុតជាង ២០ ឆ្នាំហើយ B អាចបដិសេធមិនឱ្យកាត់បន្ថយបាន ។ ផ្ទុយទៅវិញ តាមការទាមទាររបស់C ប្រសិនបើ B យល់ព្រមប្រគល់វិញចំនួន ១០០ ដុល្លារ ឱ្យ C នោះ ក៏មិនមានបញ្ហាអ្វីដែរ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ១០៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## មាត្រា ១២៣៩.– ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

(កំណត់)

មាត្រានេះចែងថា អច្ច័យលាភី ជាអាទិ៍ ដែលត្រូវបានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើង ក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយនោះ ។

មាត្រានេះ អាចអនុវត្តចំពោះករណីដែលសហសន្តតិជន និង អច្ច័យលាភី បានទទួលពិតប្រាកដនូវមតិកនោះ ។ ឧទាហរណ៍ ក្នុងករណីដែលមានការកំណត់នូវសមាមាត្រនៃចំណែកមតិក ក៏ប៉ុន្តែ មិនបានធ្វើការបែងចែកមតិកនោះទៅតាមសមាមាត្រនោះទេ នោះសហសន្តតិជនដែលត្រូវបានទាមទារឱ្យកាត់បន្ថយនោះ មិនអាចធ្វើលទ្ធកម្មនូវផលនេះបានទេ ហេតុនេះហើយ ក្នុងករណីនេះមិនអាចអនុវត្តមាត្រានេះបានទេ ។

ម្យ៉ាងទៀត ផលដែលជាកម្មវត្ថុនៃសំណងនេះ មិនត្រូវកម្រិតត្រឹមតែផលដែលបានធ្វើលទ្ធកម្មពិតប្រាកដ ក្រោយថ្ងៃដែលបានធ្វើការទាមទារទេ ។ គឺបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១៩៦ ត្រូវអនុវត្តដោយសទិស បានសេចក្តីថា ត្រូវមានករណីយកិច្ចសងសំណងនូវតម្លៃនៃផលដែលត្រូវបានខូចខាត ឬ ធ្វេសប្រហែសក្នុងការទទួល ដោយកំហុស ចាប់ពីថ្ងៃដែលបានទទួលការទាមទារឱ្យកាត់បន្ថយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣៦ នៃ ក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៤០.–** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

(កំណត់)

មាត្រានេះចែងថា ប្រសិនបើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ មិនអាចសងទ្រព្យដែលបានទទួលពីមតកជនវិញបាន ឬ មិនអាចសងនូវតម្លៃនៃទ្រព្យនោះបាន ដោយសារអសាធនភាព ការខាតបង់ដែលកើតឡើងដោយសារអសាធនភាពរបស់សហសន្តតិជននោះ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។ ក្នុងករណីដែលភាគីម្ខាងទៀតនៃសិទ្ធិទាមទារឱ្យសង ស្ថិតក្នុងអសាធនភាព តាមគោលការណ៍នៃក្រមរដ្ឋប្បវេណី អ្នកមានសិទ្ធិ ជាអ្នកទទួលបន្ទុកនូវការខាតបង់នោះ ហើយមាត្រានេះក៏អនុវត្តតាមគោលការណ៍នេះដែរ ។ លទ្ធផលនៃការអនុវត្តមាត្រានេះគឺ ទោះជាអ្នកមានកាតព្វកិច្ចជាអ្នកអសាធនក៏ដោយ អ្នកមានសិទ្ធិលើភាគបម្រុងនោះ មិនអាចទាមទារឱ្យអ្នកមានកាតព្វកិច្ចក្នុងលំដាប់បន្ទាប់ សងនូវចំណែកដែលទាមទារមិនបានគ្រប់នោះទេ ។ ឧទាហរណ៍ ក្នុងករណីនៅក្នុងមាត្រា ១២៣៨ ទោះបីជា A ជាអ្នកអសាធន ហើយមិនអាចសង ៥០ ដុល្លារចំពោះ C បានក៏ដោយ ក៏ C មិនអាចទាមទារឱ្យ B សងលើសពីចំនួន ១០០ ដុល្លារ ដែលខ្លួនត្រូវសងនោះទេ ហើយទោះជា C មានភាគបម្រុង ២៥០ ដុល្លារក៏ដោយ តាមភាពពិត បានទទួលតែ ២០០ ដុល្លារប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៤១.–** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃ

នៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

(កំណត់)

តម្លៃនៃប្រទានកម្មដែលភ្ជាប់បន្ទុក គឺជាតម្លៃនៃកម្មវត្ថុនោះ ដកនឹងតម្លៃនៃបន្ទុក ហេតុនេះហើយ មាត្រានេះចែងថា ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក តម្លៃនៃកម្មវត្ថុដកនឹងតម្លៃនៃបន្ទុក គឺជាកម្មវត្ថុនៃការកាត់បន្ថយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៤២.–** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

(កំណត់)

របបភាគបម្រុង គឺជារបបការពារជនដែលមានសិទ្ធិលើភាគបម្រុង ពីការចាត់ចែងដោយគ្មានកម្រៃ ដូច្នេះ ចំពោះកិច្ចសន្យាដែលមានតម្លៃថ្នូរមិនត្រឹមត្រូវ ជាអាទិ៍ ក៏គួរតែយកមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដែរ ។ ដូច្នេះហើយបានជាមាត្រានេះបានចាត់ទុកថា កិច្ចសន្យាប្រភេទនេះក៏ជាប្រទានកម្មដែរ ប្រសិនបើស្របនឹងល័ក្ខខ័ណ្ឌកំណត់មួយ ហើយចែងអំពីការសងនូវតម្លៃថ្នូរនោះបាន ។

កថាខណ្ឌទី ១ ចែងថា ឧទាហរណ៍ ក្នុងករណីដែលមតកជនមានទ្រព្យមួយតម្លៃ ៥០០ ដុល្លារ ហើយបានលក់តែ ១០០ ដុល្លារប៉ុណ្ណោះ ប្រសិនបើភាគីទាំងសងខាងបានដឹងថា ការលក់ទិញនេះនឹងបំពានភាគបម្រុងរបស់សន្តតិជន កិច្ចសន្យានោះត្រូវបានចាត់ទុកថាជាប្រទានកម្ម ហើយក្លាយទៅជាកម្មវត្ថុនៃការកាត់បន្ថយ ។ ក៏ប៉ុន្តែ ពេលធ្វើការកាត់បន្ថយការលក់ទិញនេះ តម្លៃថ្នូរ ១០០ ដុល្លារ ត្រូវសងទៅឱ្យអ្នកទិញវិញ ដើម្បីរក្សានូវសមភាពរវាងភាគី ។

កថាខណ្ឌទី ២ កំណត់ថា ត្រូវចាត់ចែងដូចគ្នាដែរ ចំពោះការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។ ម្យ៉ាងទៀត ការលើកលែងកាតព្វកិច្ចដោយគ្មានតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្មចំពោះចំនួនប្រាក់ទាំងអស់ ដោយ

យោងតាមមាត្រា ១២៣២ កថាខណ្ឌទី ២ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ១០៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១២៤៣.–** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

(កំណត់)

មាត្រានេះចែងអំពីវិធីចាត់ចែងដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចធ្វើបាន ចំពោះករណីដែលសហសន្តតិជនដែលត្រូវទទួលការកាត់បន្ថយ ជាអាទិ៍ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មទៅឱ្យអ្នកដទៃ ឬ បានបង្កើតផលុបភោគ ឬ សិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍ សម្រាប់អ្នកដទៃ ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិសម្រាប់ករណីដែលបានធ្វើអនុប្បទាននូវកម្មវត្ថុទៅឱ្យអ្នកដទៃ ដែលមានចែងថា ក្នុងករណីនេះ អានុប្បទាយីត្រូវសងជាប្រាក់ ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ម្យ៉ាងទៀត នៅពេលធ្វើអនុប្បទាននោះ ប្រសិនបើអនុប្បទានិកបានដឹងថា នឹងបណ្តាលឱ្យមានការខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង អ្នកមានសិទ្ធិលើភាគបម្រុងនោះ ក៏អាចទាមទារឱ្យកាត់បន្ថយ ចំពោះអនុប្បទានិកបានដែរ ។ ដូចដែលបានពន្យល់នៅក្នុងមាត្រា ១២៣៥ រួចមកហើយ លក្ខណៈតាមផ្លូវច្បាប់នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជា "សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត" ដូច្នេះ អច្ច័យទាន ឬ ប្រទានកម្ម ជាអាទិ៍ ត្រូវបាត់បង់នូវអានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតដែលបានបំពានដល់ភាគបម្រុងនោះ ដោយការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះ ។ ដូច្នេះ សិទ្ធិដែលអច្ច័យលាភីបានទទួល ត្រូវធ្លាក់ទៅលើអ្នកមានសិទ្ធិលើភាគបម្រុង ដែលបានទទួលសន្តតិកម្មពីមតកជន ក្នុងកម្រិតនោះ ។ ក៏ប៉ុន្តែ ក្នុងករណីដែលកម្មវត្ថុនោះត្រូវបានផ្ទេរទៅឱ្យអ្នកដទៃ ប្រសិនបើចាត់ទុក

ថា អនុប្បទាននោះគ្មានសុពលភាពទេ នឹងធ្វើឱ្យបាត់បង់នូវសុវត្ថិភាពក្នុងកិច្ចការជំនួញ ហេតុនេះហើយ ក្នុងករណីនេះ គ្រាន់តែតម្រូវឱ្យសងតម្លៃនោះប៉ុណ្ណោះ ហើយមានតែករណីដែលប្រសិនបើអនុប្បទានិកបានដឹងថា នឹងបណ្តាលឱ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលដែលបានទទួលអនុប្បទាននោះទេ ដែលត្រូវចាត់ទុកថា អនុប្បទាននោះគ្មានសុពលភាព តាមគោលការណ៍ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់ករណីដែលមានការបង្កើតផលុបភោគ ឬ សិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍ សម្រាប់អ្នកដទៃ ។ ដោយសារបញ្ញត្តិនៃកថាខណ្ឌទី ១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីនេះ ប្រសិនបើផលុបភោគី ជាអាទិ៍ ជាជនទុច្ចរិត ពេលបង្កើតសិទ្ធិនោះ អ្នកមានសិទ្ធិលើភាគបម្រុង អាចអះអាងអំពីការរលត់សិទ្ធិ ជាអាទិ៍ នោះបាន ហើយប្រសិនបើផលុបភោគី ជាអាទិ៍ កាន់កាប់កម្មវត្ថុនោះ អាចទាមទារឱ្យប្រគល់វិញ ឬ អាចទាមទារឱ្យអ្នកមានសិទ្ធិលើហ៊ីប៉ូតែកលុបចោលនូវការចុះបញ្ជីនៃការបង្កើតហ៊ីប៉ូតែកនោះបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៤៤.- សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងថា អ្នកមានកាតព្វកិច្ចនៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃកម្មវត្ថុនោះទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ។ ដូចដែលបានពន្យល់ក្នុងមាត្រា ១២៣៩ រួចហើយ លក្ខណៈតាមផ្លូវច្បាប់នៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជា "សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត" ដូច្នេះ សិទ្ធិដែលអច្ច័យលាភី ជាអាទិ៍ បានទទួល ត្រូវធ្លាក់ទៅលើអ្នកមានសិទ្ធិលើភាគបម្រុង ដែលបានទទួលសន្តតិកម្មពីមតកជន ដោយការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើភាគបម្រុង ក្នុងកម្រិតដើម្បីរក្សាភាគបម្រុងនោះ ។ ក៏ប៉ុន្តែ ដោយពិចារណាដល់ការការពារជីវភាពរស់នៅរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះ មិនចាំបាច់សងវត្ថុនោះវិញទេ គ្រាន់តែសង

ថ្លៃនោះវិញ ជាការគ្រប់គ្រាន់ហើយ ។ កថាខណ្ឌទី ១ ត្រូវបានចែងឡើង ក្នុងគោលគំនិតនេះ ។

ម្យ៉ាងទៀត ក្នុងករណីដែលអ្នកមានកាតព្វកិច្ចបានអះអាងថានឹងសងថ្លៃ ហើយបានព្រមព្រៀងគ្នាលើតម្លៃនោះ ក្រោយពីបានសងថ្លៃនោះហើយ សិទ្ធិទាមទារឱ្យកាត់បន្ថយនឹងរលត់ដោយស្វ័យប្រវត្តិ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកមានកាតព្វកិច្ចបានតវ៉ានឹងការសងថ្លៃនេះ តាមបណ្ដឹងនៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង តើត្រូវធ្វើការវិនិច្ឆ័យយ៉ាងដូចម្ដេច គឺជាបញ្ហាមួយដែរ ។ ប្រសិនបើដោយសារគ្រាន់តែធ្វើការតវ៉ានេះ សិទ្ធិទាមទារឱ្យកាត់បន្ថយនេះត្រូវរលត់ ហើយលើកចោលនូវការទាមទារនោះទៅ នឹងធ្វើឱ្យខូចផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់អ្នកមានសិទ្ធិ ។ ផ្ទុយទៅវិញ ការទទួលស្គាល់នូវការទាមទារ ប្រសិនបើពុំបានសងថ្លៃពិតប្រាកដ ក៏ជាបញ្ហាមួយដែលខុសនឹងគោលគំនិតនៃមាត្រានេះដែរ ជាពិសេស ពេលដែលមានវិវាទស្ដីពីតម្លៃនេះ ។ ដូច្នេះ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលាក្រម ឬសាលដីកា តុលាការគួរតែបញ្ជាក់ថា បង្គាប់ឱ្យសងនូវវត្ថុដោយការកាត់បន្ថយ ហើយកំណត់តម្លៃជាមុន ហើយប្រសិនបើអ្នកមានកាតព្វកិច្ចបានសង ០០ រៀល អ្នកមានកាតព្វកិច្ចនេះអាចរួចផុតពីការឱ្យសងវត្ថុនោះបាន ។

ម្យ៉ាងទៀត ប្រសិនបើអ្នកមានកាតព្វកិច្ចមិនបានអះអាងថា នឹងសងដោយបង់តម្លៃទេ អ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឱ្យសងជាប្រាក់បានទេ គឺអាចត្រឹមតែទាមទារឱ្យសងវត្ថុនោះវិញតែប៉ុណ្ណោះ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលមានការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ចំពោះអនុប្បទានិកជាអាទិ៍ ដែលជាជនទុច្ចរិតអំពីការបង្កឱ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ក៏អនុប្បទានិក ជាអាទិ៍ នោះអាចសងដោយបង់ជាប្រាក់បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ផ្នែកទី ៣ ការរលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.–** អាជ្ញាយុកាលនៃការរលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម ។

(កំណត់)

មាត្រានេះចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ ។

ក្នុងចំណោមអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ អំឡុងពេលខ្លី គឺត្រូវបានចែងតម្រូវទៅនឹងអំឡុងពេលនៃអាជ្ញាយុកាលនៃការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ រីឯអំឡុងពេលវែងវិញ ត្រូវបានចែងតម្រូវទៅនឹង ៥ ឆ្នាំ ដែលជាអំឡុងពេលទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ។ ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ចាំបាច់ត្រូវអនុវត្តតាមផ្លូវតុលាការ (មាត្រា ៤២៨ កថាខណ្ឌទី ១) រីឯការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មិនចាំបាច់អនុវត្តតាមផ្លូវតុលាការទេ ។ ដូច្នេះ អាចអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលដែលបានកំណត់នេះចំពោះអ្នកមានកាតព្វកិច្ច ដោយមិនចាំបាច់ដាក់ពាក្យបណ្ដឹងទេ ។ តាមរយៈការអនុវត្តសិទ្ធិទាមទារនេះ កម្មសិទ្ធិទាំងមូល ឬ មួយភាគនៃកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកមានសិទ្ធិដោយស្វ័យប្រវត្តិ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកមានកាតព្វកិច្ចមិនបានប្រគល់ ឬ សហប្រតិបត្តិការធ្វើនីតិវិធីចុះបញ្ជីទេ ចាំបាច់ត្រូវដាក់ពាក្យបណ្ដឹង ។ ចំណុចនេះ គឺដូចគ្នានឹងករណីដែលបានបង្កើតកិច្ចសន្យាលក់ទិញ ក៏ប៉ុន្តែ អ្នកលក់មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១២៤៦.- ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុ-ញ្ញាតពីតុលាការ ។

(កំណត់)

មាត្រានេះចែងថា អាចបោះបង់ភាគបម្រុងបាន ។

ការបោះបង់នូវភាគបម្រុង អាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាង ចំពោះអ្នកមានកាតព្វកិច្ច ។ តាមធម្មតាការរលត់នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នឹងកើតឡើងដោយការមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលបានចែងក្នុងមាត្រាមុននេះ ។ ប៉ុន្តែ មានឧទាហរណ៍ ដូចជាការទទួលប្រាក់កំណត់មួយពីជនដែលមានកាតព្វកិច្ច ហើយជាថ្នូរ គឺត្រូវបោះបង់នូវភាគបម្រុងដែលនៅខ្វះ ជាដើម ។

វាក្យខណ្ឌទី ២ ចែងថា ដើម្បីបោះបង់នូវភាគបម្រុងមុនពេលចាប់ផ្ដើមសន្តតិកម្ម ចាំបាច់ត្រូវមានការអនុញ្ញាតពីតុលាការ ។ ដើម្បីកុំឱ្យមានការបោះបង់សិទ្ធិនេះទុកជាមុន ដោយសារតែចាញ់អំណាចរបស់ឪពុកម្ដាយ ជាអាទិ៍ ចាំបាច់ត្រូវមានការពិនិត្យតាងនាមជាអាណាព្យាបាល ដោយតុលាការ ។ តុលាការដែលទទួលពាក្យសុំឱ្យអនុញ្ញាតនោះ ត្រូវធ្វើ

ការវិនិច្ឆ័យដោយពិនិត្យមើលថា តើការបោះបង់នោះ ជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងឬទេ តើការបោះបង់នោះមានភាពសមហេតុសមផលដែរឬទេ តើចាំបាច់បោះបង់ឬទេ តើមានតម្លៃជាថ្នូរដែរឬទេ ជាអាទិ៍ ។ ម្យ៉ាងទៀត ទោះជាបានបោះបង់សិទ្ធិនេះមុនពេលចាប់ផ្តើមសន្តតិកម្ម ដោយទទួលការអនុញ្ញាតពីតុលាការក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឱ្យតុលាការលុបចោលការអនុញ្ញាតមុនបាន នៅមុនពេលចាប់ផ្តើមសន្តតិកម្មដែរ ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ ។ នេះគឺយោងតាមការបកស្រាយថា តុលាការអាចលុបចោលនូវការអនុញ្ញាតមុន តាមពាក្យសុំបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៤៧.–** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលមានសហសន្តតិជន ភាគបម្រុងរបស់ម្នាក់ៗមានផ្សេងពីគ្នា ដូច្នេះ ការរលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង របស់សហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទេ ។

មាត្រានេះ គឺជាលទ្ធផលដែលបានមកដោយស្វ័យប្រវត្តិពីមាត្រា ១២៣០ កថាខណ្ឌទី ២ ក៏ប៉ុន្តែ ដើម្បីកុំឱ្យមានការយល់ឃើញដូចគ្នាចំពោះការបោះបង់នូវសន្តតិកម្ម ចាំបាច់ត្រូវមានបញ្ញត្តិនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៥ ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.–** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយ

កម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមតិកបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងអំពីការអាចបោះបង់ចោល ឬ អាចយល់ព្រមទាំងស្រុង ឬ ដោយកម្រិត នូវសន្តតិកម្ម ព្រមទាំងអំឡុងពេលដែលត្រូវធ្វើការសម្រេចនោះ ។

សន្តតិជនអាចបោះបង់សន្តតិកម្មបាន ។ ក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥៨៣ សន្តតិជនដែលមានភាគបម្រុងមិនអាចបោះបង់សន្តតិកម្មបានទេ ហើយប្រសិនបើមតកជនមានកាតព្វកិច្ច ត្រូវសងកាតព្វកិច្ចនេះឱ្យរួចទាំងអស់ ។ ក៏ប៉ុន្តែ បើកំណត់ដូច្នេះ សន្តតិជនដែលគ្រាន់តែបានធ្វើសន្តតិកម្ម អាចធនក្ស័យបាន ហើយនេះជាការធ្ងន់ធ្ងរពេក ហេតុនេះហើយបានជាក្រមនេះទទួលស្គាល់ឱ្យសន្តតិជនទាំងអស់បោះបង់សន្តតិកម្មបាន ។ នេះគឺមិនចំពោះតែករណីដែលមតិករបស់មតកជនមិនគ្រប់គ្រាន់ដើម្បីសងកាតព្វកិច្ចទេ ទោះជាមតកជនគ្មានកាតព្វកិច្ចក៏ដោយ ការមិនចង់បំបែកមតិក ហើយតម្រូវឱ្យសន្តតិជនណាម្នាក់ទទួលសរុប ឬ ការមិនចង់ពាក់ព័ន្ធនឹងសហសន្តតិជនផ្សេងទៀត ដោយសារការមិនចូលចិត្តគ្នាជាដើម ករណីទាំងនេះសុទ្ធតែអាចមានការបោះបង់សន្តតិកម្ម ។ម្យ៉ាងទៀត ការយល់ព្រមដោយកម្រិតរបស់សន្តតិជន ក៏អាចទទួលស្គាល់បានដែរ ។ ការយល់ព្រមដោយកម្រិត គឺការយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ (មាត្រា ១២៥៦) ហើយ ។វិធីនេះត្រូវបានប្រើសម្រាប់ករណីដែលចំនួនទឹកប្រាក់នៃកាតព្វកិច្ច មិនច្បាស់លាស់ ជាអាទិ៍ ។ម្យ៉ាងទៀត សន្តតិជនក៏អាចយល់ព្រមទាំងស្រុងបាន ដោយទទួលបន្ទុកទាំងអស់នូវមតិកសកម្ម និង មតិកអកម្ម ។ ដោយឡែក ការយល់ព្រម និង ការបោះបង់ មិនអាចធ្វើចំពោះតែសន្តតិកម្មមួយភាគបានទេ ហើយទោះបីជាបានធ្វើដូច្នោះក៏ដោយ ក៏គ្មានសុពលភាពដែរ ។ មាត្រា ១៩៤៧ និង មាត្រា ១៩៥០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មានចែងបញ្ជាក់ដែរ ក៏ប៉ុន្តែ ក្នុងនេះជាការធម្មតាទេ ។

កថាខណ្ឌទី ១ ចែងថា អំឡុងពេលដែលត្រូវធ្វើការវិនិច្ឆ័យជ្រើសរើសប្រភេទណាមួយ (ហៅថា អំឡុងពេលគិតឱ្យបានដិតដល់) គឺ ៣ ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ។ ប្រសិនបើអំឡុងពេលនេះវែងពេក អាចមានឥទ្ធិពលដល់ការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើបំណុលចំពោះមតកជន ហេតុនេះហើយបានជាបានកំណត់អំឡុងពេលដូចនេះ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមតិកស្ថិតនៅកន្លែងច្រើន ជាអាទិ៍ មានការពិបាកនឹងសម្រេចបោះបង់ ឬ យល់ព្រមក្នុងអំឡុងពេល ៣ ខែនេះដែរ ដូច្នេះ មុនពេល ៣ ខែនេះបានកន្លងផុត អាចដាក់ពាក្យសុំឱ្យតុលាការ

ពន្យារ "អំឡុងពេលគិតឱ្យបានដិតដល់" នេះបាន ។ ចំពោះតុលាការដែលបានទទួលពាក្យសុំនេះ ត្រូវធ្វើការកំណត់អំឡុងពេលដែលត្រូវពន្យារនេះ ដោយវិនិច្ឆ័យទៅតាមចំនួន ឬ គុណភាពនៃមតិក ឬ កាតព្វកិច្ច ដែលទទួលដោយសន្តតិកម្មជាអាទិ៍ ។ ជាពិសេស ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត ចាំបាច់ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ (មាត្រា ១២៥៧) ហើយដែលអាចមានការចាំបាច់ខ្លាំងក្នុងការពន្យារអំឡុងពេល ។

កថាខណ្ឌទី ២ ចែងថា សន្តតិជនអាចស្រាវជ្រាវមតិកបាន មុននឹងធ្វើការយល់ព្រម ឬ ការបោះបង់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៤៩.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

(កំណត់)

មាត្រានេះចែងអំពីករណីពិសេសនៃ "អំឡុងពេលគិតឱ្យបានដិតដល់" ក្នុងករណីដែលសន្តតិជនបានទទួលមរណភាពដោយមិនបានធ្វើការយល់ព្រម ឬ ការបោះបង់ ។

ឧទាហរណ៍ A បានទទួលមរណភាព ហើយ B និង C ជាសន្តតិជនរបស់ A ក៏ប៉ុន្តែ ប្រសិនបើ B បានទទួលមរណភាពដោយមិនទាន់យល់ព្រម ឬ បោះបង់នៅឡើយ អំឡុងពេលគិតឱ្យបានដិតដល់ចំពោះ A របស់ D ដែលជាសន្តតិជនរបស់ B ត្រូវគណនាដោយគិតពីពេលដែល D បានដឹងថា បានចាប់ផ្តើមសន្តតិកម្មពី B ។ ក្នុងករណីនេះ D ក៏ត្រូវធ្វើការយល់ព្រម ឬ បោះបង់នូវសន្តតិកម្មចំពោះមតិករបស់ B ដែរ ក៏ប៉ុន្តែ ប្រសិនបើ D បានបោះបង់នូវសន្តតិកម្មចំពោះមតិករបស់ B ពេលនោះគឺមិនអាចធ្វើការយល់ព្រម ឬ បោះបង់នូវសន្តតិកម្មចំពោះមតិករបស់ A បានទេ មានន័យថា D បានបោះបង់ចោលទាំងរបស់ A ទាំងរបស់ B ។ D អាចធ្វើការយល់ព្រម ឬ បោះបង់ចោលនូវសន្តតិកម្មចំពោះមតិករបស់ A បាន តែក្នុងករណីដែលបានយល់ព្រមនូវសន្តតិកម្មចំពោះមតិករបស់ B ប៉ុណ្ណោះ ។ D អាចយល់ព្រមដោយកម្រិតនូវសន្តតិកម្មចំពោះមតិករបស់ B ហើយអាចយល់ព្រមទាំងស្រុងនូវសន្តតិកម្មចំពោះមតិករបស់ A បាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៥០.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិពិសេសនៃអំឡុងពេលគិតឱ្យបានដិតដល់ ក្នុងករណីដែលសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ។

ប្រសិនបើសន្តតិជនជាអនីតិជន ឬ ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ ការយល់ព្រម ឬ ការបោះបង់ ចាំបាច់ត្រូវឱ្យអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាល ធ្វើការសម្រេចដើម្បីសាមីខ្លួននោះ (មាត្រា ១០៥៣, មាត្រា ១០៨០, មាត្រា ១១១៤) ។ ដូច្នេះ អំឡុងពេលគិតឱ្យបានដិតដល់នេះត្រូវគណនា ដោយគិតចាប់ពីពេលដែលអ្នកទាំងនោះបានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។ ឧទាហរណ៍ ក្នុងករណីដែលឪពុក ឬ ម្តាយដែលជាជនដែលមានអំណាចមេបាតែឯង បានទទួលមរណភាព អំឡុងពេលគិតឱ្យបានដិតដល់សម្រាប់កូនដែលជាសន្តតិជននេះ (អនីតិជន) ត្រូវគណនា ចាប់ពីថ្ងៃដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូននេះត្រូវបានជ្រើសតាំង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៥១.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនា

ដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិពិសេសស្តីពីអំឡុងពេលគិតឱ្យបានដិតដល់ ក្នុងករណីដែលសន្តតិជនមិនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលមតកជនមាន ។

ក្នុងករណីដែលសន្តតិជនបានដឹងថា មតកជនមានកាតព្វកិច្ចច្រើន ឬ អាចមានកាតព្វកិច្ចច្រើន សន្តតិជនច្បាស់ជានឹងបោះបង់ ឬ ទទួលសន្តតិកម្មដោយមានកម្រិត ។ ក៏ប៉ុន្តែ មានករណីខ្លះដែលសន្តតិជន មិនអាចដឹងបានថា តើមតកជនមានកាតព្វកិច្ចច្រើន ដោយសារស្ថានភាពនៃជីវភាពរស់នៅរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត ។ ឧទាហរណ៍ មតកជនបានធានាសម្រាប់តតិយជនណាម្នាក់ ក៏ប៉ុន្តែ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម តតិយជននោះត្រូវធនក្ស័យ ហើយម្ចាស់បំណុលនោះបានមកទាមទារឱ្យសន្តតិជនអនុវត្តកាតព្វកិច្ចធានានោះ ។ ចំពោះករណីនេះ ទោះបីជាសន្តតិជននោះមិនបានបោះបង់ ឬ យល់ព្រមដោយមានកម្រិត ក្នុងអំឡុងពេលគិតឱ្យបានដិតដល់ក៏ដោយ ប្រសិនបើឱ្យសន្តតិជននោះទទួលខុសត្រូវនូវបន្ទុកនេះដែរ គឺជាការធ្វើជ្រុលហួសហេតុពេក ។ ហេតុនេះហើយបានជា ក្នុងកថាខណ្ឌទី ១ មានចែងថា ក្នុងករណីនេះ អំឡុងពេលត្រូវគិតឱ្យបានដិតដល់នេះ ត្រូវគណនាចាប់ពីពេលដែលសន្តតិជនបានដឹងថា មានកាតព្វកិច្ចនោះ ។ បញ្ញត្តិនេះត្រូវបានចែងឡើង ដោយយោងទៅតាមសាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ១៩៨៤ ។ សាលដីកានេះសម្រេចថា ប្រសិនបើសន្តតិជនជឿជាក់ថាមតកជននេះគ្មានមតិកសកម្មទេ ហើយការជឿជាក់នេះមានហេតុផលសមរម្យ អំឡុងពេលគិតឱ្យបានដិតដល់នេះ ត្រូវគណនាពីពេលដែលបានដឹងថា មានកាតព្វកិច្ច ។ កថាខណ្ឌទី ១ បានពង្រីកគោលគំនិតនេះ ដោយចែងថា ទោះបីជាសន្តតិជនបានដឹងថា មានមតិកក៏ដោយ ក៏អាចបោះបង់នូវសន្តតិកម្មបាន ជាអាទិ៍ ដែរ ។

ទោះបីជាមានបញ្ញត្តិពិសេសដូចក្នុងកថាខណ្ឌទី ១ ស្តីពីអំឡុងពេលគិតឱ្យបានដិតដល់ក៏ដោយ ប្រសិនបើមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ផ្សេងទៀត ក៏មានករណីដែលមិនអាចទទួលនូវអំណោយផលនៃបញ្ញត្តិពិសេសនេះដែរ ។ ដូច្នេះ កថាខណ្ឌទី ២ ចែងថា ទោះបីជាសន្តតិជនបានចាត់ចែងមតិកហើយ មុនពេលបានដឹងថាមានកាតព្វកិច្ចនោះក៏ដោយ ប្រសិនបើការចាត់ចែងនោះត្រូវបានធ្វើដើម្បីសងកាតព្វកិច្ចផ្សេងទៀតដែលត្រូវទទួលដោយសន្តតិកម្ម ត្រូវចាត់ទុកថា មិនមែនជាករណីដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ទេ ដោយសារការ

ចាត់ចែងនោះ ចាំបាច់ដើម្បីអនុវត្តកាតព្វកិច្ច ។ សូមមើលសេចក្ដីកំណត់ នៅក្នុងមាត្រា ១២៥៥ ចំណុច ក ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

(កំណត់)

មាត្រានេះមានចែងថា ជាគោលការណ៍ មិនអាចលុបចោលនូវការយល់ព្រម ឬ ការបោះបង់សន្តតិកម្មបានទេ ។

កថាខណ្ឌទី ១ ចែងថា ទោះបីជាក្នុងអំឡុងពេលគិតឱ្យបានដិតដល់ក៏ដោយ ក៏ការយល់ព្រម ឬ ការបោះបង់នូវសន្តតិកម្មដែលបានធ្វើម្តងហើយ មិនអាចលុបចោលវិញបានឡើយ ។ ការកម្រិតនូវសិទ្ធិលុបចោលនេះ គឺដោយសារតែការយល់ព្រម ឬ ការបោះបង់នូវសន្តតិកម្មនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់ជនពាក់ព័ន្ធដូចជាសន្តតិជនដែលមានលំដាប់បន្ទាប់ ឬ ជនមានសិទ្ធិលើបំណុលដែលទទួលដោយសន្តតិកម្ម ជាអាទិ៍ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិមួយដែលអាចឱ្យលុបចោលនូវការយល់ព្រម ឬ ការបោះបង់បាន ក្នុងករណីដែលមានមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាករណីដែល A និង B ជាសហសន្តតិជន ហើយ A បានគម្រាមកំហែង B ឱ្យបោះបង់ចោលសន្តតិកម្មដើម្បីទទួលមតិកតែឯង ។ ក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ មានភាពចាំបាច់ត្រូវការពារសន្តតិជនដែលបានបង្ហាញឆន្ទៈនេះ ហេតុដូច្នេះ មាត្រានេះទទួលស្គាល់សិទ្ធិលុបចោលរបស់ជននោះ ។ ក៏ប៉ុន្តែ ប្រសិនបើទុកឱ្យជននោះមានសិទ្ធិនេះរហូតទៅ នឹងធ្វើឱ្យមានឥទ្ធិពលទៅលើផលប្រយោជន៍របស់

ជនដែលពាក់ព័ន្ធ ហេតុនេះហើយបានជាមានការកម្រិតនូវអំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនេះ ។ ម្យ៉ាងទៀត ទោះបីជាអំឡុងពេលគិតឱ្យបានដិតដល់នេះ បានកន្លងផុតដោយសារការភាន់ច្រឡំក៏ដោយ ក៏មិនអាចលុបចោលនូវការយល់ព្រមទាំងស្រុងតាមច្បាប់បានដែរ ព្រោះថា មិនមានការបង្ហាញឆន្ទៈ ។

កថាខណ្ឌទី ៣ ចែងអំពីវិធីលុបចោលនូវការយល់ព្រម ឬ ការបោះបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការលុបចោលនូវសកម្មភាពចាត់ចែងដែលត្រូវបានចាត់ទុកថាជាការយល់ព្រមទាំងស្រុង ដោយសារមូលហេតុនៃការភាន់ច្រឡំ ជាអាទិ៍ ការយល់ព្រមទាំងស្រុងនោះនឹងបាត់បង់ ដូច្នេះមិនចាំបាច់ដាក់ពាក្យសុំលុបចោលទៅតុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ នេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៥៣.- ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

(កំណត់)

មាត្រានេះចែងថា មិនអាចយកសិទ្ធិទាមទារចំពោះមតិកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមទទួលសន្តតិកម្មបានទេ ។

ក្នុងករណីដែលសន្តតិជនមិនទាន់បានយល់ព្រម ឬ បោះបង់ចោលនូវសន្តតិកម្មទេ អ្នកទទួលបន្តចុងក្រោយរបស់មតកជន មិនទាន់ច្បាស់លាស់ទេ ។ ដូច្នេះ មាត្រានេះត្រូវបានបញ្ញត្តឡើងសម្រាប់ករណីនេះ ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលរបស់មតកជនចង់ធ្វើបណ្តឹង ជាបឋម ត្រូវទាមទារឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ន តាមមាត្រា ១២៦៤ សិន ហើយត្រូវធ្វើបណ្តឹងចំពោះអ្នកគ្រប់គ្រងនេះ ។ ម្យ៉ាងទៀត ដូចគ្នាដែរចំពោះករណីដែលមតកជនបានទទួលមរណភាព នៅពេលបណ្តឹងចំពោះមតកជននោះកំពុងត្រូវបានចាត់ការ ហើយនីតិវិធីបណ្តឹងនោះ ត្រូវផ្អាក រហូតដល់ពេលដែលសន្តតិជនយល់ព្រមសន្តតិកម្មនោះ ។ ក្នុងករណីនេះ ប្រសិនបើភាគីម្ខាងទៀតចង់បន្តបណ្តឹងនេះឱ្យបានឆាប់ ចាំបាច់ត្រូវទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្នដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៩៥៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

# ផ្នែកទី ២ ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពតាមផ្លូវច្បាប់នៃការយល់ព្រមទាំងស្រុង ។

ជាគោលការណ៍ មាត្រានេះចែងដូចមាត្រា ១១៤៧ ដែរ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចខុសគ្នានឹងការយល់ព្រមដោយមានកម្រិត នៅក្នុងមាត្រានេះ ប្រើពាក្យ "គ្មានកម្រិត" ។

តើការយល់ព្រមទាំងស្រុង អាចធ្វើបានតាមការបង្ហាញឆន្ទៈដែរឬទេ ហើយប្រសិនបើអាច តើត្រូវបង្ហាញឆន្ទៈនោះចំពោះនរណា ទាំងនេះគឺជាបញ្ហា ។ ការយល់ព្រមដោយកម្រិត ព្រមទាំងការបោះបង់ ចាំបាច់ដាក់ពាក្យសុំទៅតុលាការ ប៉ុន្តែ មាត្រានេះ និង មាត្រាបន្ទាប់ គ្មានចែងថា ត្រូវដាក់ពាក្យសុំទៅតុលាការធ្វើទេ ។ នៅប្រទេសជប៉ុន ចំពោះចំណុចនេះ យុត្តិសាស្ត្រ និង ទស្សនៈទូទៅ បកស្រាយថា អាចយល់ព្រមទាំងស្រុង តាមការបង្ហាញឆន្ទៈបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៥៥.–** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ

បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

(កំណត់)

មាត្រានេះចែងអំពីការធ្វើ ឬ ការមិនធ្វើសកម្មភាពកំណត់មួយដោយសន្តតិជន ដែលក្លាយទៅជាមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ។

ចំណុច ក ចែងថា ការចាត់ចែងមតិកដោយសន្តតិជន នឹងក្លាយជាមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ។ ម្យ៉ាងទៀត ក្នុងអំឡុងពេលគិតឱ្យបានដិតដល់ ទោះបីជាអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្នបានធ្វើសកម្មភាពបណ្តឹងជាអាទិ៍ ស្តីពីមតិក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៦៤ ក៏ដោយ សកម្មភាពនេះមិនមែនជាសកម្មភាពរបស់សន្តតិជនទេ ហេតុនេះហើយមិនអាចយកចំណុច ក នេះមកអនុវត្តបានទេ ។ វាក្យខណ្ឌទី ២ នៃចំណុចនេះបញ្ជាក់ថា ទោះបីជាបានបោះបង់សន្តតិកម្ម ជាអាទិ៍ ក៏ដោយ ក៏សន្តតិជនដែលកាន់កាប់មតិកនោះ មានករណីយកិច្ចរក្សាគ្រប់គ្រងមតិកនោះដែរ ដូច្នេះ ទោះបីជាសន្តតិជននោះបានធ្វើសកម្មភាពចាំបាច់ដើម្បីរក្សាការពារមតិកក៏ដោយ ក៏សកម្មភាពនេះមិនមែនជាមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ទេ ។ ម្យ៉ាងទៀត ក្នុងចំណុចនេះ មានបញ្ញត្តិអញ្ញត្រកម្មនៃមាត្រា ១២៥១ កថាខណ្ឌទី ២ ។ នៅក្នុងវាក្យខណ្ឌទី ២ នៃចំណុចនេះ មានគំនិតមួយថា ឱ្យរួមបញ្ចូលទាំងករណីដែល "បានចាត់ចែងមតិកដើម្បីសងកាតព្វកិច្ចដែលទទួលតាមរយៈសន្តតិកម្ម" ដូចមាត្រា ១២៥១ កថាខណ្ឌទី ២ ដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលបានចាត់ចែងមតិកដើម្បីសងកាតព្វកិច្ចដែលទទួលតាមរយៈសន្តតិកម្ម ដោយយកការណ៍ដែលមតិកសកម្មមានច្រើនជាងកាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ករណីនេះគឺជាការយល់ព្រមទទួលសន្តតិកម្ម ហេតុនេះហើយក្នុងវាក្យខណ្ឌទី ២ នៃចំណុច ក នេះ មិនមានបញ្ចូលករណីនេះទេ ។ ក៏ប៉ុន្តែ ប្រសិនបើករណីស្របនឹងមាត្រា ១២៥១ កថាខណ្ឌទី ១ ការចាត់ចែងមតិកត្រូវបានធ្វើដោយការភាន់ច្រឡំរបស់សន្តតិជន ត្រូវជួយសង្គ្រោះអ្នកនោះ ត្រឹមកម្រិតនៃ "ការចាត់ចែងមតិកដើម្បីសងកាតព្វកិច្ចដែលទទួលតាមរយៈសន្តតិកម្ម" ដែលគ្មានគោលបំណងបង្កើនទ្រព្យសាមីខ្លួន ។

ចំណុច ខ ចែងថា ការកន្លងផុតនៃអំឡុងពេលគិតឱ្យបានដិតដល់ គឺជាមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ។ ការកំណត់នូវអំឡុងពេលគិតឱ្យបានដិតដល់នេះ គឺសម្រាប់អនុវត្តបញ្ញត្តិនៃចំណុចនេះ ។

ចំណុច គ គឺជាបញ្ញត្តិដាក់ទណ្ឌកម្ម ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្មចោល ក៏ប៉ុន្តែ បានធ្វើសកម្មភាពផ្ទុយពីនេះ ។ ក្នុងករណីដែលសន្តតិជននៃលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះត្រូវឱ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ដើម្បីឱ្យមានស្ថិរភាពតាមផ្លូវច្បាប់ ហេតុនេះហើយបានជាមានបញ្ញត្តិដូចវាក្យខណ្ឌទី ២ នៃចំណុច គ នេះ ។ ម្យ៉ាងទៀត ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពដែលបានចែងក្នុងចំណុចនេះ សន្តតិជនលំដាប់បន្ទាប់អាចធ្វើការទាមទារឱ្យសន្តតិជនលំដាប់មុននោះប្រគល់មតិកមកវិញ ឬ អាចធ្វើការទាមទារឱ្យជននោះសងនូវសំណងនៃការខូចខាតបាន ។

ចំពោះសកម្មភាពដែលបានធ្វើក្រោយការយល់ព្រមដោយកម្រិត ក៏មានបញ្ញត្តិប្រហាក់ប្រហែលគ្នានឹងចំណុចនេះ ក្នុងមាត្រា ១២៥៩ ដែរ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៩២១ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ចំពោះវាក្យខណ្ឌទី ២ នៃចំណុច ក សូមមើលមាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះចំណុច ខ សូមមើលមាត្រា ៥៩២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះចំណុច គ សូមមើលមាត្រា ៥៨៦ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## មាត្រា ១២៥៦.– ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

(កំណត់)

មាត្រានេះចែងស្តីពីការយល់ព្រមដោយមានកម្រិត ហើយកំណត់និយមន័យនេះ ជាអាទិ៍ ។

កថាខណ្ឌទី ១ ចែងអំពីនិយមន័យនៃការយល់ព្រមដោយមានកម្រិត ដែលមានខ្លឹមសារថា ធ្វើសន្តតិកម្មដែលបម្រុងសម្រាប់សងនូវកាតព្វកិច្ចដែលបានទទួលដោយសន្តតិកម្ម ដោយសងត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលបានទទួល ដោយសន្តតិកម្ម ។ មានន័យថា សន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលសន្តតិកម្មនូវកាតព្វកិច្ចទាំងអស់របស់មតកជន ក៏ប៉ុន្តែ សន្តតិជនអាចកម្រិតការទទួលខុសត្រូវសង ត្រឹមតែកម្រិតនៃមតិកដែលបានទទួលដោយសន្តតិកម្មបាន ។ ប្រសិនបើសន្តតិជនស្ម័គ្រចិត្តសងកាតព្វកិច្ចលើសពីមតិកសកម្មក៏ដោយ ក៏មិនមែនជាការសងដោយគ្មានកាតព្វកិច្ចដែរ ដូច្នេះការសងនេះ មានសុពលភាព ។ តាមទ្រឹស្តីសិក្សាចំណែកនៃកាតព្វកិច្ចដែលលើសមតិកសកម្មនេះ គេហៅថា កាតព្វកិច្ចធម្មជាតិ ហើយមានលក្ខណៈដូចកាតព្វកិច្ចដែលផុតអំឡុងពេលអាជ្ញាយុកាលដែរ ។

កថាខណ្ឌទី ២ ចែងថា ចំពោះករណីនៃសហសន្តតិកម្ម ការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមទាំងអស់គ្នា ។ ពេលយល់ព្រមដោយមានកម្រិត ចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជីដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិកម្មទាំងអស់ត្រូវមានការឯកភាពក្នុងការសងនោះ ។ នេះក៏ព្រោះថា ប្រសិនបើមានតែសន្តតិជនមួយចំនួនបានយល់ព្រមទាំងស្រុង ហើយបានអះអាងនូវចំណែកមតិកនោះ ការជម្រះបញ្ជីនូវមតិកទាំងអស់នឹងគ្មានដំណើរការល្អទេ ។ ប្រសិនបើសន្តតិជនមួយចំនួនបានបោះបង់សន្តតិកម្ម នោះគ្មានបញ្ហាចោទទេ ។ ជនដែលបាន

បោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា មិនមែនជាសន្តតិជននោះតាំងពីដំបូងមក ហេតុនេះហើយ សន្តតិជនដែលនៅសល់នោះ យល់ព្រមដោយមានកម្រិតរួមគ្នាទៅបានហើយ ។ ម្យ៉ាងទៀត មានករណីដែលសន្តតិជនមួយចំនួន ក្នុងសន្តតិជនដែលយល់ព្រមដោយមានកម្រិត មានហេតុដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៥៩ កថាខណ្ឌទី ១ ហើយត្រូវទទួលខុសត្រូវដូចគ្នានឹងការយល់ព្រមទាំងស្រុង ដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រានោះ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ មតិកទាំងអស់ត្រូវឆ្លងកាត់តាមនីតិវិធីជម្រះបញ្ជី ដូច្នេះ សន្តតិជនដែលនឹងទទួលខុសត្រូវ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥៩ នោះ មិនអាចអះអាងថា ខ្លួនមានសិទ្ធិលើចំណែកមតិកសកម្មដែលមិនទាន់បញ្ចប់នីតិវិធីនៃការជម្រះបញ្ជីនេះឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២២ មាត្រា ៩២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៩០ មាត្រា ៦០៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ១២៥៧.- វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិចែងអំពីវិធី ជាអាទិ៍ សម្រាប់ធ្វើការយល់ព្រមដោយកម្រិត ។

ដើម្បីធ្វើការយល់ព្រមដោយកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេលគិតឱ្យបានដិតដល់ ។ ក្នុងករណីនៃសហសន្តតិកម្ម ទោះបីមានសន្តតិជនណាម្នាក់ដែលបានទុកឱ្យអំឡុងពេលនេះកន្លងផុតក៏ដោយ អាចគណនាអំឡុងពេលនេះ ដោយយកថ្ងៃដែលសន្តតិជនចុងក្រោយគេដឹងថា សន្តតិកម្មបានចាប់ផ្តើម មកធ្វើជាមូលដ្ឋាន ។ ក្នុងករណីនៃសហសន្តតិកម្ម សហសន្តតិជនទាំងអស់ ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការយល់ព្រមដោយកម្រិត (មាត្រា ១២៥៦ កថាខណ្ឌទី ២) ។ ដូច្នេះ ការគណនាអំឡុងពេលនេះគឺដើម្បីការពារសិទ្ធិរបស់សន្តតិជនដែលដឹងអំពីការចាប់ផ្តើមសន្តតិកម្មក្រោយគេ ។

នៅពេលដែលដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមតិក ។ ទម្រង់នៃបញ្ជីសារពើភ័ណ្ឌ គ្មានចែងក្នុងបញ្ញត្តិទេ ក៏ប៉ុន្តែ ត្រូវធ្វើសរសេរមតិកសកម្ម មតិកអកម្ម ដែលសន្តតិជនបានទទួលបន្តដោយចាប់ផ្តើមសន្តតិកម្មទាំងអស់ ក្នុងកម្រិតដែលមានលទ្ធភាពអាចដឹង ។ ប្រសិនបើមិនបានបញ្ជាក់ក្នុងបញ្ជីសារពើភ័ណ្ឌនេះឱ្យបាន

គ្រប់គ្រាន់ដោយចេតនា ត្រូវចាត់ទុកថាជាការយល់ព្រមទាំងស្រុង (មាត្រា ១២៥៩) ។ ក្នុងករណីដែលអាចស្មានបានថាចាំបាច់ត្រូវការពេលវេលា ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌមតិកនោះ សន្តតិជនអាចសុំឱ្យពន្យារអំឡុងពេលគិតឱ្យបានដិតដល់នេះបាន ដោយយោងតាមមាត្រា ១២៤៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៩១ មាត្រា ៥៨៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២៥៨.-** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយព្យាកុលភាពឡើយ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថា ម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ជាអាទិ៍ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិស្តីពីអានុភាពជាសារធាតុនៃការយល់ព្រមដោយកម្រិត ។

ទោះបីជាបានយល់ព្រមដោយកម្រិតក៏ដោយ តាមផ្លូវច្បាប់ មតិកនោះត្រូវធ្លាក់ទៅសន្តតិជន ក៏ប៉ុន្តែ ជាសារធាតុទ្រព្យសម្បត្តិនោះត្រូវធ្វើការជម្រះបញ្ជីផ្សេងពីទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ហេតុនេះហើយ សិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់សន្តតិជន និង មតកជន មិនអាចរលត់ដោយព្យាកុលភាពទេ ពោលគឺចាំបាច់ត្រូវធ្វើការជម្រះបញ្ជី ដោយនីតិវិធីដូចគ្នានឹងការជម្រះបញ្ជីសិទ្ធិលើបំណុល និង កាតព្វកិច្ចផ្សេងដែរ ។ ដូច្នេះ កថាខណ្ឌទី ២ បានចែងថា សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថា មិនបានរលត់ដោយព្យាកុលភាពឡើយ ។

ម្យ៉ាងទៀត ការគ្រប់គ្រង ឬ ការជម្រះបញ្ជី ជាអាទិ៍ នៃទ្រព្យសម្បត្តិ ក្នុងករណីដែលមានការយល់ព្រមដោយកម្រិត មានចែងពីមាត្រា ១២៨០ ទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៥៩.–** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមត៌ក តាមចំណែកមត៌កនីមួយៗនោះបាន ។

(កំណត់)

មាត្រានេះចែងថា ចំពោះសន្តតិជនដែលបានយល់ព្រមដោយកម្រិត ប្រសិនបើមានមូលហេតុដែលត្រូវចាត់ទុកជាការយល់ព្រមទាំងស្រុងតាមច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយកម្រិតត្រូវបានបាត់បង់ ហើយសន្តតិជននោះ ត្រូវទទួលខុសត្រូវដូចគ្នានឹងករណីដែលបានយល់ព្រមទាំងស្រុងដែរ ។

កថាខណ្ឌទី ១ ចែងអំពីករណីដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត ។ ករណីនេះខុសគ្នានឹងករណីនៃកថាខណ្ឌទី ២ គឺអាចផ្ទុកទំនួលខុសត្រូវទាំងអស់ឱ្យសន្តតិជននេះភ្លាមក៏គ្មានបញ្ហាអ្វីដែរ (ក្រោយពីបានយកទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជននេះមកសងកាតព្វកិច្ចហើយ ប្រសិនបើនៅសល់មត៌កដែលទទួលដោយសន្តតិកម្ម មត៌កនោះនឹងបានទៅសន្តតិជននេះ ដូច្នេះបូកសរុបទៅឃើញសូន្យ) ហើយត្រូវចាត់ទុកថាជាការយល់ព្រមទាំងស្រុង ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលជាសហសន្តតិកម្ម ហើយសន្តតិជនម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងនោះ មានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ។ ក្នុងករណីនេះ ជាបឋម ត្រូវធ្វើការជម្រះបញ្ជីអំពីមត៌កសិន ហើយបន្ទាប់មក ប្រសិនបើនៅមានការខ្វះខាត អាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់នោះមកសងបន្ថែម ។ រីឯកម្រិតនៃការទទួលខុសត្រូវ គឺត្រឹមទំហំនៃ

ចំណែកមតិកដែលសន្តតិជននោះបានទទួលប៉ុណ្ណោះ ។ ចំពោះកម្រិតនៃការទទួលខុសត្រូវនេះ ទោះបីជាការយល់ព្រមដោយកម្រិតក៏ដោយ សហសន្តតិជនត្រូវទទួលបន្ទុកកាតព្វកិច្ចរបស់មតកជន ទៅតាមចំណែកមតិក ក៏ប៉ុន្តែ ការទទួលខុសត្រូវមានទំហំត្រឹមតែមតិក ដូច្នេះ ក្នុងស្ថានភាពនេះ ការកកើតឡើងនៃអានុភាពដូចគ្នានឹងករណីដែលសន្តតិជននោះបានយល់ព្រមទាំងស្រុង គឺជាការដែលសន្តតិជននោះបានទទួលខុសត្រូវចំពោះចំណែកមតិកដែលខ្លួនបានទទួល ។ ដូច្នេះ ក្នុងកថាខណ្ឌនេះ បានចែងថា "ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល .......... តាមចំណែកមតិកនីមួយៗនោះបាន" មានន័យថា មិនដាក់ទណ្ឌកម្មឱ្យជននោះទទួលខុសត្រូវរហូតដល់កាតព្វកិច្ចទាំងអស់ទេ ។ ចំពោះការណ៍ដែលឱ្យទទួលខុសត្រូវចំពោះតែផ្នែកដែលខ្វះខាត ប្រសិនបើមិនបានធ្វើការជម្រះទេ មិនអាចដឹងច្បាស់លាស់នូវទំហំនៃការទទួលខុសត្រូវរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់នោះទេ ដូច្នេះហើយបានជាក្នុងកថាខណ្ឌនេះបានចែងថា "ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលពុំអាចទទួលការសងដោយមតិក" ដើម្បីបញ្ជាក់ច្បាស់ថា ត្រូវទទួលខុសត្រូវចំពោះតែផ្នែកដែលខ្វះក្រោយពេលជម្រះបញ្ជីតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត កថាខណ្ឌទី ១ ព្រមទាំងទី ២ នេះ មិនត្រឹមតែអនុវត្តចំពោះករណីដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ ក្រោយការដាក់ពាក្យសុំយល់ព្រមដោយកម្រិតរបស់សន្តតិជនប៉ុណ្ណោះទេ គឺត្រូវអនុវត្តផងដែរចំពោះករណីដែលមានមូលហេតុនេះ មុនការដាក់ពាក្យសុំយល់ព្រមដោយកម្រិត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃការបោះបង់សន្តតិកម្ម ។

ការដាក់ពាក្យសុំទៅតុលាការ ត្រូវធ្វើក្នុងអំឡុងពេលដែលបានចែងក្នុងមាត្រា ១២៤៨ ជាអាទិ៍ ។ ក្នុងករណីនៃសហសន្តតិកម្ម បុគ្គលមួយចំនួនអាចធ្វើបាន ដោយមិនចាំបាច់បោះបង់ទាំងអស់គ្នាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២៦១ ថ្មី.–** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះ តាំងពីដំបូងមក ។[២]

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងអំពីអានុភាពនៃការបោះបង់ គឺជនដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា មិនមែនជាសន្តតិជនតាំងពីដំបូង ។

ក្នុងមាត្រានេះ ដោយសារតែមានបញ្ញត្តិថា "តាំងពីដំបូង" ដូច្នេះជនដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា មិនមែនជាសន្តតិជនតាំងពីដំបូង ។ ក្នុងចំណោមសហសន្តតិជន ប្រសិនបើមានតែជនមួយចំនួនទេដែលបានបោះបង់សន្តតិកម្ម សន្តតិជនផ្សេងទៀតជាអ្នកទទួលសន្តតិកម្ម ។ អ្នកដែលមានលំដាប់បន្ទាប់ អាចទទួលសន្តតិកម្មបាន លុះត្រាតែសហសន្តតិជនលំដាប់មុនទាំងអស់បានបោះបង់ ។

មាត្រានេះមានចែងថា "ចំពោះសន្តតិកម្មនោះ" ។ ឧទាហរណ៍ ក្នុងករណីដែលឪពុកឈ្មោះ A បានទទួលមរណភាព ហើយម្តាយឈ្មោះ B ក៏បានទទួលមរណភាពជាបន្តបន្ទាប់ កូនឈ្មោះ C របស់អ្នកទាំងពីរនេះ អាចបោះបង់តែសន្តតិកម្មចំពោះ A បាន ឬក៏អាចបោះបង់តែសន្តតិកម្មចំពោះ B ក៏បាន តែក្នុងករណីនេះ គ្មានឥទ្ធិពលទៅវិញទៅមកទេ ។ ក្នុងករណីដែល C បានបោះបង់សន្តតិកម្មចំពោះតែ A សន្តតិកម្មរបស់ A នឹងត្រូវធ្លាក់ទៅលើ B ព្រមទាំងបងប្អូនបង្កើតផ្សេងទៀត ឬ ជនដែលមានលំដាប់បន្ទាប់ (បុព្វញាតិផ្ទាល់ ជាអាទិ៍) ។ ដូច្នេះ ប្រសិនបើ B មិនបានបោះបង់សន្តតិកម្ម ហើយ C ក៏មិនបានបោះបង់តាមការចែងនៃមាត្រា ១២៤៩ ដែរនោះ C អាចទទួលសន្តតិកម្មរួមទាំងចំណែកដែល B បានទទួលសន្តតិកម្មពី A ដែរ ដោយសារការទទួលសន្តតិកម្មពី B នេះ ។ ផ្ទុយទៅវិញ ប្រសិនបើ C បានបោះបង់សន្តតិកម្មតែពី B នោះ C អាចទទួលសន្តតិកម្មនូវមតិកសកម្ម ព្រមទាំងអកម្មរបស់ A ពាក់កណ្តាល តែមិនអាចទទួលសន្តតិកម្មនូវមតិករបស់ B ព្រមទាំងចំណែកមតិកដែល B បានទទួលពី A ដោយសន្តតិកម្មទេ ។

ម្យ៉ាងទៀត ចំពោះការគ្រប់គ្រងមតិក ក្រោយមានការបោះបង់សន្តតិកម្ម មានចែងក្នុងមាត្រា ១២៦២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៨៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

---

[២] មាត្រា ១២៦១ នេះ ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

# ជំពូកទី ៦ ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១ ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

(កំណត់)

ក្នុងករណីដែលជនដែលបានទទួលសន្តតិកម្មតែឯង ដោយគ្មានមតកសាសន៍ បានយល់ព្រមទាំងស្រុងនូវសន្តតិកម្ម មត៌កទាំងអស់នឹងធ្លាក់ទៅអ្នកនោះ ដូច្នេះគ្មានបញ្ហាអ្វីកើតឡើងទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលជាសហសន្តតិកម្ម ឬ ករណីដែលមានការបានបោះបង់សន្តតិកម្ម ចំពោះទំនាក់ទំនងនឹងសន្តតិជនផ្សេងទៀត ជាអាទិ៍ ការរក្សាទុក និង ការគ្រប់គ្រងមត៌កនោះ អាចមានបញ្ហា ។ មាត្រានេះចែងអំពីការរក្សាទុក និង គ្រប់គ្រងមត៌កក្នុងករណីនេះ ។

កថាខណ្ឌទី ១ ចែងថា ក្នុងករណីនៃសហសន្តតិកម្ម សន្តតិជនដែលកាន់កាប់មត៌កនៅពេលដែលមតកជនទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ នេះគឺដោយសារតែ គួរតែទុកមត៌កនោះឱ្យមានស្ថានភាពដដែល រហូតដល់ពេលធ្វើការបែងចែកមត៌កនោះ ។ ចំពោះមត៌កដែលមិនត្រូវបានកាន់កាប់ដោយសន្តតិជនណាម្នាក់ទេ នៅពេលដែលមតកជនបានទទួលមរណភាព សន្តតិជនទាំងអស់ ត្រូវរក្សាទុក និង គ្រប់គ្រងជាមួយគ្នា ។

កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ គឺជាបញ្ញត្តិដែលចែងថា ក្នុងករណីដែលមានមតកសាសន៍ យោងតាមមាត្រា ១២៦៣ អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកគ្រប់គ្រងមត៌កដែលមតកសាសន៍បានកំណត់ម្ចាស់ហើយ ដូច្នេះ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ១២៦៣ មានអាទិភាពជាង ។

កថាខណ្ឌទី ២ ចែងថា ជាបឋម នៅក្នុងអំឡុងពេលគិតឱ្យដិតដល់ដែលបានចែងក្នុងមាត្រា ១២៤៨ សន្តតិជន ត្រូវគ្រប់គ្រងមតិកនោះដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែរ ។ ប្រសិនបើសន្តតិជនបានបោះបង់សន្តតិកម្ម ពេលនោះមតិកនឹងក្លាយជាទ្រព្យសម្បត្តិរបស់ជនដទៃ ដូច្នេះ នេះជាបញ្ញត្តិស្តីពីកាតព្វកិច្ចរក្សាទុកនូវទ្រព្យសម្បត្តិដែលមិនទាន់មានម្ចាស់នៅឡើយ ។ បន្ទាប់មក ក្នុងករណីដែលបានបោះបង់សន្តតិកម្ម គឺជាការរក្សាទុកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ដូច្នេះ ត្រូវរក្សាទុកនូវទ្រព្យសម្បត្តិនោះរហូតដល់ពេលដែលអ្នកដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់នេះ អាចចាប់ផ្តើមគ្រប់គ្រងមតិកនេះបាន ។ ហេតុនេះហើយបានជា នៅក្នុងមាត្រា ១២៥៥ ចំណុច ក វាក្យខណ្ឌទី ២ ចែងយ៉ាងច្បាស់ថា "សកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង" មិនត្រូវបានយកមកធ្វើជាមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ទេ ។ម្យ៉ាងទៀត ពេលសន្តតិជនថ្មីទាមទារឱ្យប្រគល់មតិកនោះវិញ គឺជាការធម្មតា ដែលត្រូវប្រគល់ទៅឱ្យគេជាបន្ទាន់ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩៩៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា រីឯកថាខណ្ឌទី ២ សូមមើលមាត្រា ៩១៨ និង មាត្រា ៩៤០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមតិក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីការគ្រប់គ្រងមតិកដោយអ្នកប្រតិបត្តិមតកសាសន៍ ។

យោងតាមមាត្រា ១២២០ អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងមតិក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ហេតុនេះហើយ នៅក្នុងផ្នែកនេះ ដែលចែងអំពីការគ្រប់គ្រងមតិក ក៏មានបន្ថែមមាត្រានេះជាពិសេស ដោយចែងថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវគ្រប់គ្រងមតិក ពេលចាប់ផ្តើមកាន់កាប់មុខងារ ។

វាក្យខណ្ឌទី ២ នៃមាត្រា នេះចែងថា ក្នុងករណីដែលមតកសាសន៍ចែងអំពីទ្រព្យសម្បត្តិជាក់លាក់ណាមួយ ដូចជាការណីដែលមតិកមានដីប៉ុន្មានឡូត៍ដែរ តែមតកសាសន៍កំណត់អំពីអច្ច័យទាននូវដីមួយចំនួនទៅឱ្យបុគ្គលណាម្នាក់ប៉ុណ្ណោះ ជាអាទិ៍ អ្នកប្រតិបត្តិមតកសាសន៍ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិជាក់លាក់នោះប៉ុណ្ណោះ ។ ចំពោះមតិកដែលមិនមានចែងក្នុងមតកសាសន៍ ត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា ១២៦២ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១២ និង មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៦៤.-** អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

(កំណត់)

មាត្រានេះចែងអំពីអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ។ អ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន មិនត្រឹមតែគ្រប់គ្រងមតិកប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចធ្វើជាអ្នកទទួលបន្ទុកក្នុងបណ្ដឹង ចំពោះសិទ្ធិទាមទារពាក់ព័ន្ធនឹងមតិកនោះបាន ដើម្បីរក្សាការពារមតិកនោះ ជាអាទិ៍ ។

កថាខណ្ឌទី ១ ចែងអំពីការជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ។ សន្តតិជនជាអាទិ៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នបាន ។ ចំពោះសន្តតិជន អាចមានករណីដែលសន្តតិជនដែលកំពុងកាន់កាប់មតិក ធ្វើការចាត់ចែងមតិកនោះ មុនពេលបានព្រមព្រៀងអំពីការបែងចែកមតិក ឬ អាចមានករណីដែលមានការចាំបាច់រក្សាការពារមតិកដោយដាក់ពាក្យបណ្ដឹង ប៉ុន្តែ មានការពិបាកនឹងព្រមព្រៀងគ្នារវាងសន្តតិជនអំពីវិធីរក្សាការពារនេះ ។ ក្នុងករណីទាំងនេះ សន្តតិជនណាម្នាក់ ឬ ច្រើននាក់ អាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នបាន ដើម្បីឱ្យជននេះគ្រប់គ្រងមតិក ព្រមទាំងដាក់ពាក្យបណ្ដឹង ។ ចំពោះអច្ច័យលាភីវិញ

ប្រសិនបើបានជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ហើយ ប្រហែលជាមិនចាំបាច់មានអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នទេ ក៏ប៉ុន្តែ បញ្ញត្តិនេះត្រូវបានចែងឡើងសម្រាប់ពេលដែលអាចមានករណីពិសេស ។ ចំពោះអ្នកមានសិទ្ធិលើបំណុលរបស់មតកជនវិញ ភាពចាំបាច់ឱ្យមានអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន មានខ្ពស់ជាងគេ ។ មានន័យថា ម្ចាស់បំណុលរបស់មតកជន មានសិទ្ធិលើបំណុលដែលអាចយកទ្រព្យសម្បត្តិរបស់មតកជនមកសង ប៉ុន្តែ ដោយសារតែមតកជនបានទទួលមរណភាព សិទ្ធិលើបំណុលនេះ ត្រូវបានបែងចែកទៅតាមចំណែកមតិករបស់សហសន្តតិជន ហើយក្នុងករណីដែលមានម្ចាស់បំណុលចំពោះសន្តតិជនផ្ទាល់ ម្ចាស់បំណុលនេះអាចអនុវត្តសិទ្ធិនេះចំពោះចំណែកកម្មសិទ្ធិអវិភាគរបស់សន្តតិជនដែលជាកូនបំណុល ។ ដូច្នេះ ចាំបាច់ត្រូវរក្សាការពារមតិកនោះ មុនពេលដែលមតិកនោះត្រូវបានចែកជាចំណែក ឬមុនពេលដែលម្ចាស់បំណុលរបស់សន្តតិជនដាក់លាក់ណាម្នាក់ អនុវត្តសិទ្ធិនោះចំពោះចំណែកកម្មសិទ្ធិអវិភាគមតិកនោះ ។ ក្នុងករណីនេះ ទោះពីជាមាន ឬ គ្មានការបោះបង់ ឬ ការយល់ព្រមរបស់សន្តតិជនក៏ដោយ ក៏ម្ចាស់បំណុលនៃមតកជនអាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ដើម្បីរក្សាការពារមតិក ហើយដាក់ពាក្យសុំឱ្យរក្សាការពារចំពោះអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ននោះ ។ ចំណុចនេះមានពន្យល់ក្នុងផ្នែកទី ៣ នៃជំពូកនេះ ស្ដីពីការសម្រួលរវាងម្ចាស់បំណុល ។

កថាខណ្ឌទី ២ ចែងអំពីសិទ្ធិអំណាចពិសេសរបស់អ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ។ សម្រាប់គោលបំណងដែលបានបញ្ជាក់ខាងលើនេះ អ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្នក៏ត្រូវបានផ្ដល់ផងដែរនូវតួនាទីដែលហៅថា អ្នកការពារមតិក (Nachlaßpfleger) ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១៩៦០ កថាខណ្ឌទី ៣ និងមាត្រា ១៩៦១ ។ ក្រមរដ្ឋប្បវេណីជប៉ុន ក៏ចែងឱ្យសន្តតិជនអាចដាក់ពាក្យសុំឱ្យតុលាការធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងបានដែរ ក៏ប៉ុន្តែសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងក្នុងករណីនេះ គឺមានត្រឹមតែសិទ្ធិអំណាចដូចអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលអវត្តមានតែប៉ុណ្ណោះ ។ រីឯមាត្រានេះវិញ ដើម្បីសម្រេចនូវគោលបំណងខាងលើនេះ បានផ្ដល់លក្ខណសម្បត្តិឱ្យធ្វើជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងចំពោះសិទ្ធិទាមទារពាក់ព័ន្ធនឹងមតិក ។ ដូច្នេះ អ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ននោះអាចធ្វើបណ្ដឹងដើម្បីរក្សាការពារ ឬ គ្រប់គ្រងមតិកនេះបាន ហើយម្យ៉ាងទៀត ក៏អាចត្រូវសន្តតិជនប្ដឹងអំពីមតិកបានដែរ ។ ទោះជាក្នុងករណីណាក៏ដោយ អានុភាពនៃសាលក្រម សាលដីកា ឬ ការសះជា មានឥទ្ធិពលទៅលើសន្តតិជនផងដែរ ។

ម្យ៉ាងទៀត ក្នុងករណីនៃសហសន្តតិកម្ម មុខនាទីរបស់អ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ននេះ នឹងត្រូវមាន "រហូតដល់ពេលធ្វើការបែងចែកមតិក" ដូចមានចែងក្នុងកថាខណ្ឌទី ១ ក៏ប៉ុន្តែ យោងតាមកថាខណ្ឌទី ២ វិញ សហសន្តតិជនអាចទទួលបន្តនូវសិទ្ធិគ្រប់គ្រងពីអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ក្រោយពេលធ្វើការយល់ព្រមបាន ។ ម្យ៉ាងទៀត ក្នុងករណីដែលមានសន្តតិកម្មតែឯង ក៏ដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩៩៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា រីឯចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ១៩៦០ កថាខណ្ឌទី ៣ និង មាត្រា ១៩៦១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

**មាត្រា ១២៦៥.-** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

(កំណត់)

មាត្រានេះចែងច្បាស់លាស់ថា ជាគោលការណ៍ សោហ៊ុយចាំបាច់ដើម្បីរក្សាការពារមត៌ក ជាអាទិ៍ ត្រូវចំណាយចេញពីមត៌ក ។

"សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក" ដែលមានចែងក្នុងមាត្រានេះ គឺមានដូចជា កម្រៃសម្រាប់អ្នកគ្រប់គ្រងមត៌ក ដែលត្រូវបានជ្រើសតាំងក្នុងករណីដែលគ្មានសន្តតិជន តាមមាត្រា ១២៩១ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ការបែងចែកមត៌ក

**មាត្រា ១២៦៦ ថ្មី.-** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយ លក្ខណ៍អក្សរ ជាអាទិ៍ ។[៣]

(កំណត់)

ការបែងចែកមត៌ក ជាគោលការណ៍ ត្រូវធ្វើតាមការពិភាក្សារវាងសហសន្តតិជន ក៏ប៉ុន្តែ ប្រសិនបើការពិភាក្សានោះ

[៣] កថាខណ្ឌទី ២ នៃមាត្រា ១២៦៦ នេះ ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

មិនបានទទួលនូវលទ្ធផលល្អទេ តុលាការនឹងធ្វើការបែងចែកមតិកនោះ ។ មាត្រានេះជាបញ្ញត្តិស្តីពីការបែងចែកមតិកដោយការពិភាក្សារវាងសហសន្តតិជន ។

ក្នុងករណីដែលមានសន្តតិជនច្រើននាក់ យោងតាមមាត្រា ១១៤៨ មតិកត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ហើយការបែងចែកមតិក គឺជាការប្តូរគ្នាទៅវិញទៅមករវាងសហសន្តតិជននីមួយៗ នូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់សាមីខ្លួនម្នាក់ៗ ចំពោះទ្រព្យសម្បត្តិច្រើនដែលជាកម្មសិទ្ធិអវិភាគនេះ រួចកំណត់ឱ្យមតិកនីមួយៗនោះ ធ្លាក់ជាកម្មសិទ្ធិឯករាជ្យដោយឡែករបស់សហសន្តតិជនណាម្នាក់ ឬ ជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនកំណត់មួយ ។ ដូច្នេះ ដើម្បីបែងចែកមតិក ចាំបាច់ត្រូវមានការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់ ។ ក្នុងចំណោមសហសន្តតិជន ទោះបីជាមានអ្នកដែលបានទទួលផលប្រយោជន៍ពិសេសច្រើន ជាហេតុធ្វើឱ្យអ្នកនោះមិនអាចទទួលសន្តតិកម្មបាន ដោយយោងតាមមាត្រា ១១៦៣ កថាខណ្ឌទី ២ ក៏ដោយ ក៏ចាំបាច់ឱ្យសន្តតិជននោះចូលរួមក្នុងការពិភាក្សាបែងចែកមតិក ដើម្បីឱ្យសន្តតិជននោះបញ្ជាក់អំពីការណ៍នេះដែរ ។

កថាខណ្ឌទី ១ ចែងថា បើអំឡុងពេលមួយខែបានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាគ្នា ដើម្បីបែងចែកមតិកពេលណាក៏បានដែរ ។ តាមភាពជាក់ស្តែង ត្រូវរកសហសន្តតិជន (ឧទាហរណ៍ ត្រូវស្រាវជ្រាវមើលថា តើពីដើមមក មតកជនមានកូនដែលមកពីអាពាហ៍ពិពាហ៍ពីមុន ឬទេ ឬ មានកូនដែលខ្លួនបានទទួលស្គាល់ឬទេ ? ជាអាទិ៍) ហើយបន្ទាប់មក ត្រូវកំណត់ថា តើសហសន្តតិជនយល់ព្រម ឬ បោះបង់សន្តតិកម្ម រួចកំណត់នូវទំហំនៃសហសន្តតិជន ហើយបន្ទាប់មកទៀត ធ្វើការពិភាក្សាដើម្បីបែងចែកមតិក ដូច្នេះ ត្រូវការពេលវេលាច្រើនគួរសមដែរ ។ ក៏ប៉ុន្តែ ទោះបីជាការស្រាវជ្រាវ ជាអាទិ៍ នោះអាចធ្វើបានងាយស្រួលក៏ដោយ ក្នុងអំឡុងពេលមួយខែក្រោយមរណភាពរបស់មតកជន ចាំបាច់ត្រូវផ្តល់ការគោរពចំពោះវិញ្ញាណក្ខន្ធមតកជន ហេតុនេះហើយបានជាក្នុងអំឡុងពេលមួយខែនេះ ហាមមិនឱ្យបែងចែកមតិក ។ ក៏ប៉ុន្តែ ទោះបីជាក្នុងអំឡុងពេលនេះក៏ដោយ ដោយសារតែកសិផលជាអាទិ៍ អាចមានការខូចខាតបើទុកចោល ដូច្នេះ អាចលក់ប្តូរជាប្រាក់បាន (សូមមើលមាត្រា ១២៦២) ហើយក្នុងករណីនេះ ទឹកប្រាក់ដែលបានមកពីការលក់នេះ នឹងក្លាយជាកម្មវត្ថុនៃការបែងចែកមតិក ។

កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ឃ្លាខាងដើម ចែងបញ្ជាក់ថា ដើម្បីការពារម្ចាស់បំណុលរបស់មតកជន ទោះបីជាការពិភាក្សាបានទទួលលទ្ធផលល្អក៏ដោយ ក៏ក្នុងអំឡុងពេលកំណត់មួយ មិនអាចប្តូរឈ្មោះពីមតកជនទៅឱ្យសន្តតិជនដែរ។ ចំពោះបញ្ហាលម្អិត សូមមើលសេចក្តីកំណត់ក្នុងមាត្រា ១២៧៧ និង សេចក្តីកំណត់នៅដើមផ្នែកទី ៣ ។

កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ឃ្លាខាងក្រោយ ចែងអំពីករណីដែលមតកជនបានហាមឃាត់មិនឱ្យធ្វើការបែងចែកមតិកក្នុងអំឡុងពេលក្រោម ៥ ឆ្នាំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៨៣ ។ នៅក្នុងមាត្រា ១២៦៦ នេះ បានចែងថា "ការបែងចែកមតិកពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ" ។ គេអាចបកស្រាយថា មិនអាចដាក់ពាក្យសុំទាមទារឱ្យតុលាការសម្រេចសេចក្តីអំពីការបែងចែកមតិក ក៏ប៉ុន្តែ ប្រសិនបើអំឡុងពេលមួយខែបានកន្លងផុតក្រោយមរណភាពរបស់មតកជន ហើយសហសន្តតិជនទាំងអស់បានព្រមព្រៀងគ្នា អាចធ្វើការបែងចែកមតិកបាន

ដោយគ្មានទាក់ទងនឹងមតកសាសន៍ទេ បានសេចក្ដីថាការបកស្រាយសម្រួលក៏ត្រូវបានអនុញ្ញាតផងដែរ ។ នៅក្នុងប្រទេសជប៉ុន បញ្ញត្តិនេះត្រូវបានបកស្រាយយ៉ាងដូច្នេះ ។ បញ្ហានេះក៏ដូចគ្នាដែរ ចំពោះករណីដែលសហសន្តតិជនទាំងអស់បានព្រមព្រៀងធ្វើការបែងចែកមតិក ដែលមានខ្លឹមសារខុសពីវិធីបែងចែកមតិកដែលបានកំណត់ដោយមតកសាសន៍ ហើយពេលនោះ ត្រូវធ្វើការបែងចែកមតិកតាមការពិភាក្សានោះ ។ តាមផ្លូវច្បាប់ គេបកស្រាយការបែងចែកបែបនេះថាជាការដែលសហសន្តតិជនបានធ្វើប្រទានកម្ម ឬ ប្ដូរគ្នាទៅវិញទៅមក បន្ទាប់ពីមតិកត្រូវបានធ្លាក់ទៅលើសន្តតិជនជាក់លាក់ តាមរយៈមតកសាសន៍ ។

ការពិភាក្សាបែងចែកមតិកនោះ មិនមែនជាសកម្មភាពចាំបាច់មានទម្រង់ទេ ហើយមិនចាំបាច់ធ្វើជាលាយល័ក្ខណ៍អក្សរ ។ ក៏ប៉ុន្តែ ក្នុងចំណោមមតិកទាំងអស់ មានមតិកខ្លះត្រូវការមានទម្រង់កំណត់មួយដើម្បីផ្ទេរសិទ្ធិ ឬ ដើម្បីឱ្យមានល័ក្ខខ័ណ្ឌតតាំង ។ ហេតុនេះហើយ នៅក្នុងកថាខណ្ឌទី ២ មានចែងថា ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុ តាមការបែងចែកមតិក ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ។ ឧទាហរណ៍ ជាលទ្ធផលនៃការបែងចែកមតិកដីធ្លីត្រូវបានបែងចែក ក្នុងករណីដែលចំណែកនៃកម្មសិទ្ធិអវិភាគត្រូវបានផ្ទេរ ឬ ក្នុងករណីដែលដីធ្លីដែលមានឈ្មោះមតកជន ត្រូវដាក់ជាកម្មសិទ្ធិរបស់សន្តតិជនកំណត់ណាមួយតែម្នាក់ឯង ដើម្បីចុះបញ្ជីបញ្ជាក់អំពីការផ្ទេរទាំងនេះ ត្រូវធ្វើលិខិតយថាភូត (សូមមើលមាត្រា ៣៣៦ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ចំពោះសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការបែងចែកមតិក ដើម្បីធ្វើការពិភាក្សាបែងចែកមតិកនោះទៅឱ្យកំណត់សន្តតិជនណាម្នាក់ជាម្ចាស់សិទ្ធិតែម្នាក់ឯង នោះចាំបាច់ត្រូវធ្វើតាមនីតិវិធីដើម្បីបំពេញល័ក្ខខ័ណ្ឌតតាំង ដែលបានកំណត់ក្នុងមាត្រា ១២៧៥ ។ ដូច្នេះ ទោះបីជាសន្តតិជនផ្សេងទៀតបានព្រមព្រៀងបែងចែកមតិកតាមផ្ទាល់មាត់ក៏ដោយ ប្រសិនបើមិនធ្វើនីតិវិធីនោះទេ គេនឹងវាយតម្លៃថាការពិភាក្សាបែងចែកមតិកមិនបានធ្វើឡើងរវាងសហសន្តតិជននោះទេ ហើយចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតិក ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩០៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៩៧ មាត្រា ៥៩៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## មាត្រា ១២៦៧.– មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមតិកនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមតិក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់លក្ខខណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

(កំណត់)

មាត្រានេះចែងអំពីមូលដ្ឋាននៃការបែងចែកមតិក ។

កថាខណ្ឌទី ១ ចែងអំពីចំណុចដែលត្រូវគិតពិចារណា ពេលធ្វើការបែងចែកមតិក ចំណុចនីមួយៗនោះជាឧទាហរណ៍ ហើយនៅខាងចុងឃ្លា ថែមទាំងបានចែងថា ឱ្យពិចារណា "ស្ថានភាពផ្សេងទៀត" ផងដែរ ។ ពេលដែលធ្វើការពិភាក្សាបែងចែកមតិករវាងសហសន្តតិជន សហសន្តតិជនត្រូវពិចារណាដល់ចំណុចទាំងអស់នេះ ប៉ុន្តែ ប្រសិនបើសហសន្តតិជនទាំងអស់បានព្រមព្រៀងគ្នា ទោះបីជាខ្លឹមសារនៃការព្រមព្រៀងនោះខុសនឹងគោលគំនិតនៃមាត្រានេះក៏ដោយ បើខ្លឹមសារនោះមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អទេ ក៏ការណ៍នេះគ្មានឥទ្ធិពលទៅលើអានុភាពនៃការព្រមព្រៀងនោះដែរ ។ កថាខណ្ឌនេះ មានន័យតាមផ្លូវច្បាប់ ដើម្បីយកមកធ្វើជាមូលដ្ឋាន ក្នុងការវិនិច្ឆ័យមើលថា តើខ្លឹមសារនៃការពិភាក្សានោះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អឬទេ និង ក្នុងការបែងចែកមតិក ដោយតុលាការ ដោយយោងតាមមាត្រា ១២៧០ ។

កថាខណ្ឌទី ២ ចែងអំពីវិធីបែងចែកតាមវិធីបង់ប្រាក់សម្រួល ។ ក្នុងការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ (មាត្រា ២១២) បានចែងអំពីដំណោះស្រាយដោយប្រាក់សំណង ហើយគោលគំនិតនៃមាត្រានេះក៏មានដូចគ្នាដែរ ។ ម្យ៉ាងទៀត កថាខណ្ឌនេះ ចែងអំពីលក្ខខណ្ឌថា "ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ" ។ បញ្ញត្តិនេះត្រូវអនុវត្តចំពោះករណីដែលតុលាការធ្វើការបែងចែកមតិកតាមមាត្រា ១២៧០ ។ ប្រសិនបើសហសន្តតិជនព្រមពៀងដោយស្ម័គ្រចិត្ត ទោះបីជាមតិកណាមួយអាចបែងចែកបានក៏ដោយ អាចពិភាក្សា ដោយឱ្យជនណាម្នាក់ទទួលមតិកនោះតែឯង ហើយជននោះបង់ប្រាក់សម្រួលទៅឱ្យសហសន្តតិជនផ្សេងទៀតបាន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៦១២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៦១៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ១០៩ នៃបទប្បញ្ញត្តិស្ដីពីការវិនិច្ឆ័យរឿងក្ដីគ្រួសារជប៉ុន ។

**មាត្រា ១២៦៨.-** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជា

កម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់នូវសិទ្ធិអាទិភាពក្នុងការធ្វើលទ្ធកម្មរបស់សហព័ទ្ធដែលនៅរស់ ចំពោះទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ និង មតកជន ពេលនៅរស់ ។

នៅក្នុងមាត្រា ៩៧៣ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ ម្ខាងបានធ្វើលទ្ធកម្ម ពេលមានចំណងអាពាហ៍-ពិពាហ៍ ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិរួម ។ ដូច្នេះ ប្រសិនបើប្តី ឬ ប្រពន្ធណាម្នាក់ទទួលមរណភាព ពាក់កណ្តាលនៃទ្រព្យសម្បត្តិនោះ ជារបស់សហព័ទ្ធដែលនៅរស់ ហើយពាក់កណ្តាលទៀត ជាមតិក ។ ក៏ប៉ុន្តែ ទ្រព្យសម្បត្តិប្រភេទនេះក្នុងករណីជាច្រើន សហព័ទ្ធដែលនៅរស់តែងតែមានបំណងចង់ទទួលតែម្នាក់ឯង ដើម្បីជាអនុស្សាវរីយ៍រវាងសហព័ទ្ធដែលនៅរស់ និង មតកជន ហើយប្រសិនបើទទួលបានកម្មសិទ្ធិឯកឯង ទំនាក់ទំនងផ្លូវច្បាប់ ពេលក្រោយ ក៏មិនសូវមានបញ្ហាដែរ ។ ដូច្នេះហើយបានជាក្នុងការបែងចែកមតិក មាត្រានេះទទួលស្គាល់ឱ្យសហព័ទ្ធ មានអាទិភាពជាងសហសន្ត-តិជនផ្សេងទៀត ក្នុងការទទួលចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន ចំពោះទ្រព្យសម្បត្តិរួម រហូតដល់បានទទួលគ្រប់ចំនួននូវចំណែកមតិករបស់ខ្លួន ។

**មាត្រា ១២៦៩.–** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

(កំណត់)

ដូចដែលបានពន្យល់ពីដើមរួចហើយ គន្ថីនេះបានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ដូច្នេះក្នុងករណីនៃសហសន្តតិកម្ម សហសន្តតិជនម្នាក់ៗត្រូវទទួលបន្តមិនត្រឹមតែសិទ្ធិរបស់មតកជនទេ គឺទាំងករណីយកិច្ចផងដែរ ទៅតាមចំណែកមតិករបស់ខ្លួន (មាត្រា ១១៤៨) ។ មាត្រានេះ ចែងអំពីវិធីបែងចែកមតិកក្នុងករណីដែលមតកជនមានកាតព្វកិច្ច ។

ចំពោះរបបច្បាប់សន្តតិកម្ម ប្រសិនបើបានជ្រើសរើសយកគោលការណ៍ជម្រះបញ្ជី គឺត្រូវទទួលសន្តតិកម្មតែមតិក

ដែលសល់ពីការជម្រះបញ្ជីនៃកាតព្វកិច្ចដែលត្រូវធ្វើសន្តតិកម្មប៉ុណ្ណោះ ហើយធ្វើការបែងចែកមតិកសកម្មដែលសល់នោះ ។ ក៏ប៉ុន្តែ វិធីនេះស្មុគស្មាញណាស់ ហើយចំណាយសោហ៊ុយច្រើនផង ហេតុនេះហើយបានជាក្នុងគន្លឹនេះ បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ ។ ក៏ប៉ុន្តែ នៅក្នុងការពិភាក្សាបែងចែកមតិក ប្រសិនបើកាតព្វកិច្ចដែលត្រូវធ្វើសន្តតិកម្មត្រូវបានដោះស្រាយរួចរាល់ជាមុន នោះនឹងមិនបន្សល់ទុកនូវបញ្ហាឡើយ ។ ដូច្នេះ មាត្រានេះចែងថា ត្រូវធ្វើការបែងចែកមតិកដោយពិចារណាដល់ការសងកាតព្វកិច្ចផងដែរ ។ ឧទាហរណ៍ ប្រសិនបើមតកជនមានប្រាក់បញ្ញើក្នុងធនាគារ សហសន្តតិជនអាចយកប្រាក់បញ្ញើនេះសងបំណុលសិន ឬ ក៏សហសន្តតិជនទាំងអស់អាចព្រមព្រៀងលក់ទ្រព្យសម្បត្តិកំណត់ណាមួយ ហើយយកប្រាក់ដែលបានមកពីការលក់ទ្រព្យនោះសងបំណុលដែលត្រូវទទួលតាមសន្តតិកម្មសិន ។ មានន័យថា មាត្រានេះបានយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកប្រើ ប៉ុន្តែ ក៏មានយកអត្ថប្រយោជន៍នៃគោលការណ៍ជម្រះបញ្ជីបញ្ចូលគ្នាផងដែរ ។ ឃ្លា "ដោយពិចារណាពីការណ៍ថា ... មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ច ... ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ" មានន័យថា ត្រូវពិចារណាថា កាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ត្រូវបានបែកចែកដោយស្វ័យប្រវត្តិ ទៅតាមសមាមាត្រនៃចំណែកម្នាក់ៗ នៅពេលចាប់ផ្តើមសន្តតិកម្ម ហើយមិនអាចប្តូរនូវសមាមាត្រនៃបន្ទុកនេះបានទេ ទោះបីជាមានការព្រមព្រៀងពីសហសន្តតិជនក៏ដោយ ។ ដូច្នេះ ក្នុងករណីដែលមតកជនបានធ្វើអាជីវកម្មអ្វីមួយ ហើយមានទ្រព្យសកម្មផង និង ទ្រព្យអកម្មផង ដើម្បីធ្វើការព្រមព្រៀងឱ្យសហសន្តតិជនណាម្នាក់ ឬ ច្រើននាក់ ទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្មនោះ ជំនួសឱ្យការទទួលបន្តអាជីវកម្មទាល់តែមានការយល់ព្រមពីម្ចាស់បំណុល ហើយមាត្រានេះក៏បានចែងច្បាស់លាស់អំពីចំណុចនេះ ។ ចំពោះម្ចាស់បំណុលវិញ គេនឹងពិចារណាថា តើសន្តតិជនដែលបានទទួលបន្តនូវអាជីវកម្មនោះ មានទេពកោសល្យដែរឬទេ តើទ្រព្យសកម្មដែលជននោះបានធ្វើលទ្ធកម្មមានប៉ុន្មាន ជាអាទិ៍ ហើយយល់ព្រម ឬ ជ្រើសរើសការបែងចែកសិទ្ធិលើបំណុលរបស់ខ្លួននេះទៅឱ្យសហសន្តតិជនម្នាក់ៗទទួលខុសត្រូវ ។

**មាត្រា ១២៧០.–** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមតិក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមតិកនោះបាន ។

២-ក្នុងការបែងចែកមតិក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធី និង គោលការណ៍ ជាអាទិ៍ ក្នុងករណីដែលតុលាការបែងចែកមតិកជំនួសសហសន្តតិជន ។

កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលការពិភាក្សារវាងសហសន្តតិជនអំពីការបែងចែកមតិក ពុំបានសម្រេច ឬ ក្នុងករណីដែលសហសន្តតិជនពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមតិកនោះបាន ។ នេះជាបញ្ញត្តិដូចគ្នានឹងបញ្ញត្តិនៃមាត្រា ២១២ ស្ដីពីវិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ។ តុលាការមិនអាចធ្វើការបែងចែកមតិកដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ ពោលគឺអាចធ្វើបានតែពេលដែលមានពាក្យសុំពីសហសន្តតិជនប៉ុណ្ណោះ ។ "បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមតិក ពុំបានសម្រេច ឬ បើពុំអាចធ្វើបានទេ" សហសន្តតិជនម្នាក់ ឬ ច្រើននាក់អាចធ្វើពាក្យសុំឱ្យតុលាការធ្វើការបែងចែកមតិក ចំពោះសហសន្តតិជនទាំងអស់ផ្សេងទៀតដែលជាភាគីម្ខាងទៀតបាន ។

កថាខណ្ឌទី ២ ចែងអំពីគោលការណ៍ក្នុងការបែងចែកមតិកដោយតុលាការ ។ បញ្ញត្តិចាប់ពីមាត្រា ១២៦៧ ដល់មាត្រា ១២៦៩ គឺជាគោលការណ៍នៃការបែងចែកមតិករវាងសហសន្តតិជន ព្រមជាមួយគ្នានេះ ក៏ជាគោលការណ៍នៃការបែងចែកមតិកដោយតុលាការដែរ ។ លើសពីនេះ តុលាការត្រូវពិចារណាដល់ "ទំនៀមទម្លាប់នៅក្នុងតំបន់" និង "មតិភាគច្រើនលើសពីពាក់កណ្ដាលរបស់សហសន្តតិជន" ផងដែរ ។ ចំពោះ "មតិភាគច្រើនលើសពីពាក់កណ្ដាលរបស់សហសន្តតិជន" ករណីភាគច្រើនដែលបានចាប់ផ្ដើមធ្វើការពិភាក្សាដើម្បីបែងចែកមតិក តែមិនអាចធ្វើទៅបានទេនោះ គឺដោយសារតែក្នុងចំណោមសហសន្តតិជន មានសហសន្តតិជនណាម្នាក់ ឬ ភាគតិចនោះ មិនសុខចិត្តសម្រុះមតិពិសេសរបស់ខ្លួនទៅនឹងមតិភាគច្រើន ហេតុនេះហើយបានជាចាំបាច់មានបញ្ញត្តិនេះ ។ ប៉ុន្តែ ទោះបីជាមានមតិភាគច្រើនរបស់សហសន្តតិជនក៏ដោយ ប្រសិនបើមតិនោះមិនសមរម្យទេ ក៏តុលាការមិនត្រូវយកតាមមតិនោះដែរ ហើយទោះបីជាមតិភាគតិចក៏ដោយ ប្រសិនបើសមរម្យ តុលាការគួរតែស្ដាប់តាមមតិភាគតិចនោះដែរ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩០៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៦១១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៦១២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## មាត្រា ១២៧១.- ការប្ដូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

(កំណត់)

មាត្រានេះចែងអំពីវិធីលក់មតិក និង បែងចែកប្រាក់ដែលបានមកពីការលក់មតិក ។

ឧទាហរណ៍ មតិកមានតែដីមួយឡូត៍ និង ប្រាក់បញ្ញើក្នុងធនាគារ ក៏ប៉ុន្តែ មានករណីដែលសហសន្តតិជនបានខ្វែងគំនិតគ្នាដោយទាមទារដីឡូត៍នេះ ឬ ខ្វែងគំនិតគ្នាអំពីវិធីបែងចែក ឬ ប្រសិនបើបែងចែកទៅ តម្លៃនៃដីនោះនឹងធ្លាក់ ជាដើម ។ ក្នុងករណីនេះ ត្រូវឱ្យដីនោះទៅសន្តតិជនណាម្នាក់ ហើយឱ្យជននោះបង់ជាប្រាក់សម្រួលទៅឱ្យសន្តតិជន ផ្សេងទៀត តាមមាត្រា ១២៦៧ កថាខណ្ឌទី ២ បានដែរ ក៏ប៉ុន្តែ មានករណីខ្លះដែលគ្មានសន្តតិជនណាម្នាក់ មានលទ្ធភាពដើម្បីបង់ប្រាក់សម្រួលនោះបាន ។ ដូច្នេះ ក្នុងករណីនេះ ដើម្បីបែងចែកមតិក តុលាការអាចដាក់មតិកនោះ លក់បាន ។ នីតិវិធីនៃការលក់មតិកនោះមានដូចជា ការបង្គាប់ដោយតុលាការ ឱ្យសហសន្តតិជនលក់តាមវិធីលក់ឡាយឡុង ហើយអាចយកមាត្រា ២១២ ស្ដីពីវិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគមកយោងបាន ។ ប្រសិនបើសាលក្រមអំពីការបែងចែកមតិកមិនបានចូលជាស្ថាពរទេ ការលក់ក៏មិនអាចធ្វើទៅបានដែរ ដូច្នេះ សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម អំពីការបែងចែកមតិក ក្នុងករណីនេះ គឺដូចជា "ត្រូវលក់អចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌដែលភ្ជាប់ជាមួយនេះ ហើយកាត់នូវសោហ៊ុយចាំបាច់ពីថ្លៃលក់នោះ ហើយនៅសល់ប៉ុន្មាននោះ សន្តតិជន A, B និង C ទទួលជាសន្តតិកម្ម ស្មើភាគគ្នា" ។ ប្រសិនបើមានគ្រាប់ត្បូងតម្លៃ ១០០ ដុល្លារ ក្រៅពីដីនេះ ហើយឱ្យ A ទទួលលទ្ធកម្មគ្រាប់ត្បូងនេះ ហើយលក់អចលនវត្ថុដែលមានបញ្ហានេះ សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម គឺ "១. A ត្រូវទទួលសន្តតិកម្មគ្រាប់ត្បូង ដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌដែលភ្ជាប់ជាមួយនេះ ។ ២. ត្រូវលក់អចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ដែលភ្ជាប់ជាមួយនេះ ហើយកាត់នូវសោហ៊ុយចាំបាច់ពីថ្លៃលក់នោះ ហើយបូកនឹងប្រាក់ ១០០ ដុល្លារ ហើយ ១ ភាគ ៣ នៃចំនួនប្រាក់នេះ សន្តតិជន B និង C ត្រូវទទួលសន្តតិកម្ម ហើយនៅសល់ប៉ុន្មាន សន្តតិជនA ជាអ្នកទទួលសន្តតិកម្ម" ។ ម្យ៉ាងទៀត នៅពេលដែលកំពុងចាត់ការរឿងក្ដីអំពីការបែងចែកមតិក តុលាការអាចធ្វើសំណូមពរឱ្យសហសន្តតិជន លក់មតិក ហើយសហសន្តតិជនទាំងអស់គ្នា អាចលក់ទ្រព្យដែលជាកម្មវត្ថុនៃមតិកនេះ ទៅតាមសំណូមពរនេះបាន ។ ក្នុងករណីនេះ ថ្លៃលក់ក៏ជាមតិកដែរ (សូមមើលមាត្រា ១២៧២) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ១៥-៤ នៃច្បាប់ស្ដីពីការវិនិច្ឆ័យរឿងក្ដីគ្រួសារជប៉ុន

## មាត្រា ១២៧២.- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានយកកម្មវត្ថុមតិក ឬ តាមកិច្ចសន្យាដែលយកមតិកជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមតិកនោះ ត្រូវស្ថិតនៅក្នុងមតិក ។

(កំណត់)

មាត្រានេះចែងអំពីទ្រព្យដែលបានធ្វើលទ្ធកម្មដោយការចាត់ចែងមតិក ជាអាទិ៍ ។

"ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម .... ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមតិកនោះ" សំដៅទៅលើផលធម្មជាតិ ឬ ផលស៊ីវិលដែលកើតឡើងពីមតិក ដូចជា ការប្រាក់ដែលកើតឡើងក្រោយពេលចាប់ផ្តើមសន្តតិកម្ម ចំពោះប្រាក់បញ្ញើក្នុងធនាគារដែលជាមតិក ជាអាទិ៍ ។ រីឯ "ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានយកកម្មវត្ថុមតិក" មានដូចជា សិទ្ធិលើបំណុលដែលអាចទាមទារសំណងនៃការខូចខាត ឬ ប្រាក់សំណងនៃការខូចខាត ក្នុងករណីដែលសហសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ឬ តតិយជនណាមួយ ទទួលបន្ទុកនូវកាតព្វកិច្ចសងសំណងនៃការខូចខាតដោយសារការធ្វើឱ្យបាត់បង់មតិក ជាដើម ។ម្យ៉ាងទៀត "ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ...... តាមកិច្ចសន្យាដែលយកមតិកជាកម្មវត្ថុ" មានដូចជា ប្រាក់ដែលបានមកពីការលក់មតិកដោយសហសន្តតិជនទាំងអស់ ឬ ដោយតុលាការ តាមបញ្ញត្តិនៃមាត្រា ១២៧១ ។ ប្រាក់ទាំងអស់នេះ សុទ្ធតែជាវត្ថុជំនួសមតិក ហើយដែលជាភាគនៃមតិកនោះ ដូច្នេះ អាចក្លាយជាកម្មវត្ថុនៃការបែងចែកបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២០៤១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ១២៧៣.-** អានុភាពនៃការបែងចែក

១-ការបែងចែកមតិក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬ បានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការបែងចែកមតិក ។

កថាខណ្ឌទី ១ ចែងថា ការបែងចែកមតិក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ចំពោះសន្តតិកម្ម ក្នុងចំណោមប្រទេសដែលបានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មានប្រទេសខ្លះទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការបែងចែក (ជប៉ុន, បារាំង ជាអាទិ៍) ហើយមានប្រទេសខ្លះ មិនទទួលស្គាល់នូវអានុភាពប្រតិសកម្មដែរ គឺតាមផ្លូវច្បាប់ ឱ្យឆ្លងកាត់តាមដំណាក់កាលផ្ទេរពីមតកជនទៅកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ហើយពីកម្មសិទ្ធិអវិភាគទៅកម្មសិទ្ធិរៀងៗខ្លួន (អាល្លឺម៉ង់ ស្វីស ជាអាទិ៍) ។ មាត្រានេះទទួលស្គាល់

នូវអានុភាពប្រតិសកម្ម ដោយសារតែបានពិចារណាចំពោះមនោសញ្ចេតនាតាមច្បាប់របស់សន្តតិជន ។ ពេលបានបែងចែកមតិក ប្រសិនបើទទួលស្គាល់នូវអានុភាពប្រតិសកម្មនេះ នោះនឹងមានសេចក្តីថា សន្តតិជនទទួលមតិកពីមតកជនផ្ទាល់ គឺមិនមែនបានទទួលពីសហសន្តតិជនផ្សេងទេ ហេតុនេះហើយ សន្តតិជននោះអាចមានមនោសញ្ចេតនាពិសេសចំពោះមតិកនោះបាន ។ម្យ៉ាងទៀត បើធ្វើដូច្នេះទៅ ឧទាហរណ៍ នីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ ក៏មិនចាំបាច់ឆ្លងកាត់តាមដំណាក់កាលចុះបញ្ជីនូវកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន គឺអាចជ្រើសរើសយកនីតិវិធីផ្ទេរកម្មសិទ្ធិផ្ទាល់ពីមតកជន ទៅសន្តតិជនដែលបានលទ្ធកម្មដោយការបែងចែកនេះ ។

ក្នុងករណីបែងចែកមតិកដែលជាអចលនវត្ថុ ដោយឱ្យសន្តតិជនណាមួយទទួលកម្មសិទ្ធិតែឯង បញ្ញត្តិនៃមាត្រា ១៣៥ មិនត្រូវយកមកអនុវត្តឡើយ ។ បានសេចក្តីថា ការចុះបញ្ជីក្នុងករណីនេះ ត្រូវបានបកស្រាយថាជាការចុះបញ្ជីដើម្បីមានល័ក្ខខ័ណ្ឌតតាំងដូចមានបញ្ញត្តក្នុងមាត្រា ១៣៤ កថាខណ្ឌទី ១ ។ ក្នុងករណីដែលអចលនវត្ថុស្ថិតក្នុងស្ថានភាពកម្មសិទ្ធិអវិភាគ តាមសហសន្តតិកម្ម នោះសហសន្តតិជនអាចប្រើប្រាស់ និង អាស្រ័យផលអចលនវត្ថុទាំងអស់ ដែលជាមតិកនោះបាន ប៉ុន្តែ មិនមែនចែកមួយភាគឱ្យសន្តតិជន A ហើយមួយភាគទៀតឱ្យសន្តតិជន B ប្រើប្រាស់ និង អាស្រ័យផលនោះឡើយ ពោលគឺសហសន្តតិជនទាំងអស់ ត្រូវគ្រប់គ្រងអចលនវត្ថុទាំងអស់ដែលជាមតិកនោះ ក្នុងលក្ខណៈត្រួតគ្នា ។ ហើយការផ្តល់ការគ្រប់គ្រងនោះប្រមូលផ្តុំទៅឱ្យសហសន្តតិជនមួយចំនួន ជាការបែងចែកមតិក ។ ដូច្នេះ ជាលទ្ធផលនៃការបែងចែកមតិក ក្នុងករណីដែលឱ្យសហសន្តតិជន A ទទួលកម្មសិទ្ធិតែឯង ប្រសិនបើឈ្មោះនៅក្នុងបញ្ជីនៅតែជារបស់មតកជននៅឡើយ អាចចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្ទាល់ទៅឱ្យ A បាន ។ ម្យ៉ាងទៀត ប្រសិនបើឈ្មោះ A និង B ត្រូវបានចុះបញ្ជីជាម្ចាស់កម្មសិទ្ធិអវិភាគ តាមរយៈសន្តតិកម្មតាមច្បាប់ ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគរបស់ B ទៅ A គឺគ្រាន់តែជាធ្វើជាលក្ខណៈបច្ចេកទេសប៉ុណ្ណោះ ។ ប្រសិនបើផ្តោតទៅលើអានុភាពនៃការបែងចែកមតិក ហាក់ដូចជាមាត្រា ១៣៥ ត្រូវយកមកអនុវត្តចំពោះការបែងចែកមតិក ដោយសារការផ្ទេរចំណែកសិទ្ធិ ដោយផ្អែកលើការព្រមព្រៀង ។ ប៉ុន្តែ ប្រសិនបើសិនផ្តោតលើគោលបំណងរបស់របបបែងចែកមតិក ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ គឺជាការរំលាយស្ថានភាពកម្មសិទ្ធិអវិភាគរបស់មតិក ដូច្នេះ មាត្រា ១៣៥ មិនត្រូវយកមកអនុវត្តឡើយ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ចែងអំពីការការពារតតិយជនដើម្បីឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ ។ ក្នុងករណីនៃសហសន្តតិកម្ម ដោយផ្អែកទៅតាមបញ្ញត្តិនៃមាត្រា ១១៤៨ មតិកត្រូវស្ថិតនៅក្នុងកម្មសិទ្ធិអវិភាគ ទៅតាមសមាមាត្រនៃចំណែករបស់សហសន្តតិជន ដូច្នេះ ទោះបីជាមុនការបែងចែកមតិកក៏ដោយ ក៏សហសន្តតិជនអាចធ្វើអនុប្បទានចំណែករបស់ខ្លួនទៅឱ្យតតិយជនបាន ឬ ក៏ម្ចាស់បំណុលរបស់សន្តតិជនណាម្នាក់ អាចរឹបអូសនូវចំណែកមតិករបស់សន្តតិជននោះបានដែរ ។ ដូច្នេះ ប្រសិនបើទទួលស្គាល់នូវអានុភាពប្រតិសកម្មនេះដោយគ្មានល័ក្ខខ័ណ្ឌទេ នឹងធ្វើឱ្យបាត់បង់នូវសុវត្ថិភាពក្នុងកិច្ចការជំនួញ ហេតុនេះហើយបានជាអានុភាពប្រតិសកម្មនៃការបែងចែកមតិកនេះ មិនត្រូវបានទទួលស្គាល់ ចំពោះតតិយជនដែលបានធ្វើនីតិវិធីចុះបញ្ជី ឬ មានល័ក្ខខ័ណ្ឌតតាំងបានឡើយ ។ តាមលទ្ធផលនេះ ការបែងចែកមតិកអាចនឹងបាត់បង់នូវអត្ថន័យ តែពេលនោះ សហសន្តតិជនដែលបានទទួលឥទ្ធិពលដោយសារតែវត្តមាន

របស់តតិយជននេះ អាចទាមទារឱ្យសហសន្តតិជនដែលបានបង្កើតឱ្យមានមូលហេតុនេះ ទទួលខុសត្រូវបាន ឬ អាចលុបចោលនូវការបែងចែកមតិកនេះ ដោយយកការភាន់ច្រឡំជាមូលហេតុ ហើយបែងចែកសាជាថ្មីឡើងវិញ ។

កថាខណ្ឌទី ២ ចែងថា តាមលទ្ធផលនៃការបែងចែក សហសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិដែលមានលិខិត/ប័ណ្ណបញ្ជាក់សិទ្ធិ អាចទទួលលិខិត/ប័ណ្ណបញ្ជាក់សិទ្ធិនោះបាន ។ នេះគឺជាបញ្ញត្តិដើម្បីឱ្យការផ្ទេរសិទ្ធិនេះធ្វើឡើងដោយគ្មានការយឺតយ៉ាវ ឧទាហរណ៍ សន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិលើប្រាក់បញ្ញើរបស់មតកជន អាចទទួលយកសៀវភៅគណនីធនាគារពីសន្តតិជនដែលបានរក្សាសៀវភៅគណនីនោះទុកបាន ។ ចំពោះករណីដែលសិទ្ធិលើបំណុលជាកម្មវត្ថុនៃការបែងចែកមតិកវិញ ទាក់ទងនឹងកថាខណ្ឌនេះ សូមមើលមាត្រា ១២៧៥ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩០៩ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៦១៦ នៃ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## មាត្រា ១២៧៤.– ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌កបើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីវិធីទាមទារចំណែកមតិករបស់ជនដែលបានក្លាយជាសន្តតិជន ដោយការទទួលស្គាល់ ក្រោយមរណភាពរបស់មតិកជន ដែលការទទួលស្គាល់នេះបានធ្វើឡើងក្រោយការបែងចែកមតិក ។

ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជន ត្រូវបានធ្វើឡើងក្រោយការបែងចែកមតិក ដោយសារតែការពិភាក្សាដើម្បីបែងចែកមតិក ត្រូវបានធ្វើឡើងដោយមានវត្តមានរបស់សហសន្តតិជនទាំងអស់នៅពេលនោះ ដូច្នេះ ការពិភាក្សានោះមានសុពលភាព ។ ផ្ទុយទៅវិញ ក្នុងករណីដែលមតកជនបានទទួលស្គាល់ជាកូនពេលនៅរស់ ក៏ប៉ុន្តែដោយសារតែសន្តតិជនផ្សេងទៀតមិនបានដឹង ហើយបានដកជនដែលត្រូវបានទទួលស្គាល់នោះចេញពីការពិភាក្សាបែងចែកមតិក ឬ ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជនត្រូវបានធ្វើឡើងមុនការបែងចែកមតិក ក៏ប៉ុន្តែសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ដោយមិនឱ្យជននោះចូលរួមក្នុងការបែងចែក ពេលនេះការបែងចែកនោះមិនបានធ្វើឡើងដោយមានវត្តមានរបស់សន្តតិជនទាំងអស់ទេ ដូច្នេះ ការបែងចែកនោះមោឃៈ ។ ចំពោះករណីពីរខាង

ក្រោយនេះ កូនដែលត្រូវបានទទួលស្គាល់ អាចទាមទារចំពោះសន្តតិជនផ្សេងទៀត ឱ្យធ្វើការបែងចែកមតិកសាជាថ្មីឡើងវិញបាន (ដោយសារថា នេះជាការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដូច្នេះ អាចធ្វើការទាមទារតែក្នុងអំឡុងពេលដែលបានចែងក្នុងមាត្រា ១៣០៤ ប៉ុណ្ណោះ) ។ ចំពោះករណីទី ១ មានន័យថា ករណីដែលបានចែងក្នុងមាត្រានេះ ការពិភាក្សាបែងចែកមានសុពលភាព ដូច្នេះ កូនដែលត្រូវបានទទួលស្គាល់នោះ មិនអាចទាមទារឱ្យធ្វើការបែងចែក សាជាថ្មីឡើងវិញបានទេ ក៏ប៉ុន្តែ ការទទួលស្គាល់មានអានុភាពប្រតិសកម្ម (មាត្រា ៩៩៩) ដូច្នេះ ជននោះគួរតែត្រូវបានទទួលនូវសិទ្ធិអ្វីមួយ ក្នុងនាមជាសន្តតិជនម្នាក់ ។ ដូច្នេះហើយបានជាមាត្រានេះចែងថា មានសិទ្ធិទាមទារឱ្យសងដោយតម្លៃជាប្រាក់ប៉ុណ្ណោះ ។ ការទាមទារនេះ ក៏ជាការទាមទារឱ្យធ្វើបដិទានសន្តតិកម្មដែរ ដូច្នេះ ត្រូវធ្វើក្នុងអំឡុងពេលដែលបានចែងក្នុងមាត្រា ១៣០៤ ។ ដោយសារការទាមទារឱ្យទទួលស្គាល់ក្រោយមរណភាព អាចធ្វើបានតែក្នុងអំឡុងពេល ១ ឆ្នាំក្រោយមរណភាពរបស់មតកជនប៉ុណ្ណោះ (មាត្រា ១០០១) ហើយអំឡុងពេលនៃការទាមទារដែលបានចែងក្នុងមាត្រានេះ មាន ៤ ឆ្នាំ ឬ លើស ចាប់ពីពេលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ដូច្នេះ គ្មានបញ្ហាអ្វីចំពោះអំឡុងពេលទេ ។ ប្រសិនបើសន្តតិជនផ្សេងបានធ្វើសកម្មភាពពន្យឺតនីតិវិធីនៃបណ្តឹង ដើម្បីឱ្យអំឡុងពេលនេះ កន្លងផុត ការណ៍ដែលសន្តតិជនផ្សេងលើកឡើងនូវមាត្រា ១៣០៤ គឺជាការបំពានសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៩១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៧៥.–** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមតិក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមតិកដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមតិកនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមតិកដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមតិកនោះបាន ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិពិសេសស្តីពីល័ក្ខខ័ណ្ឌតតាំងក្នុងករណីបែងចែកសិទ្ធិលើបំណុលរបស់មតកជន ទៅតាមភាគ

ក្រៅពីចំណែកមតិកកំណត់ដោយច្បាប់ ។

ក្នុងចំណោមសិទ្ធិលើបំណុលរបស់មតកជនដែលអាចបែងចែកបាន ដូចជាប្រាក់បញ្ញើ ជាអាទិ៍ ត្រូវបែងចែកដោយស្វ័យប្រវត្តិទៅសហសន្តតិជន តាមចំណែកដែលកំណត់ដោយច្បាប់ ដោយផ្អែកទៅតាមបញ្ញត្តិនៃមាត្រា ១១៤៨ កថាខណ្ឌទី ១ ។ ក៏ប៉ុន្តែ ប្រសិនបើមានការព្រមព្រៀងពីសហសន្តតិជនទាំងអស់ សិទ្ធិលើបំណុលនេះក៏អាចយកមកធ្វើជាកម្មវត្ថុនៃការបែងចែកមតិកបានដែរ ហើយអាចបែងចែកទៅតាមភាគក្រៅពីចំណែកមតិកកំណត់ដោយច្បាប់បានដែរ ។ ក៏ប៉ុន្តែ ចំពោះកូនបំណុលចំពោះសិទ្ធិលើបំណុលនេះវិញ ការបែងចែកទៅតាមភាគក្រៅពីចំណែកមតិកកំណត់ដោយច្បាប់ គឺគ្មានអ្វីផ្សេងក្រៅពីការធ្វើអនុប្បទានសិទ្ធិលើបំណុលនេះទេ ដូច្នេះហើយ ប្រសិនបើអនុប្បទាយីមិនបានជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៥០៣ ទេ កូនបំណុលនេះមិនចាំបាច់ធ្វើតាមការពិភាក្សានៃការបែងចែកមតិកនោះទេ ។ ដូច្នេះ រហូតដល់ពេលដែលសន្តតិជនទាំងអស់ ក្រៅពីសន្តតិជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលដោយការបែងចែកនោះ បានជូនដំណឹងដល់កូនបំណុល ការបែងចែកមតិកនោះ គ្មានអត្ថន័យទេ ហេតុនេះហើយបានជាកថាខណ្ឌទី ១ នេះ កំណត់អំពីវិធីជូនដំណឹងពិសេសនេះ ។ ក្នុងចំណោមវិធីជូនដំណឹងទាំងនោះ ការជូនដំណឹងដោយសហសន្តតិជនទាំងអស់ មិនខុសពីបញ្ញត្តិនៃមាត្រា ៥០៣ ទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបែងចែកមតិកត្រូវបានធ្វើដោយលិខិតយថាភូត ការបង្ហាញលិខិតយថាភូតនេះ ឬ ការប្រគល់លិខិតចម្លងនៃលិខិតយថាភូតនេះ គឺជាវិធីពិសេសមួយ ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិបញ្ជាក់អំពីលទ្ធផលដែលបានមកពីការបកស្រាយនៃមាត្រា ៥០៣ ។

**មាត្រា ១២៧៦.–** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមតិកនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងឡើងដើម្បីឱ្យសហសន្តតិជនផ្សេងទទួលខុសត្រូវក្នុងការធានា ប្រៀបបីដូចជាអ្នកលក់ដែរ ក្នុងករណីដែលវត្ថុ ឬ សិទ្ធិដែលសន្តតិជនបានទទួលតាមលទ្ធផលនៃការបែងចែកមតិក មានវិការៈ ។

ការបែងចែកមតិក គឺជាការធ្វើឱ្យមតិកដែលនៅក្នុងស្ថានភាពជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ឱ្យទៅជាកម្មសិទ្ធិតែម្នាក់ ដោយការពិភាក្សារបស់សហសន្តតិជន ដូច្នេះហើយ តាមភាពជាក់ស្តែង គឺជាការលក់ទិញ ឬ ការដូរ ។ ដូច្នេះ ការទទួលខុសត្រូវក្នុងការធានា ដែលបានចែងក្នុងមាត្រានេះ ជាការធម្មតាទេ ។ ម្យ៉ាងទៀត មាត្រា ១២៧៣ ទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការបែងចែកមតិក ហើយប្រសិនបើចង់សង្កត់ទៅលើចំណុចនេះ មាត្រានេះអាចគិតថាជាបញ្ញត្តិស្តីពីការទទួលខុសត្រូវពិសេស ក៏ប៉ុន្តែ ទោះបីជាទទួលស្គាល់នូវអានុភាពប្រតិសកម្មក៏ដោយ ក៏ជាសារធាតុនៅតែឆ្លងកាត់តាមដំណាក់កាលផ្លាស់ប្តូរពីកម្មសិទ្ធិរបស់មតកជនទៅជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន និង ពីកម្មសិទ្ធិ

អវិភាគទៅជាកម្មសិទ្ធិតែម្នាក់ ហេតុនេះហើយ ការទទួលស្គាល់នូវការទទួលខុសត្រូវពិសេសនេះមានហេតុផលគ្រប់គ្រាន់។ ក៏ប៉ុន្តែ ក្នុងករណីដែលវិការៈនោះធ្ងន់ធ្ងរ (ឧទាហរណ៍ មតិកមានអចលវត្ថុ និង ប្រាក់បញ្ញើនៅធនាគារ ហើយតាមលទ្ធផលនៃការបែងចែកមតិក សន្តតិជន A បានទទួលអចលនវត្ថុ រីឯ B បានទទួលប្រាក់បញ្ញើ ក៏ប៉ុន្តែ ពេលក្រោយមកបានដឹងថា អចលនវត្ថុជាកម្មសិទ្ធិរបស់អ្នកផ្សេង) នឹងលុបចោលការបែងចែកនេះដោយសារមានការភាន់ច្រឡំ រួចធ្វើការបែងចែកមតិកសាជាថ្មីឡើងវិញ ។ ម្យ៉ាងទៀត តាមធម្មតា សន្តតិជនដែលចង់ទទួលលទ្ធកម្មនូវវត្ថុណាមួយច្រើនតែមានឱកាសពិនិត្យវត្ថុនោះ និង ពិចារណាឱ្យបានច្បាស់លាស់ ហើយពេលធ្វើការបែងចែកមតិក ភាគច្រើនបានដឹងអំពីវិការៈនោះហើយ ដូច្នេះមិនសូវមានវិការៈកំបាំងទេ ។ ដូច្នេះ ករណីដែលត្រូវអនុវត្តមាត្រានេះមានតិចណាស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ផ្នែកទី ៣ ការសម្រួលរវាងម្ចាស់បំណុល

(កំណត់)

ពេលដែលបានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិសម្រាប់សន្តតិកម្ម ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ហើយសន្តតិជនមានកាតព្វកិច្ចផ្ទាល់ខ្លួន ប្រសិនបើគ្មានបញ្ញត្តិសម្រួលទេ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ហើយម្ចាស់បំណុលរបស់សន្តតិជនក៏អាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះចំណែកមតិករបស់សន្តតិជននោះ ។ ក៏ប៉ុន្តែ តាមការពិត ម្ចាស់បំណុលរបស់មតកជនច្បាស់ជាមានសិទ្ធិលើបំណុលដែលអាចយកមតិកមកទុកបម្រុង ឬ ក៏ម្ចាស់បំណុលរបស់សន្តតិជនច្បាស់ជាមានសិទ្ធិលើបំណុលដែលអាចយកទ្រព្យផ្ទាល់របស់សន្តតិជនហើយ ។ វិធីសម្រួលរវាងជនទាំងនោះមានដូចជារបបបំបែកទ្រព្យសម្បត្តិដែលមាននៅក្នុងរដ្ឋប្បវេណីជប៉ុន ក៏ប៉ុន្តែ របបនេះយកការចុះបញ្ជីជាល័ក្ខខ័ណ្ឌតតាំង ដូច្នេះ តាមភាពជាក់ស្តែងគេមិនសូវប្រើទេ ។ ហេតុដូច្នេះ ក្នុងអំឡុងពេលមួយក្រោយពីសន្តតិកម្ម (តាមធម្មតា ៣ ខែ) ត្រូវហាមកុំឱ្យធ្វើការផ្ទេរឈ្មោះមតិកទៅឱ្យសន្តតិជន ហើយក្នុងអំឡុងពេលនេះ ម្ចាស់បំណុលរបស់មតកជន អាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ន ដោយយោងតាមមាត្រា ១២៦៤ ហើយអាចបើកផ្លូវឱ្យទាមទារឱ្យធ្វើការរក្សាការពារទ្រព្យសម្បត្តិនោះ ជាអាទិ៍ ចំពោះអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ននោះ ។ ក្នុងអំឡុងពេលនេះ ម្ចាស់បំណុលរបស់មតកជនមិនអាចអនុវត្តសិទ្ធិទៅលើទ្រព្យផ្ទាល់របស់សន្តតិជនទេ តែក្នុងអំឡុងពេលនេះ ម្ចាស់បំណុលរបស់សន្តតិជនអាចចាត់ចែងឱ្យរក្សាការពារទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ជាអាទិ៍ បាន ។ នេះជាវិធីសម្រួលរវាងអ្នកទាំងពីរនេះ ។

ម្យ៉ាងទៀត ក្នុងករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ឬ បានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនមិនអាចអនុវត្តសិទ្ធិទៅលើទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានទេ រីឯម្ចាស់បំណុលរបស់សន្តតិជនក៏មិនអាចអនុវត្តសិទ្ធិទៅលើចំណែកមតិករបស់សន្តតិជនបានដែរ ដូច្នេះមិនអាចអនុវត្តតាមវិធីសម្រួលនៃផ្នែកនេះទេ ។

**មាត្រា ១២៧៧.-** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមតិក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមតិក ទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមតិក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន ។

(កំណត់)

មាត្រានេះចែងថា ក្នុងអំឡុងពេលកំណត់មួយ មិនអាចប្តូរឈ្មោះម្ចាស់សិទ្ធិលើមតិកទៅឱ្យសន្តតិជន ឬ ទៅឱ្យអច្ច័យលាភីបានទេ ដោយផ្អែកទៅតាមមូលហេតុដែលបានពន្យល់ក្នុងសេចក្តីកំណត់ខាងលើនេះ ។ ហើយក្នុងនេះ ការមិនបានកំណត់ "៣ ខែ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម" សម្រាប់អំឡុងពេលនេះ ហើយយក "អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់)" គឺដោយសារតែក្នុងករណីដែលសន្តតិជនលំដាប់ទី ១ បានបោះបង់សន្តតិកម្មចោលទាំងអស់គ្នា បញ្ហាដដែលនេះនឹងកើតឡើងចំពោះសន្តតិជនលំដាប់ទី ២ ។ បញ្ហានេះ ក៏មានដូចគ្នាចំពោះមាត្រា ១២៧៨ និង មាត្រា ១២៧៩ ដែរ ។

វាក្យខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិដើម្បីឱ្យអាចធ្វើនីតិវិធីប្តូរជាប្រាក់ភ្លាម សម្រាប់ករណីដែលបានប្តូរមតិកជាប្រាក់ ដើម្បីសងបំណុលរបស់មតកជន ។

**មាត្រា ១២៧៨.-** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

(កំណត់)

មាត្រានេះចែងថា ក្នុងអំឡុងពេលកំណត់មួយ ម្ចាស់បំណុលរបស់មតកជនមិនអាចអនុវត្តសិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានទេ ដោយផ្អែកទៅលើមូលហេតុដែលបានពន្យល់ខាងលើនេះ ។ ម្យ៉ាងទៀត ទោះបីជាសន្តតិជនបានធ្វើ

ការយល់ព្រមទាំងស្រុង ក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៤៨ កថាខណ្ឌ ទី ១ ក៏ដោយ ក៏ដូចគ្នាដែរ គឺយោងតាមមាត្រានេះ ម្ចាស់បំណុលរបស់មតកជន ត្រូវទទួលការកម្រិតក្នុងការអនុវត្តសិទ្ធិ ។ បញ្ហានេះក៏មានដូចគ្នាដែរសម្រាប់មាត្រា ១២៧៩ ។

**មាត្រា ១២៧៩.–** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

(កំណត់)

មាត្រានេះចែងថា ក្នុងអំឡុងពេលកំណត់មួយ ម្ចាស់បំណុលរបស់សន្តតិជនមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនលើមតិករបស់សន្តតិជននោះបានទេ ដោយផ្អែកទៅលើមូលហេតុដែលបានពន្យល់ខាងលើនេះ ។

## ផ្នែកទី ៤ ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.–** ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

(កំណត់)

មាត្រានេះចែងថា សន្តតិជនត្រូវគ្រប់គ្រងមតិកបន្តទៀត ក្រោយពីបានយល់ព្រមដោយមានកម្រិត ។

ការយល់ព្រមដោយកម្រិត គឺជានីតិវិធីជម្រះដែលមានលក្ខណៈដូចជាធនក្ស័យនៃមតិកដែរ ដូច្នេះ បញ្ញត្តិនេះចែងថា អ្នកយល់ព្រមដោយកម្រិត ត្រូវគ្រប់គ្រងមតិកបន្តទៀត ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ក្នុងករណីនៃសន្តតិកម្មតែឯង សន្តតិជនដែលបានយល់ព្រមដោយកម្រិត ជាអ្នកមានករណីយកិច្ចគ្រប់គ្រង រីឯក្នុងករណីនៃសហសន្តតិកម្មវិញ សន្តតិជនដែលត្រូវបានជ្រើសតាំងជាអ្នកគ្រប់គ្រងមតិក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៩ កថាខណ្ឌទី ១ ជាអ្នកមានករណីយកិច្ចគ្រប់គ្រង ។

ម្យ៉ាងទៀត ដើម្បីធ្វើការជម្រះមតិក ជនដែលបានយល់ព្រមដោយកម្រិត ត្រូវអនុវត្តតាមនីតិវិធីដែលបានចែងពីមាត្រានេះ រហូតដល់មាត្រា ១២៨៨ ។ សន្តតិជនដែលបានយល់ព្រមដោយកម្រិត អាចទទួលសន្តតិកម្មទ្រព្យសកម្មដែលនៅសល់ពីការជម្រះបាន ហើយបានយល់ព្រមទទួលដោយកម្រិត ដោយសារតែខ្លួនសង្ឃឹមថា អាចទទួល

សន្តតិកម្មនូវមតិកនេះ (ប្រសិនបើគ្មានសង្ស័យថា នឹងបានទទួលទេ គេច្បាស់ជាបោះបង់សន្តតិកម្មហើយ) ដូច្នេះ ទោះបីជាឱ្យអនុវត្តនីតិវិធីនេះ ក៏គ្មានបញ្ហាអ្វីដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨១.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

(កំណត់)

មាត្រានេះចែងថា ដើម្បីធ្វើការជម្រះមតិក ត្រូវជូនដំណឹងអំពីការយល់ព្រមដោយកម្រិតនោះ ជាអាទិ៍ ទៅម្ចាស់បំណុល ហើយក្នុងអំឡុងពេលកំណត់មួយ ប្រសិនបើម្ចាស់បំណុលមិនបានស្នើសុំទេ ត្រូវដកឈ្មោះអ្នកនោះចេញពីការជម្រះមតិក ។

ដើម្បីធ្វើការជម្រះមតិក អ្នកដែលបានយល់ព្រមដោយមានកម្រិត (មានន័យថាជាសន្តតិជនដែលត្រូវអនុវត្តនីតិវិធីជម្រះ) ចាំបាច់ត្រូវដឹងអំពីអត្ថិភាពរបស់ម្ចាស់បំណុល ។ ដោយសារមតកជនបានបន្សល់ទុកនូវកិច្ចសន្យាខ្ចីបរិភោគប្រាក់ ឬ បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុដែលជាមតិក ឬ មានសរសេរមតកសាសន៍បញ្ជាក់ការធ្វើអច្ច័យទានចំពោះតតិយជនជាអាទិ៍ មានករណីដែលអ្នកយល់ព្រមដោយកម្រិតអាចដឹងអំពីអត្ថិភាពនៃម្ចាស់បំណុល ។ ក៏ប៉ុន្តែ ក្នុងករណីដែលមតកជន

មិនបានបន្សល់ទុកនូវអ្វីសម្រាប់ឱ្យដឹង មុនពេលទទួលមរណភាពទេ មិនអាចដឹងអំពីអត្ថិភាពនៃម្ចាស់បំណុលឡើយ ។ ដូច្នេះហើយបានជាក្នុងកថាខណ្ឌទី ១ ចែងថា ក្នុងអំឡុងពេល ៥ ថ្ងៃ ក្រោយការយល់ព្រមដោយកម្រិត អ្នកយល់ព្រមដោយកម្រិតនោះត្រូវជូនដំណឹងជាសាធារណៈចំពោះម្ចាស់បំណុល និង ចំពោះអច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីនោះត្រូវស្នើសុំអំពីការទាមទារ ក្នុងអំឡុងពេលកំណត់មួយ ។ ការជូនដំណឹងនេះ គឺជាការដាស់តឿនឱ្យម្ចាស់បំណុលស្នើសុំ ហើយបន្ទាប់មកត្រូវចូលដល់ដំណាក់កាលនៃនីតិវិធីជម្រះមតិក ។

តាមកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខ្លឹមសារនៃការជូនដំណឹងជាសាធារណៈ ត្រូវបញ្ជាក់អំពីការណ៍ដែលមតកជនបានទទួលមរណភាព ការណ៍ដែលសន្តតិជនបានយល់ព្រមដោយកម្រិត ការណ៍ដែលម្ចាស់បំណុល ជាអាទិ៍ ត្រូវស្នើសុំអំពីការទាមទារសិទ្ធិលើបំណុលក្នុងអំឡុងពេលកំណត់មួយ ព្រមទាំងការណ៍ដែលម្ចាស់បំណុល ជាអាទិ៍ នោះ នឹងត្រូវដកចេញពីការជម្រះបញ្ជី ក្នុងករណីដែលមិនបានស្នើសុំឱ្យទាន់ពេលវេលា ។ ការជូនដំណឹងជាសាធារណៈនេះ ត្រូវបានធ្វើឡើងដើម្បីរកម្ចាស់បំណុលដែលអ្នកយល់ព្រមដោយកម្រិតមិនបានដឹង ដូច្នេះហើយ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹង ត្រូវធ្វើការដាស់តឿន ចំពោះម្ចាស់បំណុលម្នាក់ៗដោយឡែក ដើម្បីឱ្យគេស្នើសុំ (កថាខណ្ឌទី ៣) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨២.–** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

(កំណត់)

មាត្រានេះចែងបញ្ជាក់ថា នៅក្នុងអំឡុងពេលដាស់តឿន អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសងចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដើម្បីឱ្យមានសមភាពរវាងម្ចាស់បំណុល តាមនីតិវិធីជម្រះ ។

ទោះបីជាមានបញ្ញត្តិនៃមាត្រានេះក៏ដោយ ក្នុងករណីដែលការខូចខាតបានកើតឡើងចំពោះម្ចាស់បំណុលផ្សេងទៀត ដោយសារការសងចំពោះម្ចាស់បំណុលណាម្នាក់ក្នុងអំឡុងពេលនៃការដាស់តឿននេះ អ្នកដែលបានយល់ព្រមដោយកម្រិតត្រូវសងនូវសំណងនៃការខូចខាតចំពោះម្ចាស់បំណុលដែលបានទទួលនូវការខូចខាតនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៧ ។ គោលបំណងនៃមាត្រានេះ គឺរក្សានូវសមភាពក្នុងការសងចំពោះម្ចាស់បំណុល ដូច្នេះហើយ ក្នុងករណីដែល

ម្ចាស់បំណុលមានសិទ្ធិអាទិភាពក្នុងការទទួលការសង ដូចជាករណីដែលមតិកបានដាក់ជាហ៊ីប៉ូតែក ឬ មានឯកសិទ្ធិ ជាអាទិ៍ ទោះបីជានៅក្នុងអំឡុងពេលដាស់តឿនក៏ដោយ ក៏ម្ចាស់បំណុលនេះអាចអនុវត្តសិទ្ធិនោះបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨៣.-** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយក មតិកនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុល ផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗ នោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព បានឡើយ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងអំពីការសងដោយចែកចំណែក ក្រោយអំឡុងពេលកំណតសម្រាប់ការជូនដំណឹង ។

យោងតាមមាត្រានេះ និង មាត្រាពាក់ព័ន្ធផ្សេងទៀត លំដាប់នៃការសងមានដូចតទៅ :

១-ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព (វាក្យខណ្ឌទី ២ នៃមាត្រានេះ)

២-ម្ចាស់បំណុលដែលបានស្នើសុំក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ និង ម្ចាស់បំណុលដែលបានដឹងដោយអ្នក យល់ព្រមដោយកម្រិត (លើកលែងតែអច្ច័យលាភីនីមួយៗ ។ វាក្យខណ្ឌទី ១ នៃមាត្រានេះ)

៣-អច្ច័យលាភីដែលបានស្នើសុំក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ និង អច្ច័យលាភីដែលបានដឹងដោយអ្នកយល់ ព្រមដោយកម្រិត (មាត្រា ១២៨៥)

៤-ម្ចាស់បំណុល និង អច្ច័យលាភី ដែលមិនបានស្នើសុំក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ ហើយអ្នកយល់ព្រម ដោយកម្រិត មិនបានដឹង (មាត្រា ១២៨៨)

បន្ទាប់មក ឧទាហរណ៍ ប្រសិនបើមិនអាចសងបំណុលចំពោះម្ចាស់បំណុលទាំងអស់នៃលំដាប់ទី ២ ទេ ត្រូវសង ទៅតាមសមាមាត្រនៃទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងនោះ រីឯចំពោះម្ចាស់បំណុលលំដាប់ទី ៣ ទៅ មិនចាំបាច់សងទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨៤.–** ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

(កំណត់)

មាត្រានេះចែងថា ការសងក្នុងករណីយល់ព្រមដោយកម្រិត គឺជាការជម្រះមតិក ហេតុនេះហើយ ទោះបីជាសិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលត្រូវសងក៏ដោយ ក៏ត្រូវសងដែរ ។

ដោយយោងតាមកថាខណ្ឌទី ១ ពេលសងកាតព្វកិច្ចមុនពេលកំណត់ត្រូវសង គួរតែដកបន្ថយនូវការប្រាក់សម្រាប់អំឡុងពេលចាប់ពីពេលសងដល់ពេលកំណត់ត្រូវសង ("ការប្រាក់ពាក់កណ្ដាលកាល") ។ ចំពោះវិធីគណនាការប្រាក់ពាក់កណ្ដាលកាល មានវិធីពីរ គឺវិធីគណនាតាមរូបមន្ត Leibniz (វិធីគណនាការប្រាក់សមាស) និង វិធីគណនាតាមរូបមន្ត Hoffman (វិធីគណនាការប្រាក់ធម្មតា) ហើយនៅប្រទេសជប៉ុន គេយកការប្រាក់សមាស ។

ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់ល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ ដែលបានចែងក្នុងកថាខណ្ឌទី ២ តម្លៃជាសារធាតុនៃសិទ្ធិលើបំណុលនោះមានខុសគ្នាទៅតាមស្ថានភាពនៃភាពអាចបំពេញល័ក្ខខ័ណ្ឌនៃសិទ្ធិនោះ ជាអាទិ៍ ដូច្នេះហើយត្រូវឱ្យអ្នកដែលត្រូវបានជ្រើសតាំងដោយតុលាការ ធ្វើការវាយតម្លៃសិទ្ធិនោះ ហើយត្រូវសងទៅតាមតម្លៃនោះ ។ អ្នកវាយតម្លៃត្រូវវាយតម្លៃទៅតាមភាពពិតជាក់ស្ដែង ឬ តាមផ្លូវច្បាប់ នូវភាពនៃការបំពេញល័ក្ខខ័ណ្ឌ ជាអាទិ៍ ហើយធ្វើការគណនាតម្លៃនោះ ។ ឧទាហរណ៍ មានកិច្ចសន្យាមួយថា បង់ឱ្យមួយឆ្នាំ ១០០ ដុល្លារ រហូតមួយជីវិត ក្នុងករណីនេះ ត្រូវធ្វើការប៉ាន់ស្មាននូវអំឡុងពេលដែលអាចរស់រានមានជីវិត ដោយមើលទៅតាមអាយុកាលមធ្យម ឬ ស្ថានភាពសុខភាពរបស់អ្នកពាក់ព័ន្ធ ជាអាទិ៍ ហើយកាត់បន្ថយនូវការប្រាក់ពាក់កណ្ដាលកាល ដែលគណនាតាមវិធីខាងលើ បន្ទាប់មកធ្វើការគណនានូវតម្លៃបច្ចុប្បន្ននៃសិទ្ធិនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨៥.–** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងថា ការសងចំពោះអច្ច័យលាភី ត្រូវមានលំដាប់ក្រោយការសងចំពោះម្ចាស់បំណុលរបស់មតកជន ។

មូលហេតុនៃការតាក់តែងបញ្ញត្តិនេះ គឺទីមួយ សិទ្ធិរបស់ម្ចាស់បំណុលនៃមតកជន ត្រូវបានកំណត់ជាស្ថាពរមុនពេលចាប់ផ្ដើមសន្តតិកម្ម ដោយមើលទៅតាមស្ថានភាពទ្រព្យសម្បត្តិរបស់មតកជន ផ្ទុយទៅវិញ សិទ្ធិរបស់អច្ច័យលាភី ត្រូវបានធ្វើលទ្ធកម្មដោយចិត្តសប្បុរសធម៌របស់មតកជនដោយឯកតោភាគី ហេតុនេះហើយ ត្រូវឱ្យអាទិភាពទៅលើសិទ្ធិរបស់ម្ចាស់បំណុលនៃមតកជនវិញ ។ ទីពីរ គឺប្រសិនបើឱ្យសមភាពរវាងម្ចាស់បំណុល និង អច្ច័យលាភីទៅ អាចមានករណីដែលធ្វើអច្ច័យទានដោយមានគោលបំណងបំពានសិទ្ធិរបស់ម្ចាស់បំណុល ។ មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាក៏មានគោលគំនិតដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨៦.–** ការប្ដូរមតិកជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មតិកដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មតិកនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

(កំណត់)

មាត្រានេះចែងអំពីវិធីលក់ ក្នុងករណីដែលមានភាពចាំបាច់ត្រូវប្តូរជាប្រាក់នូវមតិក ដើម្បីសងបំណុល ។

កថាខណ្ឌទី ១ ចែងអំពីវិធីលក់ គឺការលក់ដោយបង្ខំ ឬ ការលក់ដោយខ្លួនឯងក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលបានជ្រើសតាំងដោយតុលាការ ។ ការចែងដូចនេះ គឺដោយសារតែត្រូវលក់តាមតម្លៃត្រឹមត្រូវមួយដើម្បីកុំឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុល ។ គួរតែជ្រើសតាំងអ្នកវាយតម្លៃអចលនវត្ថុ ធ្វើជាអ្នកវាយតម្លៃ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិស្តីពីអ្នកទិញតាមការលក់ដោយបង្ខំ ឬ តាមការលក់ទិញនេះ ។ តាមផ្លូវច្បាប់ អ្នកយល់ព្រមដោយកម្រិត ជាអ្នកទទួលសន្តតិកម្ម ដូច្នេះហាក់ដូចជាការទិញវត្ថុរបស់ខ្លួនឯង មានលក្ខណៈផ្ទុយ ក៏ប៉ុន្តែ ជាសារធាតុពេលធ្វើការជម្រះ វត្ថុនេះត្រូវចាត់ទុកជាវត្ថុផ្សេងពីទ្រព្យសម្បត្តិរបស់សន្តតិជន ដូច្នេះហើយ អ្នកនេះក៏មានលក្ខណសម្បត្តិជាអ្នកទិញដែរ ។ មាត្រា ១២៥៨ កថាខណ្ឌទី ២ ចែងថា អានុភាពនៃការយល់ព្រមដោយកម្រិត គឺការចាត់ទុកថា សិទ្ធិ និង ករណីយកិច្ចដែលសន្តតិជនមានចំពោះមតកជននោះ មិនត្រូវបានរលត់ដោយព្យាកុលភាពទេ ហើយមាត្រា ១២៨៦ នេះមានគោលគំនិតដូចគ្នាដែរ ។ ចំពោះម្ចាស់បំណុលរបស់មតកជន ឬ អច្ឆ័យលាភីវិញ គ្រាន់តែចែងតាមភាពជាក់ស្តែងតែប៉ុណ្ណោះ ចំណែកឯការទូទាត់នូវថ្លៃលក់ទិញ និង តម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន មិនអាចធ្វើបានទេ ដោយយោងទៅតាមគោលគំនិតនៃបញ្ញត្តិនៃកថាខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៨៧.–** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ឆ័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ឆ័យលាភីណាផ្សេងនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសងសំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាតរបស់ម្ចាស់បំណុល ឬ អច្ឆ័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ឆ័យលាភីដែលបានទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្តីអំពីការទាមទារសំណងនៃការខូចខាតចំពោះអ្នកយល់ព្រមដោយកម្រិត និង ម្ចាស់បំណុល ជាអាទិ៍ ដែលបានទទួលការសង ថ្វីត្បិតតែបានដឹងអំពីភាពមិនត្រឹមត្រូវនៃការសង ក្នុងករណីដែលអ្នកយល់ព្រមដោយកម្រិត បានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីជាក់លាក់ណាមួយ ដោយការមិនគោរពតាមនីតិវិធី ហើយដែលធ្វើឱ្យខូចខាតដល់ម្ចាស់បំណុល ផ្សេងទៀត ជាអាទិ៍ ។

កថាខណ្ឌទី ១ បានចែងតែអំពីការខូចខាតដែលបានកើតឡើង ដោយសារអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែសក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ ឬ ដោយសារអ្នកយល់ព្រមដោយកម្រិតបានសងដោយមិនអនុវត្តសិទ្ធិបដិសេធការសង ក្នុងអំឡុងពេលដាស់តឿន ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៨២ ក៏ដោយ ប៉ុណ្ណោះ ។ ហើយមាត្រា ១២៨២ ចែងតែអំពីសិទ្ធិ ហេតុនេះហើយ មាត្រានេះបានចែងពិសេសអំពីករណីយកិច្ចក្នុងការសងនូវសំណងនៃការខូចខាត ។ ក្រៅពីនេះ ចំពោះការសងមិនត្រឹមត្រូវដោយមិនគោរពតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ ដល់ មាត្រា ១២៨៥ តាមការបកស្រាយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងនូវសំណងនៃការខូចខាតដោយសារអំពើនេះ ។

កថាខណ្ឌទី ២ ចែងថា ម្ចាស់បំណុល ជាអាទិ៍ ដែលទទួលការខូចខាតដោយសារលទ្ធផលនៃការសងមិនត្រឹមត្រូវ អាចទាមទារនូវសំណងនៃការខូចខាតពីម្ចាស់បំណុល ជាអាទិ៍ ដែលបានទទួលការសង ទោះបីជាបានដឹងថា មានភាពមិនត្រឹមត្រូវក្នុងការសងនោះក្តី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៨៨.– ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែលអ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោមមត៌ក ។

(កំណត់)

មាត្រានេះចែងអំពីការសងចំពោះម្ចាស់បំណុល ក្រោយនីតិវិធីជម្រះមតិក ។

ការសងចំពោះម្ចាស់បំណុល ជាអាទិ៍ ត្រូវធ្វើតាមលំដាប់ដែលបានពន្យល់ក្នុងសេចក្តីកំណត់នៃមាត្រា ១២៨៣ ។ ហើយក្រោយពីបានសងទៅលំដាប់ទី ៣ ដែលបានបង្ហាញក្នុងនោះ មានន័យថា ក្រោយពីបានសងចំពោះអច្ច័យលាភី ហើយនៅសល់មតិកទៀត អាចសងចំពោះម្ចាស់បំណុល ជាអាទិ៍ ដែលមានលំដាប់ទី ៤ មានន័យថា ម្ចាស់បំណុលដែលមិនបានស្នើសុំក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ ព្រមទាំងអច្ច័យលាភីដែលអ្នកយល់ព្រមដោយកម្រិតមិនបានដឹង អាចអនុវត្តសិទ្ធិទៅលើមតិកដែលនៅសល់នោះ ។ មាត្រានេះមិនចែងអំពីអំឡុងពេលដែលអាចអនុវត្តសិទ្ធិនោះទេ ក៏ប៉ុន្តែអាចបកស្រាយថា អាចអនុវត្តសិទ្ធិនេះរហូតដល់ពេលដែលមតិកនៅសល់នោះត្រូវបានព្យាកុលទៅនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ឬ រហូតដល់ពេលដែលសន្តតិជននោះបានចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់នោះ ។ នេះក៏ព្រោះថា នៅពេលសន្តតិជនដែលបានយល់ព្រមដោយកម្រិត បានធ្វើរហូតដល់នីតិវិធីនៃការជូនដំណឹងជាសាធារណៈដែលបញ្ជាក់អំពីការដកហូតសិទ្ធិហើយក្តី ការណ៍ដែលឱ្យម្ចាស់បំណុលរបស់មតកជនមានសិទ្ធិទាមទាររហូត ដរាបណាមិនទាន់កន្លងផុតអាជ្ញាយុកាលនៃការរលត់សិទ្ធិនោះ មិនមែនជាការត្រឹមត្រូវឡើយ ។

វាក្យខណ្ឌទី ២ នៃមាត្រានេះ ជាបញ្ញត្តិអញ្ញត្រកម្មស្តីពីជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិជាក់លាក់ណាមួយក្នុងចំណោមមតិក ។ ចំពោះវត្ថុ ឬ សិទ្ធិជាក់លាក់ណាមួយដែលត្រូវជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ក្នុងករណីដែលបានប្តូរជាប្រាក់ក្នុងនីតិវិធីជម្រះ ជនដែលមានសិទ្ធិប្រាតិភោគ អាចទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់តាមនីតិវិធីនៃឧបាទេសកម្មលើវត្ថុ ហើយក្នុងករណីដែលបានធ្វេសប្រហែស សិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគនោះ នឹងក្លាយទៅជាសិទ្ធិដែលមិនត្រូវបានធានា ។ ហេតុនេះ វាក្យខណ្ឌទី ២ នៃមាត្រានេះ ចែងអំពីវត្ថុជាអាទិ៍ ដែលមិនបានប្តូរជាប្រាក់ ក្នុងនីតិវិធីជម្រះ ។ ទោះបីជាបានយល់ព្រមដោយកម្រិតក៏ដោយ ក៏គ្មានឥទ្ធិពលទៅលើសិទ្ធិប្រាតិភោគដែរ ដូច្នេះ វាក្យខណ្ឌទី ២ នៃមាត្រានេះ គ្រាន់តែជាបញ្ញត្តិក្រើនរំលឹកអំពីការណ៍នេះប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៨៩.- ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមតិក និង សងកាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន)

រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នកគ្រប់គ្រង ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលសហសន្តតិជនទាំងអស់បានយល់ព្រមដោយកម្រិត ត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក ហើយអ្នកគ្រប់គ្រងមតិកនេះត្រូវធ្វើនីតិវិធីជម្រះ ជាអាទិ៍ ។

ក្នុងករណីសហសន្តតិកម្ម សន្តតិជនទាំងអស់ដែលមិនបានបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំយល់ព្រមដោយកម្រិតទាំងអស់គ្នា (មាត្រា ១២៥៦ កថាខណ្ឌទី ២) ។ ក្នុងករណីនេះ កថាខណ្ឌទី ១ នៃមាត្រានេះចែងថា នៅពេលដែលទទួលពាក្យសុំនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិកពីក្នុងចំណោមសហសន្តតិជន ។ ពេលដាក់ពាក្យសុំយល់ព្រមដោយកម្រិត តាមធម្មតា សហសន្តតិជនត្រូវទាមទារឱ្យតុលាការធ្វើការជ្រើសតាំងជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់នោះធ្វើជាអ្នកគ្រប់គ្រងមតិក ។ ការជ្រើសតាំងអ្នកគ្រប់គ្រងមតិករបៀបនេះ ក៏ព្រោះថា ប្រសិនបើធ្វើការជម្រះមតិកដោយសហសន្តតិជនទាំងអស់គ្នាទៅ មានការស្មុគស្មាញណាស់ ។

កថាខណ្ឌទី ២ ចែងអំពីសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ។ តាមផ្លូវច្បាប់ អ្នកគ្រប់គ្រងត្រូវបានវាយតម្លៃថាជាអ្នកតំណាងតាមផ្លូវច្បាប់របស់សហសន្តតិជនផ្សេងទៀត ។

កថាខណ្ឌទី ៣ ជាបញ្ញត្តិស្ដីពីការអនុវត្តដូចគ្នាដែលពាក់ព័ន្ធនឹងនីតិវិធីជម្រះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៧ នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមតិក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មតិកនោះត្រូវក្លាយជានីតិបុគ្គល ។

(កំណត់)

មាត្រានេះចែងថា ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មតិកនោះត្រូវក្លាយជានីតិបុគ្គល ។

ក្នុងករណីដែលគ្មានសន្តតិជនទេ ប្រធាននៃកម្មសិទ្ធិមតិកនោះក៏គ្មានដែរ ដូច្នេះ ប្រសិនបើគ្មានបញ្ញត្តិអំពីករណីនេះទេ

ចំពោះអចលវត្ថុ ត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ (សូមមើលមាត្រា ១៦១) រីឯចលនវត្ថុវិញ អ្នកដែលបានកាន់កាប់មុន អាចនឹងក្លាយទៅជាកម្មសិទ្ធិករនៃចលនវត្ថុនោះ (សូមមើលមាត្រា ១៨៨) ។ ដូច្នេះ ម្ចាស់បំណុលរបស់មតកជន នឹងមានការពិបាកក្នុងការទទួលការសង ឬ ក៏ការប្រជែងយកចលនវត្ថុនឹងអាចកើតឡើង ហើយធ្វើឱ្យមានការជ្រួលច្របល់ដល់សង្គម ហេតុនេះហើយបានជាត្រូវចាត់ទុកថាមតិកនោះជានីតិបុគ្គល ហើយឱ្យនីតិបុគ្គលនោះធ្វើជាប្រធាននៃសិទ្ធិលើមតិកនោះ ។ បន្ទាប់មក ត្រូវធ្វើការជម្រះ ជាអាទិ៍ ទៅតាមនីតិវិធីដែលបានចែងក្នុងមាត្រាបន្តបន្ទាប់នេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមតិក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមតិកហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីនៃការជ្រើសតាំងអ្នកគ្រប់គ្រងមតិក ។

ក្នុងករណីដែលមិនដឹងច្បាស់លាស់ថាមានសន្តតិជន មតិកត្រូវចាត់ទុកថាជានីតិបុគ្គលតាមផ្លូវច្បាប់ ដោយស្វ័យប្រវត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៩០ ក៏ប៉ុន្តែ គ្មានអ្នកណាគ្រប់គ្រងទេ ហេតុនេះហើយបានជាតម្រូវឱ្យតុលាការធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមតិក តាមពាក្យសុំរបស់បុគ្គលជាក់លាក់ណាម្នាក់ដែលបានកំណត់នៅក្នុងមាត្រានេះ ។ អ្នកគ្រប់គ្រងមតិក ត្រូវទទួលសិទ្ធិ និង កាតព្វកិច្ចដែលចែងក្នុងបញ្ញត្តិនៃមាត្រា ១២៩២ ហើយត្រូវប្រតិបត្តិនូវកិច្ចការច្បាប់មួយចំនួនធំ ដូច្នេះហើយ គួរតែជ្រើសតាំងអ្នកច្បាប់ ដូចជាមេធាវី ឱ្យទទួលមុខងារនេះ ទើបជាការសមរម្យ ។

កថាខណ្ឌទី ២ ចែងអំពីនីតិវិធីជូនដំណឹងជាសាធារណៈក្រោយពេលជ្រើសតាំងអ្នកគ្រប់គ្រងមតិក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមតិក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមតិក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមតិកនោះ អ្នកគ្រប់គ្រងអាចប្តូរមតិកជាប្រាក់ ឬ អាចចាត់ចែងមតិកនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមតិកទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រងមតិក ។

នីតិបុគ្គលមតិកត្រូវគ្រប់គ្រងដោយអ្នកគ្រប់គ្រងមតិក ។ ការងារសំខាន់ៗរបស់អ្នកគ្រប់គ្រងមតិក គឺការក្តាប់ឱ្យដឹងអំពីមតិកទាំងអស់ ការសងបំណុលរបស់មតកជន ហើយការបែងចែកមតិកដែលនៅសល់ទៅឱ្យអ្នកមាននិស្ស័យពិសេស ឬ បង្វិលមតិកនោះទៅឱ្យរដ្ឋ ហើយដើម្បីធ្វើការងារទាំងនេះ ក្នុងករណីចាំបាច់ ត្រូវចាត់ចែងប្តូរមតិកនោះជាប្រាក់ ដោយទទួលការអនុញ្ញាតពីតុលាការ ។ មាត្រានេះចែងអំពីសិទ្ធិ និង កាតព្វកិច្ចដែលចាំបាច់ដើម្បីធ្វើសកម្មភាពទាំងអស់នេះ ។ អ្នកគ្រប់គ្រងមតិក គឺជាអ្នកតំណាងរបស់នីតិបុគ្គលមតិក (អ្នកតំណាងដែលច្បាប់បានកំណត់) ហើយធ្វើសកម្មភាពគតិយុត្តក្នុងនាមជា "អ្នកគ្រប់គ្រងនីតិបុគ្គលមតិករបស់មតកជនឈ្មោះ ......" ។

កថាខណ្ឌទី ១ គឺជាការធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងនឹងមតិក ។ ការធ្វើបញ្ជីគឺមិនត្រឹមតែទ្រព្យសកម្មទេ រាល់កាតព្វកិច្ចនៃសន្តតិកម្មដែលអាចដឹងបាន ក៏ចាំបាច់ត្រូវបញ្ចូលទៅក្នុងបញ្ជីនេះទាំងអស់ ។

កថាខណ្ឌទី ២ គឺការថែរក្សា និង ការគ្រប់គ្រងមតិក ហើយការថែរក្សា និង ការគ្រប់គ្រងនេះត្រូវធ្វើដើម្បីឱ្យបាន

សម្រេចនូវគោលបំណងដែលបានពន្យល់ខាងលើនេះ ដូច្នេះ ប្រសិនបើមានការចាំបាច់ អ្នកគ្រប់គ្រងអាចប្តូរជាប្រាក់ ឬ ចាត់ចែងមតិកនោះ ដោយទទួលការអនុញ្ញាតពីតុលាការបាន ។

កថាខណ្ឌទី ៣ គឺករណីយកិច្ចធ្វើការរាយការណ៍ចំពោះម្ចាស់បំណុលរបស់មតកជន ជាអាទិ៍ ។ អ្នកគ្រប់គ្រងត្រូវផ្តល់ជាចំហនូវពតិមានផ្សេងៗស្តីពីតម្លៃនៃមតិក ឬ ខ្លឹមសារ ឱ្យអ្នកដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍ ។

កថាខណ្ឌទី ៤ គឺជាបញ្ញត្តិក្រើនរំលឹក ។

កថាខណ្ឌទី ៥ គឺជាករណីយកិច្ចធ្វើការស្រាវជ្រាវនូវអង្គហេតុ ។ ការស្រាវជ្រាវនេះ មិនត្រឹមតែមានការស្រាវជ្រាវអំពីមតិកប៉ុណ្ណោះទេ មានរួមទាំងការស្រាវជ្រាវអ្នកមាននិស្ស័យពិសេសដែលបានចែងក្នុងមាត្រា ១២៩៩ ផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៣ និង មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៩៣.– កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្តល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមតិក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមតិក និង ស្ថានភាពផ្សេងទៀត ។

(កំណត់)

មាត្រានេះចែងអំពីកម្រៃសម្រាប់អ្នកគ្រប់គ្រងមតិក ។

ដូចដែលបានពន្យល់ក្នុងមាត្រា ១២៩១ រួចមកហើយ គួរតែជ្រើសតាំងអ្នកច្បាប់ ដូចជាមេធាវី ជាអាទិ៍ ធ្វើជាអ្នកគ្រប់គ្រងមតិក ដូច្នេះហើយត្រូវតែបង់កម្រៃឱ្យសមរម្យទៅតាមនោះដែរ ។ នៅប្រទេសជប៉ុន តុលាការបានបង្កើតនូវតារាងបទដ្ឋាននៃកម្រៃនេះ ដោយយកតម្លៃមតិក អំឡុងពេលគ្រប់គ្រងកិច្ចការដែលត្រូវធ្វើ (មានបណ្តឹងឬទេ បានប្តូរមតិកជាប្រាក់ឬទេ ជាអាទិ៍) មកធ្វើជាមូលដ្ឋាននៃការគណនា ដើម្បីសម្រេចនូវកម្រៃនេះដោយលក្ខណៈសត្យានុម័ត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៣ និង មាត្រា ២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១២៩៤.– ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមតិកត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលបានដឹងថាមានសន្តតិជន ក្រោយពេលជ្រើសតាំងអ្នកគ្រប់គ្រងមតិក ។

ក្រោយពេលបានជ្រើសតាំងអ្នកគ្រប់គ្រងមតិក ហើយអ្នកគ្រប់គ្រងមតិកនេះ បានអនុវត្តសិទ្ធិ និង កាតព្វកិច្ច តាមបញ្ញត្តិនៃមាត្រា ១២៩២ ហើយ ក្នុងករណីដែលបានដឹងអំពីសន្តតិជន តាមការជូនដំណឹងជាសាធារណៈដើម្បីស្វែងរកសន្តតិជនតាមមាត្រា ១២៩៧ ឬ ដោយមូលហេតុផ្សេងៗ អានុភាពនៃការឱ្យកម្មសិទ្ធិមតិកទៅនរណាម្នាក់ ឬ អានុភាពនៃការចាត់ចែងមតិកនឹងមានបញ្ហា ។ មាត្រានេះ បានចាត់ទុកថា នីតិបុគ្គលមតិក គ្មានអត្ថិភាពតាំងពីដំបូង ហើយចាត់ទុកថាសន្តតិជនបានទទួលសន្តតិកម្មមតិកនោះ តាំងពីពេលដែលមតកជនបានទទួលមរណភាព រីឯសកម្មភាពដែលបានធ្វើឡើងក្រោមសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងមតិកត្រូវចាត់ទុកថាមានសុពលភាព ដើម្បីការពារផលប្រយោជន៍របស់តតិយជនផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩៥.–** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងមតិក ក្នុងករណីដែលបានដឹងថាមានសន្តតិជន ។

កថាខណ្ឌទី ១ ចែងអំពីពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ។ ទោះបីជាបានដឹងថាមានសន្តតិជនក៏ដោយ ប្រសិនបើសន្តតិជននេះបោះបង់សន្តតិកម្ម នោះនឹងធ្លាក់ចូលក្នុងស្ថានភាពមិនដឹងថាមានសន្តតិជនច្បាស់លាស់ម្តងទៀត ដូច្នេះ មាត្រានេះបញ្ជាក់ថា សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងមិនត្រូវរលត់រហូតដល់សន្តតិជនយល់ព្រមសន្តតិកម្ម ។ ការយល់ព្រមនេះ មានរួមទាំងការយល់ព្រមទាំងស្រុង និង ការយល់ព្រមដោយកម្រិត ។

កថាខណ្ឌទី ២ ជាបញ្ញត្តិបង្គាប់ឱ្យអ្នកគ្រប់គ្រងមតិកបង្ហាញឱ្យបានច្បាស់លាស់នូវស្ថានភាពដែលខ្លួនបានគ្រប់គ្រងរហូតដល់ពេលនោះ ក្នុងករណីដែលសន្តតិជនបានយល់ព្រមសន្តតិកម្ម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩៦.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមតិកជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្តីពីការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍ ។

គោលបំណងនៃនីតិបុគ្គលមតិក គឺការជម្រះមតិក ហេតុនេះហើយ ជាបឋម មតិកត្រូវយកទៅសងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ។ នីតិវិធីនេះ ស្រដៀងគ្នានឹងករណីនៃការយល់ព្រមដោយកម្រិតដែរ ដូច្នេះ ជាគោលការណ៍ បញ្ញត្តិចាប់ពីមាត្រា ១២៨១ ដល់មាត្រា ១២៨៨ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។ ក៏ប៉ុន្តែ បញ្ញត្តិអំពីអំឡុងពេលដែលបានចែងក្នុងមាត្រា ១២៨១ មិនអាចយកមកអនុវត្តដូចគ្នា ហេតុនេះហើយបានជាក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ចែងបញ្ជាក់ច្បាស់លាស់អំពីអំឡុងពេល ហើយកថាខណ្ឌទី ២ ចែងអំពីការអនុវត្តដូចគ្នា តាមបញ្ញត្តិចាប់ពីកថាខណ្ឌទី ២ នៃមាត្រា ១២៨១ ទៅ ។

ដោយសារតែអ្នកគ្រប់គ្រងមតិក ជាអ្នកតំណាងតាមផ្លូវច្បាប់របស់នីតិបុគ្គលមតិក វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ចែងអំពីការកម្រិតចំពោះជននោះ ។ ចំណុចនេះ ខុសគ្នានឹងអ្នកយល់ព្រមដោយកម្រិត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩៧.–** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិស្តីពីការជូនដំណឹងជាសាធារណៈដើម្បីស្វែងរកសន្តតិជន ។

ការជូនដំណឹងចំពោះម្ចាស់បំណុល ជាអាទិ៍ ដែលចែងក្នុងមាត្រា ១២៩៦ ជាការជូនដំណឹងចំពោះម្ចាស់បំណុលរបស់មតកជន ជាអាទិ៍ ហើយតាមរយៈការជូនដំណឹងនេះ គេអាចដឹងថា មតកជនបានទទួលមរណភាព និង អ្នកគ្រប់គ្រងមតិកត្រូវបានជ្រើសតាំង ។ ហេតុនេះហើយ ប្រសិនបើមានសន្តតិជន សន្តតិជននេះអាចដឹងថា សន្តតិកម្មត្រូវបានចាប់ផ្តើម តាមរយៈការជូនដំណឹងនេះ ។ ក៏ប៉ុន្តែ ដើម្បីធ្វើការដកហូតសិទ្ធិដែលចែងក្នុងមាត្រា ១២៩៨ មាត្រានេះចែងជា បុរេល័ក្ខខ័ណ្ឌថាត្រូវធ្វើការជូនដំណឹងជាសាធារណៈ ចំពោះសន្តតិជន ។

ក៏ប៉ុន្តែ ការដកហូតសិទ្ធិសន្តតិជន ជាអាទិ៍ គឺជារបបមួយដែលបង្កើតឡើងដើម្បីធ្វើការសម្រេចឱ្យបានឆាប់រហ័សនូវអ្នកដែលត្រូវទទួលមតិក ក្នុងករណីដែលមានមតិក ហើយក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានសេសសល់មតិកក្រោយពីការសងបំណុល ជាអាទិ៍ របស់មតកជនទេ ទោះបីជាខំប្រឹងប្រែងស្វែងរកសន្តតិជនក៏ដោយ ក៏គ្មានប្រយោជន៍ ដែរ ។ ហេតុនេះហើយបានជា ចំពោះករណីបែបនេះ កថាខណ្ឌទី ២ ចែងថា មិនចាំបាច់ស្វែងរកសន្តតិជនទេ ។ ម្យ៉ាងទៀត ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មតិកទេ ប្រសិនបើម្ចាស់បំណុលរបស់មតកជនមានច្រើននាក់ ការគ្រប់គ្រងមតិកត្រូវបញ្ចប់ ក្រោយពីបានសងដោយចែកចំណែក ដោយយោងទៅតាមមាត្រា ១២៨៣ ដែលត្រូវបានយកមកអនុវត្តដូចគ្នា តាមមាត្រា ១២៩៦ កថាខណ្ឌទី ២ ឬ ប្តូរទៅនីតិវិធីធនក្ស័យនៃមតិកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩៨.–** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិនអាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីការដកហូតសិទ្ធិសន្តតិជន ជាអាទិ៍ ដែលជាលទ្ធផលនៃការប្រកាសជាសាធារណៈ ដោយយោងតាមមាត្រា ១២៩៧ ។

ក្នុងករណីដែលគ្មានសន្តតិជនចេញបង្ហាញខ្លួនតាមការប្រកាសជាសាធារណៈ ដើម្បីស្វែងសន្តតិជន តាមបញ្ញត្តិនៃមាត្រា ១២៩៧ មានភាពចាំបាច់ត្រូវដកហូតសិទ្ធិពីសន្តតិជន ដើម្បីធ្វើការបែងចែកមតិកទៅឱ្យអ្នកមាននិស្ស័យពិសេស ជាអាទិ៍ ។ សន្តតិជននឹងត្រូវបានដកហូតសិទ្ធិ បន្ទាប់ពីមតកជនបានទទួលមរណភាព ហើយចាំបាច់ត្រូវឆ្លងកាត់តាមការប្រកាសជាសាធារណៈ ៣ ដង មានន័យថា យ៉ាងតិច ៨ ខែ ។ ដូច្នេះ ការការពារសិទ្ធិរបស់សន្តតិជន អាចគិតថាគ្រប់គ្រាន់ហើយ ។

ម្យ៉ាងទៀត ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលអ្នកគ្រប់គ្រងមិនបានដឹងទេនោះ ដោយសារតែមិនបានស្នើសុំអំពីការទាមទារសិទ្ធិក្នុងអំឡុងពេលនៃការប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ១២៩៦ ជាបឋម អាចទទួលការសងពីទ្រព្យដែលសេសសល់តែប៉ុណ្ណោះ (មាត្រា ១២៨៨ ដែលត្រូវបានអនុវត្តដូចគ្នា តាមមាត្រា ១២៩៦ កថាខណ្ឌទី ២) លើសពីនេះ ប្រសិនបើមិនបានស្នើសុំសិទ្ធិនៅក្នុងអំឡុងពេលប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ ថែមទៀតទេ ត្រូវដកហូតសិទ្ធិដោយយោងតាមមាត្រា ១២៩៨ នេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៨-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១២៩៩.–** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយ

ផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

(កំណត់)

មាត្រានេះចែងអំពីការចែកមត៌កដោយតុលាការ តាមពាក្យសុំរបស់ជនដែលមាននិស្ស័យពិសេស ។

នៅក្នុងក្រមនេះ ទំហំនៃសន្តតិជនដែលច្បាប់បានកំណត់ ត្រូវបានកម្រិតត្រឹមតែបច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ បងប្អូនបង្កើត និង កូនរបស់បងប្អូនបង្កើតនោះ ព្រមទាំងសហព័ទ្ធរបស់មតកជននោះ ហេតុដូច្នេះ ឧទាហរណ៍ ក្មួយអាចទទួលសន្តតិកម្មពីឪពុកមាបាន ក៏ប៉ុន្តែ ឪពុកមាមិនត្រូវទទួលសន្តតិកម្មពីក្មួយទេ ហើយបងប្អូនជីដូនមួយក៏មិនអាចទទួលសន្តតិកម្មទៅវិញទៅមកបានដែរ ។ ក៏ប៉ុន្តែ ក៏អាចមានករណីជនដែលមិនបានរៀបអាពាហ៍ពិពាហ៍ ហើយឪពុកម្តាយជាអាទិ៍ បានទទួលមរណភាពហើយ ក៏ប៉ុន្តែ រស់នៅសុខដុមរមនា ជាមួយបងប្អូនជីដូនមួយ ហើយជននោះបានទទួលមរណភាពតែគ្មានបន្សល់ទុកនូវមតកសាសន៍ ។ ក្នុងករណីប្រភេទនេះ ការចែកមត៌កឱ្យបងប្អូនជីដូនមួយនោះ គឺជាការសមរម្យ ។ម្យ៉ាងទៀត បុគ្គលដែលបានរស់នៅឯកោតែឯងសឹងតែមួយជីវិត តែដល់ពេលចាស់ជរា បានអ្នកជិតខាងជួយមើលថែរក្សា ។ ក្នុងករណីនេះ ទោះបីជាមិនមែនជាសាច់ញាតិក៏ដោយ ក៏ការចែកមត៌ករបស់បុគ្គលនោះ ឱ្យទៅអ្នកជិតខាងនេះ ជាការមួយស្របនឹងឆន្ទៈរបស់មតកជនដែរ ។ ដូច្នេះ ក្នុងករណីដែលមានជនដែលមានជីវភាពរស់នៅជាមួយនឹងមតកជន ជនដែលបានខិតខំប្រឹងប្រែងមើលថែទាំព្យាបាលមតកជន ឬ ជនផ្សេងទៀតដែលមាននិស្ស័យពិសេសនឹងមតកជន មាត្រានេះទទួលស្គាល់នូវការចែកមត៌កឱ្យអ្នកទាំងនោះ តាមពាក្យសុំរបស់អ្នកនោះ ទោះបីជាមាន ឬ គ្មានទំនាក់ទំនងជាញាតិជាមួយមតកជនក៏ដោយ ។

កថាខណ្ឌទី ១ ចែងអំពីល័ក្ខខ័ណ្ឌនៃការចែកមត៌ក ដែលល័ក្ខខ័ណ្ឌទាំងនេះមានការនៅសល់មត៌កក្រោយការជម្រះ

ការមានពាក្យសុំពីជនដែលមាននិស្ស័យពិសេសនឹងមតកជន និង ការមាននិស្ស័យពិសេសដែលសមរម្យនឹងទទួលមតិក (នេះគឺជាអត្ថន័យនៃ "បើយល់ឃើញថាសមរម្យ") ។ ក្នុងករណីដែលជនមាននិស្ស័យពិសេសមានច្រើននាក់ ត្រូវចែកមតិកឱ្យជនមាននិស្ស័យនោះមួយភាគម្នាក់ ទៅតាមទំហំនៃនិស្ស័យពិសេសនោះ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នេះ ចែងថា ចំនួនសរុបនៃទ្រព្យដែលបានចែកឱ្យជនទាំងនោះ មិនអាចលើសពីចំនួនពាក់កណ្ដាលនៃមតិកដែលសល់របស់មតកជននោះបានទេ ។ អាចមានករណីច្រើនដែលមតកជនដែលគ្មានសន្តតិជនអាចមានជីវភាពរស់នៅ ដោយទទួលជំនួយពីសង្គម ដូច្នេះហើយ គួរសងគុណដល់សង្គមមួយភាគវិញ ដោយឱ្យមតិកនោះទៅជាទ្រព្យរដ្ឋយ៉ាងតិចពាក់កណ្ដាល ។ ក៏ប៉ុន្តែ ទោះបីជាក្នុងវាក្យខណ្ឌទី ២ នេះ ចែងដូច្នេះក៏ដោយ ក៏មិនមែនមានន័យថាជាការកម្រិតចំពោះមតកសាសន៍ទេ គឺមតកជនអាចធ្វើអច្ច័យទានមតិកទាំងអស់ឱ្យបុគ្គលជាក់លាក់ណាម្នាក់ ឬ ច្រើននាក់បាន ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិអំពីការដាក់ពាក្យសុំរបស់ជនមាននិស្ស័យពិសេស ។ ការដែលមានកំណត់នូវអំឡុងពេលដាក់ពាក្យសុំនោះ គឺដោយសារតែមិនគួរចាត់ទុកវត្ថុនោះឱ្យនៅជានីតិបុគ្គលមតិករហូតទេ ម្យ៉ាងគឺដើម្បីត្រៀមក្នុងករណីដែលមានជនមាននិស្ស័យពិសេសច្រើននាក់ផងដែរ ។

កថាខណ្ឌទី ៣ ចែងអំពីសិទ្ធិស្រាវជ្រាវនូវអង្គហេតុដោយតុលាការ ។ មេឃុំ ឬ ចៅសង្កាត់ អាចដឹងនូវជីវភាពរបស់មតកជនពេលនៅរស់ ដោយផ្ទាល់ ឬ តាមរយៈអ្នកធ្វើការក្រោមបង្គាប់ ហេតុនេះបានជាកំណត់ថា អាចសួរយោបល់ពីអ្នកទាំងនោះបាន ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៩៥៨-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ចំពោះផ្នែកខាងក្រោយនៃកថាខណ្ឌទី ២ វិញ សូមមើលមាត្រា ១១៩-២ នៃបទប្បញ្ញត្តិស្ដីពីការវិនិច្ឆ័យរឿងក្ដីគ្រួសាររបស់ជប៉ុន ។

## មាត្រា ១៣០០.- មតិកដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មតិកដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមតិកឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះចែងអំពីការដាក់មតិកទៅជាទ្រព្យសម្បត្តិរដ្ឋ ។

ចំពោះមតិកដែលគ្មានសន្តតិជន ហើយមិនត្រូវបានចែកទៅឱ្យជនដែលមាននិស្ស័យពិសេស ត្រូវក្លាយទៅជាទ្រព្យរដ្ឋ។

វាក្យខណ្ឌទី ២ នៃមាត្រានេះបានចែងថា អ្នកគ្រប់គ្រងមតិកត្រូវតណនាអំពីការគ្រប់គ្រង ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។ម្យ៉ាងទៀត យោងតាមបញ្ញត្តិនៃមាត្រានេះ មតិកដែលត្រូវបានចែកឱ្យទៅជនដែលមាននិស្ស័យពិសេស ត្រូវក្លាយជាទ្រព្យរដ្ឋ ដោយស្វ័យប្រវត្តិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥០៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## ជំពូកទី ៨ ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

(កំណត់)

ជំពូកនេះមានបញ្ញត្តស្តីពីការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ។ ការទាមទារឱ្យធ្វើបដិទាននេះ មានភាពខុសនឹងករណីដែលសន្តតិជនធ្វើការទាមទារដើម្បីយកមតិកមកវិញ ក្នុងករណីដែលតតិយជនដែលគ្មានពាក់ព័ន្ធ បានកាន់កាប់មតិកដោយគ្មានសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់ ។ ការទាមទារដើម្បីយកមតិកមកវិញនេះ គឺជាការទាមទារដោយយោងតាមបញ្ញត្តិទូទៅអំពីសិទ្ធិប្រត្យក្ស ជាអាទិ៍ ហើយបញ្ញត្តិក្នុងជំពូកនេះមិនអាចយកមកអនុវត្តទេ។ ដូចដែលបានចែងក្នុងមាត្រា ១៣០២ ថា "អាចទាមទារចំពោះជនដែលបានទទួលមតិក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញនូវទ្រព្យដែលបានទទួលនោះ" ដែរ ក្នុងករណីដែលជនដែលគេយល់ថាជាសន្តតិជនតាមសភាពខាងក្រៅ កំពុងកាន់កាប់មតិកដោយមូលហេតុទទួលសន្តតិកម្ម ជំពូកនេះ គឺជាបញ្ញត្តិសម្រាប់ឱ្យសន្តតិជនពិតប្រាកដធ្វើការទាមទារយកមកវិញនូវមតិកដោយសន្តតិជនពិតប្រាកដ ចំពោះសន្តតិកម្ម "ដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម" ដូចដែលចែងក្នុងមាត្រា ១៣០១ ។ មូលហេតុនៃការកើតមានឡើងនូវសភាពនេះ គឺឧទាហរណ៍ មានកំណត់ត្រាណាមួយខុសនៅក្នុងសំបុត្រកំណើត ហើយកូនដែលមិនមែនជាកូនពិតប្រាកដរបស់មតកជនបានទទួលសន្តតិកម្មពីមតកជននោះ ដោយផ្អែកលើសំបុត្រកំណើតនេះ ឬ ករណីដែលមុននឹងរួមរស់ជាមួយគ្រួសារនេះ មតកជនមានកូនជាមួយអ្នកផ្សេង ក៏ប៉ុន្តែ មិនបានទាក់ទងជាយូរយារណាស់មកហើយ ហើយមានការទទួលសន្តតិកម្មតែក្នុងរង្វង់គ្រួសារ ជាអាទិ៍ ។ ក្នុងករណីទី ១ នេះ គឺជាករណីដែលបុគ្គលគ្មានលក្ខណៈសម្បត្តិជាសន្តតិជនបានទទួលសន្តតិកម្ម ។ ករណីទី ២ គឺជាករណីដែលសន្តតិជនបានទទួលនូវសន្តតិកម្មលើសចំណែកមតិករបស់ខ្លួន ។ ទោះបីជាករណីណាក៏ដោយ ក៏បញ្ញត្តិនៃជំពូកនេះត្រូវយកមកអនុវត្តដែរ ។

**មាត្រា ១៣០១.-** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមតិកទាំងអស់ ឬ មួយភាគ បាន ។

(កំណត់)

មាត្រានេះចែងអំពីគោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ។ រួមទាំងមាត្រា ១៣០២ បញ្ជាក់ច្បាស់លាស់ថា អ្វីទៅដែលហៅថា ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ។

ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម គឺជាការទាមទាររបស់សន្តតិជន ឱ្យធ្វើបដិទានសន្តតិកម្មដែលខ្លួនត្រូវបានដកហូតសិទ្ធិសន្តតិកម្ម ហើយខ្លឹមសារលម្អិតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ចំណុចនេះត្រូវបានចែងក្នុងមាត្រា ១៣០២ យ៉ាងច្បាស់លាស់ ។ ម្យ៉ាងទៀត ក្នុងករណីដែលជាសហសន្តតិកម្មដែលមានសន្តតិជនស្របច្បាប់ច្រើននាក់ ប្រសិនបើសន្តតិជនផ្សេងទៀតមិនទាន់បានពិភាក្សាបែងចែកមតិកនៅឡើយទេ ការ "ដកហូតសិទ្ធិសន្តតិកម្ម" នោះ មិនទាន់កើតឡើងនៅឡើយទេ ដូច្នេះករណីនេះ សន្តតិជនមិនទទួលនូវការកម្រិតដោយជំពូកនេះទេ ហើយអាចស្នើសុំឱ្យសហសន្តតិជនផ្សេងទៀតធ្វើការពិភាក្សាការបែងចែកមតិក ពេលណាក៏បានដែរ ។ ក្នុងករណីដែលសហសន្តតិជនផ្សេងទៀត បានពិភាក្សាការបែងចែកមតិករួចហើយ ទើបត្រូវអនុវត្តតាមជំពូកនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦២៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១៣០២.–** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមតិក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមតិកធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម ។

ឧទាហរណ៍ ជនដែលមិនមែនជាកូនពិតប្រាកដរបស់មតកជនសោះ តែនៅក្នុងសំបុត្រកំណើតសរសេរខុសថា ជននោះជាកូនរបស់មតកជន ហើយជននោះបានទទួលលទ្ធកម្មនូវមតិក តាមរយៈសិទ្ធិសន្តតិកម្មដែលតាមពិតខ្លួនគ្មានសោះ ។ ក្នុងករណីនេះ មាត្រានេះចែងថា សន្តតិជនពិតប្រាកដអាចធ្វើការទាមទារឱ្យជននោះប្រគល់នូវមតិកនោះមកវិញបាន ។ ដូចករណីនេះដែរ ក្នុងករណីដែលជនមិនមែនជាសន្តតិជនពិតប្រាកដបានទទួលលទ្ធកម្មនូវទ្រព្យសម្បត្តិ ដោយសន្តតិកម្ម ជនដែលជាសន្តតិជនពិតប្រាកដអាចទាមទារឱ្យជននោះប្រគល់ទ្រព្យសម្បត្តិដែលជននោះបានទទួលទាំងអស់មកវិញបាន។ ក្រៅពីនេះ មានករណីដែលសន្តតិជនបានទទួលសន្តតិកម្មលើសចំណែកមតិករបស់ខ្លួន ។ ឧទាហរណ៍ ពេលនៅរស់

មតកជនបានទទួលស្គាល់បុគ្គលណាម្នាក់ជាកូនរបស់ខ្លួន ក៏ប៉ុន្តែ ដោយសារតែគ្រួសាររបស់មតកជនមិនបានដឹង ហើយមិនបានទាក់ទងនឹងជននោះទេ ដូច្នេះហើយសហព័ទ្ធ និង កូនរបស់មតកជននោះ បានជឿជាក់ថា សន្តតិជនមានតែសាមីខ្លួនប៉ុណ្ណោះ ហើយបានធ្វើលទ្ធកម្មនូវមតិករបៀង១ខ្លួន ដោយបែងចែកមតិករួចហើយ ។ ក្នុងករណីនេះ ជនដែលត្រូវបានទទួលស្គាល់ជាកូន ត្រូវគេបំពាននូវចំណែកមតិករបស់ខ្លួន ដូច្នេះ ជននោះអាចទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មចំពោះសន្តតិជនផ្សេងទៀតបាន ។ វិធីទាមទារជាក់ស្តែងក្នុងករណីនេះ គឺការទាមទារឱ្យធ្វើការបែងចែកមតិកសាជាថ្មីទៀត ។ ការបែងចែកមតិកដែលបានធ្វើឡើងដោយអវត្តមានរបស់សន្តតិជននេះ គឺជាការបែងចែកមោឃៈ ដោយសារមានសន្តតិជនមិនគ្រប់ចំនួន ។ម្យ៉ាងទៀត ចាំបាច់ត្រូវការពារជនដែលបានទទួលអនុប្បទាននូវមតិក ពីជនដែលបានបន្លំឋានៈរបស់ខ្លួនជាសន្តតិជន ដូច្នេះ ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម គឺសំដៅលើ "ជនដែលបានទទួលមតិក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ" ។

ម្យ៉ាងទៀត ចំពោះករណីដែលជនដែលត្រូវបានទទួលស្គាល់ក្រោយមរណភាពរបស់មតកជន ទាមទារមតិក ក្រោយការបែងចែក ចែងក្នុងមាត្រា ១២៧៤ ក្នុងករណីនេះ ជនដែលត្រូវបានទទួលស្គាល់ក្រោយមរណភាពរបស់មតកជនមិនមែនជាសន្តតិជន នៅពេលធ្វើការបែងចែកមតិកនោះទេ ដូច្នេះ ការបែងចែកមតិកនោះមានសុពលភាព ហេតុនេះហើយបានជាចែងបញ្ញត្តិពិសេសដូចក្នុងមាត្រា ១២៧៤ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទាន បានលក់មតិកនោះហើយជាគោលការណ៍ មិនអាចទាមទារឱ្យធ្វើបដិទានចំពោះអ្នកទិញបានទេ ដូច្នេះ អាចធ្វើការទាមទារនូវថ្លៃលក់ដែលជាវត្ថុជំនួសមតិកនោះបាន (ដោយឡែក តាមការបកស្រាយ ប្រសិនបើអ្នកទិញបានដឹងថា ជនដែលបានបន្លំឋានៈរបស់ខ្លួនជាសន្តតិជនដែលជាអ្នកលក់នោះ គ្មានសិទ្ធិសន្តតិកម្មទៅលើមតិកនោះទេ ហើយនៅតែធ្វើកិច្ចសន្យាលក់ទិញទៀតនោះ សន្តតិជនពិតប្រាកដអាចទទួលមកវិញនូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះ ដោយអះអាងថា កម្មសិទ្ធិលើវត្ថុនោះមិនត្រូវបានផ្ទេរទៅអ្នកទិញ ដោយកិច្ចសន្យាលក់ទិញនោះបានទេ) ។

(មាត្រាពាក់ព័ន្ធ)

សូមមើលមាត្រា ៦២៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ២០១៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

## មាត្រា ១៣០៣.– ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មតិកមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើន

តម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

(កំណត់)

មាត្រានេះចែងអំពីខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ របស់ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ។

កថាខណ្ឌទី ១ ចែងអំពីការដែលត្រូវតែប្រគល់មតិកវិញ ព្រមទាំងចែងអំពីសិទ្ធិនៃការធ្វើលទ្ធកម្មនូវផល ជាអាទិ៍ ក្នុងករណីដែលភាគីម្ខាងទៀតនោះសុចរិត ។

កថាខណ្ឌទី ២ ចែងអំពីទំនាក់ទំនងនៃសិទ្ធិបន្ទាប់បន្សំរបស់ភាគីម្ខាងទៀត ក្នុងករណីដែលភាគីម្ខាងទៀតទុច្ចរិត ។ ការមិនឱ្យមានសិទ្ធិទាមទារសំណង ចំពោះកាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ដែលខ្លួនបានសងរួចរាល់ ជាអាទិ៍ ហាក់ដូចជាការធ្វើជ្រុលពេក ក៏ប៉ុន្តែ ដោយសារតែជននោះបានដឹងថា ខ្លួនគ្មានសិទ្ធិសន្តតិកម្ម ប៉ុន្តែ នៅតែទទួលសន្តតិកម្ម ហើយថែមទាំងបានចេញសោហ៊ុយដើម្បីសងទៀតនោះ ដូច្នេះ អាចចាត់ទុកដូចជាការសងដោយគ្មានកាតព្វកិច្ចដោយទុច្ចរិត ។ ហេតុនេះហើយ នេះគឺជាបញ្ញត្តិធម្មតាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ២០២០ ដល់ មាត្រា ២០២៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ១៣០៤.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមតិកត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមតិក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។

(កំណត់)

មាត្រានេះបានកំណត់នូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម គឺ ៥ ឆ្នាំ ។

ការកំណត់ត្រឹម ៥ ឆ្នាំ សម្រាប់ការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មនេះ គឺព្រោះថា ប្រសិនបើមើលពីតតិយជនជនដែលបានបន្លំឋានៈរបស់ខ្លួនជាសន្តតិជន ក៏មិនខុសពីសន្តតិជនធម្មតាផ្សេងទៀតដែរ ដូច្នេះ ចាំបាច់ត្រូវធ្វើឱ្យមានស្ថិរភាពនៃទំនាក់ទំនងសិទ្ធិ ហើយម្យ៉ាងទៀត ទាំងអំឡុងពេលនេះ ក៏ត្រូវសម្របទៅនឹងអំឡុងពេលនៃការរំលត់សិទ្ធិលើបំណុល (កាតព្វកិច្ច) ដែរ ។ ចំពោះករណីដែលបានទទួលសន្តតិកម្មតែឯង ទ្រព្យសន្តតិកម្មត្រូវបានផ្ទេរនៅថ្ងៃដែលមតកជនបានទទួលមរណភាព បានសេចក្តីថា នៅពេលចាប់ផ្តើមសន្តតិកម្ម ដូច្នេះ ត្រូវធ្វើការគណនាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ចាប់ពីថ្ងៃនោះទៅ ។ រីឯក្នុងករណីនៃសហសន្តតិកម្ម ត្រូវធ្វើការគណនា ពីថ្ងៃដែលមតិកត្រូវបានផ្ទេរទៅតាមមតកសាសន៍ ឬ ការបែងចែកមតិកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦២៥ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

# គន្ថីទី ៩ អវសានប្បញ្ញត្តិ
# ជំពូកតោល អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.–** កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និង ចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិអំពីកាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍ ។

កថាខណ្ឌទី ១ កំណត់អំពីកាលបរិច្ឆេទនៃការអនុវត្ត ។ យោងទៅតាមមាត្រា ៩៣ កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ជាគោលការណ៍ ច្បាប់ទាំងឡាយ នឹងត្រូវចូលជាធរមាន នៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ និង នៅទូទាំងប្រទេស ក្នុងរយៈពេល ២០ ថ្ងៃ ក្រោយថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែ ច្បាប់ដែលនាំឱ្យមានឥទ្ធិពលលើប្រជាពលរដ្ឋយ៉ាងទូលំទូលាយ ដូចក្រមរដ្ឋប្បវេណី គួរតែចាប់ផ្ដើមអនុវត្ត ក្រោយអំឡុងពេល សមរម្យដើម្បីផ្សព្វផ្សាយទៅប្រជាពលរដ្ឋ បន្ទាប់ពីការអនុម័ត ។ ហេតុដូច្នេះ កថាខណ្ឌទី ១ នេះ ចែងថា ក្រមរដ្ឋប្បវេណី ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ដោយច្បាប់ផ្សេង ហើយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនឹងត្រូវបានធ្វើឡើង ក្នុងនាមជា "ច្បាប់ផ្សេង" នោះ ។ម្យ៉ាងទៀត ការអនុវត្តក្រមរដ្ឋប្បវេណីដោយប្រតិសកម្ម គឺជាបញ្ហាសំខាន់មួយ ហើយចំពោះចំណុចនេះ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបញ្ញត្តថា ជាគោលការណ៍ ក្រមរដ្ឋប្បវេណីនេះមិនត្រូវអនុវត្ត ដោយប្រតិសកម្មឡើយ ។ ប៉ុន្តែ ក្នុងចំណោមវិស័យរដ្ឋប្បវេណី មានផ្នែកខ្លះដែលគ្មានច្បាប់កន្លងមក ហេតុដូច្នេះ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីចែងផងដែរថា ក្រមរដ្ឋប្បវេណីអាចយកមកអនុវត្តជាគោលការណ៍សមធម៌ (equity) ចំពោះផ្នែកបែបនេះ ។

កថាខណ្ឌទី ២ ចែងថា ចំពោះចំណុចចាំបាច់ដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។ ចំណុចចាំបាច់នេះមានដូចជានិយមន័យនៃកាលបរិច្ឆេទស្ថាពរ និង លិខិតយថាភូត ជាអាទិ៍ ដែលចាំបាច់មានដើម្បីអនុវត្តជាក់ស្តែងនូវក្រមរដ្ឋប្បវេណី វិធានការអន្តរកាល និង ការធ្វើវិសោធនកម្ម ឬ ធ្វើឱ្យនិរាករណ៍នូវច្បាប់ដែលមានភាពផ្ទុយនឹងក្រមរដ្ឋប្បវេណី ជាអាទិ៍ ហើយចំណុចចាំបាច់ទាំងនេះ ក៏នឹងត្រូវកំណត់នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែរ ។

RULE-JICA Seminar 5

# សិក្ខាសាលាស្តីពី

# មូលដ្ឋានគ្រឹះនៃសត្តិកម្ម (ផ្នែក២)

វាគ្មិន៖ បណ្ឌិត ហាប់ ផល្លី, លោកស្រី ប៉ូលី បញ្ញា
លោក គង់ សុភ័ក្រ្ត

កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦

ទីកន្លែង៖ សហសាលG1, សភគវិស

1

# មាតិកា

1. សត្តិកម្មតាមមតកសាសន៍
   1.1. គំនិតជាមូលដ្ឋាននៃសត្តិកម្ម
   1.2. ទម្រង់នៃមតកសាសន៍
   1.3. ចំណុចនៃមតកសាសន៍
   1.4. ភាគបម្រុង
   1.5. ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
   1.6. ទ្រព្យជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
   1.7. អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
2. ការបោះបង់សត្តិកម្ម និងការយល់ព្រមដោយកម្រិត
   2.1. ការបោះបង់សត្តិកម្ម
   2.2. ការយល់ព្រមដោយមានកម្រិត

2

## 1.1. គំនិតជាមូលដ្ឋាននៃសន្តតិកម្ម

មតកជន អាចសម្រេចអំពីវិធីបែងចែកទ្រព្យសម្បត្តិក្រោយពេលខ្លួនមរណភាព ដោយខ្លួនឯងបាន តាមរយៈការធ្វើមតកសាសន៍។ សន្តតិជន ត្រូវតែគោរពតាមមតកសាសន៍របស់មតកជន។ ក្រមរដ្ឋប្បវេណី បញ្ញត្តនូវវិធានយ៉ាងលម្អិតអំពីទម្រង់នៃមតកសាសន៍ និង ខ្លឹមសារនៃមតកសាសន៍។

សន្តតិកម្មតាមមតកសាសន៍ មិនមែនមានន័យថា ជាសន្តតិកម្មដែលខុសគ្នាទាំងស្រុងពីសន្តតិកម្មតាមច្បាប់ទេ។ ក្នុងករណីសន្តតិកម្មតាមមតកសាសន៍ ខ្លឹមសារនៃមតកសាសន៍ មានអាទិភាពជាង ប៉ុន្តែចំណុចក្រៅពីនេះ ត្រូវអនុវត្តតាមវិធានសន្តតិកម្មតាមច្បាប់។

3

## 1.2. ទម្រង់នៃមតកសាសន៍ (1)

មតកសាសន៍ មានអានុភាពក្រោយពេលមតកជនទទួលមរណភាព។ នៅពេលមតកជនបានទទួលមរណភាព ប្រសិនបើខ្លឹមសារមតកសាសន៍មិនមានភាពច្បាស់លាស់ ហើយទោះបីជាមានបញ្ហានៅត្រង់ថា មតកសាសន៍ពិតជាស្របតាមឆន្ទៈរបស់មតកជនមែន ឬយ៉ាងណានោះ មិនអាចសួរទៅកាន់មតកជនបានទេ។ ហេតុនេះ នៅក្នុងក្រមរដ្ឋប្បវេណី បញ្ញត្តនូវវិធានយ៉ាងតឹងរ៉ឹងអំពីទម្រង់នៃមតកសាសន៍ ដើម្បីកុំឱ្យមានបញ្ហាកើតឡើងក្រោយពេលមតកជនទទួលមរណភាព (មាត្រា១១៧០-១១៨១) ។

4

## 1.2. ទម្រង់នៃមរតកសាសន៍ (2)

- មរតកសាសន៍ដោយលិខិតយថាភូត (មាត្រា១១៧៣)
- មរតកសាសន៍ដោយលិខិតឯកជន (មាត្រា១១៧៤)
- មរតកសាសន៍ដោយលិខិតសម្ងាត់ (មាត្រា១១៧៥)
- មរតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា១១៧៦)
- មរតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា១១៧៧)
- មរតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង (មាត្រា១១៧៨)

5

## 1.3. ចំណុចនៃមរតកសាសន៍

ខ្លឹមសារដែលអាចបង្កើតមរតកសាសន៍បានមានដូចខាងក្រោម៖

- ការកំណត់ចំណែកមត៌ក (មាត្រា១១៨២)
- ការកំណត់នូវវិធីបែងចែកដោយមរតកសាសន៍ (មាត្រា១១៨៣)
- អច្ច័យទាន (មាត្រា១១៩៩)

6

## 1.3.1. ការកំណត់ចំណែកមតិក (មាត្រា១១៨២)

ការកំណត់ចំណែកមតិក គឺជាការផ្លាស់ប្តូរភាគនៃចំណែកសន្តតិកម្មតាមច្បាប់។




មតកសាសន៍

មតិកពាក់កណ្តាលឲ្យទៅកូន A

7

## 1.3.2. ការកំណត់នូវវិធីបែងចែកមតិក (មាត្រា១១៨៣)

ជាការសម្រេចថា ត្រូវផ្តល់ប្រភេទទ្រព្យសម្បត្តិបែបណាទៅឲ្យសន្តតិជនមួយណា។




មតកសាសន៍

ឲ្យផ្ទះទៅកូន A។ ឲ្យរូបិយវត្ថុ និងសាច់ប្រាក់ចំនួន ៣០០០ ដុល្លារទៅកូន B។ ឲ្យសាច់ប្រាក់ចំនួន៤០០០ ដុល្លារទៅកូន C។

8

## ការកំណត់ចំណែកមត៌ក និងការកំណត់នូវវិធីបែងចែកមត៌ក

អាចធ្វើឡើងក្នុងពេលព្រមគ្នាបាន។




9

## 1.3.3. អច្ច័យទាន

អច្ច័យទាន គឺជាការធ្វើប្រទានកម្មទ្រព្យសម្បត្តិតាមរយៈមតកសាសន៍របស់មតកជន។ ការកំណត់ចំណែកមត៌ក និងការកំណត់វិធីបែងចែកចំណែកមត៌ក ជាកម្មវត្ថុចំពោះតែសន្តតិជនប៉ុណ្ណោះ ប៉ុន្តែ អច្ច័យទានអាចជាកម្មវត្ថុចំពោះតតិយជន ក្រៅពីសន្តតិជនបាន។ អច្ច័យទានមានអច្ច័យទានសកល និងអច្ច័យទានមានកំណត់ (មាត្រា១១៩៩)។

10

## 1.3.3. អច្ច័យទាន

អច្ច័យទានសកល គឺជាការធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ (មាត្រា១១៩៩)។

អច្ច័យលាភីសកល មានសិទ្ធិ និងករណីកិច្ច ដូចគ្នានឹងសន្តតិជន (មាត្រា១២១២(១))។

11

## អច្ច័យទានសកល (មាត្រា១១៩៩)




12

# អច្ច័យទានសកល (មាត្រា១១៩៩)

ផ្ទះតម្លៃ៥០០០ដុល្លារ
រថយន្តតម្ល ១០០០ដុល្លារ
សាច់ប្រាក់ចំនួន១០០០០ដុល្លារ




កូន A និង B ត្រូវបាត់ទុកជា មិនបានទទួលសន្តតិកម្ម (មាត្រា ១២១២(២))។

※ ស្ដីអំពីភាគបម្រុង យើងនឹងធ្វើការពន្យល់តាមក្រោយ ។

ផ្ទះតម្លៃ ៥០០០ ដុល្លារ
រថយន្តតម្លៃ ១០០០ ដុល្លារ
សាច់ប្រាក់ចំនួន ១០០០០ ដុល្លារ

13

# អច្ច័យទានមានកំណត់

ការប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ ដោយមតកជន។

ផ្ទះតម្លៃ ៥០០០ ដុល្លារ
រថយន្តតម្លៃ ១០០០ ដុល្លារ
សាច់ប្រាក់ចំនួន ១០០០០ ដុល្លារ




ឧទាហរណ៍

ផ្ទះ និងប្រាក់ ២៥០០ ដុល្លារ　　៧៥០០ ដុល្លារ　　រថយន្ត

14

## 4.1. ភាគបម្រុង

ដូចដែលបានរៀបរាប់ពីខាងលើមកដល់ត្រឹមចំណុចនេះ មតកជនអាចសម្រេចចិត្តដោយខ្លួនឯងអំពីវិធីនៃការបែងចែកទ្រព្យសម្បត្តិក្រោយពីទទួលមរណភាព តាមរយៈការធ្វើមតកសាសន៍បាន។ ប៉ុន្តែ ដោយសារតែអ្នកដែលត្រូវបានបញ្ញត្តទុកថា អាចទទួលទ្រព្យសម្បត្តិរបស់មតកជនដោយសន្តតិកម្ម (អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន) មានដូចជា សហព័ទ្ធ និងកូនរបស់មតកជនជាដើម រំពឹងទុកចំពោះការធ្វើសន្តតិកម្ម ហេតុនេះចាំបាច់ត្រូវតែមានការការពារលើការរំពឹងទុកបែបនោះ។ ដូច្នេះ នៅក្នុងក្រមរដ្ឋប្បវេណីបញ្ញត្តអំពីប្រព័ន្ធមួយដែលហៅថា ភាគបម្រុង។ នៅក្នុងចំណោមបំណែកមតិករបស់សន្តតិជន ភាគបម្រុង គឺជាផ្នែកមួយដែលមិនអាចធ្វើការបំពានដោយមតកសាសន៍ជាអាទិ៍បានឡើយ។

15

## អ្នកមានសិទ្ធិលើភាគបម្រុង (មាត្រា១២៣០)

អ្នកមានសិទ្ធិលើភាគបម្រុង គឺបច្ឆាញាតិផ្ទាល់ ឬឪពុកម្ដាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ មានន័យថាអ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃបំណែកមតិកដែលច្បាប់បានកំណត់ នឹងក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង។ ប៉ុន្តែ បងប្អូនបង្កើតមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីជាត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនក៏ដោយ។

16

## អ្នកមានសិទ្ធិលើភាគបម្រុង (មាត្រា១២៣០)




17

## ភាគនៃភាគបម្រុង (មាត្រា១២៣០)

១ភាគ៣ នៃទ្រព្យរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្ដាយ ឬជីដូន ជីតាប៉ុណ្ណោះ (មាត្រា១២៣០(១) ចំណុច ក)។




18

# ភាគនៃភាគបម្រុង (មាត្រា១២៣០)

ក្រៅពីករណីនេះ ភាគបម្រុង គឺ១ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន។




មតកសាសន៍
ឱ្យទ្រព្យសម្បត្តិទាំងអស់ទៅមិត្តភក្តិ D

ភាគបម្រុងសរុបរបស់សន្តតិជន
១២០០០ ÷ ២ = ៦០០០
ដូច្នេះ ត្រូវបែងចែកជា៣ចំណែកមានដូចជា ប្រពន្ធ A, កូន B និងកូន C។

19

# ភាគនៃភាគបម្រុង (មាត្រា១២៣០)

ក្រៅពីករណីនេះ ភាគបម្រុង គឺ១ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន។




មតកសាសន៍
ឱ្យទ្រព្យសម្បត្តិទាំងអស់ទៅកូន B

ភាគបម្រុងសរុបរបស់សន្តតិជន
១២០០០ ÷ ២ = ៦០០០
ដូច្នេះ ត្រូវបែងចែកជា ៣ ចំណែកមានដូចជា ប្រពន្ធ A, កូន B និង កូន C។

20

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ទ្រព្យដែលជាមូលដ្ឋាននៅពេលគណនាភាគបម្រុង មិនមែនមានត្រឹមតែមតិកតែប៉ុណ្ណោះទេ។ ភាគបម្រុងត្រូវគណនាដោយយក តម្លៃនៃមតិកដែលមតកជនមាននៅពេលទទួលមរណភាព បូកតម្លៃនៃផលប្រយោជន៍ពិសេស និង តម្លៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងអំឡុងពេលនៅរស់ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ច (មាត្រា១២៣១)។

តម្លៃទ្រព្យប្រទានកម្មដែលបានកំណត់ក្នុងអំឡុងពេលនៅរស់ មានដូចខាងក្រោម (មាត្រា១២៣២(១))៖

- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។
- ក្រៅពីប្រទានកម្មនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។

21

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង
៣០០០០+១២០០០−៦០០០=៣៦០០០

22

# 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ភាគបម្រុងរបស់សន្តតិជនទាំងអស់
៣៦០០០÷២=១៨០០០

23

# 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ភាគបម្រុងរបស់សន្តតិជន១នាក់
១៨០០០÷២=៩០០០

24

## 4.3.2. វិធីគណនានៃចំនួនដែលបំពានភាគបម្រុង

ចំនួនដែលបំពានភាគបម្រុង គឺត្រូវគណនាដោយយកភាគបម្រុងរបស់បុគ្គលនោះ ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលបុគ្គលនោះទទួលបានដោយសន្តតិកម្ម និងផលប្រយោជន៍ពិសេស ហើយ បូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម (មាត្រា១២៣៤)។

25

## 4.3.2. វិធីគណនានៃចំនួនដែលបំពានភាគបម្រុង




| | កូន A | កូន B | មិត្តភក្តិ C |
|---|---|---|---|
| ចំនួនទទួលបាន | ៧៥០០ដុល្លារ | ៧៥០០ដុល្លារ | ១៥០០០ដុល្លារ |
| កាតព្វកិច្ចលើបំណុល | ៣០០០ដុល្លារ | ៣០០០ដុល្លារ | |
| ភាគបម្រុង | ៩០០០ដុល្លារ | ៩០០០ដុល្លារ | |
| ចំនួនដែលបំពានលើភាគបម្រុង | ? ០ ដុល្លារ | ? ៤៥០០ ដុល្លារ | |

26

## 1.5. ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ឧទាហរណ៍៖ ទោះបីជាអ្នកមានសិទ្ធិលើភាគបម្រុងក៏ដោយ ក៏មិនមែនមានន័យថាទ្រព្យសម្បត្តិនឹងត្រូវបានបែកទៅឲ្យបុគ្គលនោះដោយស្វ័យប្រវត្តិនោះដែរ។ ក្នុងករណី មតកសាសន៍ដែលធ្វើឲ្យបំពានភាគបម្រុងរបស់បុគ្គលណាម្នាក់ត្រូវបានកើតឡើង អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែអនុវត្តការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (មាត្រា១២៤៥)។

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងថា ភាគបម្រុងរបស់ខ្លួនត្រូវបានបំពានដោយអច្ច័យទានជាដើម។ ម្យ៉ាងវិញទៀត សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា១២៤៥)។

27

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺអច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្មជាក់លាក់ក្នុងអំឡុងពេលនៅរស់ដែលបានកំណត់នៅក្នុងមាត្រា១២៣២នៃក្រមរដ្ឋប្បវេណី (មាត្រា១២៣៣)។

ករណី ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមានច្រើន លំដាប់អាទិភាពនៃការកាត់បន្ថយ មានដូចខាងក្រោម (មាត្រា១២៣៦-១២៣៨)៖

លំដាប់ទី១ អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន។

លំដាប់ទី២ អច្ច័យទានដែលត្រូវបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន។

លំដាប់ទី៣ ប្រទានកម្ម ឬផលប្រយោជន៍ពិសេស។ ចំពោះប្រទានកម្ម ឬផលប្រយោជន៍ពិសេសគឺជាវត្ថុថ្មី មានន័យថា ជាវត្ថុដែលត្រូវបានកើតឡើងតាមក្រោយដូច្នេះវានឹងមានអាទិភាពជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

28

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង




**គណនាភាគបម្រុងរបស់កូន B**

ភាគបម្រុងរួម៖ ១៨០០០+១៥០០០+៧០០០=៤០០០០

ភាគបម្រុងសម្រាប់សន្តតិជនម្នាក់ៗ៖ ៤០០០០÷២÷២=១០០០០

ដូចនេះ ភាគបម្រុងរបស់កូន B មានចំនួន១០០០០ដុល្លារ

29

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង




ចំនួនដែលបំពានភាគបម្រុងរបស់កូន B = ១០០០០−១០០០ = ៩០០០ដុល្លារ

30

## ការកាត់បន្ថយភាគបម្រុងតាមលំដាប់អាទិភាព




### លំដាប់នៃការកាត់បន្ថយភាគបម្រុង

ទី១៖ អច្ច័យទានទៅកូនត្រឹមផ្នែកដែលលើសភាគបម្រុងរបស់កូន A៖ 14,000 – 10,000 = $4,000

ទី២៖ អច្ច័យទានទៅ មិត្តភក្តិ C ចំនួន $3,000 = $3,000

ទី៣៖ ប្រទានកម្មនៃវត្ថុប្អូនក្នុងអំឡុងពេលនៅរស់ឲ្យកូន A ចំនួន $7,000 = $2,000

31

## 1.7. អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

នៅពេលដែលមានការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យទាន និងចំណែកមតិកដែលបានកំណត់ជាដើម នឹងបាត់បង់អានុភាពភ្លាមត្រឹមកម្រិតបំពានភាគបម្រុង ហើយសិទ្ធិនៃផ្នែកទាំងនោះ គឺជារបស់អ្នកដែលបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

32

## 2. ការបោះបង់សន្តតិកម្ម និងការយល់ព្រមដោយមានកម្រិត
### 2.1. ការបោះបង់សន្តតិកម្ម

សន្តតិជនអាចបោះបង់សន្តតិកម្មបាន (មាត្រា១២៦០)។ បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា១២៦១)។

ឧទាហរណ៍៖ ករណី មតកជន X មានកាតព្វកិច្ចច្រើន នៅពេលទទួលសន្តតិកម្ម សន្តតិជននឹងទទួលការខូចខាត។ ហេតុនេះ សន្តតិជនអាចបោះបង់សន្តតិកម្មនោះបាន។

គោលគំនិតនៃមាត្រាទាំងពីរខាងលើ គឺ៖

- ការពារផលប្រយោជន៍សន្តតិជន
- គោរពឆន្ទៈរបស់សន្តតិជន។

33

## 2.2. ការយល់ព្រមដោយមានកម្រិត

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណង កាតព្វកិច្ច និង អច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ (មាត្រា១២៥៦)។ ករណីនេះហៅថា ការយល់ព្រមដោយមានកម្រិត។

34

## 2.2. ការយល់ព្រមដោយមានកម្រិត




មាន ដី, រថយន្ត, ត្បូង និងសាច់ប្រាក់ជាដើម ច្រើន។

ប្រសិនបើ មត៌កដែលបានប្រើប្រាស់ក្រោយពីសងបំណុល មានមត៌កនៅសល់ សន្តតិជនប្រាកដជាចង់ធ្វើសន្តតិកម្ម។ ទោះបីជាបំណុលច្រើនជាងមត៌ក ក៏ដោយក៏ សន្តតិជន មិនចង់សងបំណុលដោយប្រើប្រាស់ប្រាក់របស់ខ្លួនទេ។

→ នៅក្នុងករណីបែបនេះ គឺអាចយល់ព្រមដោយមានកម្រិតបាន។

35

## 2.2. ការយល់ព្រមដោយមានកម្រិត




នៅពេលដែលធ្វើការយល់ព្រមដោយមានកម្រិត ជាដំបូងត្រូវប្រើប្រាស់មត៌ករបស់មតកជន មកសងកាតព្វកិច្ចសិន។ បន្ទាប់មក ប្រសិនបើ មានមត៌កនៅសល់ សន្តតិជន អាចធ្វើការបែងចែកមត៌កទាំងនោះ ហើយអាចធ្វើលទ្ធកម្មបាន។

36

## 2.2. ការយល់ព្រមដោយមានកម្រិត




ប្រសិនបើ មតិកដែលបានប្រើប្រាស់ក្រោយពីសងកាតព្វកិច្ច ទោះបីជាកាតព្វកិច្ចនៅសល់ក៏ដោយ ក៏សន្តតិជនមិនចាំបាច់សងកាតព្វកិច្ចនោះដែរ។

37

# សូមអរគុណ!!!

# Q & A

## ឯកសារពិគ្រោះ

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃឆ្នាំ២០០៩។

38